ទស្សនាវដ្តី

# រាជបណ្ឌិត្យសភាកម្ពុជា

## Royal Academy of Cambodia Review

## Revue de l’Académie Royale du Cambodge

លេខ ៦ ខែ ឧសភា ឆ្នាំ ២០១៤ | Issue 6 - May - 2014



រក្សាសិទ្ធិគ្រប់យ៉ាង

## នាយកការផ្សាយ

បណ្ឌិតសភាចារ្យ ជា ឈោង

## និពន្ធនាយក

បណ្ឌិត អ៊ឹម បុណ្ណា

## លេខាធិការ

បណ្ឌិត ដូ ច័ន្ទដារី

បណ្ឌិត ធុយ ចាន់ធួន

បណ្ឌិត ម៉ុង ស៊ាងឌីម

បណ្ឌិត សុខ ស៊ីណា

បណ្ឌិត តាំង ស៊ិន

## ហេរញ្ញិក

បណ្ឌិត អ៊ុំ ប៉ុម

បេក្ខជនបណ្ឌិត លី សុធីរ័ត្ន

បេក្ខជនបណ្ឌិត គឹម ឫទ្ធី

បេក្ខជនបណ្ឌិត ហួត រ៉ា

## បច្ចេកទេសកុំព្យូទ័រ

បេក្ខជនបណ្ឌិត សុខ ឧស្សាហ៍

បេក្ខជនបណ្ឌិត លឹម សេងឌី

បេក្ខជនបណ្ឌិត ឃិន ពោ

បេក្ខជនបណ្ឌិត ធឿន សុត្ថា

បេក្ខជនបណ្ឌិត ម៉ន ឫត្ថា

## អក្ខរាវិរុទ្ធ

បណ្ឌិត ជួរ គារី

បណ្ឌិត មាឃ បូរ៉ា

បេក្ខជនបណ្ឌិត ប៉ាង ចាន់ថា

បេក្ខជនបណ្ឌិត ឃិន យ៉ង់

## ទីប្រឹក្សា

បណ្ឌិតសភាចារ្យ ខ្លួត ធីតា

បណ្ឌិតសភាចារ្យ រស់ ចន្ទ្រាបុត្រ

បណ្ឌិតសភាចារ្យ ព្រំ ម៉ល់

បណ្ឌិតសភាចារ្យ សំ សោតាន់

បណ្ឌិតសភាចារ្យ ស៊ុំ ឈុំប៊ុន

បណ្ឌិតសភាចារ្យ សោម សុមុនី

## គណៈកម្មការត្រួតពិនិត្យ

បណ្ឌិត ច័ន្ទ សំណាញ

បណ្ឌិត ស៊ុន សុត

បណ្ឌិត នូ ចាន់សុភី

បណ្ឌិត សុខ ទូច

## បោះពុម្ព និង ចែកផ្សាយ

បណ្ឌិត ព្រំ ទេវី

បេក្ខជនបណ្ឌិត កែវ សុជាតិ

បេក្ខជនបណ្ឌិត ហេង ហុកវេន

បេក្ខជនបណ្ឌិត ជួន សោរិទ្ធី

បេក្ខជនបណ្ឌិត តាំង មុយគា

# អារម្ភកថា

ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និង បោះពុម្ពផ្សាយជាកត្តារួមចំណែកមួយក្នុងការអភិវឌ្ឍន៍សង្គមជាតិ ដែលក្នុងនោះរាជបណ្ឌិត្យសភាកម្ពុជាបានសិក្សាលើជំនាញផ្សេងៗ ហើយបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រនៃរាជបណ្ឌិត្យសភាកម្ពុជាចំនួន ៥លេខរួចមកហើយ។ នៅក្នុងលេខទីប្រាំមួយនេះ មានអត្ថបទជាច្រើនថែមទៀតដែលទាក់ទងនឹងភូមិវិទ្យា គ្រប់គ្រងសាធារណៈ ទស្សនវិជ្ជា គណិតវិទ្យា វិទ្យាសាស្ត្រសុខាភិបាល វិទ្យាសាស្ត្រអប់រំ វិទ្យាសាស្ត្រនយោបាយ និង នីតិសាស្ត្រ ជាដើម ដែលសុទ្ធតែជាអត្ថបទសិក្សាស្រាវជ្រាវ និងវិភាគបែបវិទ្យាសាស្ត្រ ហើយអត្ថបទទាំងនេះអាចជាជំនួយស្មារតីដល់អ្នកសិក្សាស្រាវជ្រាវទាំងឡាយសម្រាប់វិភាគជាលក្ខណៈវិទ្យាសាស្ត្រ ថ្មីៗ ផ្សេងទៀតផងដែរ។

ទស្សនាវដ្ដីរាជបណ្ឌិត្យសភាកម្ពុជាបានបោះពុម្ពស្នាដៃវិទ្យាសាស្ត្ររបស់បេក្ខជន បណ្ឌិត នៃរាជបណ្ឌិត្យសភាកម្ពុជានិងស្នាដៃថ្មីៗ របស់អ្នកស្រាវជ្រាវដទៃទៀតផងដែរ ដែលទើបនឹងរកឃើញ ដើម្បីផ្ដល់នូវចំណេះដឹងបែបវិទ្យាសាស្ត្រ ជូនដល់សង្គមជាតិនិងជួយសម្រួលដល់សិស្ស និស្សិត និងអ្នកស្រាវជ្រាវទូទៅសិក្សាស្វែងយល់ និងជួយជំរុញដល់អ្នកស្រាវជ្រាវទាំងឡាយឱ្យកាន់តែមានឆន្ទៈស្រាវជ្រាវប្រកបដោយវិទ្យាសាស្ត្រ។ ទស្សនាវដ្ដីនេះក៏ជាចំណាងដៃមួយសម្រាប់អ្នកស្រាវជ្រាវទាំងអស់មានឱកាសបង្ហាញនូវស្នាដៃស្រាវជ្រាវរបស់ខ្លួន ពិសេសទស្សនាវដ្ដីនេះ ចុះផ្សាយនូវអត្ថបទស្រាវជ្រាវរបស់បេក្ខជនបណ្ឌិតដែលសិក្សានៅរាជបណ្ឌិត្យសភាកម្ពុជា និងក្រៅរាជបណ្ឌិត្យសភាកម្ពុជា។

ជាមួយគ្នានេះដែរ គណៈកម្មការទស្សនាវដ្ដីវិទ្យាសាស្ត្រនៃរាជបណ្ឌិត្យសភាកម្ពុជា សង្ឃឹមថា អត្ថបទទាំងអស់ដែលបានចុះផ្សាយក្នុងទស្សនាវដ្ដីនេះនឹងក្លាយទៅជាឯកសារមួយដ៏សំខាន់ ដែលជាម៉ែត្រមួយសម្រាប់វាស់រាល់កិច្ចការស្រាវជ្រាវទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យកាន់តែមានភាពសុក្រឹត និងមានស្តង់ដាវិទ្យាសាស្ត្រ។

គណៈកម្មការយើងខ្ញុំរង់ចាំទទួលការរិះគន់ក្នុងន័យស្ថាបនាពីប្រិយមិត្តអ្នកអាន និងអ្នកស្រាវជ្រាវគ្រប់មជ្ឈដ្ឋាន ដែលបានផ្ដល់មតិយោបល់កែលម្អនូវកង្វះខាត និងកំហុសឆ្គងដែលអាចកើតមានឡើង ទាំងលើខ្លឹមសារ និងបច្ចេកទេស ដើម្បីឱ្យទស្សនាវដ្ដីនេះមានខ្លឹមសារ និងសារៈសំខាន់រួមចំណែកអភិវឌ្ឍន៍ប្រទេសយើង៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៤

**គណៈកម្មការទស្សនាវដ្ដីរាជបណ្ឌិត្យសភាកម្ពុជា**

# មាតិកា


១. ការវិភាគអំពីចរិតលក្ខណៈនៃកម្លាំងពលកម្មក្នុងប៉ូលសេដ្ឋកិច្ចភ្នំពេញ ព្រះសីហនុនិងសៀមរាប (២០០៨–២០១៨)បេក្ខជនបណ្ឌិត **ជា ចន្ទា** ផ្នែកភូមិវិទ្យានិងនគរូបនីយកម្ម ..........................១

២. ការសិក្សាឫសគល់ទស្សនវិជ្ជាខ្មែរ បេក្ខជនបណ្ឌិត **ប៉ាន់ វុត្ថា** ផ្នែកទស្សនវិជ្ជា............................៨

៣. ទស្សនវិស័យទូទៅក្នុងការជំរុញនិងសម្របសម្រួលការនាំចេញអង្ករ បេក្ខជនបណ្ឌិត **មិន ប្រុសបញ្ញារិទ្ធិ** ផ្នែកគ្រប់គ្រងសាធារណៈ ................................................១៤

៤. វិធីសាស្ត្របង្រៀនភាសាខ្មែរ នៅបឋមសិក្សា (១៩៥៣-២០១១) បេក្ខជនបណ្ឌិត **សូ សុធីរ** ផ្នែកវិទ្យាសាស្ត្រអប់រំ..........................................................................................១៩

៥. ការគ្រប់គ្រងសំណល់នៅរាជធានីភ្នំពេញ២០០៩-២០១៥ បេក្ខជនបណ្ឌិត **សេង សំអឿន** ផ្នែកភូមិវិទ្យានិងនគរូបនីយកម្ម ...........................................................................២៤

៦. ម៉ូដែលព្យាករណ៍កំណើនប្រជារាស្ត្រ បេក្ខជនបណ្ឌិត **លឹម សេងឌី** ផ្នែកគណិតវិទ្យា .............២៩

៧. ឋានន្តរសក្តិរបស់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមុខងារសាធារណៈ បេក្ខបណ្ឌិត **ស៊ន សុឃន** ផ្នែកនីតិសាស្ត្រ ........................................................................................................៣៦

៨. ទស្សនៈនានាស្តីពីច្បាប់និងប្រព័ន្ធច្បាប់សមណ បេក្ខបណ្ឌិត **សុខ ប៊ុនធឿន** ផ្នែកនីតិសាស្ត្រ....៤៣

៩. ទំនក់ទំនងនយោបាយរវាងកម្ពុជានិងចិន បេក្ខជនបណ្ឌិត **ប៊ុន ធឿន** វិទ្យាសាស្ត្រនយោបាយ ..៤៩

១០. ព្រះសង្ឃ ទស្សនវិទូនិងអ្នកវិទ្យាសាស្ត្រ បេក្ខបណ្ឌិត **សៅរ៍ ចន្ទថុល្ល** ផ្នែកទស្សនវិជ្ជា ..........៥៥

១១.ប្រវ៉ាឡង់ជំងឺគ្រុនចាញ់ឆ្នាំ២០០៩ បេក្ខជនបណ្ឌិត **ម៉ាន់ សុងញា** វិទ្យាសាស្ត្រសុខាភិបាល ..៦០

១២. គ្រោះថ្នាក់ការងារចំពោះកម្មករ-និយោជិតនៅក្នុងសហគ្រាសកាត់ដេរ បេក្ខជនបណ្ឌិត **សុខ បូរី** ជំនាញ នីតិសាស្ត្រ ...............................................................................................៦៤

១៣. ដំណើរអាជីវកម្មនាំចូលនិងនាំចេញតាមមាត់ច្រកអន្តរជាតិភ្នំដិន បេក្ខជនបណ្ឌិត **ចិន្តា បណ្ឌិត** ឯកទេស គ្រប់គ្រង.........................................................................................................៧១

១៤. ការគ្រប់គ្រងនិងការអភិវឌ្ឍកំពង់ផែស្វយ័តភ្នំពេញ បេក្ខជនបណ្ឌិត **ជា ប៊ុនធៀង** ...............៧៧

# ការវិភាគអំពីចរិតលក្ខណៈនៃកម្លាំងពលកម្មក្នុងប៉ូលសេដ្ឋកិច្ច ភ្នំពេញ ព្រះសីហនុនិងសៀមរាប (២០០៨-២០១៨)


**បេក្ខជនបណ្ឌិត ជា ចន្ថា**

**ផ្នែកភូមិវិទ្យានិងនគរូបនីយកម្ម**




## សេចក្ដីផ្ដើម

កម្លាំងពលកម្មបានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងប្រទេសនីមួយៗ។ ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ចគឺពឹងអាស្រ័យជាខ្លាំងទៅលើចំនួនមនុស្សជាកម្លាំងពលកម្មដែលមានគុណភាពការងារបទពិសោធន៍ ភាពជាប់លាប់នៃការងារ និងភាពហ្មត់ចត់របស់គេដែលអាចផលិតបាននូវមុខទំនិញនិងការងារ សេវាកម្មដទៃទៀត បានទាំងបរិមាណនិងគុណភាព។ ជាពិសេស ការចូលរួមនៃកម្លាំងពលកម្មទៅ ក្នុងវិស័យ សកម្មភាពសេដ្ឋកិច្ចនៅតាមប៉ូលសំខាន់ៗ ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការសិក្សាពីចរិតលក្ខណៈនៃកម្លាំងពលកម្មនៅតាមប៉ូលទាំងនោះកាន់តែមានអត្ថន័យសំខាន់ថែមទៀត ដើម្បីស្វែងយល់ពីទម្រង់នៃកម្លាំងពលកម្មការបណ្ដុះបណ្ដាលជំនាញ ប្រភេទការងារ មុខរបរ ប្រាក់ចំណូល បទពិសោធន៍ការងារ កម្រិតវប្បធម៌ មូលហេតុបន្លាស់ទីនិងដំណោះស្រាយនានាដែលទាក់ទងកម្លាំងពលកម្មនិងជនបម្លាស់ទី។

និក្ខេបបទស្ដីពីការវិភាគអំពីចរិតលក្ខណៈនៃកម្លាំងពលកម្មក្នុងប៉ូលភ្នំពេញ ព្រះសីហនុ និងសៀមរាប បានប្រើប្រាស់ទិន្នន័យមួយផ្នែករបស់ជំរឿនប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៨ និងទិន្នន័យចុះអង្កេតផ្ទាល់ខ្លួនទៅលើកម្លាំងពលកម្មនៅតាមប៉ូលនីមួយៗក្នុងឆ្នាំ២០១៣។ ការវិភាគទិន្នន័យទាំងនេះ បានសិក្សាស្វែងយល់អំពីចរិតលក្ខណៈនៃកម្លាំងពលកម្មដែលចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច និងរួមចំណែកផ្ដល់នូវព័ត៌មានទូទៅសម្រាប់ជាជំនួយដល់ការអភិវឌ្ឍតំបន់ប៉ូលទៅអនាគត។

ពាក្យថា *កម្លាំងពលកម្ម (Labor Force)* ក្នុងនិក្ខេបបទនេះ គឺប្រើក្នុងន័យកំណត់ពីការមានការងារធ្វើ និងគ្មានការងារធ្វើរបស់ប្រជាជនក្នុងប៉ូលសេដ្ឋកិច្ចទាំងបី។ ពោលគឺប្រើក្នុងន័យបញ្ជាក់ពីទំហំ *ប្រជាជនសកម្មសេដ្ឋកិច្ច (Economically Active Population)* ហើយអត្ថន័យនៃពាក្យនេះ មានន័យដូចគ្នានឹងពាក្យថា *កម្លាំងពលកម្ម*។ ចំពោះអាយុនៃកម្លាំងពលកម្មដែលបានកំណត់ក្នុងការសិក្សានេះ គឺចាប់គិតពី១៥ឆ្នាំឡើងដោយមិនរាប់បញ្ចូលកម្លាំងពលកម្មរបស់កុមារក្រោមអាយុ១៥ឆ្នាំឡើយ។ នេះមិនមានន័យថាក្មេងក្រោមអាយុ១៥ឆ្នាំមិនអាចចូលរួមធ្វើការហើយទទួលបានប្រាក់កម្រៃនោះទេ ប៉ុន្តែដោយជៀសវាងការពាក់ព័ន្ធទៅនឹងការរំលោភបំពានពលកម្មកុមារ។ ជាពិសេស យោងទៅលើច្បាប់ស្ដីពីការងារដែលបានកំណត់អាយុអប្បបរមាអាចចូលធ្វើជាកម្មករនិយោជិតបាន គឺចាប់ពីអាយុ១៥ឆ្នាំឡើង[១]។ ជាងនេះទៅទៀត គឺលក្ខខណ្ឌសុខភាព សន្តិសុខនិងសីលធម៌របស់ក្មេងទាំងនោះបានធានាដោយពេញលេញហើយគេអាចទទួលបាននូវការអប់រំយ៉ាងត្រឹមត្រូវនិងការបណ្ដុះបណ្ដាលវិជ្ជាជីវៈនៅក្នុងសកម្មភាពដែលពាក់ព័ន្ធ។

[១] សូមមើល : ក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន ***ច្បាប់ស្ដីពីការងារ*** ភ្នំពេញ ក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន ១៩៩៨ ទំព័រ ៨២។

## ១- ការវាយតម្លៃចរិតលក្ខណៈនៃកម្លាំងពលកម្មក្នុងប៉ូលនីមួយៗ

តាមរយៈការវិភាគអំពីចរិតលក្ខណៈនៃកម្លាំងពលកម្ម បានរកឃើញប៉ូលសៀមរាបមានអត្រាចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចខ្ពស់បំផុតប្រមាណ ៨០,៥% ខណៈប៉ូលព្រះសីហនុមាន ៦៨,៥% និងប៉ូលភ្នំពេញមាន ៦៥,១%។ ហេតុផលចម្បងអាចដោយសារប៉ូលសៀមរាបមានប្រជាជនរស់នៅជនបទបានចូលរួមក្នុងកម្លាំងពលកម្មមានអត្រាខ្ពស់ ជាពិសេស ការងារនៅក្នុងវិស័យកសិកម្មដូចជា ដាំដុះ ចិញ្ចឹមសត្វ វុក្ខាប្រមាញ់និងនេសាទជាដើម។ ក្នុងចំណោមប្រជាជនសរុបចាប់ពីអាយុ ១៥ឆ្នាំឡើង ១ ៧៥៩ ៧០១នាក់ក្នុងប៉ូលទាំងបី គឺមាន ៦៧,៧% ជាអ្នកមានការងារធ្វើ ២,៧% ជាអ្នកគ្មានការងារធ្វើនិងក្រៅពីនោះជាអ្នកមិនបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចស្រួបយក ២៩,៦%។ ចំពោះមនុស្សដែលមិនបានចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនិងរួមទាំងចំនួនក្មេងដ៏ច្រើននៅក្រោមអាយុ១៥ឆ្នាំផង ជាបន្ទុកមួយសម្រាប់មនុស្សស្ថិតក្នុងសកម្មភាពសេដ្ឋកិច្ចត្រូវរ៉ាប់រងចិញ្ចឹមពួកគេ។

បុរសមានអត្រាចូលរួមក្នុងកម្លាំងពលកម្មខ្ពស់ជាងស្ត្រី (បុរស ៧៦,៥% និង ស្ត្រី ៦៥,១%) ហើយជាលទ្ធផលនៃអត្រាគ្មានការងារធ្វើស្ត្រីមានអត្រាខ្ពស់ជាងបុរសវិញ (បុរសមាន៣% និងស្ត្រីមាន៤,៨%)។ មានហេតុផលមួយចំនួនដែលអាចបញ្ជាក់ពីអំណះអំណាងខាងលើនេះបានដូចជា ស្ត្រីទទួលភារកិច្ចជាអ្នកធ្វើការផ្ទះមិនបានចាត់ទុកជាសកម្មភាពសេដ្ឋកិច្ចនោះទេ។ អត្រាគ្មានការងារធ្វើរបស់ស្ត្រីនៅទីប្រជុំជនកាន់តែបង្ហាញមានកម្រិតខ្ពស់ថែមទៀត គឺស្មើរពីរដងខ្ពស់ជាងអត្រាគ្មានការងារធ្វើបុរស (បុរសមាន ៤,២% និង ស្ត្រីមាន ៧,០%)។ គួរកត់សម្គាល់ថា បទពិសោធន៍ការងារអាចជាចំណុចសំខាន់មួយជួយជំរុញឱ្យកម្លាំងពលកម្មបុរសនិងស្ត្រីរកការងារធ្វើបានទៅតាមកម្រិតជំនាញរបស់ពួកគេ។

មានបញ្ហាប្រឈមមួយចំនួនចំពោះស្ត្រីដូចជាគម្លាតយេនឌ័រនៅក្នុងវិស័យការងារ និងការទទួលបានការអប់រំតិចតួចនៅក្នុងចំណោមស្ត្រីជាកម្មករដែលអាចនាំឱ្យស្ត្រីមានជម្រើសតិចតួចក្នុងការប្រកបរបរចិញ្ចឹមជីវិត ឬមានវិសមភាពយេនឌ័រក្នុងការងារសំខាន់ៗ និងតួនាទីធ្វើសេចក្តីសម្រេចចិត្តនិងការកើនឡើងចំណាកស្រុកដើម្បីស្វែងរកការងារធ្វើ។ ឆ្លើយតបទៅនឹងបញ្ហានេះ គួរយកចិត្តទុកដាក់ដល់ការសិក្សារបស់ក្មេងស្រីដើម្បីឱ្យគេទទួលបានកម្រិតសិក្សាអប់រំខ្ពស់ៗ ហើយទន្ទឹមនឹងនោះគួរផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗដល់ស្ត្រីដើម្បីឱ្យគេអាចបង្កើតមុខរបរនិងប្រាក់ចំណូលក្នុងក្រុមគ្រួសារ។ ជាពិសេស ការបង្កើតមុខរបរដល់ស្ត្រីដែលងាយរងគ្រោះនិងស្ត្រីជាជនបន្លាស់ទី តាមរយៈការផ្តល់ដើមទុនឬប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាបនិងមានការបណ្តុះបណ្តាលអាជីពឱ្យបានត្រឹមត្រូវនិងបន្តពិនិត្យតាមដាននិងផ្តល់ប្រឹក្សាឱ្យបានទៀងទាត់ផងនោះ នឹងផ្តល់ឱកាសបង្កើនការងារដល់ស្ត្រីនិងបង្កើនជីវភាពរស់នៅបានប្រសើរឡើង។

អត្រាគ្មានការងារធ្វើក្នុងប៉ូលភ្នំពេញមាន៥,៥% ខណៈប៉ូលពីរទៀតមានអត្រាគ្មានការងារធ្វើប្រហាក់ប្រហែលគ្នាប្រមាណ២%ប៉ុណ្ណោះ។ នេះអាចចាត់ទុកថា មានអ្នកស្វែងរកការងារធ្វើច្រើននៅក្នុងប៉ូលភ្នំពេញបើប្រៀបធៀបទៅនឹងប៉ូលសៀមរាបនិងប៉ូលព្រះសីហនុ។ ការសិក្សាបានរកឃើញមានកំណើនឡើងនៃអ្នកស្វែងរកការងារធ្វើក្នុងស្រទាប់យុវជនដែលទើបបញ្ចប់ការសិក្សា។ ដូច្នេះ ការត្រៀមរៀបចំបង្កើតការងារថ្មីៗឱ្យបានច្រើនដល់យុវជនទាំងនោះ អាចជាការចាំបាច់ដើម្បីរួមចំណែកកាត់បន្ថយអត្រាគ្មានការងារធ្វើ ការបង្កើនឱកាសការងារនិងប្រាក់ចំណូលផងដែរ ព្រោះមកដល់ពេលនេះ យុវជនដែលមានដើមកំណើតដ៏ច្រើនលើសលប់ក្នុងទសវត្សរ៍ឆ្នាំ១៩៨០និងឆ្នាំ១៩៩០ បានឈានដល់វ័យមានគូស្រករនិងត្រូវស្វែងរកការងារធ្វើ។ វិស័យជាអាទិភាពសំខាន់ៗដែលអាចផ្តល់ការងារធ្វើច្រើនដល់កម្លាំងពលកម្មថ្មីៗក្នុងប៉ូលភ្នំពេញមាននៅក្នុងវិស័យសេវាកម្មនិងឧស្សាហកម្ម។

ក្នុងទិសដៅយុទ្ធសាស្ត្រអភិវឌ្ឍប៉ូលភ្នំពេញរយៈពេលខ្លីខាងមុខគឺត្រូវពង្រីកគោលដៅទីផ្សារលំនាំចេញផលិតផលទៅកាន់បរទេស ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ការបង្កើតតំបន់ឧស្សាហកម្មប្រមូលផ្តុំនិងបង្កើនការងារក្នុងវិស័យសេវាកម្ម ដើម្បីបង្កើតឱកាសការងារដល់កម្លាំងពលកម្ម។ អាចសម្រេចបាននូវការងារទាំងនេះទាមទារឱ្យមានវិនិយោគទុនក្នុងទ្រង់ទ្រាយធំដែលអាចបង្កើនសន្ទុះអភិវឌ្ឍសេដ្ឋកិច្ច និងមានការចូលរួមលើកទឹកចិត្តពីសំណាក់រាជរដ្ឋាភិបាល។

បើពិនិត្យមើល អត្រាចូលរួមក្នុងកម្លាំងពលកម្មតាមក្រុមអាយុក្នុងប៉ូលនីមួយៗមានកម្រិតខ្ពស់ពី ៧០ទៅ ៩៤% នៅចន្លោះអាយុ២៥ទៅ៥៤ឆ្នាំ។ នេះអាចចាត់ទុកថា ជាក្រុមអាយុដែលសកម្មក្នុងសកម្មភាពសេដ្ឋកិច្ចឬជាអ្នករកចំណូលដើម្បីផ្គត់ផ្គង់ជីវភាពក្រុមគ្រួសារ។ ប៉ុន្តែនៅក្រុមអាយុក្មេង ១៥-១៩ឆ្នាំ អត្រាចូលរួមក្នុងកម្លាំងពលកម្មហាក់មានកម្រិតទាបនៅឡើយ (ពី៣៥ទៅ៥០%) និងកាន់តែមានកម្រិតទាបទៅៗចាប់ពីអាយុ ៦០ឆ្នាំឡើង។ និន្នាការនេះ អាចដោយសារមនុស្សភាគច្រើននៅក្រុមអាយុក្មេងជាអ្នករស់នៅក្នុងបន្ទុកឬជាសិស្សដែលគេមិនទាន់ចូលរួមក្នុងកម្លាំងពលកម្មនៅឡើយ។ រីឯវ័យចំណាស់ចាប់ពី៦០ឆ្នាំឡើង មានសមាមាត្រចូលរួមក្នុងកម្លាំងពលកម្មទាប អាចដោយសារពួកគាត់បានចូលនិវត្តន៍ឬបានឈប់ពីការងារភាគច្រើន។

ភាពមានការងារធ្វើជាប់លាប់របស់កម្លាំងពលកម្មជារឿងសំខាន់មួយដែលគួរយកចិត្តទុកដាក់ ព្រោះពលករអាចផលិតបាននូវផលិតផលទៅតាមតម្រូវការទីផ្សារ បង្កើនបានបច្ចេកទេស បទពិសោធន៍និងរួមទាំងប្រាក់បៀវត្សរ៍ដើម្បីទ្រទ្រង់ជីវភាពរស់នៅ។ម្យ៉ាងទៀត បានផ្តល់នូវលទ្ធភាពគ្រប់គ្រាន់ដល់ក្រុមអាយុដែលសកម្មក្នុងសកម្មភាពសេដ្ឋកិច្ច អាចរកប្រាក់ចំណូលដើម្បីចិញ្ចឹមមនុស្សនៅក្នុងបន្ទុកនិងផ្គត់ផ្គង់ជីវភាពក្រុមគ្រួសាររបស់គេទាំងមូល។

តាមលទ្ធផលនៃការវិភាគបង្ហាញថា អ្នកគ្មានការងារធ្វើមិនជាប់ទាក់ទិនទៅនឹងភាពចេះអក្សរនិងភាពមិនចេះអក្សររបស់គេនោះទេ។ ជាទូទៅ កម្លាំងពលកម្មមានកម្រិតសិក្សាទាបៗអាចរកការងារធ្វើបានទៅតាមជំនាញបទពិសោធន៍និងតាមស្ថានភាពនៃការងារនីមួយៗដែលមិនទាមទារនូវកម្រិតវប្បធម៌ខ្ពស់ពេកឬលក្ខខណ្ឌការងារចាំបាច់ផ្សេងៗដែលទាក់ទិនដល់សមត្ថភាពរបស់កម្លាំងពលកម្មជាចាំបាច់។ ការងារទាំងនោះ ច្រើនជាការងារទូទៅដែលធ្វើដោយកម្លាំងកាយ មាននៅក្នុងវិស័យកសិកម្មដូចជា ដាំដុះ នេសាទនិងបរចិញ្ចឹមសត្វជាដើម។ ម្យ៉ាងទៀត នៅតាមទីក្រុងនិងទីប្រជុំជនធំៗដែលមានសម្មភាពសេដ្ឋកិច្ចនិងពាណិជ្ជកម្មមមាញឹកនោះ កម្លាំងពលកម្មអាចរកការងារធ្វើបានដូចជា កម្មករលីសែង កម្មករដឹកជញ្ជូនទំនិញ កម្មករសំណង់ដែលគ្មានជំនាញកម្មកររោងចក្រកាត់ដេរនិងកិច្ចការប្រកបរបររកស៊ីផ្ទាល់។

ការសិក្សាបានរកឃើញអត្រាគ្មានការងារធ្វើរបស់ស្ត្រីដែលមិនចេះអក្សរនៅតាមប៉ូលនីមួយៗ មានតួលេខខ្ពស់ជាងបុរសបន្តិច ខណៈអត្រាចេះអក្សរមានកម្រិតប្រហាក់ប្រហែលគ្នា។ តាមស្ថានភាពនេះ ស្ត្រីអាចជួបនឹងការលំបាកច្រើន ប្រសិនបើពួកគាត់ជាមេគ្រួសារឬជាអ្នករកចំណូលផ្គត់ផ្គង់ក្នុងជីវភាពរស់នៅ ហើយស្ថិតក្នុងស្ថានភាពគ្មានការងារធ្វើនៅបន្តដដែលនោះ។ ការលើកកម្ពស់ឱកាសការងារដល់ស្ត្រី តាមរយៈការបង្កើតមុខរបរខ្នាតតូចពីអង្គការក្រៅរដ្ឋាភិបាលដែលជាដៃគូនិងពីរាជរដ្ឋាភិបាលអាចរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ចរបស់ស្ត្រី។ ការបណ្តុះបណ្តាលជំនាញនិងការបង្កើតការងារឱ្យបានច្រើនគឺជាគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងន័យនេះ ទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីរួមចំណែកធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជន ការកាត់បន្ថយភាពក្រីក្រនិងពន្លឿនកំណើនសេដ្ឋកិច្ចជាតិ។ ទន្ទឹមនឹងនោះ គួរជំរុញលើកទឹកចិត្តឱ្យមានវិនិយោគទុនពីផ្នែកឯកជនបន្ថែមទៀត ទាំងនៅទីប្រជុំជននិង

ជនបទ។ ទាក់ទងការបណ្តុះបណ្តាលជំនាញស្របទៅនឹងការងារថ្មីៗ អាចតម្រូវឱ្យមានការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យបានច្រើនឡើង។ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានដើរតួនាទីសំខាន់ក្នុងការផ្តល់កម្មវិធីបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមគ្រឹះស្ថានបណ្តុះបណ្តាលកម្រិតបឋម កម្រិតមធ្យម និងកម្រិតឧត្តម។

ប៉ូលទាំងបីមានអ្នកមានការងារធ្វើសរុប ១ ១៩៧ ៨៦២នាក់ ក្នុងនោះមាន ៤៤,៦% បានបម្រើការងារក្នុងវិស័យសេវាកម្ម ខណៈមួយភាគបីធ្វើការក្នុងវិស័យកសិកម្មនិងក្រៅពីនោះ ២១,១% មាននៅក្នុងវិស័យឧស្សាហកម្ម។ ស្ត្រីបានបម្រើការងារក្នុងវិស័យទី១និងវិស័យទី២មានសមាមាត្រខ្ពស់ (៣៦,៩%និង២៣,៧%) បើប្រៀបធៀបទៅនឹងបុរសក្នុងវិស័យជាមួយគ្នា។ ប្រការនេះបញ្ជាក់ថា ស្ត្រីច្រើនប្រកបមុខរបរក្នុងផ្នែកកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់និងក្នុងរោងចក្រកែច្នៃម្ហូបអាហារនិងគ្រឿងឧបភោគបរិភោគ។ តាមការសង្កេតជាទូទៅ ការងារនៅក្នុងវិស័យកសិកម្មនៅតំបន់ជនបទក្នុងប៉ូលនីមួយៗបានផ្តល់ឱកាសការងារធ្វើច្រើនដល់កម្លាំងពលកម្មជាស្ត្រី។ ទន្ទឹមនឹងនោះ នៅតាមទីប្រជុំជនក៏មានឧស្សាហកម្មធុនស្រាលផ្នែកកាត់ដេរសម្លៀកបំពាក់និងវាយនភណ្ឌបានស្រូបយកកម្លាំងពលកម្មជាស្ត្រី និងផ្តល់ឱកាសការងារច្រើនដល់ស្ត្រីផងដែរ។ ដោយឡែក វិស័យទី៣ឬវិស័យសេវាកម្មបានស្រូបយកសមាមាត្របុរសខ្ពស់ជាងស្ត្រីវិញ (បុរសមាន ៤៩,៥% ខណៈស្ត្រីមាន ៣៩,៤%)។ ទាំងនេះដោយសារការងារក្នុងផ្នែកដឹកជញ្ជូននិងទូរគមនាគមន៍ ជួសជុលយានយន្តនិងឃ្លាំង ការសិក្សាអប់រំនិងផ្នែករដ្ឋបាលសាធារណៈ និង ការពារសន្តិសុខសង្គមដែលមានការពារប្រទេសនិងប៉ូលិស បានផ្តល់ការងារដល់បុរសច្រើននៅតាមប៉ូលនីមួយៗ។ តាមការសន្និដ្ឋានជាទូទៅ គឺប៉ូលសេដ្ឋកិច្ចទាំងឡាយណាដែលមានភាគរយអ្នកមានការងារធ្វើខ្ពស់ក្នុងវិស័យឧស្សាហកម្មនិងវិស័យសេវាកម្មនោះ អាចចាត់ទុកថាមានសំទុះអភិវឌ្ឍន៍សេដ្ឋកិច្ចរីកចម្រើនជាងប៉ូលដែលមានភាគរយអ្នកមានការងារធ្វើខ្ពស់ក្នុងវិស័យទី១ឬវិស័យកសិកម្ម។

ចំនួនគំរូតំណាងនៃកម្លាំងពលកម្មសរុបដែលបានសម្ភាសក្នុងប៉ូលទាំងបីមាន ៤៦០នាក់។ ក្នុងនោះមាន ៥៨,៧% ជាជនបម្លាស់ទី និង ៤១,៣% ជាជនមិនបម្លាស់ទី។ សមាមាត្របុរសជាជនបម្លាស់ទីមាន ៥៩,៤% ខណៈស្ត្រីមាន ៥៨,១%។ ទិន្នន័យចុះអង្កេតលើកម្លាំងពលកម្មក្នុងប៉ូលទាំងបី ហាក់បង្ហាញជនបម្លាស់ទីមានសមាមាត្រទាបបន្តិច បើប្រៀបធៀបទៅនឹងទិន្នន័យជំរឿនប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៨។ ប្រការនេះអាចដោយសារតែចំនួនគំរូនៃកម្លាំងពលកម្មនៅក្នុងការសិក្សានេះមានតិច និងការជ្រើសរើសដោយចៃដន្យសម្ភាសប៉ះចំទៅលើកម្លាំងពលកម្មដែលជាជនមិនបម្លាស់ទី។

ក្នុងចំណោមកម្លាំងពលកម្មជាជនបម្លាស់ទីសរុបចំនួន ២៧០នាក់ ដែលបានសម្ភាសក្នុងប៉ូលទាំងបី គឺអ្នកដែលបានបម្លាស់ទីដោយមូលហេតុស្វែងរកការងារធ្វើ ស្រូបយកតួលេខខ្ពស់បំផុតរហូតដល់ ៦៧% គ្រួសារផ្លាស់ប្តូរលំនៅឋានមាន ១៣% រៀបអាពាហ៍ពិពាហ៍មាន ៧,៨% ប្តូរទីកន្លែងធ្វើការមាន ៧,៤% និងក្រៅពីនោះបម្លាស់ទីដោយមូលហេតុសិក្សាមាន ៤,៨%។ ចំពោះជនបម្លាស់ទីភាគច្រើនដោយមូលហេតុស្វែងរកការងារធ្វើនៅតាមប៉ូលនីមួយៗ អាចដោយសារប៉ូលទាំងនោះជាកន្លែងប្រមូលផ្តុំនូវសកម្មភាពសេដ្ឋកិច្ចសំខាន់ៗនៅក្នុងប្រទេសផ្តល់នូវឱកាសការងារនិងជាគោលដៅនៃជនបម្លាស់ទីមករកការងារធ្វើ។ ការអភិវឌ្ឍតំបន់ប៉ូលនីមួយៗនាពេលបច្ចុប្បន្ននិងទៅអនាគត អាចនឹងទាក់ទាញបានឬជាកត្តាស្រូបកម្លាំងពលកម្មថែមទៀតពីតំបន់ជុំវិញ។

ទោះជាយ៉ាងនេះក្តីការធ្វើបម្លាស់ទីនៃកម្លាំងពលកម្មពីតំបន់ជនបទទៅរកការងារធ្វើនៅទីក្រុងអាចបណ្តាលមកពីលក្ខខណ្ឌផ្សេងៗទៀត ដែលបណ្តាលមកពីកត្តារុញច្រានផងដែរ។ ក្នុងនោះរួមបញ្ចូលទាំងស្ថានភាព

សេដ្ឋកិច្ចមានភាពយ៉ាប់យ៉ឺន កង្វះមុខរបរនិងដើមទុន ភាពគ្មានការងារធ្វើនិងមានការងារធ្វើមិនជាប់លាប់នៅក្នុងមូលដ្ឋានដែលគេរស់នៅជាដើម។ ដោយជួបប្រទះនូវការលំបាកមួយចំនួនក្នុងការងារបង្កបង្កើនផលដូចជាមានដីស្រែតិចតួច ទិន្នផលស្រូវទាប ជួបប្រទះនូវគ្រោះទឹកជំនន់ ភាពរាំងស្ងួតឬជំពាក់បំណុលផងនោះនាំឱ្យការសម្រេចចិត្តធ្វើបន្លាស់ទីទៅរកការងារនៅទីក្រុងក្នុងតំបន់ប៉ូលសេដ្ឋកិច្ចនីមួយៗកាន់តែប្រាកដក្នុងចិត្តឡើង។ ជារឿយៗជនបន្លាស់ទីតែងគិតថា អាចរកការងារធ្វើបាននៅទីក្រុង ដោយទទួលបានប្រាក់កម្រៃសមរម្យនិងអាចសន្សំប្រាក់កាសបានខ្លះៗផង។ ប៉ុន្តែ ជនបន្លាស់ទីមកពីជនបទភាគច្រើនមិនសូវមានជំនាញគ្រប់គ្រាន់ ដូច្នេះពួកគេអាចប្រឈមនិងការលំបាកស្វែងរកការងារធ្វើនិងការរស់នៅទីក្រុង ព្រោះតម្លៃចាយវាយនៅទីក្រុងមានតម្លៃច្រើនជងខ្ពស់ជាងនៅជនបទ។

ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទ អាចជួយកាត់បន្ថយបម្លាស់ទីទៅរកការងារធ្វើឆ្ងាយៗនិងបម្លាស់ទីឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសជិតខាង។ តាមរយៈការបង្កើតមុខរបរខ្នាតតូចនៅតាមក្រុមគ្រួសារ ដោយផ្តល់ដើមទុនឬប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាបពីអង្គការនិងស្ថាប័នមី-ក្រូហិរញ្ញវត្ថុដល់ប្រជាកសិករ ដើម្បីឱ្យពួកគាត់មានលទ្ធភាពពង្រីកការដាំដុះ ការចិញ្ចឹមសត្វនិងបង្កើតមុខរបរផ្សេងៗនោះនឹងជួយបង្កើនជីវភាពរស់នៅ និងរួមចំណែកកាត់បន្ថយបម្លាស់ទីពីជនបទទៅរកការងារធ្វើនៅទីក្រុងនិងបម្លាស់ទីឆ្លងដែនដោយខុសច្បាប់ទៅប្រទេសជិតខាង។ ទន្ទឹមនឹងនោះ ការចូលរួមលើកស្ទួយវិស័យកសិកម្មនៅតំបន់ជនបទតាមកម្មវិធីអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល បានរួមចំណែកកាត់បន្ថយបម្លាស់ទីពីជនបទផងដែរ។

ការសិក្សាបានរកឃើញថា ក្នុងចំណោមជនបម្លាស់ទីសរុបដោយមូលហេតុស្វែងរកការងារធ្វើក្នុងប៉ូលទាំងបីគឺមាន ៦៩,៦% បានសម្រេចចិត្តបម្លាស់ទីដោយខ្លួនឯង ខណៈតាមមិត្តភក្តិនិងឪពុកម្តាយមានសមាមាត្រស្មើគ្នា (១០,២%) និងក្រៅពីនោះ បានបម្លាស់ទីតាមរយៈសាច់ញាតិឬអ្នកជិតខាងរបស់ខ្លួន។ កង្វះព័ត៌មានក្នុងការទទួលបានការងារធ្វើដល់អ្នករស់នៅជបទក្នុងប្រទសកម្ពុជានៅមានកម្រិតនៅឡើយ។ ជនបម្លាស់ទីតែសម្រេចចិត្តធ្វើបន្លាស់ទីដើម្បីស្វែងរកការងារធ្វើនៅតាមទីក្រុងនិងទីប្រជុំជនដោយខ្លួនឯង ដោយពុំបានទទួលព័ត៌មានអំពីការងារដែលនៅទំនេរទាំងនោះឡើយ។ ការធ្វើបម្លាស់ទីបែបនេះអាចប្រឈមនូវការលំបាកមួយចំនួនដូចជាត្រូវចាយវាយថវិកាអស់ច្រើនទម្រាំរកការងារបានធ្វើ ភាពគ្មានការងារធ្វើអូសបន្លាយយូរថ្ងៃឬមានការងារធ្វើដែរតែមិនជាប់លាប់និងទទួលប្រាក់កម្រៃទាប។

ចំពោះការងារជំនាញនិងការប្រកបមុខរបរអាជីពមួយចំនួននៅទីក្រុងក្នុងប៉ូលនីមួយៗ អាចតម្រូវឱ្យជនបម្លាស់ទីត្រូវមានជំនាញសមស្របទៅតាមប្រភេទនៃការងារនិងមុខរបរនីមួយៗ។ ប៉ុន្តែទន្ទឹមនឹងនោះ ក៏មានការងារមួយចំនួនដែលជនបម្លាស់ទីអាចស្វែងរកធ្វើបានខ្លះៗដែរដូចជា កម្មករលីសែង កម្មករសំណង់ដែលគ្មានជំនាញ ជាងជួសជុល កម្មករអនាម័យនិងសណ្តាប់ធ្នាប់ សន្តិសុខនិងធ្វើជាអ្នកបម្រើនៅតាមផ្ទះឬភោជនីយដ្ឋាននិងការប្រកបមុខរបររកស៊ីផ្ទាល់ខ្លួនជាច្រើនទៀត។ ការងារទាំងនោះហាក់មិនទាមទារនូវកម្រិតជំនាញខ្ពស់ពេកជាជាងបទពិសោធន៍ការងារដែលគេមាន។

នៅក្នុងកម្រងសំណួរអង្កេតផ្ទាល់ខ្លួនទៅលើកម្លាំងពលកម្មក្នុងប៉ូលនីមួយៗ ឆ្នាំ២០១៣ ក៏បានបញ្ចូលនូវសំណួរទាក់ទងអំពីមូលហេតុឬកត្តាមិនបានជោគជ័យក្នុងការស្វែងរកការងារធ្វើផងដែរ។ ដោយយោងទៅលើបទពិសោធន៍ក្នុងការស្វែងរកការងារធ្វើកន្លងមក ជនបម្លាស់ទីបានលើកឡើងនូវមូលហេតុឬកត្តាមួយចំនួនដែលមិនបានជោគជ័យក្នុងការស្វែងរកការងារធ្វើដូចជា ពុំមានការងារគ្រប់គ្រាន់ឬពុំមានការងារធ្វើនៅទំនេរច្រើនមានការងារធ្វើដែរប៉ុន្តែពុំបានទទួលព័ត៌មានពីការងារទាំងនោះ ពុំមានជំនាញត្រូវនឹងការងារ មានកម្រិតសិក្សាអប់រំ

ទាបនិងពុំចេះភាសាបរទេស ពុំមានបទពិសោធន៍ការងារ មានប្រាក់ខែទាបនិងផ្សេងៗទៀត។ ក្នុងប៉ូលទាំងបី មានជនបម្លាស់ទីដោយមូលហេតុស្វែងរកការងារធ្វើមាន ៣៤,៨% បានឆ្លើយថាគ្មានជំនាញ ខណៈ ២៤,៣% បានលើកឡើងថាគ្មានបទពិសោធន៍ការងារ ១៩,៣% មានកម្រិតសិក្សាអប់រំទាប ១១,៦% ឆ្លើយថាមកពីគ្មាន ការងារធ្វើគ្រប់គ្រាន់និងក្រៅពីនោះ ពុំបានទទួលព័ត៌មានពីការងារមាន ៩,៩%។ ដូច្នេះ ជំនាញនិងបទពិសោធន៍ ការងារជាគន្លឹះសំខាន់ជួយឱ្យជនបម្លាស់ទីអាចស្វែងរកការងារធ្វើបាន។

ជាទូទៅនិន្នាការក្នុងការប្រកាសជ្រើសរើសបុគ្គលិកឱ្យចូលធ្វើការនៅតាមក្រុមហ៊ុន រោងចក្រសហគ្រាស និងអង្គការនានា ច្រើនតម្រូវឱ្យមានលក្ខខណ្ឌចាំបាច់ជាច្រើនដូចជាត្រូវមានបទពិសោធន៍ការងារច្រើនឆ្នាំទៅតាម ជំនាញដែលគេចង់បាន មានសញ្ញាបត្រឬមានកម្រិតសិក្សាអប់រំខ្ពស់ ត្រូវចេះភាសាបរទេសនិងជំនាញផ្សេងៗ ទៀត។ ទាំងនេះអាចចាត់ទុកថា ជាការងារដែលទទួលបានប្រាក់កម្រៃសមរម្យ។ តាមការសិក្សាបានរកឃើញថា ជនបម្លាស់ទីពីតំបន់ជនបទពុំមានលក្ខណវិនិច្ឆ័យសមស្របទៅតាមប្រភេទនៃការងារទាំងនោះឡើយ។ នេះជា ឧបសគ្គមួយដែលរារាំងក្តីស្រមៃរបស់ជនបម្លាស់ទីដែលប្រាថ្នាចង់បានការងារដែលមានប្រាក់កម្រៃខ្ពស់។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ជនបន្លាស់ទីតែងស្វះស្វែងរកការងារធ្វើទៅតាមលទ្ធភាពរបស់ខ្លួន បទពិសោធន៍ការងារនិង តាមស្ថានភាពការងារនីមួយៗ ដែលពួកគាត់អាចទទួលបាននូវប្រាក់កម្រៃ ការបណ្តុះបណ្តាលជំនាញនិងបច្ចេក-ទេសថ្មីៗពីការងារទាំងនោះ។

ក្នុងទិសដៅនេះ ការបង្កើតការងារស្របតាមកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល គឺជាអាទិភាព សំខាន់មួយ ដើម្បីផ្តល់ការងារធ្វើឱ្យបានច្រើនដល់ស្រទាប់យុវជនដែលនឹងចូលរួមក្នុងទីផ្សារកម្លាំងពលកម្មក្នុង ពេលឆាប់ៗខាងមុខ។ ជាពិសេស យុវជនដែលមានដើមកំណើតនៅចុងទសវត្សរ៍ឆ្នាំ១៩៨០ និងនៅក្នុងឆ្នាំជា បន្តបន្ទាប់នៃទសវត្សរ៍ឆ្នាំ១៩៩០ ព្រោះមកដល់ពេលនេះពួកគេដែលមានសមាមាត្រដ៏ច្រើនលើសលប់នោះនឹងត្រូវ ដល់វ័យចូលរួមក្នុងកម្លាំងពលកម្មឬត្រូវស្វែងរកការងារធ្វើ។ ការពង្រីកឧស្សាហកម្មនាំចេញតាមរយៈវិនិយោគទុន ពីបរទេស និងប្រើប្រាស់ធនធានក្នុងស្រុកឱ្យបានប្រសើរជាឱកាសបង្កើតការងារ និងប្រាក់ចំណូលដល់កម្លាំង ពលកម្មនិងរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ទន្ទឹមនឹងនោះ គួរពង្រឹងវិស័យឯកជន ដើម្បីជំរុញឱកាសវិនិយោគទុន ជាតិនិងអន្តរជាតិមកក្នុងតំបន់ប៉ូលនីមួយៗ ព្រោះការរីកចម្រើនក្នុងវិស័យឯកជននឹងជួយជំរុញឱ្យមានកំណើន សេដ្ឋកិច្ចជាតិនិងឱកាសបង្កើតការងារបានយ៉ាងច្រើនដល់កម្លាំងពលកម្ម។

ក្នុងចំណោមគំរូតំណាងនៃកម្លាំងពលកម្មសរុប ៤៦០នាក់ ដែលបានសម្ភាសន៍ក្នុងប៉ូលទាំងបី គឺអ្នក ដែលចេះអក្សរស្រួបយកភាគរយខ្ពស់បំផុតរហូតដល់ ៩៨,៥% ខណៈអ្នកមិនចេះអក្សរមានត្រឹម ១,៥%។ ទោះ ជាយ៉ាងនេះក្តី បើពិនិត្យមើលកម្រិតសិក្សានៃកម្លាំងពលកម្មទាំងនោះវិញហាក់មានកម្រិតសិក្សាទាបៗនៅឡើយ។ ប្រមាណ៣៤,១%បានបញ្ចប់មធ្យមសិក្សាបឋមភូមិ ៣០% បញ្ចប់បឋមសិក្សា ២៧,៨% មិនបានបញ្ចប់បឋម សិក្សានិងក្រៅពីនោះ អ្នកដែលមានកម្រិតសិក្សាខ្ពស់ៗកាន់តែមានចំនួនតិចទៅៗគឺប្រមាណ ៤,៣% បានបញ្ចប់ មធ្យមសិក្សាឬមានសញ្ញាបត្រទុតិយភូមិនិងថ្នាក់ឧត្តមសិក្សាមាន ២,២%។ ស្ត្រីបានបង្ហាញសមាមាត្រខ្ពស់ ជាងបុរសបន្តិចនៅឯកម្រិតសិក្សាទាបៗដូចជាមិនបានបញ្ចប់កម្រិតបឋមសិក្សានិងកម្រិតបឋមសិក្សា ប៉ុន្តែនៅ ឯកម្រិតសិក្សាខ្ពស់ៗបុរសបានបង្ហាញសមាមាត្រខ្ពស់ជាងស្ត្រីវិញ ដូចជាមធ្យមសិក្សាបឋមភូមិ បានបញ្ចប់ មធ្យមសិក្សានិងថ្នាក់ឧត្តមសិក្សា។ ទាក់ទងនឹងសមាមាត្ររវាងបុរសនឹងស្ត្រីតាមកម្រិតសិក្សានីមួយៗអាចបញ្ជាក់ អំពីសមាសភាពនៃការចូលរួមក្នុងកម្លាំងពលកម្មតាមវ័យនិងតាមប្រភេទការងារផងដែរ។ ស្ត្រីវ័យក្មេងៗបាន បញ្ឈប់ពីការសិក្សានៅឯកម្រិតសិក្សាទាបៗ ដោយឆាប់ចូលរួមក្នុងកម្លាំងពលកម្មមុនបុរស ដើម្បីរកចំណូលជួយ

ទ្រទ្រង់ក្នុងជីវភាពក្រុមគ្រួសារ។ និន្នាការនេះ អាចកើតមានឡើងចំពោះគ្រួសារដែលមានជីវភាពខ្សត់ខ្សោយនៅតំបន់ជនបទ គឺកូនស្រីត្រូវបោះបង់ចោលការសិក្សានៅឯកម្រិតសិក្សាទាបៗឬបានបញ្ចប់ត្រឹមថ្នាក់បឋមសិក្សាប៉ុណ្ណោះ។

ការទទួលបានកម្រិតសិក្សាទាបៗ អាចជាចំណុចអសកម្មមួយធ្វើឱ្យកម្លាំងពលកម្មពិបាកចាប់យកនូវមុខជំនាញឬបច្ចេកទេសថ្មីៗ ដែលវិទ្យាសាស្ត្របច្ចុប្បន្នកំពុងរីកចម្រើនយ៉ាងខ្លាំង ហើយទន្ទឹមនឹងនោះវិស័យការងារមួយចំនួនក៏បានប្រើប្រាស់នូវបច្ចេកវិជ្ជានិងឧបករណ៍ផ្នែកវិទ្យាសាស្ត្រទំនើបៗផងដែរ។ ទាំងនេះតម្រូវឱ្យបុគ្គលិកបម្រើការងារនៅតាមផ្នែកមួយចំនួនត្រូវមានកម្រិតយល់ដឹងខ្ពស់រួមទាំងចំណេះដឹងខាងភាសាបរទេសថែមទៀត។ យ៉ាងណាមិញ កម្លាំងពលកម្មដែលមានកម្រិតសិក្សាខ្ពស់ងាយចាប់យកនូវជំនាញបច្ចេកទេសថ្មីៗនិងអាចបង្កើនបានសមត្ថភាពនិងបទពិសោធន៍ការងារបានឆាប់រហ័ស៕

# ការសិក្សាឫសគល់ទស្សនវិជ្ជាខ្មែរ

## បេក្ខជនបណ្ឌិត ប៉ាន់ ខុន្ថា
## ផ្នែកទស្សនវិជ្ជា

## ១- សេចក្ដីផ្ដើម

ការសិក្សាស្រាវជ្រាវអំពី **ឫសគល់ទស្សនវិជ្ជាខ្មែរ** ចាំបាច់យើងត្រូវមើលគំរូប្រព័ន្ធទស្សនវិជ្ជាក្នុងសាកលលោក ទាំងលោកខាងលិចទាំងលោកខាងកើតដើម្បីយកមកធ្វើជាប្រទីបក្នុងការឆ្លុះមើលនិងជីករកឫសគល់ទស្សនវិជ្ជាខ្មែរ។

## ១.១- ទស្សនវិជ្ជាបស្ចិមប្រទេស

ទស្សនវិជ្ជាបស្ចិមប្រទេស មានប្រវត្តិ មានប្រព័ន្ធ មានគោលគំនិតសិក្សារួម ហើយជាទូទៅ មានទំនាស់នឹងគ្រិស្តសាសនាជាប្រចាំ។

- ប្រវត្តិទស្សនវិជ្ជាបស្ចិមប្រទេស ចែកជា ៦សម័យកាល

- ជាតុជាមូលដ្ឋានគ្រឹះក្នុងទស្សនវិជ្ជាបស្ចិមប្រទេសមានៈ ភាសាវិទ្យា អស្តិរូបវិជ្ជា តក្កវិជ្ជា សោភ័ណវិជ្ជា សីលវិជ្ជានិងទ្រឹស្តីពុទ្ធិ

-ទ្រឹស្តីទស្សនវិជ្ជាបស្ចិមប្រទេសអាចមានប្រភពចេញមកពីវិទូម្នាក់និងអាចមានប្រភពចេញមកពីទស្សនវិទូមួយក្រុមដែលមានគំនិតស្របគ្នា មានវិធីសិក្សាដូចគ្នាមានកម្មវត្ថុសិក្សាដូចគ្នាមានទស្សនវិស័យ គោលបំណង គោលដៅ វត្ថុបំណងដូចគ្នា។

ទស្សនៈរបស់ទស្សនវិទូម្នាក់ៗមានដូចជាទស្សនៈរបស់ សូក្រាត ប្លាតុង អារីស្តូត ខុងជឺ ឡៅស៊ឺ ព្រះពុទ្ធ មហាម៉ាត់ យេស៊ូ មហាត្មៈគន្ធី ហ្សង់ប៉ូលហ្សាត ដេកាត អាដាមស្មីតហេហ្គែល កាលម៉ាក្ស លេនីន ជាដើម។

ទស្សនៈរបស់ទស្សនវិទូមួយក្រុម ដែលមានគំនិតដូចគ្នា គេចាត់ចូលជានិកាយ មានដូចជានិកាយអេលេ និកាយរូបជាតុនិយមនិកាយមនោនិយម និកាយតថនិយម និកាយអត្ថិភាពនិយម និកាយទិ្វនិយម និកាយវិចារណញ្ញាណនិយម និកាយបុគ្គលនិយម និកាយពិសោធន៍និយម និកាយផលប្រយោជន៍និយម ជាដើម។ ទ្រឹស្តីទស្សនវិជ្ជា អាចយកទៅអនុវត្តក្នុងវិស័យផ្សេងៗនៅក្នុងសង្គម។



### ១.២- ទស្សនវិជ្ជាបូព៌ាប្រទេស

ទស្សនវិជ្ជាបូព៌ាប្រទេស គ្មានប្រព័ន្ធ គ្មានគោលគំនិតសិក្សារួមទេ ទ្រឹស្តីទស្សនវិជ្ជា សិក្សាទៅតាមប្រទេសនីមួយៗរៀងៗខ្លួន ដូចជា ទស្សនវិជ្ជាចិន ទស្សនវិជ្ជាឥណ្ឌា ទស្សនវិជ្ជាកូរ៉េ ទស្សនវិជ្ជាជប៉ុន ទស្សនវិជ្ជាវៀតណាម ទស្សនវិជ្ជាខ្មែរ ... ហើយជាទូទៅ ទស្សនវិជ្ជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនិងលាយចូលជាមួយសាសនាជានិច្ច។ ហេតុនេះ បើចង់សិក្សាទស្សនវិជ្ជា គេត្រូវសិក្សាសាសនា យល់ដឹងសាសនា គឺយល់ដឹងពីទស្សនវិជ្ជា។

## ២- ឫសគល់និងតម្លៃទស្សនវិជ្ជាខ្មែរ

**ទស្សនវិជ្ជា** និង **សាសនា** កើតចេញពីឫសគល់តែមួយ ហើយរីកលូតលាស់រួមគ្នានៅក្នុងអរិយធម៌អាស៊ី។ ការសិក្សាពី **ឫសគល់ទស្សនវិជ្ជាខ្មែរ** ចាំបាច់ត្រូវរួមបញ្ចូលការសិក្សាឱ្យបានទូលំទូលាយនិងស៊ីជម្រៅនូវប្រព័ន្ធជំនឿខ្មែរដែលមានពីមុនៗមក ដូចជា ជំនឿតូតឹម ជំនឿវិញ្ញាណនិយម ជំនឿលើអ្នកតា ជំនឿលើប្រផ្នូលជំនឿលើសម្បថ ជំនឿលើខ្មោច ព្រាយ បិសាច... ដំណាលគ្នានឹងការសិក្សាព្រហ្មញ្ញសាសនា ពុទ្ធសាសនាទាំងមហាយាន ទាំងហិនយាននិងសាសនាផ្សេងៗ ទៀតដែលមានវត្តមាននៅក្នុងសង្គមខ្មែរតាំងពីបុរាណរហូតមកដល់សព្វថ្ងៃនេះ។ ការសិក្សាពីសញ្ញាណឫសគល់ទស្សនវិជ្ជាខ្មែរ គឺផ្តោតទៅលើចំណុចសំខាន់ៗះ

### ២.១- និកាយទស្សនវិជ្ជាខ្មែរ

និកាយមានន័យថាជាសាលារៀនជាកន្លែងកកើតគំនិត ឬទស្សនៈក្នុងក្រុមមួយ។ របកគំហើញគំនិតឬទស្សនៈចែកជា ៣និកាយគឺនិកាយអាស្រម និកាយប្រាសាទ និងនិកាយវត្ត ដែលជាសាលាទិសាប៉ាម៉ោក។

### ២.២- ទស្សនវិទូខ្មែរ

ក្នុងទស្សនៈរបស់ខ្មែរពាក្យទស្សនវិទូមានន័យស្មើនឹងអាចារ្យឬបណ្ឌិតាចារ្យ។ យោងតាមវចនានុក្រមខ្មែរ សម្ដេច ជួន ណាត ថា ៖ **អាចារ្យ** ឬ **អាចរិយៈឬ បណ្ឌិតាចារ្យ** មានន័យថា អ្នកប្រដៅឬអ្នកបង្ហាត់មារយាទ អ្នកប្រព្រឹត្តល្អ អ្នកកាន់ត្រឹមត្រូវ អ្នកដែលសិស្សត្រូវគោរព អ្នកធ្វើប្រយោជន៍ដល់សិស្ស អ្នកបង្រៀនចំណេះដឹងដល់គេអ្នកអប់រំសីលធម៌អ្នកផ្តល់ទស្សនាទាន។ សម័យមហានគរ(ស.វ.ទី៩គ.ស.៨០២ ដល់ ស.វ.ទី១៤គ.ស. ១៣៣៦) គេឃើញមានបណ្ឌិតាចារ្យជាច្រើនរូបសុទ្ធសឹងតែជាបណ្ឌិតធំៗ និងមានជំនាញច្បាស់លាស់ដោយឡែកៗពីគ្នាក្នុងនោះមានះបណ្ឌិត **សិវសោម** បណ្ឌិត **យតិអមរភាវៈ** បណ្ឌិត **ទិវាករ** បណ្ឌិត **កវិន្ទ្រៈ** បណ្ឌិត **យោគីស្វរ** បណ្ឌិត **ភូបេន្ទ្រៈ** បណ្ឌិត **ឥន្ទ្រទេវី** បណ្ឌិត **សិវាចារ្យ** ...**បណ្ឌិតាចារ្យ** ទាំងអស់នេះសុទ្ធតែជាអ្នកដឹកនាំពិធីសំខាន់ៗ ក្នុងព្រះរាជវាំង និងមានតួនាទីរៀបចំទំនៀមទម្លាប់របស់ព្រះមហាក្សត្រ និងមន្ត្រីជាន់ខ្ពស់ក្នុងសម័យនោះ។ ពិសេស បណ្ឌិតាចារ្យទាំងនោះ ដើរតួនាទីជាអាចារ្យបង្រៀនផង ជារាជគ្រូផង ជាស្ថាបត្យករផង ជាអ្នកចារសិលាចារឹកនិងជាអ្នកផ្តល់ប្រឹក្សាដល់ព្រះមហាក្សត្រ ក្នុងការដឹកនាំប្រទេសជាតិផង។

### ២.៣- ឫសគល់ទស្សនវិជ្ជាខ្មែរ

#### ក- តូតឹមនិយម(ទស្សនៈនិងជំនឿលើសត្វ ជំនឿលើដើមឈើ)

##### ក១- ទស្សនៈខ្មែរអំពីសត្វ

**ជំនឿតូតឹម** គឺជាជំនឿលើសត្វដែលជាដើមសន្តតិវង្ស ជាអាទិទេពជាអវតារបស់អាទិទេពជាអ្នកនាំសាររវាងមនុស្សនឹងអាទិទេព ជាភាវៈមានអំណាចសក្តិសិទ្ធិដែលគួរឬត្រូវគោរពបូជា ជាភាវៈនាំមកនូវប្រផ្នូលល្អឬអាក្រក់។ **សត្វ**ទាំងនោះមានជាអាទិះ នាគ ក្រពើ អណ្តើក ត្រី គោ ក្របី តោ ខ្លា ដំរី គ្រុឌ ហង្ស លលកខ្មោចខ្លែងស្រាក ហ៊ីង គីង្គក់។ល។ វត្តមានគំនូរនិងចម្លាក់សត្វ សបញ្ជាក់ថា ខ្មែរបុរាណ ផ្សារភ្ជាប់ខ្លួនជាមួយបរិស្ថាន

ដែលស្ថិតនៅជុំវិញខ្លួន ជានិមិត្តរូបនៃថាមពលធម្មជាតិ ដែលជាឫសកែវនៃជីវិត។ មនុស្ស បរិស្ថាន សត្វ រុក្ខជាតិ មានអន្តរទំនាក់ទំនងគ្នានិងទ្រទ្រង់ស្ថិរភាពបរិស្ថាន។ ទន្ទឹមនឹងនេះដែរ រូបសត្វទាំងអស់នោះក៏អាចឆ្លុះបញ្ចាំងឱ្យយើងឃើញនូវជំនឿសាសនារបស់ជនជាតិខ្មែរនាសម័យបុរាណដែរ។ ក្នុងទស្សនៈខ្មែរយើងចាត់ទុកត្រីនាគ ហ៊ីងជាសត្វតំណាង ទឹក។ចាបឬបក្សីតំណាងខ្យល់ឬអាកាស។ សត្វជើងបួនដូចជាគោ ក្របី តំណាងដី។ កង្កែប ហ៊ីង គីង្គក់ នាគ តំណាង ភ្លៀង។ សត្វតំណាងនូវឥទ្ធិពលនៃធម្មជាតិដែលជាប្រភពនៃជីវិតនិងទ្រទ្រង់ជីវិត។ ក្នុងជំនឿតូតឹមនេះទៀតសោត គឺគេជឿលើសត្វទាំងមូលឬគ្រាន់តែជាភាគណាមួយនៅលើខ្លួនសត្វ ដូចជា ស្នែង ភ្លុក ចង្កូម ខ្នាយ ចៃ ជាដើម។ ក្នុងពុទ្ធសាសនាក៏បានផ្សារភ្ជាប់ប្រវត្តិព្រះពុទ្ធទាំង៥អង្គ មានរូបតំណាងព្រះពុទ្ធអង្គនីមួយៗក្រោមរូបភាពជាសត្វដែរ។

**ក២- ទស្សនៈខ្មែរអំពីដើមឈើ**

ក្រៅពីជំនឿលើសត្វ ប្រជាជនខ្មែរក៏មានជំនឿលើដើមឈើផងដែរ។ គេជឿថា ដើមឈើធំៗសុទ្ធតែមានភូតអមនុស្សគ្រប់គ្រង កាន់កាប់ឬជាជម្រករបស់អារុក្ខ អារក្ខ អ្នកតា ខ្មោច ព្រាយបិសាច ដូចជា គេជឿថា ខ្មោចអាស្រ័យទីជម្រកនៅដើមចេកថ្វា ព្រាយបិសាច អាស្រ័យទីជម្រកនៅដើមអំពិលឬដើមពោធិ។ ពេលគេសម្រាកស្នាក់អាស្រ័យក្រោមដើមឈើធំៗឬត្រូវបត់ជើងតូចធំក្បែរគល់ដើមឈើធំៗ និងកាប់ដើមឈើយកទៅធ្វើរបស់ប្រើប្រាស់ឬធ្វើផ្ទះ គេត្រូវជម្រាបសុំអារុក្ខ អារក្ខ អ្នកតា ខ្មោច ព្រាយបិសាច មើលថែរក្សាដើមឈើនោះ បើមិនដូច្នោះទេ គេនឹងមិនមានសេចក្តីសុខឡើយ។

**ខ- ទស្សនវិជ្ជាមនោនិយម**

ទស្សនវិជ្ជាមនោនិយម ផ្តោតការសិក្សាទៅលើជំនឿលើព្រលឹង ម្រេញគង្វាល ជំនាងផ្ទះ ព្រះភូមិ អ្នកតា ព្រលឹងមេបា(មាតាធិបតេយ្យ) គ្រូអាចារ្យ គ្រូឧបជ្ឈាយ៍ គ្រូបាធ្យាយ កូនក្រកនិងកូនព្រាយ អាប ព្រាយ បិសាច។

ដោយការជឿលើព្រលឹងនេះហើយ ទើបប្រជាជនខ្មែរបានប្រារព្ធធ្វើពិធីជញ្ជាត់ព្រលឹងនិងធ្វើទង់ព្រលឹងតំណាងព្រលឹងរបស់មនុស្សយើងនៅពេលស្លាប់ ព្រោះគេជឿថា រូបកាយយើងស្លាប់មែនតែព្រលឹងមិនស្លាប់ទេ។ គេមានជំនឿលើ កម្មពៀរ បុណ្យ បាប។ ខ្មែរមានជំនឿថា អ្នកដែលបានសាងអំពើបាប ក្រោយពេលស្លាប់ទៅព្រលឹងរបស់គេនឹងត្រូវធ្លាក់ទៅក្នុងនរក។ នរកមាន៣២ជាន់។ ព្រលឹងនៅឋាននរកនោះ ក្លាយទៅជាប្រេតហើយទទួលទារុណកម្មយ៉ាងសាហាវព្រៃផ្សៃ ដូចជា ដុតក្នុងភ្លើង ដាក់ចូលក្នុងខ្ទះខ្លាញ់ឬទឹកកំពុងពុះ ដុតដែកក្តៅក្រហមរងៀលហើយយកមកចាក់ដោតលើស្បែក មិនបានទទួលសំណែនពីកូនចៅឧទ្ទិសឱ្យជាដើម។ ស្ត្រីដែលយកប្តីគេដល់ពេលស្លាប់ធ្លាក់ទៅឋាននរក ត្រូវទទួលទារុណកម្មឡើងដើមរកាដែក។ នៅលើជញ្ជាំងប្រាសាទនានាតែងតែមាននូវរូបចម្លាក់ស្តីពីរឿងបុណ្យបាប ពីនរកនិងសួគ៌និងរឿងជាច្រើនទៀត ដែលសុទ្ធសឹងជាមេរៀនសម្រាប់ពង្រឹងជំនឿនិងក្រមសីលធម៌។

រាល់ការដោះស្រាយបញ្ហាក្នុងជីវិតតថៈ ពេលមនុស្សខ្មែរអសមត្ថភាព ខ្វះចំណេះដឹង ខ្វះបញ្ញា ខ្វះប្រាជ្ញា ខ្វះលទ្ធភាព គេបែរមកបន់ស្រន់ សែនព្រេន រកជំនួយពី**កម្លាំងអធិធម្មជាតិនិងភូតអមនុស្ស**ឱ្យមកជួយការពារគាំពារនិងជួយដោះស្រាយបញ្ហាលំបាក ទុក្ខព្រួយជាដើម។ ការបន់ស្រន់គឺជាការលួងចិត្ត ជាការឃុំគ្រងស្មារតី ជាការលើកទឹកចិត្ត យើងចាត់ទុកវាជាទស្សនវិស័យដែលមនុស្សដាក់ចេញដើម្បីឱ្យមានការតស៊ូតាំងចិត្តជម្នះក្នុងការប្រតិបត្តិការងារក្នុងជីវិត។ នេះជាអាគមផ្សំអាយុ។

ក្រៅពីជំនឿលើព្រលឹង ប្រជាជនខ្មែរមានជំនឿលើត្រណម ប្រផ្នូលផ្សេងៗនិងការផ្សង ការស្បថ ការប្រើនិម្មិតរូបឧបកិច្ចនិងការគោរពព្រះរស់(ឪពុកម្តាយ)ផងដែរ។

**គ- ទស្សនវិជ្ជារូបធាតុនិយម**( **លោកធាតុវិទ្យា ៖ ទឹក ដី ភ្លើង ខ្យល់** )

ព្រះពុទ្ធបានបរិយាយអំពីធាតុ៤ គឺ **ទឹក ដី ភ្លើង ខ្យល់** ជាលោកធាតុដំបូងដែលទ្រទ្រង់ការកកើតនៃភាវៈទាំងអស់នៅលើលោកយើងនេះ មានដូចជា មនុស្ស សត្វ រុក្ខជាតិនិងវត្ថុអវិញ្ញាណកៈទាំងអស់។បញ្ញត្តិ **ទឹក ដី ភ្លើង ខ្យល់** នៅក្នុងទស្សនវិជ្ជាខ្មែរ មិនគ្រាន់តែមានអត្ថន័យត្រឹមតែជាលោកធាតុវិទ្យាដូចក្នុងទស្សនវិជ្ជាបស្ចិមប្រទេសទេ តែវាមានអត្ថន័យបន្ថែមជាច្រើនអនេកទាក់ទងនឹងជំនឿសាសនាផងដែរ ទាំងក្នុងជំនឿជីវចលនិយម ទាំងក្នុងព្រហ្មញ្ញសាសនា ទាំងក្នុងពុទ្ធសាសនា។

**ឃ- ទស្សនវិជ្ជាទ្វិនិយម**

ទស្សនវិជ្ជាខ្មែរ កសាងឡើងលើគោលការណ៍ទ្វិនិយម។ ទស្សនៈទ្វិនិយម មានដូចជា **អាក្រក់របៀមល្អ សបៀមខ្មៅ ក្តៅបៀមត្រជាក់ ប្រុសនិងស្រី មេនិងបា នាមនិងរូប**។ល។ ការផ្គួបភាពផ្ទុយគ្នា២ឱ្យទៅជាអង្គភាពរួមមួយ និម្មិតទៅជាកម្លាំង ជាថាមពល ជាសក្តានុពល។

**ង- ទស្សនវិជ្ជាលេខ** ( Philosophy of Number )

**លេខ**តំណាងបរិមាណវត្ថុណាមួយនិងមានសារៈសំខាន់ក្នុងការគិតគូរជាអរូបិយ សម្រាប់បម្រើផលប្រយោជន៍ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ក្រៅពីតំណាងចំនួនមនុស្ស សត្វ ដើមឈើ វត្ថុអវិញ្ញាណកៈ **លេខ** ក៏បង្កប់នូវតម្លៃទស្សនវិជ្ជាយ៉ាងច្រើនក្នុងផ្នត់គំនិតប្រជាជនខ្មែរ ដោយផ្សារភ្ជាប់នឹងការងារ សកម្មភាពផ្សេងៗ ក្នុងជីវភាពតាំងពីថ្ងៃកើតរហូតដល់ថ្ងៃស្លាប់ ហើយនិងទាក់ទងនឹងជំនឿសាសនាផងដែរ។ ក្នុងផ្នត់គំនិតខ្មែរយល់ថា **លេខគត់ លេខគូ លេខសេស** ទាក់ទងនឹងផ្កាយព្រះគ្រោះជាមួយនឹងជោគជតារាសីក្នុងទំនាក់ទំនងដំណើរជីវិត មាន ក្រ រាសីឡើង រាសីចុះ ការរស់នៅជួបជុំគ្នាមានសុភមង្គល ការព្រាត់ប្រាស វិនាសអន្តរាយ មានលាភ ជួបគ្រោះចង្រៃ ជាដើម។

**ច- ទស្សនវិជ្ជាលំហ**( Philosophy of Space )

លំហ ជាវេខាគណិតមាត្រអរូប( គ្មានចម្ងាយ គ្មានទិស គ្មានទំហំ គ្មានរូបរាងនិងគ្មានដែនឬមាត្រ )។ វត្តមាន លំហ( ទីកន្លែង) មានពាក់ព័ន្ធគ្រប់ផ្នែក គ្រប់វិស័យ គ្រប់សកម្មភាពនិងមានសារសំខាន់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ។ ផ្នត់គំនិតនយោបាយ សេដ្ឋកិច្ច (កសិកម្ម សិប្បកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម) ការអប់រំ វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ជំនឿ សាសនា ច្បាប់ សង្គមកិច្ច សុខាភិបាល រដ្ឋបាល ការចងក្រងប្រវត្តិសាស្ត្រ ការដាក់ស្លាននាម ការរៀបចំនគរូបនីយកម្ម ដូចជាការរៀបចំទីទួលភូមិឋាន ការសាងសង់សំណង់លំនៅដ្ឋាន ការសាងសង់សំណង់ប្រាសាទ ទីសក្ការៈនិងការប្រារព្ធពិធីក្បួនរីតិ៍ ការរៀបចំកន្លែងកប់សព ការរៀបចំទីកសិកម្ម ជីវដ្ឋាន ជលដ្ឋាន ប្រព័ន្ធគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ ការរៀបចំទីក្រុង ... សុទ្ធតែបានបង្កើតចេញពីអានុភាពគំនិតទស្សនវិជ្ជា កាល-លំហ ទាំងអស់ ហើយវាក៏ឆ្លុះបញ្ចាំងពីអត្តចរិត អាកប្បកិរិយា របៀបរស់នៅអន្តរទំនាក់ទំនងរវាងមនុស្សខ្មែរជាមួយ ទេវ ភូតអមនុស្ស ជោគជតារាសីក្នុងការរស់នៅផងដែរ។

**ឆ- ទស្សនវិជ្ជាកាល** ( Philosophy of Time )

វត្តមាន កាល(ពេលវេលា) មានពាក់ព័ន្ធគ្រប់ផ្នែក គ្រប់វិស័យ គ្រប់សកម្មភាពនិងមានសារៈសំខាន់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ។ ពេលវេលា ដើរតួសំខាន់ក្នុងការកត់ត្រាឬកំណត់កាលបរិច្ឆេទព្រឹត្តិការណ៍និងមានបង្កប់នូវអត្ថន័យទស្សនវិជ្ជាយ៉ាងជ្រាលជ្រៅផងដែរ។ ក្នុងផ្នត់គំនិតខ្មែរ ថ្ងៃ ខែ ឆ្នាំ រដូវ ដើរតួយ៉ាងសំខាន់សម្រាប់គន់គូរនូវរាល់ការទស្សន៍ទាយមើលពីពេលា ជោគជតារាសី ការផ្សំផ្គុំគូស្រករ ទស្សន៍ទាយមើលហេតុភេទដែលអាចនឹងកើតមានក្នុងការធ្វើដំណើរនិងក្នុងការប្រកបកិច្ចការអ្វីមួយ ការទស្សន៍ទាយពីជំងឺព្យាបាលបានឬមិនបាន និងការកំណត់ថ្ងៃអន្សារបស់មនុស្សម្នាក់ៗផងដែរ។ ក្នុងការរស់នៅប្រចាំថ្ងៃ ជតារាសីជីវិតរបស់គេ

ជួបរឿងល្អឬអាក្រក់ គឺអាស្រ័យទៅនឹងទីតាំងក្រុមផ្កាយទាំង៩ គិតជៀបមកលើផែនដី។ ខ្មែរមានជំនឿលើ ឆ្នាំ ខែ ថ្ងៃអណ្ដែតនិងឆ្នាំ ខែ ថ្ងៃ លិច ដែលជាពេលាល្អណាស់ឬពេលាល្អល្មមឬពេលាអាក្រក់ ហើយគេជ្រើសរើសយក តែ ឆ្នាំ ខែ ថ្ងៃ ដែលជាពេលាមង្គលជាពេលាល្អណាស់ឬពេលាល្អល្មម សម្រាប់រៀបចំពិធីសំខាន់ៗ សម្រាប់ខ្លួនធ្វើអ្វីៗក្នុងជីវិតនិងដើម្បីប្រារព្ធពិធីផ្សេងៗក្នុងសាសនា ដើម្បីឱ្យមានសិរីសួស្ដី ជៀសវាងការខាតបង់និងមានគ្រោះថ្នាក់។ រីឯ ឆ្នាំ ខែ ថ្ងៃ ដែលជាពេលាអាក្រក់ គេមិនហ៊ានធ្វើពិធីនិងសម្រេចធ្វើកិច្ចការអ្វីទេ ព្រោះគេបារម្ភណ៍ខ្លាចជួបគ្រោះថ្នាក់ឬខាតបង់ទ្រព្យសម្បត្តិ។ ដោយសារតែសារសំខាន់នៃពេលវេលានេះហើយ ដែលអាចធ្វើឱ្យខកខានក្នុងការប្រារព្ធពិធីក៏មាន ព្រោះតែរើសពេលាមិនបានឬពេលដែលត្រូវធ្វើនោះ កន្លងផុតទៅដោយគេមិនអាចរកថ្ងៃថ្មីមកជំនួស ដូច្នេះ គេត្រូវរង់ចាំ ខែ ថ្ងៃ ដែលជាពេលាល្អនៅពេលក្រោយ។

**ជ- ទស្សនវិជ្ជាជីវិត** ( Philosophy of Life )

ក្នុងផ្នត់គំនិតខ្មែរ មានច្បាប់និងកាតព្វកិច្ចដែលត្រូវផ្សារភ្ជាប់គ្នាក្នុងដំណាក់កាលផ្សេងៗ នៃជីវិតរស់នៅរបស់គេ ដោយឆ្លងកាត់ពីភពមួយទៅភពមួយ ពីវ័យមួយទៅវ័យមួយ គេឱ្យឈ្មោះថា ពិធីឆ្លងភព ពីធីឆ្លងវ័យ ហើយពីធីនេះមានដូចជា ពិធីកាត់សក់បង្កក់ឆ្នបអាពាហ៍ពិពាហ៍ ពិធីបុណ្យសពនិងការកប់ខ្មោច។ ពិធីទាំងនេះឆ្លុះបញ្ចាំងពីគោលការណ៍សីលធម៌ក្នុងការរស់។

**ឈ- ទស្សនវិជ្ជាស្ត្រីនិយម( មាតាធិបតេយ្យ )**

ទស្សនៈរបស់ខ្មែរ ផ្ទុយពីទស្សនៈរបស់ចិននិងទស្សនៈរបស់ឥណ្ឌា ដែលធ្លាប់បានជះឥទ្ធិពលរបស់ខ្លួនមកលើជាតិខ្មែរ។ ក្នុងសង្គមខ្មែរបានឱ្យតម្លៃខ្ពស់ទៅលើស្ត្រីថា៖ ស្ត្រីមានតួនាទីសំខាន់ណាស់ក្នុងការកំណត់ស្ថានភាពនិងសុភមង្គលគ្រួសារ។ ចាស់បុរាណ លោកចាត់ទុកថា ទ្រព្យសម្បត្តិ កិត្តិយស ការស្រឡាញ់រាប់អានពីញាតិមិត្ត សិរីជ័យមង្គលនៅក្នុងគ្រួសារ គឺអាស្រ័យទៅលើសមត្ថភាពនិងភាពប៉ិនប្រសប់របស់ស្ត្រីមេផ្ទះ។ ក្នុងគ្រួសារគេនិយមយកមេជាធំ គេរាប់ញាតិតាមខ្សែស្រឡាយខាងម្ដាយ គឺសង្គមមាតាធិបតេយ្យ។ ក្នុងទស្សនៈនៃសង្គមមាតាធិបតេយ្យ **ស្ត្រី**គឺជានិមិត្តរូបនៃវប្បធម៌ជាតិសាសន៍ សេរីសួស្ដី សុភមង្គល កិត្តិយស សេចក្ដីថ្លៃថ្នូរ សោភ័ណភាព ភាពសប្បាយរីករាយ ភាពទន់ភ្លន់ ក្នុងសង្គម។ មាតាធិបតេយ្យ គឺជាព្រលឹងរបស់ជនជាតិខ្មែរ ដែលឆ្លុះបញ្ចាំងពីទឹកចិត្តនិងផ្នត់គំនិតខ្មែរក្នុងវិស័យសេដ្ឋកិច្ច អប់រំ គ្រប់គ្រងគ្រួសារ ជំនឿ ទំនៀមទម្លាប់ ហើយមានអត្ថិភាពរហូតមកដល់សព្វថ្ងៃ ដូចជាពិធីឡើងផ្ទះថ្មី ពិធីចូលម្លប់ពិធីសែនមេបា ពិធីពេលមានគត៌ ពិធីចែចូវ ពិធីស្ដីដណ្ដឹង ពិធីស៊ីស្លា ពិធីអាពាហ៍ពិពាហ៍ )។

## ៣- សន្និដ្ឋាន

អត្ថិភាពនៃជំនឿលើ រុក្ខជាតិ សត្វ ការគោរពទឹក ដីធ្លី ភ្លើង ខ្យល់ជំនឿលើលេខ ជឿលើព្រលឹងដូនតា អារុក្ខ អារក្ស ព្រលឹងមេបា ព្រាយបិសាច ការស្បថស្បែ ការប្រើនិមិត្តរូបឧបកិច្ច... គឺជាគ្រឹះក្នុងទស្សនវិជ្ជាខ្មែរ។ ពីបុព្វកាលរៀងមក ត្បិតមែនតែមានឥទ្ធិពលគំនិតទស្សនវិជ្ជាពីបរទេសក៏ដោយ តែខ្មែរពុំនិយមយកមកអនុវត្តតាមឬចម្លងតាមទាំងដុលដែរ គឺខ្មែរតែងយកគំនិតទស្សនវិជ្ជាបរទេសទាំងនោះមកកែច្នៃផ្សេផ្សំឱ្យទៅជាលក្ខណៈជាតិ ស្របតាមទស្សនៈនិងផ្នត់គំនិតខ្មែរជាដរាប ពោលគឺ ខ្មែរបានធ្វើ **ជាតូបនីយកម្មខ្មែរនីយកម្ម ខ្មែរូបនីយកម្ម** ដើម្បីតម្រូវទៅតាមទស្សនៈចំណង់ចំណូលចិត្តទំនៀមទម្លាប់និងប្រពៃណីខ្មែរជានិច្ច។ រីឯលក្ខណៈបរទេសណាដែលមិនស្រប មិនស៊ីគ្នានឹងទស្សនៈ ចំណង់ចំណូលចិត្ត ទំនៀមទម្លាប់ និងប្រពៃណីរបស់ខ្មែរត្រូវខ្មែរផាត់ចោល ឬក៏ត្រូវសាបរលាបដោយខ្លួនឯងទៅវិញ។

# គន្ថនិទ្ទេស


១- ខ្លួត ធីតា៖ **ទស្សនវិជ្ជាខ្មែរសម័យអង្គរ** ការផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០០៨។

២- ត្រឹង ងា៖ **អរិយធម៌ខ្មែរ** ភ្នំពេញ គ.ស.១៩៧៤ បោះពុម្ពលើកទី៣។

៣- មីសែល ត្រាណេ៖ **ប្រព័ន្ធគំនិតខ្មែរ** ភាគ១។

៤- អ៊ុំ ប៉ុម៖ **គំនិតទស្សនវិជ្ជាខ្មែរតាមរយៈចំនួនលេខ** ភ្នំពេញ ២០០៩ទំព័រ១-៦០។

៥- អាំងជូលាន៖ **តួនាទីវត្តក្នុងការអប់រំនៅតំបន់អង្គរ** ភ្នំពេញ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ឆ្នាំ១៩៩៨

៦- ងួន ញិល៖ **ព្រលឹងមាតាធិបតេយ្យក្នុងសង្គមខ្មែរ** ភ្នំពេញ បោះពុម្ពនៅរោងពុម្ពកាសែតប្រជាជន ១៩៩២

# ទស្សនវិស័យទូទៅក្នុងការជំរុញនិងសម្របសម្រួលការនាំចេញអង្ករ

**បេក្ខជនបណ្ឌិត មិន ប្រុសបញ្ញារិទ្ធិ**
**ផ្នែកគ្រប់គ្រងសាធារណៈ**



## ១- ស្ថានភាពនៃផលិតកម្មស្រូវនៅកម្ពុជាពីឆ្នាំ១៩៨០-២០១២

### ១.១- ស្ថានភាពនៃផលិតកម្មស្រូវពីឆ្នាំ១៩៨០-១៩៨៩

ស្ថានភាពនៃផលិតកម្មស្រូវពីឆ្នាំ១៩៨០[២]ដល់១៩៨៩ មានការប្រែប្រួលផ្ទៃដីទិន្នផលបរិមាណផលទៅតាមកត្តាផ្សេងៗ ដូចជាកត្តាអាកាសធាតុ កត្តាគ្រោះធម្មជាតិ កត្តាផលិតកម្ម និងកត្តាសត្វចង្រៃបំផ្លាញ។ ផ្ទៃដីដាំដុះស្រូវនៅឆ្នាំ១៩៨០មាន ១,៤៤១លានហិកតា កើនឡើងដល់ ១,៩៣២លានហិកតានៅឆ្នាំ១៩៨៩ ប៉ុន្តែនៅឆ្នាំ១៩៩០និង១៩៩៣ ផ្ទៃដីដាំដុះស្រូវមានការថយចុះបន្តិចវិញមកនៅត្រឹម ១,៨៩០លានហិកតា និង ១,៨៥៦លានហិកតា។ រីឯទិន្នផលស្រូវមានការកើនឡើងយឺតបន្តិចពីឆ្នាំ១៩៨០ ដល់១៩៨៩ គឺកើនពី១,១៩តោន/ហិចតាដល់ ១,៤៤តោន/ហិចតា។ ម្យ៉ាងទៀតបរិមាណផលស្រូវដែលទទួលបានពីឆ្នាំ១៩៨០ ដល់១៩៨៩ កើនពី ១,៧១៧លានតោនដល់ ២,៦៧២លានតោន។ ដើម្បីងាយស្រួលក្នុងការប្រៀបធៀបទិន្នន័យក្នុងឆ្នាំនីមួយៗឱ្យបានច្បាស់លាស់ យើងខ្ញុំលើកយកទាំងផ្ទៃដីដាំដុះស្រូវទិន្នផលស្រូវនិងបរិមាណផលស្រូវចាប់ពីឆ្នាំ(១៩៨០-២០១២)មកបង្ហាញដោយសង់ដ្យាក្រាមផ្តោតទៅលើទិន្នផលស្រូវតែប៉ុណ្ណោះ។

### ១.២- ស្ថានភាពនៃផលិតកម្មស្រូវពីឆ្នាំ១៩៩០-១៩៩៩

ស្ថានភាពនៃផលិតកម្មស្រូវពីឆ្នាំ១៩៩០ដល់១៩៩៩ក៏មានការប្រែប្រួលផ្ទៃដីទិន្នផលបរិមាណផលទៅតាមកត្តាផ្សេងៗដែរដូចជាកត្តាអាកាសធាតុកត្តាគ្រោះធម្មជាតិកត្តាផលិតកម្មនិងកត្តាសត្វចង្រៃបំផ្លាញ។ ផ្ទៃដីដាំដុះស្រូវនៅឆ្នាំ១៩៩០មាន ១,៨៩០លានហិកតាកើនឡើងដល់ ២,១៥៨លានហិកតានៅឆ្នាំ១៩៩៩។ រីឯទិន្នផលស្រូវមានការកើនឡើងពី ១,៣៥តោន/ហិកតាដល់ ១,៩៤តោន/ហិកតា។ ម្យ៉ាងវិញទៀតបរិមាណផលស្រូវដែលទទួលបានពីឆ្នាំ១៩៩០ដល់១៩៩៩ កើនពី ២,៥០លានតោនដល់ ៤,០៤០លានតោន។

### ១.៣- ស្ថានភាពនៃផលិតកម្មស្រូវពីឆ្នាំ២០០០-២០០៨

ស្ថានភាពនៃផលិតកម្មស្រូវពីឆ្នាំ២០០០ដល់២០០៨ក៏នៅតែមានការប្រែប្រួលផ្ទៃដីទិន្នផលបរិមាណផលទៅតាមកត្តាផ្សេងៗដែរ ដូចជាកត្តាអាកាសធាតុ កត្តាគ្រោះធម្មជាតិ កត្តាផលិតកម្ម និងកត្តាសត្វចង្រៃបំផ្លាញ។ ផ្ទៃដីដាំដុះស្រូវនៅឆ្នាំ២០០០មាន ២,៣១៨លានហិកតាកើនឡើងដល់ ២,៦១៥លានហិកតា។ រីឯទិន្នផលស្រូវមានការកើនឡើងពី២,១១តោន/ហិកតាដល់២,៧៤តោន/ហិកតា។ ម្យ៉ាងទៀត បរិមាណផលស្រូវដែលទទួលបានពីឆ្នាំ២០០០ដល់២០០៨ កើនពី ៤,០២៦លានតោនដល់ ៧,១៧លានតោន។

### ១.៤- ស្ថានភាពនៃផលិតកម្មស្រូវពីឆ្នាំ២០០៩-២០១២

ស្ថានភាពនៃផលិតកម្មស្រូវពីឆ្នាំ២០០៩ដល់២០១២ក៏នៅតែមានការប្រែប្រួលផ្ទៃដីទិន្នផលបរិមាណផលទៅតាមកត្តាផ្សេងៗ ដូចជា កត្តាអាកាសធាតុ កត្តាគ្រោះធម្មជាតិ កត្តាផលិតកម្ម និងកត្តាសត្វចង្រៃបំផ្លាញ។ ផ្ទៃដីដាំដុះស្រូវនៅឆ្នាំ២០០៩មាន២,៧១៩លានហិកតាកើនឡើងដល់ ២,៩៨១លានហិកតា។ រីឯទិន្នផលស្រូវ

[២] ម៉ែន សារុម៖ *ជំណាំស្រូវនៅកម្ពុជា* វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា២០០៧ទំព័រ១៨។

មានការកើនឡើងពី២,៨៣តោន/ហិកតាដល់ ៣,១៧តោន/ហិកតាក្នុងឆ្នាំ២០១១ កើនឡើងដល់ ៣,២២តោន/ហិកតាក្នុងឆ្នាំ២០១២។ ម្យ៉ាងទៀតបរិមាណផលស្រូវដែលទទួលបានពីឆ្នាំ២០០៩ដល់២០១២កើនពី៧,៥៨៥លានតោនដល់ ៨,៧៧៩លានតោនក្នុងឆ្នាំ២០១១ បានកើនឡើងដល់ ៩,៣០៩លានតោនក្នុងឆ្នាំ២០១២។

## ២- គោលនយោបាយនិងកត្តាជំរុញផលិតកម្មអង្ករ

### ២.១- យុទ្ធសាស្ត្រជំរុញការនាំចេញអង្ករ

ចក្ខុវិស័យនិងយុទ្ធសាស្ត្រជំរុញការនាំចេញអង្ករ រាជរដ្ឋាភិបាលគឺចង់ឱ្យកម្ពុជាក្លាយជាជង្រុកស្រូវនិងជាប្រទេសនាំចេញអង្ករសំខាន់មួយលើទីផ្សារពិភពលោក។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានកំណត់យកឆ្នាំ២០១៥[៣] ជាឆ្នាំគោលដើម្បី (១)ជំរុញការផលិតស្រូវលើសឱ្យបានច្រើនជាង ៤លានតោន ក្នុងនោះបរិមាណអង្ករសម្រាប់នាំចេញត្រូវសម្រេចឱ្យបានយ៉ាងតិច១លានតោននិង (២)ធ្វើឱ្យអង្ករកម្ពុជាត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ។ ក្នុងការអនុវត្តគំនិតផ្តួចផ្តើមនេះ រាជរដ្ឋាភិបាលនឹងគោរពប្រតិបត្តិគោលការណ៍សំខាន់ៗ មានដូចតទៅនេះ៖ (ក)ប្រកាន់យកគោលការណ៍ទីផ្សារដោយរក្សាការប្រកួតប្រជែង (ខ)លើកទឹកចិត្ត និងគាំទ្រពីការចូលរួមពីសំណាក់កសិករនិងសហគមន៍កសិករនិងការពារផលប្រយោជន៍របស់ពួកគាត់ (គ)ជំរុញកិច្ចសប្រតិបត្តិការនិងភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍សង្គមស៊ីវិលព្រមទាំងវិស័យឯកជន (ឃ)លើកកម្ពស់ប្រសិទ្ធភាពក្នុងការសម្របសម្រួលរវាងក្រសួងស្ថាប័ននានា(ង)ជំរុញការបង្កើនសមត្ថភាពនាំចេញអង្ករពីកម្ពុជាដោយខ្លួនឯងដោយលើកទឹកចិត្តដល់ក្រុមហ៊ុនទាំងអស់មកបើកស្នាក់ការប្រមូលទិញកែច្នៃស្រូវនៅក្នុងប្រទេស។ តាមការសិក្សាស្រាវជ្រាវរបស់ក្រុមអ្នកស្រាវជ្រាវស្តីពីអាស៊ីប៉ាស៊ីហ្វិក និងបណ្តាញបណ្តុះបណ្តាលអំពីជំនួញនៃកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិបានដាក់ចេញនូវយន្តការជំរុញការនាំចេញរបស់ប្រទេសនីមួយៗ ដោយផ្តោតទៅលើការចរាចរតាមមូលនាទីក្រុងដូហា[៤]។

### ២.២- យន្តការជំរុញការនាំចេញអង្ករ

យន្តការស្ថាប័នសម្រាប់អនុវត្តគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ រាជ-រដ្ឋាភិបាលសម្រេចដាក់ចេញនូវយន្តការស្ថាប័នសម្រាប់សម្របសម្រួល និងតាមដានការអនុវត្តដូចខាងក្រោម[៥]៖ (១)គណៈកម្មាការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទទួលខុសត្រូវតាមដានវាយតម្លៃនិងសម្របសម្រួលកម្រិតគោលនយោបាយ (២)គណៈកម្មាធិការជំរុញការនាំចេញកសិផលដែលដឹកនាំដោយក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ និងក្រសួងពាណិជ្ជកម្មជាអ្នកទទួលបន្ទុកសម្របសម្រួលរួមនិងជាសេនាធិការឱ្យប្រមុខរាជរដ្ឋាភិបាល (៣)ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងធនាគារជាតិនៃកម្ពុជាត្រូវទទួលខុសត្រូវរៀបចំនិងដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការបង្កើតស្ថាប័នហិរញ្ញវត្ថុ (៤)ក្រសួងស្ថាប័នពាក់ព័ន្ធនានាត្រូវអនុវត្តតាមការបែងចែកមុខងារនិងភារកិច្ចដូចមានចែងក្នុងវិធានការនិងយន្តការស្ថាប័ន។ យោងតាមស្ថិតិនាំចេញនៃព្រះរាជាណាចក្រកម្ពុជាតាមមុខទំនិញឆ្នាំ២០១០មានចំនួនទឹកប្រាក់ជារៀល ៣,៣៩០,៥៣៥,៥៥៦,២៩៩.៩០រៀល និងជាដុល្លារអាម៉េរិក៥, ៥៨៣, ៥៥៩, ៤៤៥.១២ដុល្លារ[៦]។

---

[៣] រាជរដ្ឋាភិបាលកម្ពុជា៖ *ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ*២០១០ ទំព័រ៤។

[៤] United Nations :*Trade Facilitation Beyond the Multilateral Trade Negotiations : Regional Practices, Customs Valuation and Other Emerging Issues*, New York, 2007, p.11.

[៥] រាជរដ្ឋាភិបាលកម្ពុជា៖ ឯកសារគោលនយោបាយ*ស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ*ដ.ឯ.ម.ទំព័រ១៦-១៧។

[៦] ក្រសួងពាណិជ្ជកម្ម៖ *ស្ថិតិនាំចេញនៃព្រះរាជាណាចក្រកម្ពុជាតាមមុខទំនិញឆ្នាំ២០១០*ភ្នំពេញ ២០១០ ទំព័រ៧។

## ៣. មូលដ្ឋានគ្រឹះសម្រាប់បម្រើដល់ការនាំចេញអង្ករ

មូលដ្ឋានគ្រឹះទាំងនេះមានដូចជាមូលដ្ឋានសន្តិភាពនិងស្ថិរភាពនយោបាយមូលដ្ឋានអតិរេកអង្ករមូលដ្ឋានសមាហរណកម្មអន្តរជាតិនាំឱ្យពាណិជ្ជកម្មក្រៅប្រទេសកើនឡើង មូលដ្ឋានការកែច្នៃអង្ករ មូលដ្ឋានគុណភាពផលិតផលអង្ករ មានរសជាតិឆ្ងាញ់ ការវេចខ្ចប់ ផលិតផលសម្រេចប្រកបដោយភាពទាក់ទាញមូលដ្ឋានផលិតអ្វីៗឱ្យស្របនឹងបទបញ្ញាបច្ចេកទេសស្តង់ដាអន្តរជាតិ និងអង្គការអន្តរជាតិនិងវិធានការអនាម័យភូតគាមអនាម័យ យើងក៏មានមូលដ្ឋានអង្គការអន្តរជាតិសំខាន់ៗដែលទាក់ទងនឹងការនាំចេញអង្ករផងដែរ។ ប្រជាកសិករទូទាំងប្រទេសមានឱកាសនិងលទ្ធភាពគ្រប់គ្រាន់ក្នុងការធ្វើស្រែចម្ការ ដែលជាហេតុធ្វើឱ្យផលិតកម្មស្រូវមានកំណើនគួរឱ្យកត់សម្គាល់ ដែលមិនត្រឹមតែអាចផ្គត់ផ្គង់សម្រាប់តម្រូវការក្នុងស្រុកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចនាំចេញទៅកាន់ទីផ្សារអន្តរជាតិថែមទៀត[៧]។ ការដឹកជញ្ជូន គឺជាវិស័យមួយនៃសេដ្ឋកិច្ចជាតិ ដែលពាក់ព័ន្ធទៅនឹងការបម្លាស់ទីនៃបន្ទុកទំនិញតាមរយៈមធ្យោបាយនិងឧបករណ៍ដឹកជញ្ជូនដ៏សមស្រប[៨]។ម្យ៉ាងទៀតដោយសារទីផ្សារពិភពលោកកើនឡើង បច្ចុប្បន្ននេះប្រជាជនពិភពលោកត្រូវគេប៉ាន់ស្មានថាមានចំនួន ៧.០៣៥ពាន់លាននាក់[៩] តាមការធ្វើជំរឿនរបស់ការិយាល័យជំរឿនរបស់សហរដ្ឋអាម៉េរិក។

## ៤. ដំណោះស្រាយជម្លោះកិច្ចសន្យាអន្តរជាតិ

ច្បាប់លើវិធីដោះស្រាយជម្លោះ កិច្ចសន្យាមួយទោះបីវាជាកិច្ចសន្យាអន្តរជាតិឬមិនមែនក៏ដោយក៏វាគឺជាប្រភពច្បាប់ទីមួយ ស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់ពួកគេ និងស្តីពីដំណោះស្រាយជម្លោះទាក់ទិនទៅនឹងកិច្ចសន្យា។ ផ្នែកខ្លះៗនៃកិច្ចសន្យាអាចមានសារសំខាន់ពិសេសក្នុងការជួយភាគីនិងតុលាការក្នុងការកំណត់ថា តើច្បាប់ណាដែលគ្រប់គ្រងកិច្ចសន្យានិងថា តើជម្លោះត្រូវបានដោះស្រាយដោយវិធីណា។ ផ្នែកសំខាន់ពីរក្នុងចំណោមផ្នែកសំខាន់ៗទាំងនេះនៃកិច្ចសន្យាគឺសេចក្តីចែងស្តីពីការជ្រើសរើសច្បាប់និងការជ្រើសរើសសាលាជម្រះក្តី។ ឧបមាថា ភាគីនៃកិច្ចសន្យាជ្រើសរើសយកច្បាប់របស់សិង្ហបុរីដើម្បីដោះស្រាយជម្លោះណាមួយដែលកើតឡើងប្រហែលដោយសារតែច្បាប់នេះមានភាពងាយស្រួលក្នុងការអនុវត្តឬដោយសារហេតុផលណាមួយដទៃទៀត។ ដើម្បីឱ្យប្រាកដថា សេចក្តីប្រាថ្នារបស់គេត្រូវគោរព ភាគីអាចដាក់បញ្ចូលនូវសេចក្តីចែងមួយទៅក្នុងកិច្ចសន្យាដូចជាថា អ្នកទិញនិងអ្នកលក់យល់ព្រមថា រាល់ជម្លោះដែលកើតមានឡើងពីកិច្ចសន្យាត្រូវស្ថិតនៅក្រោមសមត្ថកិច្ចនៃច្បាប់សិង្ហបុរីនោះ[១០]។ ភាគីអាចជ្រើសរើសយកកិច្ចព្រមព្រៀងអន្តរជាតិឱ្យគ្រប់គ្រងកិច្ចសន្យារបស់គេបានផងដែរ ដូចជា អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការលក់ទំនិញអន្តរជាតិឆ្នាំ១៩៨០ឬក្រមវិធានដទៃទៀត ដូចជាគោលការណ៍នៃកិច្ចសន្យាពាណិជ្ជកម្មអន្តរជាតិUNIDROIT ឆ្នាំ១៩៩៤[១១] និងWTO ដែលមានសមាជិក១៦៧ប្រទេស[១២]។

---

[៧] ម៉ែនសារុម៖ *ដំណាំស្រូវនៅកម្ពុជា* ជ.ឯ.ម. ទំព័រ១៩។

[៨] អ៊ុំថាមរិទ្ធ៖ *ការគ្រប់គ្រងគុណភាពទំនិញ* រោងពុម្ពអាយអាយស៊ី ភ្នំពេញ ២០០៦ ទំព័រ២៨៧។

[៩] http://w.w.w.en.m.wikipedia, theworld population is the sum total of all living humans on earth. Asof today, it is estimated to number 7.035 billion by the United States Census Bureau. The United States Census Bureau estimates that the world population exceeded 7 billion on March /12/ 2012.

[១០] មូលនិធិអាស៊ី៖ *ច្បាប់កិច្ចសន្យាអន្តរជាតិ* រោងពុម្ពអន្តរជាតិ ភ្នំពេញ ២០០១ ទំព័រ១៣-១៤។

[១១] -ដ-ទំព័រ១៥-១៦។

[១២] ហ៊ាន សាហ៊ីប ៖ *គ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* ភ្នំពេញ ២០០៦ ទំព័រ៥៥៨។

## ៥- ដំណោះស្រាយបញ្ហាប្រឈមនិងកាលានុវត្តភាព

**ដំណោះស្រាយ**ត្រូវតែធ្វើជាបន្ទាន់ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើដែលជាកត្តារាំងស្ទះមួយចំនួនដល់ការនាំចេញអង្ករ។ដូច្នេះដំណោះស្រាយគួរគប្បីមានដូចតទៅ៖ (១)ដំណោះស្រាយទាក់ទងនឹងផលិតកម្មស្រូវ (២)ដំណោះស្រាយទាក់ទងនឹងវិស័យកែច្នៃស្រូវនិងពាណិជ្ជកម្មអង្ករ (៣)ដំណោះស្រាយទាក់ទងនឹងប្រព័ន្ធសម្របសម្រួល (៤)ដំណោះស្រាយទាក់ទងនឹងទីផ្សារ (៥)ដំណោះស្រាយទាក់ទងនឹងទម្រង់បែបបទនាំចេញនិងច្បាប់អន្តរជាតិ (៦)ដំណោះស្រាយផ្នែកថវិកាដើម្បីទិញស្រូវស្តុកទុកនិងទប់ស្កាត់ការរត់ពន្ធខុសច្បាប់ (៧) ដំណោះតាមរយៈការធ្វើទំនើបកម្មរោងម៉ាស៊ីនកិនស្រូវ។ តាមរយៈដំណោះស្រាយដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមយើងអាចទទួល**កាលានុវត្តភាព** (១)មាននិរន្តរភាពទីផ្សារលក់អង្ករ (២)មានកំណើនផលិតផលអង្ករសម្រាប់នាំចេញ (៣)មានកំណើនប្រាក់ចំណូលជាតិ (៤)ធ្វើកំណែទម្រង់ពាណិជ្ជកម្មជាតិឱ្យស្របនឹងពាណិជ្ជកម្មអន្តរជាតិ (៥)ប្រើប្រាស់សិទ្ធិធ្វើពាណិជ្ជកម្មអន្តរជាតិក្នុងឋានៈជាសមាជិកដាប់បិលយូធីអូ (៦)ទទួលបានសិទ្ធិជាប្រទេសអនុគ្រោះពន្ធនាំចេញ (៧)បង្ហាញអត្តសញ្ញាណប្រភពដើមនៃផលិតផលអង្ករលើទីផ្សារអន្តរជាតិ។

## សន្និដ្ឋាន

ការសិក្សាស្រាវជ្រាវលើ ប្រធានបទស្តីពី "យន្តការសេវាសាធារណៈនៃការនាំចេញអង្ករពីប្រទេសកម្ពុជា (២០០៩-២០១២)"គឺជាស្នាដៃស្រាវជ្រាវស៊ីជម្រៅមួយដែលផ្តោតទៅលើការធ្វើជំនួញជាអន្តរជាតិ នៅក្នុងនោះក៏មានរំលេចឱ្យឃើញនូវការធ្វើពិពិធភាវូបនីយកម្មអង្ករកម្ពុជានៅលើទីផ្សារអន្តរជាតិ ដោយប្រើប្រាស់នូវយន្តការសេវាសាធារណៈនៃការនាំចេញអង្ករពីប្រទេសកម្ពុជា ដើម្បីធ្វើជាត្រីវិស័យបង្ហាញផ្លូវក្នុងដំណើរការនាំអង្ករចេញឱ្យមាននិរន្តរភាពយូរអង្វែង។ យើងបានដឹងរួចមកហើយថា ប្រទេសកម្ពុជាធ្លាប់បាននាំអង្ករចេញទៅកាន់ទីផ្សារអន្តរជាតិក្នុងទសវត្សរ៍ទី៦០ ក្នុងបរិមាណតិចតួចក្រោយមកបានផ្អាកទៅវិញដោយសារសង្រ្គាម។ រីឯប្រទេសដទៃទៀតបានបន្តការនាំចេញអង្ករទៅកាន់ទីផ្សារអន្តរជាតិរហូតមកដល់បច្ចុប្បន្ននេះដែលធ្វើឱ្យទីផ្សារអង្កររបស់គេមានលក្ខណៈរឹងមាំយូរអង្វែងពោរពេញដោយបទពិសោធន៍ទាំងការផលិត និងការលក់នៅលើឆាកអន្តរជាតិបានជោគជ័យប្រទេសទាំងនោះមានដូចជាប្រទេសថៃវៀតណាមសហរដ្ឋអាម៉េរិក។ល។ដូច្នេះប្រទេសកម្ពុជាត្រូវតែខិតខំយកចិត្តទុកដាក់ស្វែងយល់ឱ្យបានល្អិតល្អន់អំពីផលិតផលអង្កររបស់ខ្លួន ទីផ្សារអន្តរជាតិ ការផ្សាយព័ត៌មានដែលទាក់ទងនឹងផលិតផលអង្ករឱ្យបានទូលំទូលាយដល់អតិថិជន ព្រមទាំងកំណត់តម្លៃលក់ឱ្យបានសមស្របផងដែរ ទើបអាចបញ្ជៀតខ្លួនចូលទៅក្នុងទីផ្សារអន្តរជាតិបាន។ សរុបសេចក្តីមកដើម្បីឱ្យការនាំចេញអង្ករពីប្រទេសកម្ពុជាបានជោគជ័យគួរគប្បីមានយន្តការ (១)យន្តការផលិតស្រូវ-អង្ករ(២)យន្តការកំណត់តម្លៃអង្ករ (៣)យន្តការទីផ្សារអង្ករ (៤)យន្តការផ្សព្វផ្សាយ (៥)យន្តការប្រតិបត្តិករ (៦)យន្តការដោះស្រាយជម្លោះ (៧)យន្តការ"ឈ្នះ-ឈ្នះ"ជាអន្តរជាតិ។

# គន្ថនិទ្ទេស


## ក- ភាសាខ្មែរ

១. ច័ន្ទ សារុន៖ ***យុទ្ធសាស្ត្របង្កើនផលិតកម្មដំណាំស្រូវប្រកបដោយចីរភាព*** ភ្នំពេញ ឆ្នាំ២០០៦។

២. ម៉ែន សារុម៖ ***ដំណាំស្រូវនៅកម្ពុជា*** វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា ឆ្នាំ២០០៧។

៣. មូលនិធិអាស៊ី៖ ***ច្បាប់កិច្ចសន្យាអន្តរជាតិ*** បោះពុម្ពលើកទី១ ឆ្នាំ២០០១។

៤. រាជរដ្ឋាភិបាល៖ ***ឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ*** អនុម័តដោយគណៈរដ្ឋមន្ត្រីភ្នំពេញថ្ងៃទី២៥ខែមិថុនាឆ្នាំ២០១០។

៥. សុក ស៊ីផាន់ណា៖ ***មគ្គុទ្ទេសក៍ពាណិជ្ជកម្មឆ្ពោះទៅរកប្រព័ន្ធពាណិជ្ជកម្មពិភពលោក*** បោះពុម្ពលើកទី២ មជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិទីក្រុងហ្សឺណែវឆ្នាំ១៩៩៩។

៦. ហ៊ាន សាហ៊ីប៖ ***គ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*** វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ភ្នំពេញ ឆ្នាំ២០០៦។

៧. ហ៊ីង ថូរ៉ាក់ស៊ី៖ការអភិវឌ្ឍវិស័យវិនិយោគកម្ពុជា ***គោលនយោបាយនិងការអនុវត្ត*** ភ្នំពេញ ឆ្នាំ២០០២។

៨. អ៊ុំ ឋាមរិទ្ធ៖ ***ការគ្រប់គ្រងគុណភាពទំនិញ*** បោះពុម្ពលើកទី១រោងពុម្ពអាយអាយស៊ី ភ្នំពេញ ឆ្នាំ២០០៦។

## ខ- ភាសាបរទេស

1. ADB : ***Food Prices and Inflation in Developing Asia : Is Poverty Reduction Coming to an End ?*** Asian Development Bank, Manila, 2008.
2.. David N. Hyman, ***Microeconomics,*** the United States of America, Von HoffmannPress Inc., 1996.
3.. http://www.oryza.com/...FAO, Global Rice exports estimates 2011 and 2012.
4. http://www.en.m.wikipedia, the world population is the sum total of all living humans on earth.
5.. Robert Frank & Ben Bernanke, ***Principle of Economics,*** New York, Quebecor World/Hawkins, 2001.
6. World Bank : Cambodia Sustaining Rapid Growth in a Challenging Environment, the World Bank, 2009.

# វិធីសាស្ត្របង្រៀនភាសាខ្មែរ នៅបឋមសិក្សា (១៩៥៣-២០១១)

**បេក្ខជនបណ្ឌិត សូ សុធីរ**
**ផ្នែកវិទ្យាសាស្ត្រអប់រំ**

## ១- វិធីសាស្ត្របង្រៀនភាសាខ្មែរ នៅបឋមសិក្សា ពីឆ្នាំ១៩៥៣-១៩៧០

### ១.១- ស្ថានភាពទូទៅខ្លះៗនិងភាសាខ្មែរ

ការអប់រំមានការរីកចម្រើនយ៉ាងខ្លាំងចាប់តាំងពីមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សានិងឧត្តមសិក្សា។ ភាសាខ្មែរត្រូវគេនិយមប្រើប្រាស់ជាភាសាផ្លូវការរបស់ជាតិជាជាងភាសាបារាំង ចំណែកភាសាបារាំងត្រូវគេចាត់ទុកជាជីវភាសា មិនមែនជាភាសាយាន ដូចក្នុងសម័យអាណានិគមនិយមបារាំងទៀតទេ។

### ១.២- វិធីបង្រៀនទូទៅ

គេបានបែងចែកវិធីបង្រៀនជា ២ផ្នែក គឺអនុមានរួមនិងអនុមានញែក វិធីទាំង២នេះមានទម្រង់ដូចជា វិធីរ៉ាយរ៉ាប់ វិធីសន្ទនានិងវិធីចម្រុះ។ ក្រៅពីនោះក៏មានសិក្សាពីវិធីបង្រៀនផ្ទាល់ ល្បិចបង្រៀន វិធីប្រើប្រាស់សំណួរ ហើយពិសេសជាងគេបំផុតនោះ គេបានចាប់ផ្តើមប្រើប្រាស់វិធីសកម្ម។

### ១.៣- កម្មវិធីសិក្សាភាសាខ្មែរនិងសៀវភៅភាសាខ្មែរ

### ១.៤- កម្មវិធីសិក្សាភាសាខ្មែរ

គេបានអនុវត្តតាមកម្មវិធីសិក្សាតាំងពីសម័យអាណានិគមនិយមបារាំង លុះមកដល់ខែកញ្ញាឆ្នាំ១៩៥៨ ក្រសួងអប់រំជាតិបានអភិវឌ្ឍកម្មវិធីសិក្សាចាស់នេះឱ្យមានលក្ខណៈទំនើបឡើង ក្នុងនោះក៏មានរាប់បញ្ចូលកម្មវិធីសិក្សាភាសាខ្មែរដែរ។ ម៉ោងសិក្សាក្នុងមួយសប្តាហ៍ ៣០ម៉ោង ក្នុងនោះម៉ោងសិក្សាភាសាមានប្រហែល៤០%។

### ១.៥- សៀវភៅភាសាខ្មែរ

សៀវភៅនេះគាត់តែងឡើងដោយឯកជន។ សៀវភៅណាល្អក្រសួងអប់រំជាតិបញ្ជាទិញ។ ចាប់ពីឆ្នាំ១៩៥៧ ការនិពន្ធសៀវភៅសិក្សាបានទម្លាក់មកឱ្យទីចាត់ការកិច្ចការគរុកោសល្យ។

### ១.៦- វិធីសាស្ត្របង្រៀនភាសាខ្មែរ

ក្នុងនោះមានវិធីបង្រៀនអំណាន មេសូត្រ សរសេរតាមអាន វេយ្យាករណ៍ តែងសេចក្តី ការនិយាយឆ្លើយឆ្លងគ្នា អក្សរផ្ចង់។

វិធីសាស្ត្របង្រៀនភាសាខ្មែរនៅសម័យសង្គមរាស្ត្រនិយមបានប្រើគោលវិធីគ្រូមជ្ឈមណ្ឌលជាធំ។ ទោះជាយ៉ាងនេះក្តីគេបានអនុវត្តវិធីសកម្ម។ គេបានឃើញវិធីនេះចាប់ផ្តើមប្រើជាក់ស្តែងនៅក្នុងសៀវភៅចិត្តគរុកោសល្យទូទៅ។ ដោយហេតុនេះហើយកម្មវិធីសិក្សាភាសាខ្មែរនិងសៀវភៅភាសាខ្មែរក៏ត្រូវរៀបចំទៅតាមនោះដែរ។ នៅក្នុងកម្មវិធីសិក្សាភាសាខ្មែរ ក៏មានបង្ហាញវិធីនិងល្បិចបង្រៀនដែរ។

## ២- វិធីសាស្ត្របង្រៀន ភាសាខ្មែរ នៅបឋមសិក្សាពីឆ្នាំ១៩៧០-១៩៧៥

### ២.១- ស្ថានភាពទូទៅខ្លះៗនិងភាសាខ្មែរ

ការអប់រំមានការថយចុះបន្តិចម្តងៗ។ ភាសាខ្មែរនៅតែមានតួនាទីសំខាន់ក្នុងការសិក្សា។ ការលុបភាសាបារាំងពីបឋមសិក្សានៅតែមិនទាន់បានសម្រេច។

### ២.២- វិធីបង្រៀនទូទៅ

គេបានអនុវត្តវិធីបង្រៀនទូទៅ នៅសម័យសង្គមរាស្ត្រនិយម ប៉ុន្តែគេបានបន្ថែមវិធីបង្រៀនថ្មីមួយទៀតគឺវិធីទាក់ទាញអារម្មណ៍។

### ២.៣- កម្មវិធីសិក្សាភាសាខ្មែរនិងសៀវភៅភាសាខ្មែរ

#### ២.៣.១- កម្មវិធីសិក្សាភាសាខ្មែរ

គេបានអនុវត្តតាមកម្មវិធីសិក្សាខែកញ្ញាឆ្នាំ១៩៥៨។ សិក្ខាសាលាថ្នាក់ជាតិលើកទី១ ស្តីពីបឋមសិក្សាបានធ្វើឡើងនៅថ្ងៃទី២-៤ ខែមីនា ១៩៧២។ គេបានសុំកែលម្អកម្មវិធីសិក្សាថ្មីបន្ថយម៉ោងសិក្សាខ្លះ ហើយថែមទាំងសុំទៅក្រសួងអប់រំចាត់ចែងឱ្យមានកម្មវិធីសិក្សាសម្រាប់តំបន់នីយកម្ម។

#### ២.៣.២- សៀវភៅភាសាខ្មែរ

សៀវភៅភាសាខ្មែរ ត្រូវនិពន្ធដោយឯកជននិងទីចាត់ការកិច្ចការគរុកោសល្យ ដូចក្នុងសម័យសង្គមរាស្ត្រនិយមដែរ។ សៀវភៅសិក្សាបានផ្លាស់ប្តូរថ្មីនិងមានខ្លឹមសារថ្មី ដោយលុបចោលខ្លឹមសារដែលទាក់ទងទៅនឹងរបបរាជានិយម។

### ២.៤- វិធីសាស្ត្របង្រៀនភាសាខ្មែរ

គេបានអនុវត្តតាមវិធីសាស្ត្របង្រៀនភាសាខ្មែរនៅសម័យសង្គមរាស្ត្រនិយម។ ដូច្នេះផ្នែកវិធីសាស្ត្របង្រៀនភាសាខ្មែរមិនមានអ្វីប្រែប្រួលផ្លាស់ប្តូរទេ។

នៅសម័យនោះការអប់រំបានចាប់ផ្តើមចុះខ្សោយបន្តិចម្តងៗដោយសារសង្គ្រាមក្នុងស្រុក។ វិធីសាស្ត្របង្រៀនភាសាខ្មែរនៅសម័យនេះបានយកតាមលំនាំតាមវិធីសាស្ត្របង្រៀនភាសាខ្មែរនៅសម័យសង្គមរាស្ត្រនិយម។ តែកម្មវិធីសិក្សានិងសៀវភៅសិក្សាមានការផ្លាស់ប្តូរ។

## ៣- វិធីសាស្ត្របង្រៀនភាសាខ្មែរ នៅបឋមសិក្សាពីឆ្នាំ១៩៧៥-១៩៧៩

### ៣.១- ស្ថានភាពទូទៅខ្លះៗនៃភាសាខ្មែរ

ការអប់រំធ្លាក់ចុះស្ទើរដល់កម្រិតសូន្យ។ ពួកគេបានអនុញ្ញាតឱ្យប្រើតែភាសាខ្មែរតែមួយគត់។ អ្នកនិយាយភាសាផ្សេងក្រៅពីភាសាខ្មែរនឹងត្រូវសម្លាប់ចោល។

### ៣.២- វិធីបង្រៀនទូទៅ

គេបានអនុវត្តការបង្រៀន ដោយឱ្យកុមារទន្ទេញចាំមាត់ដូចសេកនូវឃ្លានិងពាក្យស្លោករបស់ពួកគេ។ គេមិនឃើញមានវិធីបង្រៀនអ្វីច្បាស់លាស់ទេ ព្រោះពួកនេះមិនចូលចិត្តការសិក្សានៅសាលារៀនទេ សាលារៀនរបស់ពួកនេះគឺនៅក្នុងទីវាលស្រែ ចម្ការ ដែលជាកន្លែងអនុវត្តផ្ទាល់។

### ៣.៣- កម្មវិធីសិក្សាភាសាខ្មែរនិងសៀវភៅភាសាខ្មែរ

#### ៣.៣.១- កម្មវិធីសិក្សាភាសាខ្មែរ

គេមិនឃើញមានកម្មវិធីសិក្សាទេ។ ការបង្រៀន កំណត់ទៅលើគ្រូជាអ្នកសម្រេច។ គ្រូបង្រៀនរបស់ពួកខ្មែរក្រហមជាមនុស្សអវិជ្ជាឬដែលរៀនសូត្របានបន្តិចបន្តួច ហើយជាពួកមូលដ្ឋានដែលទទួលបាននូវការអប់រំនូវមនោគមវិជ្ជាក្រហមឆ្អិនឆ្អៅ។ ការបង្រៀន ត្រូវគេអនុវត្តទៅតាមការនឹកឃើញរបស់ពួកគេ។

នៅក្នុងសវនាការកាត់ក្តីមេដឹកនាំជាន់ខ្ពស់របស់ពួកខ្មែរក្រហមក្នុងសំណុំរឿង០០១ ឌុច ដែលគេបានមើលឃើញ តាមការផ្សាយរបស់ទូរទស្សន៍ CTN INTERNATIONAL កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ នោះបាននិយាយថា កម្មវិធីសិក្សានៅក្នុងរបបប៉ុលពតត្រូវគេរៀបចំឱ្យមានរយៈពេលសិក្សាដូចជានៅបឋមសិក្សាមានរយៈពេល៤ឆ្នាំ មធ្យមសិក្សាមានរយៈពេល៤ឆ្នាំ និងឧត្តមសិក្សាមានរយៈពេល៤ឆ្នាំ។

### ៣.៣.២- សៀវភៅភាសាខ្មែរ

គេឃើញមានតែពីរថ្នាក់ទេគឺ ថ្នាក់ទី១ និង ថ្នាក់ទី២។ សៀវភៅថ្នាក់ទី១បានគេបោះពុម្ពនៅឆ្នាំ១៩៧៦ ហើយសៀវភៅថ្នាក់ទី២បោះពុម្ពនៅឆ្នាំ១៩៧៧ ដោយក្រសួងសិក្សាធិការជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ។

### ៣.៤- វិធីសាស្ត្របង្រៀនភាសាខ្មែរ

វិធីសាស្ត្របង្រៀនភាសាខ្មែរមានតែនៅផ្នែកខាងដើមនៃសៀវភៅភាសាខ្មែរដែលមានតែ ២ក្បាលគឺថ្នាក់ទី១ និងថ្នាក់ទី២ប៉ុណ្ណោះ។ វាមានលក្ខណៈជាសេចក្ដីណែនាំច្រើនជាង។ នៅក្នុងសម័យនេះ ពួកខ្មែរក្រហមមិនចង់បន្តនិរន្តរភាពនៃវិធីសាស្ត្របង្រៀនភាសាខ្មែររបបមុនៗទេ។ គ្រូបង្រៀនរបស់ពួកគេបង្រៀនតាមតែចិត្តពួកគេ។

សរុបមកការសិក្សាអប់រំនៅសម័យនេះបានធ្លាក់ស្ទើរស្មើសូន្យ។ បញ្ញវន្តត្រូវគេសម្លាប់ស្ទើរអស់។ វិធីសាស្ត្របង្រៀនភាសាខ្មែរមិនមានច្បាស់លាស់ទេ។ កម្មវិធីសិក្សាក៏មិនមានច្បាស់លាស់ដែរ។ ការសិក្សាមានតិចតួចហើយមិនទៀងទាត់ទៀត។ ចំណែកសៀវភៅសិក្សាក៏មានតែថ្នាក់ទី១ និងទី២។

## ៤- វិធីសាស្ត្របង្រៀន ភាសាខ្មែរ នៅបឋមសិក្សាពីឆ្នាំ១៩៧៩-១៩៩៦

### ៤.១- ស្ថានភាពទូទៅខ្លះៗនិងភាសាខ្មែរ

ការអប់រំ បានចាប់ផ្តើមរីកចម្រើនឡើងវិញបន្តិចម្តងៗ បន្ទាប់ពីការវិនាសអន្តរាយនៅក្នុងរបបខ្មែរក្រហម។ ភាសាខ្មែរត្រូវប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងការបង្រៀននៅបឋមសិក្សានិងមធ្យមសិក្សា។

### ៤.២- វិធីបង្រៀនទូទៅ

គេបែងចែកវិធីបង្រៀនជា៤ប្រព័ន្ធគឺវិធីប្រើប្រាស់ពាក្យសម្ដីឬប្រើប្រាស់សៀវភៅសិក្សា វិធីរូបី វិធីហ្វឹកហាត់ប្រតិបត្តិជាក់ស្តែង វិធីត្រួតពិនិត្យនិងដាក់មូលវិចារ។ គេមិនឃើញមានវិធីសកម្មទេ។ នៅចុងសម័យនេះ គេបានចាប់ផ្តើមការបង្រៀនភាសាខ្មែរ ដោយអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌល។

### ៤.៣- កម្មវិធីសិក្សាភាសាខ្មែរនិងសៀវភៅភាសាខ្មែរ

#### ៤.៣.១- កម្មវិធីសិក្សាភាសាខ្មែរ

កម្មវិធីសិក្សានេះសំដៅបណ្តុះបណ្តាលមនុស្សសង្គមនិយម។ គេបានតម្រូវឱ្យរៀននៅបឋមសិក្សាតែ៤ឆ្នាំទេ និងនៅមធ្យមសិក្សា៦ឆ្នាំ។ ម៉ោងសិក្សាមានប្រហាក់ប្រហែលនឹងសម័យសង្គមរាស្ត្រនិយម ប៉ុន្តែរយៈពេលបង្រៀន ពេលវេលាបង្រៀន និងមុខវិជ្ជាសិក្សាខុសគ្នា។ តាំងពីពេលនោះមកកម្មវិធីសិក្សាភាសាខ្មែរបានផ្លាស់ប្តូរចំនួនពីរដងទៀត គឺនៅឆ្នាំ១៩៨៦ និងឆ្នាំ១៩៩៦។

#### ៤.៣.២- សៀវភៅភាសាខ្មែរ

សៀវភៅសិក្សាទាំងនេះត្រូវបោះពុម្ពនៅក្នុងក្រុងហូជីមិញ ប្រទេសវៀតណាម។ ខ្លឹមសារសៀវភៅត្រូវស្របតាមលទ្ធិសង្គមនិយម សៀវភៅសិក្សាសម័យនោះមិនសូវមានរចនាបទល្អទេ។ មុខវិជ្ជាខ្មែរ នៅច្របូកច្របល់នឹងភូមិវិទ្យា ប្រវត្តិវិទ្យានិងចំណេះវិទ្យាសាស្ត្រប្រើប្រាស់ក្នុងជីវភាពធម្មតា។ សៀវភៅរៀនអក្សរថ្នាក់នីមួយៗ មានពីរភាគគឺភាគទី១ និងភាគទី២។ គេមិនទាន់ឃើញមានសៀវភៅគ្រូទេ។ ដោយសារតែកម្មវិធីសិក្សាភាសាខ្មែរបានផ្លាស់ប្តូរ សៀវភៅភាសាខ្មែរក៏បានផ្លាស់ប្តូរទៅតាមសម័យកាលនោះដែរ។ តាមកម្មវិធីសិក្សាភាសាខ្មែរឆ្នាំ១៩៩៦ គេបានបង្កើតសៀវភៅគ្រូបន្ថែមទៀត។

ចាប់ពីឆ្នាំ១៩៨៩មក សៀវភៅភាសាខ្មែរមានការផ្លាស់ប្តូរជាញឹកញាប់។ គេឃើញមានសៀវភៅដែលបោះពុម្ពនៅសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា រដ្ឋកម្ពុជានិងសម័យដើមរាជាណាចក្រកម្ពុជាទី២។ សៀវភៅភាសាខ្មែរក្នុងរបបរដ្ឋកម្ពុជានិងដើមរាជាណាចក្រកម្ពុជាមានខ្លឹមសារថ្មីសមស្របតាមរបបនយោបាយថ្មី។

### ៤.៤- វិធីសាស្ត្របង្រៀនភាសាខ្មែរ

វិធីសាស្ត្របង្រៀនភាសាខ្មែរមាននៅផ្នែកខាងដើមសៀវភៅភាសាខ្មែរក្នុងនោះមានអំណាន តែងសេចក្ដី មេសូត្រ វេយ្យាករណ៍ សរសេរតាមអាន អក្សរផ្ចង់និងរៀនពាក្យ។ គេយកចិត្តទុកដាក់តែសមត្ថភាព និយាយ អាននិងសរសេរ។ ក្រោយមក ទើបវិធីបង្រៀនភាសាខ្មែរត្រូវគេសិក្សាតាមសៀវភៅ ដែលបង្រៀននៅតាមសាលាគរុកោសល្យនិងវិក្រឹតការ។

តាមកម្មវិធីសិក្សាភាសាខ្មែរនៅឆ្នាំ១៩៨៦ វិធីសាស្ត្របង្រៀនភាសាខ្មែរត្រូវបានគេគិតដល់សមត្ថភាពទាំង៤ ក្នុងនោះមាន ស្ដាប់ និយាយ អាន សរសេរ។ វិធីបង្រៀនភាសាខ្មែរសំខាន់ៗ មានអំណាន តែងសេចក្ដី មេសូត្រ វេយ្យាករណ៍ អក្សរផ្ចង់ រឿងនិទាន សរសេរតាមអាន រៀនពាក្យ។

ការអប់រំនៅសម័យកាលនោះ ខ្វះខាតយ៉ាងខ្លាំង ទាំងបុគ្គលិកសិក្សា ទាំងអគារសិក្សា សម្ភារៈសិក្សា ព្រមទាំងសិស្សផងដែរ។ វិធីសាស្ត្របង្រៀនភាសាខ្មែរ មិនទាន់មានច្បាស់លាស់ទេ។ វិធីសកម្មមិនទាន់បានបញ្ចូលទៅក្នុងគរុកោសល្យទូទៅទេ។ កម្មវិធីសិក្សាភាសាខ្មែរ មានច្បាស់លាស់ហើយ តែមិនទាន់ធ្លាក់ដល់ដៃគ្រូទាន់ពេលវេលា។ សៀវភៅភាសាខ្មែរ ក៏មិនទាន់រៀបចំបានដោយខ្លួនឯងដែរ។ ក្រោយឆ្នាំ១៩៩៣ វិធីសាស្ត្របង្រៀនភាសាខ្មែរបានប្រែប្រួល ដោយគេចាប់ផ្ដើមយកចិត្តទុកដាក់ទៅលើវិធីសកម្មនិងគោលវិធីសិស្សមជ្ឈមណ្ឌល។ កម្មវិធីសិក្សាភាសាសខ្មែរនិងសៀវភៅភាសាខ្មែរបានប្រែប្រួល។

## ៥- វិធីសាស្ត្របង្រៀនភាសាខ្មែរ នៅបឋមសិក្សាពីឆ្នាំ១៩៩៦-២០១១

### ៥.១-ស្ថានភាពទូទៅខ្លះៗនិងភាសាខ្មែរ

ភាសាខ្មែរនាសម័យកាលនេះ នៅតែមានសារៈសំខាន់ ទាំងនៅបឋមសិក្សា ទាំងនៅមធ្យមសិក្សា ប៉ុន្តែគេបានបញ្ចូលកម្មវិធីភាសាបារាំងឬភាសាអង់គ្លេសចំនួន(៣ម៉ោង)នៅថ្នាក់ទី៤ទី៥និងទី៦។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក្ដី ការបង្រៀនភាសាបរទេសមិនទាន់អាចដំណើរការបានទេ មកដល់ពេលចុងក្រោយនេះ។

### ៥.២- វិធីបង្រៀនទូទៅ

គេបានបែងចែកប្រព័ន្ធវិធីបង្រៀនជា ៤ដូចមុនឆ្នាំ១៩៩៦ដែរ។ ទោះបីជាគេបានចែកប្រព័ន្ធវិធីបង្រៀនដូច្នេះក្ដីក៏ខ្លឹមសារមេរៀននៃប្រព័ន្ធវិធីបង្រៀនទាំងនេះ ភាគច្រើនបំផុតបានបកប្រែទាំងស្រុងចេញពីវិធីបង្រៀនទូទៅនៅក្នុងរបបសង្គមរាស្ត្រនិយម។ ចំណុចមួយដែលថ្មីនៅក្នុងសៀវភៅគរុកោសល្យក្រោយនេះ គឺមានបញ្ចូលមេរៀនគោលវិធីសិស្សមជ្ឈមណ្ឌលនិងវិធីបង្រៀនថ្នាក់គួប។

### ៥.៣- កម្មវិធីសិក្សាភាសាខ្មែរនិងសៀវភៅភាសាខ្មែរ

#### ៥.៣.២- កម្មវិធីសិក្សាភាសាខ្មែរ

កម្មវិធីសិក្សាភាសាខ្មែរក្នុងកម្មវិធីសិក្សាថ្មីមានលក្ខណៈជាប្រព័ន្ធនិងមានលំដាប់កើនឡើងផ្នែកបម្រើបម្រាស់ភាសា ដោយសង្កត់ធ្ងន់ទៅលើសមត្ថភាពធំៗទាំង៤ និងសង្កត់ធ្ងន់ទៅបម្រើបម្រាស់ភាសាតាមគោលបំណងផ្សេងៗ និងតម្រូវការដាក់ស្ដែងក្នុងជីវភាពរស់នៅ។ ម៉ោងបង្រៀនប្រចាំសប្ដាហ៍ មិនទាន់អាចបង្កើនបានលើសពី២៥ម៉ោងទេ។ ចំណែកភាសាបារាំងនិងអង់គ្លេស មិនទាន់បានអនុវត្តបានតាមសំណូមពរដែរ។

#### ៥.៣.២- សៀវភៅភាសាខ្មែរ

សៀវភៅសិក្សាបានបែងចែកជា២ គឺសៀវភៅសិស្សនិងសៀវភៅគ្រូ។ ប៉ុន្តែ សៀវភៅភាសាខ្មែរ ដែលបានបោះពុម្ពទៅតាមកម្មវិធីសិក្សាភាសាខ្មែរឆ្នាំ២០០៦ មិនមានសៀវភៅគ្រូទេ។ ទាំងនេះជាមូលហេតុដែលធ្វើឱ្យគ្រូ

បឋមសិក្សាមានការលំបាកជាខ្លាំង។ ផ្ទុយទៅវិញ សៀវភៅភាសាខ្មែរដែលបោះពុម្ពក្នុងឆ្នាំ២០១១ មានបញ្ចូលទាំងកម្មវិធីសិក្សាភាសាខ្មែរនិងល្បិចបង្រៀនភាសាខ្មែរផងដែរ។

### ៥.៤- វិធីសាស្ត្របង្រៀនភាសាខ្មែរ

វិធីបង្រៀនភាសាខ្មែរត្រូវគេបែងចែកទៅតាមសមត្ថភាពទាំង៤គឺស្តាប់ និយាយ អាននិងសរសេរ។ ក្នុងសមត្ថភាពនីមួយៗ វិធីសាស្ត្របង្រៀនត្រូវចែកចេញជា៣ដំណាក់កាលគឺដូចជាសមត្ថភាពអានមានមុនពេលអាន ពេលអាននិងក្រោយពេលអាន។ ក្រៅពីនេះវិធីសាស្ត្របង្រៀនភាសាខ្មែរ ក៏មាននៅក្នុងសៀវភៅវគ្គតម្រង់ទិសការប្រើប្រាស់កម្មវិធីសិក្សាភាសាខ្មែរនិងសៀវភៅភាសាខ្មែរថ្មីទៀតផង។

សរុបមកយើងឃើញថា វិស័យអប់រំនៅសម័យនេះ មានការរីកចម្រើនតាំងពីមត្តេយ្យ បឋមសិក្សា មធ្យមសិក្សាដល់ឧត្តមសិក្សានិងរហូតដល់ក្រោយឧត្តមសិក្សា។ ប៉ុន្តែគុណភាពនៃការអប់រំនៅតែស្ថិតនៅកម្រិតទាប។ ទាំងនេះបណ្តាលមកពីកត្តាផ្សេងៗជាច្រើន ក្នុងនោះមានទាំងវិធីសាស្ត្របង្រៀនភាសាខ្មែរផងដែរ។ តាមរយៈការសិក្សាស្រាវជ្រាវខាងលើគេបានឃើញថា៖ ការបង្រៀនភាសាខ្មែរ នៅសម័យសង្គមរាស្ត្រនិយមទទួលបានគុណភាពខ្ពស់និងទទួលបានភាពជោគជ័យនោះ បណ្តាលមកពីប្រទេសខ្មែរមានស្ថិរភាពនយោបាយដោយបានរួចចាកផុតពីរបបអាណានិគមនិយមបារាំង។ បន្ទាប់មក នៅក្នុងសម័យសង្គ្រាមស៊ីវិលធនធានមនុស្សក្នុងសង្គមដូចជាក្នុងវិស័យអប់រំត្រូវគេសម្លាប់និងស្លាប់ស្ទើរអស់ ចំណែកធនធានសម្ភារៈក៏ត្រូវវិនាសអន្តរាយយ៉ាងធ្ងន់ធ្ងរផងដែរ។ ការបង្រៀនភាសាខ្មែរក៏បានធ្លាក់ចុះខាងគុណភាពដោយសារបញ្ហាទាំងនេះ។ ក្រោយពេលខ្មែរបានបញ្ចប់សង្គ្រាម ផលវិបាកទាំងនេះមិនទាន់ដោះស្រាយបានទាំងស្រុងទេ។ ផលវិបាកនេះ បណ្តាលមកពីកត្តាសិស្ស គ្រូ អ្នកគ្រប់គ្រងអប់រំ កម្មវិធីសិក្សា សៀវភៅសិក្សា សម្ភារៈសិក្សា សម្ភារៈឧបទេស។ល។

# ការគ្រប់គ្រងសំណល់នៅរាជធានីភ្នំពេញ
# ២០០៩-២០១៥

**បេក្ខបណ្ឌិត សេង សំអឿន**
**ផ្នែកភូមិវិទ្យានិងនគរូបនីយកម្ម**



## សេចក្តីផ្តើម

ប្រជាជនលើពិភពលោកបានកើនយ៉ាងឆាប់រហ័សពី ២,២ពាន់លាននៅឆ្នាំ១៩៥០ ទៅ៥,៨៥ពាន់លាននៅពាក់កណ្តាលឆ្នាំ១៩៩៧។ ចំនួននេះ ត្រូវគេប៉ាន់ស្មានថានឹងឡើងដល់ ៦,៨៩៤ពាន់លាននៅឆ្នាំ២០១១ និង៨,០៣៦ពាន់លាននៅឆ្នាំ២០២៥។ ចំនួនប្រជាជនលើពិភពលោកនឹងឡើងដល់១៥ពាន់លាននាក់នៅចុងសតវត្សរ៍ទី២២(ឆ្នាំ២១១០)។ចំនួនមនុស្សកើនឡើងទ្វេដងនៅលើពិភពលោកក្នុងរយៈពេល៤៧ឆ្នាំចុងក្រោយនេះជាអត្រាមួយគួរឱ្យព្រួយបារម្ភសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ យ៉ាងណាមិញ ប្រទេសកម្ពុជាបន្ទាប់ពីការបង្កើតទីផ្សារសេរីធ្វើឱ្យសេដ្ឋកិច្ចមានការរីកចម្រើនយ៉ាងឆាប់រហ័ស ដែលជាបុព្វហេតុធ្វើឱ្យមានការបម្លាស់ទីពីជនបទមកកាន់ទីក្រុងយ៉ាងច្រើនយ៉ាងសន្ធឹកសន្ធាប់។ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានធ្វើឱ្យប្រទេសកម្ពុជាឈានឆ្ពោះទៅមុខយ៉ាងរឹងមាំប្រកបដោយភាពសុទិដ្ឋិនិយមនិងការប្តេជ្ញាខ្ពស់ក្នុងការអភិវឌ្ឍប្រទេសជាតិ ដើម្បីកែប្រែមុខមាត់និងលើកស្ទួយកិត្តិសព្ទប្រទេសកម្ពុជាឱ្យបានល្អប្រពៃដូចសម័យអង្គរដ៏រុងរឿងដែលកូនខ្មែរគ្រប់ៗរូបមិនអាចបំភ្លេចបាន ប៉ុន្តែការរីកចម្រើននេះក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសំណល់រឹង និងសំណល់រាវនៅទីប្រជុំជនធំៗ ពិសេសរាជធានីភ្នំពេញដែលបេះដូងនៃប្រទេសជាតិផងដែរ។

## ក- ស្ថានភាពគ្រប់គ្រងសំណល់រាវ

ការអភិវឌ្ឍក្រុងភ្នំពេញសព្វថ្ងៃនេះផ្តល់ជម្រើសមួយឱ្យយើងក្នុងការស្វែងយល់ឱ្យបានស៊ីជម្រៅពីផែនការកសាងរាជធានីក៏ដូចជានគរូបនីយកម្ម(ការរីកក្រុង)។ ការរៀបចំផែនការអភិវឌ្ឍទីក្រុងភ្នំពេញ មានតាំងពីឆ្នាំ១៩៥៦សម្រាប់ទប់ស្កាត់នៃកំណើនប្រជាជនរបស់ទីក្រុងនាពេលអនាគត ហើយផែនការគ្រប់គ្រងនេះបានបន្តដំណើរការរហូតដល់ឆ្នាំ១៩៧១។ រហូតមកដល់ឆ្នាំ១៩៩៦ ដោយមានជំនួយពីធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តួចផ្តើមសិក្សាមួយលើអនាគតនៃរាជធានីភ្នំពេញដែលលទ្ធផលបង្ហាញថា បញ្ហាដែលប្រឈមនៅភ្នំពេញត្រូវតែដោះស្រាយបញ្ហាកំណើនប្រជាជនយ៉ាងលឿនបំផុត(របេកក្រុង) និងបញ្ហាធំបង្អស់នៃបរិស្ថានក្រុងភ្នំពេញគឺការលិចទឹក និងការបង្ហូរទឹកចេញពីរាជធានីភ្នំពេញ។ ដោយសារការពង្រីកក្រុង(នគរូបនីកម្ម) ដោយស្លាបនាទំនប់ជាច្រើនដែលលាតសន្ធឹងចេញពីមណ្ឌលនៃខណ្ឌដូនពេញស្ថិតនៅតាមបណ្តោយច្រាំងទន្លេសាប។ ការបង្ហូរទឹកចេញពីក្រុងតែងតែចោទជាបញ្ហាចម្បង ប្រសិនជាទឹកជំនន់ទន្លេមេគង្គឡើងខ្ពស់បំផុតកម្រិតសមត្ថភាពប្រព័ន្ធបូមទឹកចេញសព្វថ្ងៃរបស់ក្រុងនឹងអាចមានមហន្តរាយមួយនឹងកើតមានមិនខាននាពេលអនាគត។ ក្នុងទសវត្សរ៍ឆ្នាំ៦០ ក្រុងភ្នំពេញមានប្រព័ន្ធបង្ហូរទឹកចេញ ដែលដំណើរការល្អ ហើយដែលអាចបញ្ចេញទឹកភ្លៀងទៅក្រៅ ដោយប្រើស្ថានីយបូមទឹកនានារបស់ទីក្រុង។ សព្វថ្ងៃដោយសារខ្វះការថែទាំបណ្តាញបង្ហូរទឹកដែលមានត្រូវជាប់គាំងស្ទើរទាំងអស់ ដោយទឹកដែលប្រើប្រាស់តាមផ្ទះសម្បែងនិងទឹកភ្លៀងមកផ្តុំគ្នានៅក្នុងប្រឡាយបង្ហូរទឹកនាវដូវវស្សាតែមួយ ជាហេតុនាំឱ្យតំបន់នៅកណ្តាលក្រុងនិងតំបន់ខ្លះដែលស្ថិតនៅតាមបណ្តោយបំពង់បង្ហូរឆ្ពោះទៅបឹងត្របែក

បឹងសាឡាង អូរបែកក្អម បឹងពោងពាយ និងបឹងប្រយ៉ាបត្រូវលិចលង់។ សំណល់រាវមួយចំនួនបង្ហូរទៅបឹងទំពុន និងប្រឡាយស្ទឹងមានជ័យហូរពុំទាន់សភាពទឹកភ្លៀង ដែលហូរចាក់ពីភាគខាងលិច និងភាគខាងត្បូងរាជធានីភ្នំពេញ។

នៅក្នុងរាជធានីភ្នំពេញ គឺការបង្ហូរកាកសំណល់ធ្វើឡើង ជាបឋមតាមរយៈបណ្តាញលូ ទឹកស្អុយនិងលូបង្ហូរទឹកភ្លៀង(លូកប់ក្នុងដីនិងប្រលាយ)ចាក់ចូលទៅក្នុងអាងស្តុកដែលជាបឹងតូចៗ និងបន្ទាប់មកគេក៏បូមទឹកសំអុយទាំងនោះចេញទៅក្នុងបឹងនានាវិញ។ នៅភ្នំពេញមានបណ្តាញលូ បង្ហូរទឹកស្អុយនិងស្ថានីយបូមទឹកចំនួន ៩ និងអាងស្តុកទឹកមួយចំនួនទៀតដូចជាបឹងត្របែក បឹងសាឡាង បឹងទំពុន ស្ទឹងមានជ័យ បឹងពោងពាយ បឹងប្រយ៉ាប ហើយអាងទាំងនោះកំពុងទទួលរងការចាក់ដីបំពេញយ៉ាងអនាធិបតេយ្យពីសំណាក់ប្រជាជនដែលរស់នៅតំបន់ជុំវិញបឹងនានាទាំងនោះ។

## ១- ប្រភេទនៃការបញ្ចេញសំណល់រាវ

តាមរយៈរបាយការណ៍ស្ថានភាពបរិស្ថាននៅឆ្នាំ២០១២ បានបង្ហាញថាសំណល់រាវមានច្រើនប្រភេទដែលគេបានកំណត់តាមរយៈប្រភពនៃការបញ្ចេញនៃសំណល់រាវទាំងនោះមាន៖ ប្រភេទទី១គឺសំណល់រាវដែលចេញពីលំនៅឋាននិងតំបន់អាជីវកម្ម សេវាកម្មផ្សេងៗនិង ប្រភេទទី២ គឺសំណល់រាវដែលចេញពីឧស្សាហកម្ម។ ប៉ុន្តែប្រព័ន្ធសំណល់រាវនៅរាជធានីភ្នំពេញ គឺជាប្រព័ន្ធរួមរវាងសំណល់រាវនៃលំនៅដ្ឋាន អាជីវកម្ម សេវាកម្មផ្សេងៗ ឧស្សាហកម្មនិងទឹកភ្លៀង។ នៅភ្នំពេញប្រព័ន្ធនេះត្រូវគេសាងសង់មុនទសវត្សរ៍ឆ្នាំ១៩៧០ ដែលភាគច្រើនត្រូវកកស្ទះនិងរំដោះទឹកភ្លៀងពុំទាន់ពេលវេលា ដែលជាកត្តាធ្វើឱ្យតំបន់មួយចំនួនត្រូវជន់លិចក្នុងរយៈពេលខ្លី។ រីឯការគ្រប់គ្រងប្រព័ន្ធបង្ហូរសំណល់រាវនេះមានលក្ខណៈពីរយ៉ាង៖

១-ការបង្ហូរសំណល់រាវចម្រុះផ្ទាល់ចូលទៅក្នុងទន្លេ (ទន្លេបាសាក់ ទន្លេសាបនិងចំណុចចតុមុខ)

២-ប្រព័ន្ធបង្ហូរសំណល់រាវចម្រុះហូរចូលទៅក្នុងបឹងធំៗឬតំបន់ទំនាបដូចជា បឹងសាឡាង បឹងត្របែក និងបឹងទំពុនតាមរយៈអាងអុកស៊ីតកម្មធម្មជាតិ ដែលអាចបង្ហូរសំណល់រាវចម្រុះទាំងនោះចេញតែម្តងនៅរដូវវស្សានៅពេលមានភ្លៀងធ្លាក់ច្រើន។

### ១.១- សំណល់រាវតាមលំនៅស្ថាន

នៅតាមលំនៅឋានភាគច្រើនតែងប្រើបង្គន់ លូ ដែលមិនបានតភ្ជាប់ទៅនឹងបំពង់ទុយោនៃប្រព័ន្ធលូទឹកដែលកកស្ទះដោយសារវត្តមាននៃវត្ថុរឹង។ កត្តានេះអាចបង្កឱ្យមានបញ្ហានៅតំបន់ភាគច្រើននៃរាជធានីភ្នំពេញពិសេសម្តុំទូតចិន វត្តមហាមន្ត្រី អូរបែកក្អម មុខផ្សារទួលទំពូង មុខវិទ្យាល័យបឹងត្របែកជាដើមត្រូវទទួលជន់លិចនៅរដូវភ្លៀងធ្លាក់ម្តងៗ។ បើតាមទិន្នន័យទទួលបានពីថ្នាក់សង្កាត់ទូទាំងរាជធានីនាឆ្នាំ២០១២ បានឱ្យដឹងថា ៩០% នៃប្រជាជនក្នុងក្រុងធ្វើបង្គន់អនាម័យ ដោយពុំមានលក្ខណៈស្តង់ដា (លូបញ្ចេញមានទំហំតូច) ព្រោះលំនៅឋានក្នុងក្រុងសុទ្ធសឹងសាងសង់ក្នុងមុនឆ្នាំ២០០០។ដោយឡែកសំណល់រាវ ទោះចេញពីលំនៅឋានមន្ទីរពេទ្យសិប្បកម្ម សេវាកម្មផ្សេងៗត្រូវតភ្ជាប់ទៅបណ្តាញលូសាធារណៈតែមួយ ហើយបន្តបង្ហូរចូលក្នុងប្រភពទឹកដែលងាយបង្កការប៉ះពាល់ដល់សុខភាពសាធារណៈ។

### ១.២- សំណល់រាវឧស្សាហកម្ម

អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលទឹកបានតម្រូវឱ្យរោងចក្រ ឧស្សហកម្ម សុំលិខិតអនុញ្ញាតបញ្ចេញសំណល់រាវពីក្រសួងបរិស្ថាន និងយកសំណាកសំណល់របស់ខ្លួនមកឱ្យមកក្រសួងបរិស្ថានធ្វើការវិភាគជាមុននឹងបញ្ចេញចោលទៅតំបន់ទឹកទីសាធារណៈឬអាងស្តុកទឹកធម្មជាតិ។ តែមកដល់ឆ្នាំ២០០២ ក្រសួងបរិស្ថាន

បានចេញលិខិតអនុញ្ញាតដល់ម្ចាស់រោងចក្រចំនួន១២០ ដែលត្រូវកត់ត្រាសម្រាប់តំបន់ភ្នំពេញ ក្រៅពីនេះរោងចក្រចំនួន៣៤០ទៀតមិនមានច្បាប់អនុញ្ញាតត្រឹមត្រូវឡើយ។

## ២- ការគ្រប់គ្រងសំណល់រាវនិងបណ្តាញលូ

ក្នុងរាជធានីភ្នំពេញ គេតែងប្រើប្រព័ន្ធបង្ហូរលូរួមរវាងសំណល់រាវ និងលូទឹកភ្លៀង រួមក្នុងលូតែមួយ ប្រព័ន្ធលូទាំងនេះមានភ្ជាប់ទៅនឹងបង្គន់ចាក់ទឹកដែលជួនកាលនោះហូរចូលទៅក្នុងអាងសិបទិចតូចៗ ហើយលាមកត្រូវស្តុកក្នុងអាងសិបទិច ធ្វើឱ្យទឹកលូសំអុយហូរតាមបំពង់ចូលទៅក្នុងលូ គឺស្ថិតនៅតាមបណ្តោយផ្លូវទៅលាយជាមួយនឹងទឹកភ្លៀង លូបង្ហូរទាំងនោះមិនបានហូរចូលទៅក្នុងប្រព័ន្ធសម្អាតទេ ប៉ុន្តែហូរចាក់ចូលទៅក្នុងប្រព័ន្ធផ្លូវទឹកឬប្រភពទឹកនានាដូចជា បឹង ទន្លេ ដែលជាប្រភពទឹកសម្រាប់ប្រើប្រាស់ បរិភោគ ងូត ហែលកម្សាន្តនិងស្រោចស្រពទៅវិញ។

### ២.១- បណ្តាញលូទឹកសំអុយ

#### ១- លូមានគម្រប

នៅក្នុងឆ្នាំ២០០៩ មានបណ្តាញលូទឹកសំអុយជាច្រើន ក៏ប៉ុន្តែវានៅតែមិនគ្រប់គ្រាន់នៅឡើយនៅក្នុងរាជធានីភ្នំពេញក្តីនិងនៅតាមបណ្តាខណ្ឌនានានៃជាយក្រុង ដោយយោងតាមឯកសារនៅក្នុងឆ្នាំ២០០៩ដោយការស្រាវជ្រាវនៅឯមន្ទីរសាធារណការដឹកជញ្ជូនរាជធានីភ្នំពេញ ចុះថ្ងៃទី១-៦-២០១០បានឱ្យឃើញថាប្រព័ន្ធលូដែលមានគម្រប ២០០៩ មានជាងប្រហែល ៩០ ០០០កន្លែង។

#### ២- លូគ្មានគម្រប

ក្នុងឆ្នាំ២០០៩ យើងឃើញហើយថានៅក្នុងប្រទេសកម្ពុជាមានប្រព័ន្ធលូជាច្រើនដែលគ្មានគម្រប ហេតុដូច្នេះបានជាមានការស្ទះទឹកមិនអាចហូរបាន ពីព្រោះបណ្តាលមកពីការយកសំរាមសំណល់ផ្សេងៗជាច្រើនចាក់ក្នុងលូនិងតាមដងផ្លូវក្បែរលូគ្មានគម្របនិងនៅមានក្លិនមិនល្អចេញពីក្នុងលូ ហើយធ្វើឱ្យខូចបរិស្ថាន យោងតាមឯកសារដដែលនោះដែរ លូគ្មានគម្របមានប្រហែលជាង ៧៦.៨០០កន្លែង និងប្រឡាយដែលកសាងដោយរដ្ឋាភិបាលជប៉ុន(JICA)មាន២ខ្សែប្រវែង ៧គ.ម.។

### ២.២- អាងទទួលសំណល់រាវធម្មជាតិនៅរាជធានីភ្នំពេញ

#### ១- ដីបាតខ្ទះបឹងសាឡាង

បណ្តាញលូបង្ហូរទឹកនៅទីនេះក៏ត្រូវជួសជុលស្តារឡើងវិញ មិនតែប៉ុណ្ណោះត្រូវពង្រីកនិងថែទាំឡើងវិញដើម្បីបង្ហូរទឹកសំអុយ ព្រមទាំងទឹកភ្លៀងឱ្យបានត្រឹមត្រូវ។ ប្រព័ន្ធប្រឡាយមានតែមួយទេនៅទីនោះ ដែលនាំទឹកទាំងអស់បញ្ចូលក្នុងបឹងសាឡាង។ ប្រព័ន្ធមួយនេះសម្រាប់ញែកទឹកភ្លៀងឱ្យដាច់ចេញពីទឹកប្រើប្រាស់។ ទឹកប្រើប្រាស់នឹងបង្ហូរចូលទៅក្នុងស្ថានីយបូមទឹក ដោយមានប្រព័ន្ធប្រឡាយថ្មីមួយទៀតនៅតាមបណ្តោយបឹងជួយសម្រួលទៀតផង។ បឹងសាឡាងមានចំណុះតិចជាង១៥០.០០០ម$^{៣}$។

#### ២- ដីបាតខ្ទះពេទ្យរុស្ស៊ី

នៅទីនេះមិនខុសអ្វីពីខណ្ឌបឹងសាឡាងឡើយ គឺនឹងត្រូវពឹងផ្អែកលើប្រព័ន្ធថ្មីតែមួយដែលនាំទឹកទាំងអស់ឆ្លងកាត់ទំនប់ផ្លូវស្ពានស្ទឹងមានជ័យសំដៅទៅស្ពានក្បាលថ្នល់ដែលមានតួនាទីនៅក្នុងប្រព័ន្ធបង្ហូរទឹកក្រុងភ្នំពេញភាគខាងត្បូងនិងខាងកើតមហាវិថីម៉ៅសេទុង (ផ្សារទួលទំពូងនិងសង្កាត់ទំនប់ទឹក)។

៣- ដីបាតខ្ទះបឹងត្របែក

បណ្តាញបង្ហូរទឹកនៅទីនេះក៏ត្រូវតែជួសជុលស្តារពង្រីកនិងថែទាំឡើងវិញ ដើម្បីបង្ហូរទឹកភ្លៀងផងនិងទឹកប្រើប្រាស់ផង ប្រព័ន្ធតែមួយនេះបង្ហូរទឹកបានទាន់ពេល ទោះជាពេលទឹកខ្លាំងក៏ដោយនិងដោយសារគេមានរៀបចំលូបង្ហូរទឹកភ្លៀងភ្ជាប់ទៅទ្វារទឹកផ្សេងៗតាមបណ្តោយទន្លេបាសាក់។ រីឯទឹកដែលមិនហូរជាគំហុកនោះ គឺហូរទៅជាធម្មតាតាមបណ្តាញប្រឡាយដែលមានស្រាប់ ប្រឡាយទាំងនោះសុទ្ធតែមានទ្វារទឹកអាចបញ្ចេញទឹកមួយភាគទៅស្ថានីយបឹងត្របែក បើកាលណាទឹកឡើងខ្លាំងហួសកម្រិតទំនប់។ ប្រសិនបើបណ្តាញបឹងត្របែកសម្អាតនិងបានស្តារឱ្យបានត្រឹមត្រូវគឺអាចផ្ទុកទឹកបានរហូតដល់ ៥០០.០០០ម$^{៣}$។

៤- ដីបាតខ្ទះបឹងកក់

យោងតាមសេចក្តីប្រកាសរបស់សាលាក្រុងភ្នំពេញនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០បានលើកឡើងថាបឹងកក់ជាបឹងធម្មជាតិដែលមានទំហំសរុប១៣៣ហ.ត. ទាំងផ្ទៃទឹកនិងផ្ទៃបឹង ក្នុងនោះមានផ្ទៃបឹងប្រមាណ១០៤ហ.ត. តែបច្ចុប្បន្នតំបន់នេះត្រូវរដ្ឋាភិបាលកំពុងអភិវឌ្ឍ។ ហេតុនេះសំណល់រាវដែលហូរពីតំបន់ជុំវិញបឹងកក់និងតាមផ្លូវទំនប់ទឹកទួលគោក ត្រូវចាក់តាមប្រឡាយថ្មីមួយដែលសាងដោយក្រុមហ៊ុនអភិវឌ្ឍន៍តំបន់បឹងកក់ចូលទៅបឹងប្រយ៉ាបផ្នែកខាងជើងក្នុងខណ្ឌឫស្សីកែវ។(កាត់ផ្លូវរថភ្លើង)

៥- បឹងទំពុន

យោងតាមទិន្នន័យបានបង្ហាញថាបឹងទំពុនស្ថិតនៅក្នុងខណ្ឌមានជ័យនិងមានផ្ទៃក្រឡាជាង ៣០០ហ.ត. មានភារកិច្ចទទួលទឹកសំអុយនិងទឹកភ្លៀងដ៏ធំពីរាជធានីភ្នំពេញ។ បច្ចុប្បន្ននៅជុំវិញបឹងទំពុនមានប្រជាជនរស់នៅប្រមាណ៧០០គ្រួសារ ប្រជាជនទាំងនោះសង់ផ្ទះឈើប្រក់ស្លឹកនិងថ្ម កំពុងចោលកម្ទេចកម្ទី (សំណល់រឹង) និងចាក់ដីបំពេញក្នុងអាងទទួលទឹកនោះទៀតផង។

## ៣- បញ្ហាប្រឈម

បច្ចុប្បន្នរាជធានីភ្នំពេញកំពុងមានបញ្ហាប្រឈមជាច្រើនចំពោះមុខដូចជា៖

១-ប្រជាជនពុំទាន់យល់ដឹងពីគ្រោះថ្នាក់នៃសំណល់រាវ បើយើងមិនបានគ្រប់គ្រងវាត្រឹមត្រូវ

២-រដ្ឋាភិបាលពុំទាន់មានថវិកាគ្រប់គ្រាន់សម្រាប់បម្រើការគ្រប់គ្រងសំណល់រាវ ពិសេសប្រឡាយមេ និងលូសម្រាប់បង្ហូរទឹកសំអុយ

៣-ច្បាប់ស្តីពីការគ្រប់គ្រងសំណល់រាវនៅធូររលុង ឬពុំទាន់មានប្រសិទ្ធភាពខ្ពស់សម្រាប់អនុវត្ត

៤-នៅអមប្រឡាយបង្ហូរសំណល់រាវ ប្រជាជនទន្ទ្រានសង់លំនៅស្ថាន ជាហេតុនាំឱ្យប្រឡាយរួមតូចចង្អៀត ទឹកសំអុយហូរមិនទាន់។

# សន្និដ្ឋាននិងអនុសាសន៍

## សន្និដ្ឋាន

ជាការពិតសំណលរាវជាផ្នែកមួយសំខាន់ណាស់ ដែលមនុស្សគ្រប់រូបត្រូវតែយកចិត្តទុកនិងគ្រប់គ្រងឱ្យបានត្រឹមត្រូវ ព្រោះសំណល់ទាំងនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសុខភាពមនុស្ស សត្វ ដូច្នេះយើងគ្រប់គ្នាត្រូវមានវិធានការទៅលើបញ្ហាសំណល់រាវ ការគ្រប់គ្រងសំណល់រាវ ដោយឧស្សាហ៍កាយសម្អាត លុបកប់ឱ្យបានត្រឹមត្រូវ នោះសំណល់រាវមិនបង្កគ្រោះថ្នាក់ដល់សុខភាពនិងរក្សាសោភណភាពរាជធានីភ្នំពេញទៀតផង។

**អនុសាសន៍**

១-គួរមានប្រឡាយសម្រាប់បញ្ចេញចោលសំណល់រាវដោយឡែកពីប្រឡាយទទួលទឹកភ្លៀង ព្រោះងាយស្រួលចម្រោះមេរោគ( កាតាលីករបម្លែង )និងទឹកសំអុយហូរបានលឿនជាងមុន

២-អនុវត្តវិធានការយ៉ាងតឹងរឹងចំពោះជនល្មើសដែលមិនគោរពច្បាប់គ្រប់គ្រងសំណល់រាវ

៣-រាល់អាងស្តុកទឹកសំណល់រាវពីធម្មជាតិមិនអនុញ្ញាតឱ្យចាក់ដី សង់លំនៅឋានឬចោលសំណល់រឹង

៤-រាល់ការអភិវឌ្ឍក្រុងភ្នំពេញត្រូវគិតពីផលប៉ះពាល់ដល់អាងស្តុកទឹកសំណល់រាវ

៥-សំណល់រាវដែលបញ្ចេញចោលត្រូវចូលក្នុងអាងធម្មជាតិចៀសវាងបញ្ចូលទៅក្នុងប្រភពទឹកប្រើប្រាស់។

## គន្ថនិទ្ទេស


១. អ៊ូ វ៉ើះ *ទស្សនវិជ្ជាភូមិវិទ្យា*ភ្នំពេញឆ្នាំ២០០៨ សម្រាប់បណ្តុះបណ្តាលនិស្សិតថ្នាក់បណ្ឌិត។

២. ប៉េង ហុងសុជាតិខេមរ៉ូ បណ្ឌិត ឌី ខាល ឡាទីនីសះ បុព្វកថាចំពោះការរៀបចំគ្រប់គ្រងធនធានវប្បធម៌ ខែមករា បោះពុម្ពឆ្នាំ២០០២។

៣. សុន្ទរកថារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុនសែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាស្តីពីយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២។

៤. ក្រសួងបរិស្ថានៈការប្រែប្រួលអាកាសធាតុនិងយន្តការអភិវឌ្ឍស្អាត ឆ្នាំ២០០៤។

៥. RGC, General Population Census of Cambodia 1998. Analysis of CensusResults Report.

៦. Nuptiality. Phnom Penh, NIS, Ministry of Planning, 1999.

៧. Global Disaster Situation and Global Warming from Plan Philippines.

៨. Phnompenhpost.Com/City/distric/boeung trabek Commun.

៩. www.phnompenh.gov.kh\distrct.php.

១០. Song khat in khan Duan Penh.

# ម៉ូដែលព្យាករណ៍កំណើនប្រជារាស្ត្រ

**បេក្ខជនបណ្ឌិត លឹម សេងឌី**
**ផ្នែកគណិតវិទ្យា**



## ១.១- ប្រវត្តិនៃកំណើន

ក្នុងឆ្នាំ១៧៩៨ លោកថូម៉ាសរ៉ូប៊ែម៉ាល់ថូស-Thomas Robert Malthus (១៧៦៦-១៨៣៤) បានបោះពុម្ពស្នាដៃដ៏ល្បីល្បាញលើកទីមួយរបស់គាត់ដែលមានចំណងជើងថា "Essay on the Principle of Population"។ ទ្រឹស្តីឬច្បាប់មូលដ្ឋានក្នុងស្នាដៃនេះបានបង្ហាញថា «ប្រជារាស្ត្រកើនតាមទំនាក់ទំនងសមាមាត្រធរណីមាត្រ ហើយមធ្យោបាយចិញ្ចឹមជីវិតរបស់មនុស្សកើនតាមទំនាក់ទំនងសមាមាត្រនព្វន្តសាស្ត្រ»[១៣]។ នេះមានន័យថា កំណើនប្រជារាស្ត្រកើនលឿនជាងកំណើនស្បៀងអាហារ ពោលគឺកំណើនប្រជារាស្ត្រកើនបែបនិទស្សន៍ ៧ ១៤ ២៨ ៥៦ ១១២ ចំណែកឯស្បៀងអាហារកើនបែបនព្វន្តសាស្ត្រ ៧ ១៤ ២១ ២៨ ៣៥ រៀងគ្នា។ យោងតាមតួលេខនេះ ចំនួនប្រជារាស្ត្រកើនតាមផលគុណ រីឯស្បៀងអាហារកើនតាមផលបូក ហើយបើសរសេរជាទំនាក់ទំនងសមាមាត្ររវាងប្រជារាស្ត្រនឹងស្បៀងអាហារគឺ ៧:៧ ១៤:១៤ ២៨:២១ ៥៦:២៨ និង ១១២:៣៥។ ប៉ុន្តែ កំណើននេះកើនមិនកំណត់មានន័យថា កំណើនប្រជារាស្ត្រនិងមធ្យោបាយចិញ្ចឹមជីវិតក្នុងតំបន់ឬប្រទេសណាមួយកើនរកទីបញ្ចប់គ្មាន។ ដូច្នេះ ក្នុងឆ្នាំ១៨៤៦ [១៤] លោក ព្យែ ហ្វ្រង់ស្វ វែហុល-Pierre François Verhulst (១៨០៤-១៨៤៩) ក៏បានបង្ហាញថាកំណើនប្រជារាស្ត្រមិនត្រឹមតែអាស្រ័យលើចំនួនប្រជារាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាស្រ័យលើប្រសិទ្ធភាពនៃចំនួនប្រជារាស្ត្រអតិបរមា(Carrying Capacity) ក្នុងតំបន់ទៀតផងដែលកំណត់នូវកំណើន។ គាត់បង្ហាញថា កម្លាំងដែលទប់ស្កាត់កំណើនប្រជារាស្ត្រកើនតាមសមាមាត្រទំនាក់ទំនងប្រជារាស្ត្រដែលលើសទៅនឹងប្រជារាស្ត្រសរុប[១៥]។ គាត់និយាយថា[១៦] បើយើងគិតពីកំណើនសត្វគ្រប់ប្រភេទ យើងត្រូវតែទទួលស្គាល់ថា សត្វទាំងនោះមិនមែនកើនឡើងច្រើនដងរាល់ឆ្នាំនោះទេ ខ្លះកើនលឿន ខ្លះកើនយឺត។ ប៉ុន្តែក៏គ្មានអ្វីអាចកើនឡើងតាមនិទស្សន៍ជារៀងរហូតនោះដែរ។ ដែនកំណត់ត្រូវមានជានិច្ច ដោយសារអ្នកអាចគិតថា ដែនកំណត់សម្រាប់កំណើនប្រជារាស្ត្រមាន ការខ្វះខាតស្បៀងអាហារ ជំងឺនិងការកាប់សម្លាប់គ្នា។

## ១.២- កំណើនធម្មជាតិ

យោងតាមច្បាប់ធម្មជាតិ បើយើងសន្មតថាចំនួនប្រជារាស្ត្រគ្មានបម្លាស់ទី នោះចំនួនប្រជារាស្ត្រចុងឆ្នាំស្មើនឹងចំនួនប្រជារាស្ត្រដើមឆ្នាំបូកនឹងកំណើតប្រជារាស្ត្រ រួចដកនឹងចំនួនប្រជារាស្ត្រស្លាប់។ តាមន័យនេះគេទទួលបានរូបមន្តដូចខាងក្រោម៖

---

[១៣] Malthus Thomas Robert, *Essay on the Principle of Population*, London, 1798, p 4, 6-8 and 33-34។

[១៤] http://polaris.gseis.ucla.edu/rhayes/courses/Other/Logistic%20Equation.ppt

[១៥] http://www.ma.utexas.edu/users/davis/375/LECTURES/L2/Verhulst.pdf

[១៦] Richard Golden, Cary Sneider, Eloise Farmer, and Alan Gould, *Population Growth*, USA, Regents of the University of California, 2009, p 22

$$P_{n+1} = P_n + B - D$$

ដែល $P_n$ ជាចំនួនប្រជារាស្ត្រនៅដើមឆ្នាំ

$P_{n+1}$ ជាចំនួនប្រជារាស្ត្រនៅចុងឆ្នាំ

$B$ ជាចំនួនកំណើតប្រជារាស្ត្រនៅចន្លោះ $P_{n+1}$ និង $P_n$

$D$ ជាចំនួនប្រជារាស្ត្រស្លាប់នៅចន្លោះ $P_{n+1}$ និង $P_n$

## ១.៣- វិធីកំណើននព្វន្តសាស្ត្រ

កំណើននព្វន្តសាស្ត្រជាវិធីសាស្ត្រមួយដែលក្នុងនោះកំណើនមធ្យមប្រចាំឆ្នាំត្រូវគណនាដោយយកផលសងរវាងចំនួនប្រជារាស្ត្រនៃជំរឿនពីរជាប់ៗគ្នាចុងក្រោយ ចែកនឹងរយៈពេល(ចំនួនឆ្នាំ)នៃជំរឿនទាំងពីរនោះ[១៧]។

កំណើននព្វន្តសាស្ត្រជាវិធីសាស្ត្រមួយងាយស្រួលបំផុតក្នុងការព្យាករចំនួនប្រជារាស្ត្រ នៅចន្លោះពេលពីរ ឬជំរឿនពីរ។ វិធីសាស្ត្រនេះមានការសន្មតថាកំណើនប្រជារាស្ត្រពីមួយឆ្នាំទៅមួយឆ្នាំគឺថេរ ហើយដោយសារកំណើនប្រជារាស្ត្រថេរ ដូច្នេះចំនួននេះបង្កើតបានជាជំនឿននព្វន្ត ហើយទំនាក់ទំនងរវាងរយៈពេល និងចំនួនប្រជារាស្ត្រនាពេលអនាគតមានខ្សែកោងរាងជាបន្ទាត់។ រូបមន្តកំណើននព្វន្តសាស្ត្រនិងខ្សែកោងមានរាងជាបន្ទាត់ត្រង់៖

$$P_n = P_0(1 + nr) \text{ ឬ } P_n = P_0 + kn$$




រូប១-៣៖ ខ្សែកោងកំណើននព្វន្តសាស្ត្រ

យោងតាមតួលេខប្រជារាស្ត្រនៃទីក្រុងធំៗនៃសហរដ្ឋអាម៉េរិក[១៨] ពីខែមេសា ឆ្នាំ១៩៩៩ ដល់ខែមេសា ឆ្នាំ២០០៩ និងតួលេខចន្លោះជំរឿនពីឆ្នាំ១៩៩០ដល់ឆ្នាំ២០០០ ជាមួយការព្យាករចំនួនប្រជារាស្ត្រពីឆ្នាំ២០០១ ដល់ឆ្នាំ២០០៩ យើងបានសង្កេតឃើញថា គេព្យាករកំណើនប្រជារាស្ត្រគិតជាភាគរយនៃបណ្តាទីក្រុងទាំងនោះតាមវិធីកំណើននព្វន្តសាស្ត្រ។

---

[១៧] http://faculty.ksu.edu.sa/Ashry/lectures/PRINCIPLES%20OF%20DEMOGRAPHY.pdf។

[១៨] http://www.ofm.wa.gov/pop/april1/default.asp, រួចទាញយកឯកសារឈ្មោះ gmacountychange.xls ឬ cocmpch2009.xl ឬ intercensalto09.xls។

## ១.៤- វិធីកំណើនធរណីមាត្រ

កំណើនធរណីមាត្រជាវិធីសាស្ត្រមួយដែលសម្គាល់ទៅលើស្ថានភាពដែលការផ្លាស់ប្តូរចំនួនប្រជារាស្ត្រខុសគ្នាតាមទំនាក់ទំនងសមាមាត្រថេរ[១៩]។

វិធីធរណីមាត្រ ជាវិធីសាស្ត្រមួយខុសពីវិធីនព្វន្តសាស្ត្រដែលក្នុងនោះអត្រាកំណើនធរណីមាត្រសមាមាត្រផ្ទាល់ទៅនឹងចំនួនប្រជារាស្ត្រចំណែកឯចំនួនកំណើនប្រជារាស្ត្រវិញប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ហើយនាំទៅរកចំនួនដ៏ធំយ៉ាងឆាប់រហ័ស។ ដូច្នេះចំនួនកំណើនប្រជារាស្ត្រមិនថេរទេ មានន័យថាប្រែប្រួល តែផ្ទុយទៅវិញអត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំមានតម្លៃថេរ។ រូបមន្តកំណើនធរណីមាត្រនិងខ្សែកោងកំណើនមានរាងដូចខាងក្រោម៖

$$P_n = P_0(1+r)^n \text{ ឬ } P_n = P_t\left(\sqrt[t]{\frac{P_t}{P_0}}\right)^{t_n} \text{ ឬ } \log P_n = \log P_0 + \log(1+r)\times n$$




រូប ១-៤៖ ខ្សែកោងកំណើនធរណីមាត្រ

**ចំណាំ៖** ផលវិបាកនៃវិធីធរណីមាត្រគឺថាផលបូកសរុបនៃចំនួនប្រជារាស្ត្រតាមតំបន់( ទីប្រជុំជនជនបទ ) មិនស្មើនឹងចំនួនប្រជារាស្ត្រសរុបឡើយ។

ក្នុងជំរឿនឆ្នាំ២០០១និងជំរឿនឆ្នាំ២០០៦ អូស្ត្រាលីមានចំនួនប្រជារាស្ត្រសរុប ១៨ ៧៦៩ ២៤៩ នាក់និង ១៩ ៨៥៥ ២៨៨នាក់រៀងគ្នា[២០]និងមានកំណើនជាមធ្យមប្រចាំឆ្នាំប្រែប្រួលជុំវិញ ១,៣%[២១]។ តាមតួលេខនេះ

---

[១៩] http://stats.oecd.org/glossary/detail.asp?ID=6685។

[២០] http://www.censusdata.abs.gov.au/ABSNavigation/prenav/ViewData?action=404& documentproductno=0 & documenttype=Details&order=1&tabname=Details&areacode=0&issue=2006&producttype=Census%20Tables&javascript=true&textversion=false&navmapdisplayed=true&breadcrumb=LPTD&&collection=Census&period=2006&productlabel=Age%20by%20Sex&producttype=Census%20Tables&method=Place%20of%20Usual%20Residence&topic=Population%20Size%20&%20Growth& រួចទាញយកឯកសារ ឈ្មោះ20680-b04-Australia (Australia).xlsនិង សូមមើលhttp://www.censusdata.abs.gov.au/ABSNavigation/prenav/ViewData?action=404&documentproductno=0&documenttype=Details&order=1&tabname=Details&areacode=0&issue=2001&producttype=Census%20Tables&javascript=true&textversion=false&navmapdisplayed=true&breadcrumb=LPTD&&collection=Census&period=2001&productlabel=Age%20by%20Sex&producttype=Census%20Tables&method=Place%20of%20Usual%20Residence&topic=Population%20Size%20&%20Growth&រួចទាញយកឯកសារឈ្មោះ20680-u04-Australia (Australia).xls។

[២១] http://www.abs.gov.au/AUSSTATS/abs@.nsf/DetailsPage/2070.02006?OpenDocument។ រួចទាញយកឯកសារ ឈ្មោះ 20700_a_picture_of_the_nation.pdf បន្ទាប់មកមើលទំព័រទី១១និងទី២៣៣។

យើងបានគណនារកអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ បន្ទាប់មកយើងសង្កេតឃើញថា គេបានប្រើរូបមន្តកំណើនធរណីមាត្រ។

## ១.៥- វិធីកំណើននិទស្សន៍

កំណើននិទស្សន៍[២២]ជាកំណើនដែលក្នុងនោះចំនួនប្រជារាស្ត្រកើនឡើងតាមភាគរយថេរ ក្នុងកំលុងពេលឆ្នាំនីមួយៗឬរយៈពេលណាមួយ។ កាលណាគេយកកំណើននេះមកគូសជាខ្សែកោង គេទទួលបានលទ្ធផលខ្សែកោងរាងជាអក្សរ «J»។

កំណើននិទស្សន៍យោងលើស្ថានភាពដែលមានកំណើនកើនតៗគ្នានៅគ្រប់ខណៈពេល។ ដូច្នេះហើយជួនកាលគេអាចហៅវាថា «កំណើនភ្លាមៗ(Instantaneous growth)»។ កំណើនធរណីមាត្រ(ប្រើប្រាស់ចន្លោះពេលវែង)ជាករណីពិសេសនៃកំណើននិទស្សន៍ ដោយសារបណ្តុំកំណើនកើតឡើងនៅចន្លោះពេលវែងជាង។ ចន្លោះពេលដែលកំណើនកើតឡើងកាន់តែខ្លី ចំនួនប្រជារាស្ត្រកើនឡើងកាន់តែលឿននិងឆាប់។ កំណើននិទស្សន៍ជាកំណើនពេញនិយមមួយក្នុងចំណោមសំណើកំណើនចុងសតវត្សទី២០ស្តីពីគោលការណ៍គណិតវិទ្យាសម្រាប់កំណើនប្រជារាស្ត្រ។

កំណើននិទស្សន៍ទទួលលទ្ធផលខ្ពស់ជាងកំណើនធរណីមាត្រ (បើដឹង $P_0$, $r$ និង $n$) ជាពិសេសសម្រាប់រយៈពេលវែងឬពេលអត្រាកំណើនខ្ពស់។ នេះដោយសារកំណើននិទស្សន៍ផ្តុំចូលគ្នានៅរាល់ចន្លោះពេលខ្លីៗជាជាងនៅចន្លោះពេលកំណត់មួយ។ ផ្ទុយមកវិញអត្រាកំណើននិទស្សន៍ជានិច្ចកាលទាបជាងអត្រាកំណើនធរណីមាត្រ(បើដឹង $P_0$, $P_n$ និង $n$) ហើយចំនួនប្រជារាស្ត្រព្យាករណ៍កំណើននិទស្សន៍និងធរណីមាត្រមានចំនួនស្មើគ្នា។ រូបមន្តកំណើននិងរាងនៃខ្សែកោង៖

$$P_n = P_0 e^{rn} \text{ ឬ } \ln P_n = \ln P_0 + rn$$




រូប១-៥៖ ខ្សែកោងកំណើននិទស្សន៍

[២២] http://dictionary.babylon.com/Exponential%20growth

បើយោងតាមទិន្នន័យស្ថិតិចុងក្រោយ[២៣] ក្នុងខែកញ្ញាឆ្នាំ២០០៩នៃស្ថាប័នស្ថិតិរបស់ប្រទេសនូវែលសេឡង់ ចំនួនប្រជារាស្ត្រនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៨ មានចំនួន ៤ ២៧៩ ៨០០នាក់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ មានចំនួន ៤ ៣៣១ ៦០០នាក់និងមានអត្រាកំណើន១,២%។ តាមតួលេខនេះយើងសង្កេតឃើញថាវិធីសាស្ត្រព្យាករណ៍ទិន្នន័យអត្រាកំណើនប្រជារាស្ត្រគឺជាវិធីសាស្ត្រកំណើនតាមនិទស្សន៍។

ចំណែកឯប្រទេសកម្ពុជា យោងតាមការអង្កេតចំនួនប្រជារាស្ត្រឆ្នាំ១៩៩៦និងការអង្កេតចំនួនប្រជារាស្ត្រនៅចន្លោះជំរឿនឆ្នាំ២០០៤ តាមតួលេខស្ថិតិនៃជំរឿនឆ្នាំ១៩៩៨/២០០៨ និងតាមតួលេខនៃការធ្វើចំណោលប្រជារាស្ត្រកម្ពុជាឆ្នាំ១៩៩៨-២០២០[២៤]រូបមន្តសម្រាប់ព្យាករណ៍កំណើនប្រជារាស្ត្រគិតជាភាគរយដែលកម្ពុជាប្រើគឺវិធីសាស្ត្រកំណើននិទស្សន៍។

## ១.៦- វិធីកំណើនឡូស៊ីស្ទិក

តាមទ្រឹស្តីកំណើនប្រជារាស្ត្ររបស់លោក Pierre François Verhulst ក្នុងឆ្នាំ១៨៤៦ បានបង្ហាញថាកំណើន ប្រជារាស្ត្រមិនត្រឹមតែអាស្រ័យនឹងចំនួនប្រជារាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងអាស្រ័យនឹងផលប៉ះពាល់នឹងចំនួនប្រជារាស្ត្រអតិបរមាក្នុងតំបន់មួយទៀតផង ដែលកំណត់ដែនកំណត់នៃកំណើន។ រូបមន្តកំណើនឡូស៊ី-ស្ទិកនិងខ្សែកោងរបស់វាមានរាង៖

$$P_t = \frac{K}{1 + Ae^{-rt}} \quad , \quad A = \frac{K - P_0}{P_0}$$




រូប ១-៦៖ ខ្សែកោងកំណើនឡូស៊ីស្ទិក

លោក Verhulst បានព្យាករចំនួនប្រជារាស្ត្របែលហ្ស៊ិកខ្ពស់បំផុតគឺប្រហែល៩ ៤០០ ០០០នាក់។ តាមពិតចំនួនប្រជារាស្ត្រក្នុងឆ្នាំ១៩៩៤ មាន ១០ ១១៨ ០០០នាក់។

ពីឆ្នាំ១៩២០ ដល់ឆ្នាំ១៩៤០ សហរដ្ឋអាម៉េរិកប្រើកំណើនឡូស៊ីស្ទិកសម្រាប់ព្យាករណ៍ចំនួនប្រជារាស្ត្ររបស់ខ្លួន ហើយទទួលបានលទ្ធផលដ៏ល្អ[២៥]។

---

[២៣] http://img.scoop.co.nz/media/pdfs/0911/NationalPopulationEstimatesSep09qtrHOTP.pdf។

[២៤] National Institute of Statistics, "First revision Population Projection for Cambodia 1998-2020", Phnom Penh, 2004, p. 29។

[២៥] http://www.oup.com/uk/orc/bin/9780198752639/ch02.pdf។

## ១.៧- វិធីកំណើនតិត្ថិកម្ម

វិធីកំណើនតិត្ថិកម្ម (Saturation Method) ជាវិធីមួយដែលគេប្រើសម្រាប់ប្រៀបធៀបលទ្ធផល ព្យាករជាមួយវិធីកំណើនធរណីមាត្រ។ ប្រសិនបើចំនួនប្រជារាស្ត្រព្យាករណ៍នាពេលអនាគតតាមកំណើនធរណីមាត្រធំជាងចំនួនប្រជារាស្ត្រតាមកំណើនតិត្ថិកម្ម នោះយើងគួរតែយកចំនួនប្រជារាស្ត្រតាមតិត្ថិកម្មមកប្រើប្រាស់។ តែបើចំនួនប្រជារាស្ត្រព្យាករណ៍តាមកំណើនធរណីមាត្រតូចជាងចំនួនប្រជារាស្ត្រតាមកំណើនតិត្ថិកម្ម នោះយើងគួរតែយកចំនួនប្រជារាស្ត្រតាមធរណីមាត្រមកប្រើជំនួសវិញ។ ដោយវិធីកំណើនធរណីមាត្រជាករណីពិសេសនៃវិធីកំណើននិទស្សន៍ នោះយើងគិតថា យើងអាចប្រើវិធីកំណើនតិត្ថិកម្មសម្រាប់ប្រៀបធៀបជាមួយវិធីកំណើននិទស្សន៍បានដែរ។ វិធីកំណើនតិត្ថិកម្មត្រូវគណនាតាមរូបមន្តខាងក្រោម៖

តារាង៖ រូបមន្តកំណើនតិត្ថិកម្ម

| |
|---|
| ក្រឡាផ្ទៃរស់នៅ = ក្រឡាផ្ទៃសរុប គុណនឹង ភាគរយនៃក្រឡាផ្ទៃរស់នៅ (ដោយសារគិតពីក្រឡាផ្ទៃនៃសួន និង ផ្លូវ) |
| ក្រឡាផ្ទៃអគារ = ក្រឡាផ្ទៃរស់នៅ គុណនឹង ភាគរយនៃអគារ |
| ក្រឡាផ្ទៃរស់នៅសរុប = ក្រឡាផ្ទៃអគារ គុណនឹង ចំនួនជាន់គិតជាមធ្យមនៃអគារនីមួយៗ |
| ចំនួនផ្ទះ (ល្វែង) = ក្រឡាផ្ទៃរស់នៅសរុប ចែកនឹង ក្រឡាផ្ទៃមធ្យមនៃផ្ទះមួយ |
| ដូច្នេះ ចំនួនប្រជាជនតាមតិត្ថិកម្ម[២៦] = ចំនួនផ្ទះ គុណនឹង ចំនួនសមាជិកក្នុងគ្រួសារនីមួយៗ |

ខាងក្រោមជាឧទាហរណ៍នៃការប្រើប្រាស់វិធីតិត្ថិកម្ម៖

ក្រឡាផ្ទៃសរុបនៃតំបន់រស់នៅមួយ = ១០០០ម៉ែត្រការ៉េ។ ដោយតំបន់នេះមានសួននិងផ្លូវ និងគិតជាភាគរយ មានចំនួន២០%។ នោះយើងទទួលបាន៖

ក្រឡាផ្ទៃរស់នៅ = ៨០% x ១០០០ = ៨០០ម៉ែត្រការ៉េ។ ដោយអគារមាន ៦០% នៃក្រឡាផ្ទៃរស់នៅ យើងទទួលបាន៖

ក្រឡាផ្ទៃអាគារ = ៦០% x ៨០០ = ៤៨០ម៉ែត្រការ៉េ។ ដោយអគារនីមួយៗមាន ៣ជាន់ តាមសម្មតិកម្មនេះ យើងទាញបាន៖

ក្រឡាផ្ទៃរស់នៅសរុប = ៤៨០ x ៣ =១៤៤០ម៉ែត្រការ៉េ។ ដោយផ្ទះនីមួយៗមានក្រឡាផ្ទៃ ៤៨ម៉ែត្រការ៉េ ។ ដូច្នេះ

ចំនួនផ្ទះ = ១៤៤០/៤៨ = ៣០។ បើសិនមួយគ្រួសារមានសមាជិកចំនួន៤នាក់ នោះជាលទ្ធផល៖ចំនួនប្រជារាស្ត្រ = ៣០ x ៤ = ១២០នាក់។

យោងតាមឧទាហរណ៍ខាងលើវិធីសាស្ត្រនេះពុំសូវមានការប្រើប្រាស់ទេ ដោយសារទាក់ទងនឹងទំហំក្រឡាផ្ទៃអគារ ចំនួនជាន់នៃផ្ទះនីមួយៗ និងចំនួនសមាជិកក្នុងគ្រួសារ។

## ១.៨- វិធីគំនូសតាង

គំនូសតាងជាវិធីមួយសម្រាប់ព្យាករចំនួនប្រជារាស្ត្រ ដោយយកចំនួនប្រជារាស្ត្រនៃជំរឿនឬពេលជាប់ៗគ្នាមកដៅលើអ័ក្ស រួចភ្ជាប់ចូលគ្នាដោយបន្ទាត់មួយដែលបន្លាយទៅរកឆ្នាំនាពេលអនាគត។ ឧទាហរណ៍ យើងមាន

[២៦] ចំនួនអតិបរមាដែលអាចមានក្នុងតំបន់មួយឬទីក្រុងមួយ។

ទិន្នន័យចំនួនប្រជារាស្ត្រគិតជាលាននាក់ពីឆ្នាំ១៩២០ដល់ឆ្នាំ២០០០។ ឆ្នាំ១៩២០មានចំនួន៥៤៧ឆ្នាំ១៩៣០ មានចំនួន៧១៥៧ ឆ្នាំ១៩៤០មានចំនួន៨២៩០ ឆ្នាំ១៩៥០មានចំនួន៩៥៥០ ឆ្នាំ១៩៦០មានចំនួន១០២៧២ ឆ្នាំ១៩៧០ មានចំនួន១២០៤៥ ឆ្នាំ១៩៨០មានចំនួន១៥០៣៣ ឆ្នាំ១៩៩០ មានចំនួន១៦១៤១ និងឆ្នាំ២០០០ មានចំនួន១៨០២៥។ យើងទទួលបានរូប៖




រូប១-៨៖ ខ្សែកោងកំណើនតាមគំនូសតាង

សរុបមកការរៀបរាប់ខាងលើនេះគឺជាវិធីសាស្ត្រផ្សេងៗ ដែលគេនិយមយកមកប្រើសម្រាប់ព្យាករណ៍។ ក្រៅពីនោះក៏មានវិធីសាស្ត្រមួយចំនួនទៀត សម្រាប់ការព្យាករនៃករណីពិសេសផ្សេងៗទៀត។

# ឋានន្តរសក្តិរបស់មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌមុខងារសាធារណៈ



**បេក្ខបណ្ឌិត ស៊ិន សុឃន**
**ផ្នែកនីតិសាស្ត្រ**

## ១- ឋានន្តរស័ក្តិ

មន្ត្រីរាជការស៊ីវិលទាំងអស់ត្រូវរៀបចំជាក្របខ័ណ្ឌដែលត្រូវបែងចែកជាឋានន្តរសក្តិជាលំដាប់ឋានានុក្រមនៃក្របខ័ណ្ឌ។ ក្របខ័ណ្ឌនីមួយៗត្រូវបែងចែកជា៣ឋានន្តរស័ក្តិ។ ឋានន្តរសក្តិនីមួយៗឆ្លើយតបទៅនឹងមុខតំណែងឬសារព័ន្ធមុខតំណែងដែលមានការទទួលខុសត្រូវកាន់តែខ្ពស់។

ឋានន្តរសក្តិក្នុងក្របខ័ណ្ឌប្រភេទ «**ក**» ក្របខ័ណ្ឌប្រភេទ «**ក**» ត្រូវបែងចែកជា ៣ឋានន្តរសក្តិ តាមលំដាប់លំដោយពីតូចទៅធំដូចខាងក្រោមឋានន្តរសក្តិទី៣នៃក្របខ័ណ្ឌប្រភេទ «**ក**»(ក$_៣$) ជាឋានន្តរសក្តិទាបបំផុតនៃក្របខ័ណ្ឌប្រភេទ (ក) ហៅថា ឋានន្តរសក្តិតាមការជ្រើសរើស។

ការបញ្ចូលក្នុងឋានន្តរសក្តិនេះធ្វើឡើងតាមរយៈការប្រឡងប្រជែងចូលក្នុងក្របខ័ណ្ឌប្រភេទ «**ក**» ពីក្នុងចំណោមនិស្សិតដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បូក៤ឆ្នាំសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាយ៉ាងតិចនិងមន្ត្រីរាជការដែលស្ថិតយ៉ាងតិចបំផុតថ្នាក់លេខ១១នៃក្របខ័ណ្ឌប្រភេទ «**ខ**» និងមានអាយុយ៉ាងច្រើន ៤៥ឆ្នាំនិងចំពោះមន្ត្រីរាជការដែលមានសញ្ញាបត្រសមមូលនឹងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបូក៤ឆ្នាំសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាអាចប្រឡងបានដោយមិនគិតពីឋានន្តរសក្តិនិងប្រភេទក្របខ័ណ្ឌឡើយ។ ចំពោះសិស្សមន្ត្រីជាន់ខ្ពស់ដែលបានរៀនចប់ប្រកបដោយជោគជ័យនៅសាលាភូមិន្ទរដ្ឋបាលនិងការប្រឡងប្រជែងផ្ទៃក្នុង[២៧]។

ឋានន្តរសក្តិទី៣នេះ មានឧបនិស្ស័យកាន់មុខតំណែងជាអនុប្រធាននាយកដ្ឋានក្នុងរដ្ឋបាលកណ្តាល ប្រធានមន្ទីរនៅខេត្ត/រាជធានី អភិបាលក្រុង/ស្រុក/ខណ្ឌ ព្រឹទ្ធបុរសមហាវិទ្យាល័យ អធិការរង នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ នាយកសាលាគរុកោសល្យខេត្ត/រាជធានី នាយកវិទ្យាល័យនិងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួងស្ថាប័ន។

ឈ្មោះនៅក្នុងឋានន្តរសក្តិទី៣នៅក្នុងក្របខ័ណ្ឌប្រភេទ «**ក**» ប្រែប្រួលទៅតាមប្រភេទនៃក្របខ័ណ្ឌដែលមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗមាន៖

ចំពោះ «អនុមន្ត្រី» សម្រាប់ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនិងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ «អនុមន្ត្រីការបរទេស» សម្រាប់ក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ «គ្រូបង្រៀនកម្រិតឧត្តម» សម្រាប់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម «មន្ត្រីបច្ចេកទេសជាន់ខ្ពស់» សម្រាប់ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់និង «មន្ត្រីសុខាភិបាលជាន់ខ្ពស់» សម្រាប់ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់[២៨]។

ចំណែកឯឋានន្តរស័ក្តិទី២នៃក្របខ័ណ្ឌប្រភេទ "**ក**"(ក$_២$) ឋានន្តរស័ក្តិទី២នេះ ហៅថា «ឋានន្តរស័ក្តិតាមការដំឡើង» ដែលសម្រាប់អនុវត្តចំពោះមន្ត្រីរាជការមានស្នាដៃខ្ពស់។ មន្ត្រីរាជការក្នុងឋានន្តរសក្តិទី៣អាច

---

[២៧] ព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល។

[២៨] ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌសុខាភិបាលជាន់ខ្ពស់។

ដំឡើងទៅក្នុងឋានន្តរសក្តិទី២ត្រូវអនុវត្តទៅតាមចំនួនតំណែងដែលមានទំនេរនៅក្នុងឋានន្តរស័ក្តិនេះនិងធ្វើឡើងតាមរយៈការចុះឈ្មោះក្នុងតារាងដំឡើងឋានន្តរសក្តិ ការប្រឡងប្រជែងផ្ទៃក្នុងនិងការបណ្តុះបណ្តាលរយៈពេលវែងនៅក្នុងនិងក្រៅប្រទេស[២៩]។

ឧទាហរណ៍៖បណ្តុះបណ្តាលជាអធិការមធ្យមសិក្សា។ អ្នកដែលមាននិក្ខេបបទឬមានសញ្ញាបត្របណ្ឌិតវេជ្ជសាស្ត្រទូទៅឬឯកទេសបណ្ឌិតឱសថសាស្ត្រឬបណ្ឌិតឱសថសាស្ត្រឯកទេសបណ្ឌិតទន្តវេទនសាស្ត្រឬបណ្ឌិតទន្តវេទនសាស្ត្រឯកទេសឬសញ្ញាបត្រដទៃដែលមានតម្លៃស្មើ។

ការដំឡើងទៅក្នុងឋានន្តរសក្តិទី២នេះធ្វើឡើងចំពោះមន្ត្រីដែលបានឡើងដល់ថ្នាក់ទី១១ នៃឋានន្តរសក្តិទី៣(**ក**៣.១១) និងត្រូវសម្រេចដោយអនុក្រឹត្យ។ ការដំឡើងឋានន្តរសក្តិនេះជាគោលការណ៍ត្រូវដំឡើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរសក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវដំឡើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី។

ការដំឡើងទៅក្នុងឋានន្តរសក្តិទី២ នេះអាចផ្តល់ឧបនិស្ស័យដល់មន្ត្រីសាមីក្នុងការអនុវត្តមុខតំណែងទាំងឡាយដែលស្របទៅនឹងឋានន្តរស័ក្តិនេះ[៣០]។

មន្ត្រីក្នុងឋានន្តរសក្តិទី២ មានឧបនិស្ស័យកាន់មុខតំណែងជាអគ្គនាយករង អគ្គាធិការរង ប្រធាននាយកដ្ឋានក្នុងរដ្ឋបាលកណ្តាលអភិបាលខេត្ត-រាជធានីរង អគ្គទីប្រឹក្សា ទីប្រឹក្សា អគ្គកុងស៊ុលនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស សាកលវិទ្យាធិការរង ព្រឹទ្ធបុរសមហាវិទ្យាល័យ អធិការ អគ្គលេខាធិការរងនិងមុខតំណែងផ្សេងទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួង/ស្ថាប័ន។ ការឱ្យឈ្មោះឋានន្តរសក្តិទី២នៅក្នុងក្របខ័ណ្ឌប្រភេ "**ក**" ប្រែប្រួលទៅតាមប្រភេទក្របខ័ណ្ឌដែលមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗមាន «វរមន្ត្រី» សម្រាប់ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនិងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ «វរមន្ត្រីការបរទេស» សម្រាប់ក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ «គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ» សម្រាប់ក្របខ័ណ្ឌមន្ត្រីគ្រូបង្រៀនកម្រិតឧត្តម «មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ» សម្រាប់ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់និង «មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ» សម្រាប់ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់[៣១]។

ឋានន្តរស័ក្តិទី១នៃក្របខ័ណ្ឌប្រភេទ "**ក**" (ក១) ឋានន្តរសក្តិទី១នេះហៅថា «ឋានន្តរសក្តិតាមការដំឡើង» ដែលសម្រាប់អនុវត្តចំពោះមន្ត្រីរាជការមានស្នាដៃខ្ពស់។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិទី២ត្រូវដំឡើងនៅក្នុងឋានន្តរសក្តិទី១ ត្រូវអនុវត្តស្របទៅតាមចំនួនតំណែងមានទំនេរនៅក្នុងឋានន្តរសក្តិនេះ។ ការដំឡើង ធ្វើឡើងចំពោះមន្ត្រីរាជការដែលបានឡើងដល់ថ្នាក់លេខ៧នៃឋានន្តរសក្តិទី២(**ក**២.៧) តាមរយៈការចុះឈ្មោះក្នុងតារាងដំឡើងឋានន្តរសក្តិការប្រឡងប្រជែងផ្ទៃក្នុង និងការបណ្តុះបណ្តាលរយៈពេលវែងនៅក្នុងនិងក្រៅប្រទេស។

ការដំឡើងឋានន្តរសក្តិទៅឋានន្តរសក្តិទី១ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ។ ការដំឡើងឋានន្តរសក្តិនេះជាគោលការណ៍ត្រូវដំឡើងទៅថ្នាក់ដំបូងនៃឋានន្តរសក្តិខ្ពស់លើបន្ទាប់ឬក្នុងករណីចាំបាច់ត្រូវដំឡើងក្នុងថ្នាក់

[២៩] ព្រះរាជក្រឹត្យលេខជស/រកត/០៣០០/១១៦ មាត្រា ១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល។

[៣០] ព្រះរាជក្រឹត្យលេខជស/រកត/០៣០០/១១៦ មាត្រា ១៤ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល។

[៣១] លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗរបស់មន្ត្រីរាជការស៊ីវិល។

ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី។ ការដំឡើងទៅក្នុងឋានន្តរស័ក្តិទី១នេះអាចផ្តល់ឧបនិស្ស័យដល់មន្ត្រីសាមីក្នុងការអនុវត្តនូវមុខតំណែងដែលស្របទៅនឹងឋានន្តរស័ក្តិទី១នេះ[៣២]។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិទី១មានឧបនិស្ស័យកាន់មុខតំណែងជាអគ្គនាយក អគ្គាធិការ អគ្គលេខាធិការ អភិបាលខេត្ត/រាជធានី ឯកអគ្គរាជទូត អគ្គរាជទូត សាកលវិទ្យាធិការនិងមុខតំណែងផ្សេងទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួងស្ថាប័ន[៣៣]។

ឈ្មោះក្នុងឋានន្តរស័ក្តិទី១នៅក្នុងក្របខ័ណ្ឌប្រភេទ"**ក**" (ក១) ប្រែប្រួលទៅតាមប្រភេទក្របខ័ណ្ឌដែលមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗមាន «ឧត្តមមន្ត្រី» សម្រាប់ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល និងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ«គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែពិសេស» សម្រាប់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម «ឧត្តមមន្ត្រីការបរទេស» សម្រាប់ក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ «មន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែពិសេស» សម្រាប់ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និង «មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែពិសេស» សម្រាប់ក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់។

ឋានន្តរស័ក្តិនៃក្របខ័ណ្ឌប្រភេទ "**ខ**" ត្រូវបែងចែកជា៣ឋានន្តរស័ក្តិដែលរៀបតាមលំដាប់លំដោយពីតូចទៅធំដូចខាងក្រោម៖

ឋានន្តរស័ក្តិទី៣ក្នុងក្របខ័ណ្ឌប្រភេទ "**ខ**"(ខ៣) ឋានន្តរស័ក្តិទី៣ជាឋានន្តរស័ក្តិទាបបំផុតនៃក្របខ័ណ្ឌប្រភេទ "**ខ**" ហៅថា «ឋានន្តរស័ក្តិតាមការជ្រើសរើស»។ ការបញ្ចូលក្នុងឋានន្តរស័ក្តិនេះធ្វើឡើងតាមរយៈការប្រឡងប្រជែងចូលក្នុងក្របខ័ណ្ឌប្រភេទ"**ខ**" ពីក្នុងចំណោមនិស្សិតដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបូក២ឆ្នាំសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាយ៉ាងតិច និងមន្ត្រីរាជការដែលស្ថិតយ៉ាងតិចបំផុតថ្នាក់លេខ១១នៃក្របខ័ណ្ឌប្រភេទ "**គ**" និងមានអាយុយ៉ាងច្រើន៤០ឆ្នាំនិងចំពោះមន្ត្រីរាជការដែលមានសញ្ញាបត្រសមមូលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបូក២ឆ្នាំសិក្សានៅគ្រឹះស្ថានឧត្តមសិក្សាអាចប្រឡងបាន ដោយមិនគិតពីឋានន្តរស័ក្តិនិងប្រភេទក្របខ័ណ្ឌឡើយ។ សិស្សមន្ត្រីក្រមការដែលបានរៀនចប់ប្រកបដោយជោគជ័យនៅសាលាភូមិន្ទរដ្ឋបាលនិងការប្រឡងប្រជែងផ្ទៃក្នុង[៣៤]។

មន្ត្រីក្នុងឋានន្តរស័ក្តិទី៣នេះ មានឧបនិស្ស័យកាន់មុខតំណែងជាអនុប្រធានការិយាល័យនៃមន្ទីរនៅខេត្ត/រាជធានី អនុប្រធានការិយាល័យសាលាខេត្ត/រាជធានី ប្រធានការិយាល័យក្រុង/ស្រុក/ខណ្ឌ នាយកអនុវិទ្យាល័យ នាយកសាលាបឋមសិក្សា នាយកសាលាមត្តេយ្យសិក្សា ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងមុខតំណែងផ្សេងទៀត ដែលមានថ្នាក់ស្មើនិងមុខតំណែងខាងលើដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួង/ស្ថាប័ន[៣៥]។

ការឱ្យឈ្មោះឋានន្តរស័ក្តិទី៣នៃក្របខ័ណ្ឌប្រភេទ "**ខ**" ប្រែប្រួលទៅតាមប្រភេទនៃក្របខ័ណ្ឌដែលមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗដូចជា «មន្ត្រីក្រមការ» សម្រាប់ក្របខ័ណ្ឌមន្ត្រីក្រមការនិងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ «គ្រូបង្រៀនកម្រិតមូលដ្ឋាន» សម្រាប់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន

---

[៣២] ព្រះរាជក្រឹត្យលេខជស/រកត/០៣០០/១១៦ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល។

[៣៣] មាត្រា ៥ -ជ-។

[៣៤] មាត្រា ៦ ៧ និង៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ។

[៣៥] មាត្រា៥ -ជ-។

«មន្ត្រីបច្ចេកទេសមធ្យម» សម្រាប់ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម «មន្ត្រីសុខាភិបាលមធ្យម» សម្រាប់ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យមនិង «មន្ត្រីក្រមការការបរទេស» សម្រាប់ក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស[៣៦]។

ឋានន្តរសក្តិទី២ នៃក្របខ័ណ្ឌប្រភេទ "**ខ**" (ខ២) ឋានន្តរសក្តិទី២នេះហៅថា «ឋានន្តរសក្តិតាមការដំឡើង» ដែលសម្រាប់អនុវត្តចំពោះមន្ត្រីរាជការមានស្នាដៃខ្ពស់។

ចំពោះបែបបទនិងគោលការណ៍នៃការដំឡើងចូលក្នុងឋានន្តរស័ក្តិនេះត្រូវអនុវត្តតាមចំនួនតំណែងដែលមានទំនេរនៅក្នុងឋានន្តរស័ក្តិនេះតាមរយៈការចុះឈ្មោះក្នុងតារាងដំឡើងឋានន្តរស័ក្តិការប្រឡងប្រជែងផ្ទៃក្នុងនិងការបណ្តុះបណ្តាលរយៈពេលវែងនៅក្នុងនិងក្រៅប្រទេស[៣៧]។ ឧទាហរណ៍៖បណ្តុះបណ្តាលអធិការបឋមសិក្សា។

ការដំឡើងទៅក្នុងឋានន្តរស័ក្តិទី២នេះត្រូវធ្វើឡើងចំពោះមន្ត្រីដែលបានឡើងដល់ថ្នាក់ទី១១ នៃឋានន្តរ-សក្តិទី៣(**ខ៣.១១**) ឡើងទៅនិងត្រូវសម្រេចដោយប្រកាស[៣៨]។

មន្ត្រីក្នុងឋានន្តរស័ក្តិទី២ មានឧបនិស្ស័យកាន់មុខតំណែងជាអនុប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាលប្រធានការិយាល័យនៃមន្ទីរខេត្ត/រាជធានី ប្រធានការិយាល័យនៅសាលាខេត្ត/រាជធានី និងមុខតំណែងផ្សេងទៀតដែលមានថ្នាក់ស្មើនិងមុខតំណែងខាងលើដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួង/ស្ថាប័ន[៣៩]។

ការឱ្យឈ្មោះមន្ត្រីឋានន្តរស័ក្តិទី២នៃក្របខ័ណ្ឌប្រភេទ "**ខ**" ប្រែប្រួលទៅតាមប្រភេទក្របខ័ណ្ឌដែលមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗមាន «ក្រមការដើមខ្សែ» សម្រាប់ក្របខ័ណ្ឌមន្ត្រីក្រមការនិងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។ ចំពោះ «ក្រមការដើមខ្សែការបរទេស» សម្រាប់ក្របខ័ណ្ឌមន្ត្រីក្រមការការបរទេស «គ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ» សម្រាប់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន «មន្ត្រីបច្ចេក-ទេសមធ្យមដើមខ្សែ» សម្រាប់ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យមនិង «មន្ត្រីសុខាភិបាលមធ្យមដើមខ្សែ» សម្រាប់ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យមដែលការបញ្ចូលក្នុងឋានន្តរស័ក្តិទី២នេះត្រូវសម្រេចដោយប្រកាស[៤០]។

ឋានន្តរស័ក្តិទី១នៃក្របខ័ណ្ឌប្រភេទ "**ខ**"(**ខ១**) ជាឋានន្តរស័ក្តិខ្ពស់បំផុតនៃក្របខ័ណ្ឌប្រភេទ "**ខ**" ហៅថា «ឋានន្តរស័ក្តិតាមការដំឡើង» សម្រាប់អនុវត្តចំពោះមន្ត្រីរាជការដែលមានស្នាដៃខ្ពស់។ ការដំឡើងត្រូវធ្វើឡើងចំពោះមន្ត្រីរាជការដែលបានឡើងដល់ថ្នាក់លេខ៧ នៃឋានន្តរស័ក្តិទី២(**ខ២.៧**) ឡើងទៅ តាមរយៈការចុះឈ្មោះក្នុងតារាងដំឡើងឋានន្តរស័ក្តិការប្រឡងប្រជែងផ្ទៃក្នុង និងការបណ្តុះបណ្តាលរយៈពេលវែងនៅក្នុងនិងក្រៅប្រទេសហើយការដំឡើងទៅក្នុងឋានន្តរស័ក្តិនេះត្រូវធ្វើឡើងដោយប្រកាស[៤១]។

មន្ត្រីក្នុងឋានន្តរស័ក្តិទី១ មានឧបនិស្ស័យកាន់មុខតំណែងជាប្រធានការិយាល័យក្នុងរដ្ឋបាលកណ្តាលអនុប្រធានមន្ទីរនៅខេត្ត/រាជធានី អភិបាលក្រុង/ស្រុក/ខណ្ឌរងនិងមុខតំណែងផ្សេងៗទៀត ដែលមានថ្នាក់ស្មើនិងមុខតំណែងខាងលើដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួង/ស្ថាប័ន[៤២]។

---

[៣៦] លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗរបស់មន្ត្រីរាជការស៊ីវិល។

[៣៧] មាត្រា ១៣នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ជ.ឯ.ម.។

[៣៨] មាត្រា១៤-ជ-។

[៣៩] មាត្រា៥ -ជ-។

[៤០] លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗរបស់មន្ត្រីរាជការស៊ីវិល។

[៤១] មាត្រា១៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ជ.ឯ.ម.។

[៤២]មាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ជ.ឯ.ម.។

ការឱ្យឈ្មោះមន្ត្រីក្នុងឋានន្តរសក្តិទី១នៅក្នុងក្របខ័ណ្ឌប្រភេទ "ខ" ប្រែប្រួលទៅតាមប្រភេទក្របខ័ណ្ឌដែលមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗមាន «នាយក្រមការ» សម្រាប់ក្របខ័ណ្ឌមន្ត្រីក្រម-ការនិងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ «នាយក្រមការការបរទេស» សម្រាប់ក្របខ័ណ្ឌមន្ត្រីក្រមការការ-បរទេស «មន្ត្រីបច្ចេកទេសដើមខ្សែពិសេស» សម្រាប់ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម «មន្ត្រីសុខាភិបាលមធ្យមដើមខ្សែពិសេស» សម្រាប់ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យមនិងគ្រូបង្រៀនកម្រិតមូលដ្ឋានដើមខ្សែ ពិសេសសម្រាប់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន[៤៣]។

ឋានន្តរសក្តិនៃក្របខ័ណ្ឌប្រភេទ "គ" ក្របខ័ណ្ឌប្រភេទ "គ" ត្រូវបែងចែកជា៣ឋានន្តរសក្តិដែលរៀបតាមលំដាប់លំដោយពីតូចទៅធំដូចខាងក្រោម៖

ឋានន្តរសក្តិទី៣នៃក្របខ័ណ្ឌប្រភេទ "គ"(**គ៣**) ជាឋានន្តរសក្តិទាបបំផុតនៃក្របខ័ណ្ឌប្រភេទ "គ" ហៅថា «ឋានន្តរសក្តិតាមការជ្រើសរើស» ហើយមន្ត្រីដែលបញ្ចូលក្នុងឋានន្តរសក្តិនេះធ្វើឡើងតាមរយៈការប្រឡងប្រជែងចូលក្នុងក្របខ័ណ្ឌប្រភេទ"គ"ពីក្នុងចំណោមសិស្សនិស្សិតដែលមានសញ្ញាត្រមធ្យមសិក្សាទុតិយភូមិយ៉ាងតិចមន្ត្រីរាជការក្របខ័ណ្ឌប្រភេទ "ឃ" ដែលបានបំពេញការងារ៥ឆ្នាំពេញលេញយ៉ាងតិចរួចមកហើយ និងមន្ត្រីក្របខ័ណ្ឌដែលមានសញ្ញាបត្រសមមូលនិងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនិងការប្រឡងប្រជែងផ្ទៃក្នុង[៤៤]។

មន្ត្រីឋានន្តរសក្តិទី៣នេះ មានឱកាសបរិស្ស័យកាន់មុខតំណែងជាអ្នកគ្រប់គ្រងអ្នកទោសក្នុងពន្ធនាគារនិងមុខតំណែងដទៃទៀតដែលមានថ្នាក់ស្មើនិងមុខតំណែងសម្រាប់ក្របខ័ណ្ឌប្រភេទ"គ"រួម។ ម៉្យាងទៀតនៅក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌប្រភេទ"គ"នេះ មិនមានចែងអំពីមុខតំណែងណាមួយច្បាស់លាស់សម្រាប់ឋានន្តរសក្តិនីមួយៗនៃក្របខ័ណ្ឌប្រភេទ "គ" នេះទេ ពោលគឺចែងពីមុខតំណែងសម្រាប់ក្របខ័ណ្ឌប្រភេទ "គ" ទាំងមូលលើកលែងតែលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌអនុរក្សពន្ធនាគារ។ អង្គការងារទូតមិនមានក្របខ័ណ្ឌប្រភេទ"គ"ទេ[៤៥]។

មុខតំណែងសម្រាប់មន្ត្រីក្នុងក្របខ័ណ្ឌប្រភេទ "គ" មានអនុប្រធានការិយាល័យនៅសាលាក្រុង/ស្រុក/ខណ្ឌស្មៀនឃុំ/សង្កាត់ នាយករងសាលាបឋមសិក្សា នាយករងសាលាមត្តេយ្យសិក្សានិងមុខតំណែងផ្សេងៗទៀតដែលមានថ្នាក់ស្មើនិងមុខតំណែងខាងលើដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួងស្ថាប័ន[៤៦]។

ឈ្មោះសម្រាប់ឋានន្តរសក្តិទី៣នៅក្នុងក្របខ័ណ្ឌប្រភេទ "គ" ប្រែប្រួលទៅតាមប្រភេទនៃក្របខ័ណ្ឌដែលមានចែងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗមាន «លេខាធិការរដ្ឋបាល» សម្រាប់ក្របខ័ណ្ឌលេខា-ធិការរដ្ឋបាលនិងលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ «មន្ត្រីបច្ចេកទេសបឋម» សម្រាប់ក្របខ័ណ្ឌមន្ត្រីបច្ចេក-ទេសបឋម «គ្រូបង្រៀនកម្រិតបឋម» សម្រាប់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម «អនុរក្ស» សម្រាប់ក្របខ័ណ្ឌអនុរក្សពន្ធនាគារក្រសួងមហាផ្ទៃ» និង «មន្ត្រីសុខាភិបាលបឋម» សម្រាប់ក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋម[៤៧]។

---

[៤៣]លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗរបស់មន្ត្រីរាជការស៊ីវិល។

[៤៤]មាត្រា៥, ៦នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/១០៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល។

[៤៥]មាត្រា ៣-ដ-។

[៤៦]មាត្រា ៣នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/១០៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល និងមាត្រា៥នៃព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។

[៤៧]លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗរបស់មន្ត្រីរាជការស៊ីវិល។

ឋាននន្តរសក្តិទី២នៃក្របខ័ណ្ឌប្រភេទ "គ"(គ២) ឋាននន្តរស័ក្តិនេះហៅថា «ឋាននន្តរសក្តិតាមការដំឡើង» ដែលសម្រាប់អនុវត្តចំពោះអ្នករាជការដែលមានស្នាដៃខ្ពស់។ ការដំឡើងត្រូវអនុវត្តចំពោះមន្ត្រីរាជការដែលបានឡើងដល់ថ្នាក់លេខ១១ នៃឋាននន្តរសក្តិទី៣(គ៣.១១) តាមរយៈការចុះឈ្មោះក្នុងតារាងដំឡើងឋាននន្តរសក្តិការប្រឡងប្រជែងផ្ទៃក្នុងនិងការបណ្តុះបណ្តាលរយៈពេលវែងនៅក្នុងនិងក្រៅប្រទេស[៤៨]។

មន្ត្រីក្នុងឋាននន្តរសក្តិនេះមានឧបនិស្ស័យកាន់មុខតំណែងរួមរបស់ក្របខ័ណ្ឌប្រភេទ "គ" និងនាយរងផ្នែករដ្ឋបាលនិងភារកិច្ចប្រតិបត្តិក្នុងពន្ធនាគារនិងមុខតំណែងដទៃទៀតដែលមានថ្នាក់ស្មើសម្រាប់ក្របខ័ណ្ឌអនុរក្សពន្ធនាគារក្រសួងមហាផ្ទៃ[៤៩]។

ឈ្មោះក្នុងឋាននន្តរសក្តិទី២នៅក្នុងក្របខ័ណ្ឌប្រភេទ "គ" ប្រែប្រួលទៅតាមប្រភេទក្របខ័ណ្ឌដែលមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗមាន «លេខាធិការរដ្ឋបាលដើមខ្សែ» សម្រាប់ក្របខ័ណ្ឌលេខាធិការរដ្ឋបាលនិងក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ។ ចំពោះ «គ្រូបង្រៀនកម្រិតបឋមដើមខ្សែ» សម្រាប់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម «មន្ត្រីបច្ចេកទេសបឋមដើមខ្សែ» សម្រាប់ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម «មន្ត្រីសុខាភិបាលបឋមដើមខ្សែ» សម្រាប់ក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋមនិង«អនុរក្សដើមខ្សែ» សម្រាប់ក្របខ័ណ្ឌអនុរក្សពន្ធនាគារក្រសួងមហាផ្ទៃ[៥០]។

ឋាននន្តរសក្តិទី១នៃក្របខ័ណ្ឌប្រភេទ "គ" (គ១)គឺជាឋាននន្តរសក្តិខ្ពស់បំផុតក្នុងក្របខ័ណ្ឌប្រភេទ "គ" ហៅថា «ឋាននន្តរសក្តិតាមការដំឡើង» ដែលសម្រាប់អនុវត្តចំពោះមន្ត្រីរាជការដែលមានស្នាដៃខ្ពស់។

ការដំឡើងត្រូវអនុវត្តចំពោះមន្ត្រីរាជការ ដែលបានឡើងដល់ថ្នាក់លេខ៧ នៃឋាននន្តរសក្តិទី២(គ២.៧) ឡើងទៅ តាមរយៈការចុះឈ្មោះក្នុងតារាងដំឡើងឋាននន្តរសក្តិការប្រឡងប្រជែងផ្ទៃក្នុង និងការបណ្តុះបណ្តាលរយៈពេលវែងនៅក្នុងនិងក្រៅប្រទេស[៥១]។

មន្ត្រីក្នុងឋាននន្តរសក្តិនេះ មានឧបនិស្ស័យកាន់មុខតំណែងរួមរបស់ក្របខ័ណ្ឌប្រភេទ "គ" និងនាយផ្នែករដ្ឋបាលនិងប្រតិបត្តិការប្រចាំថ្ងៃក្នុងពន្ធនាគារនិងមុខតំណែងផ្សេងទៀតដែលមានថ្នាក់ស្មើ។

ឈ្មោះក្នុងឋាននន្តរសក្តិទី១ នៃក្របខ័ណ្ឌប្រភេទ "គ" ប្រែប្រួលទៅតាមប្រភេទក្របខ័ណ្ឌដែលមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗមាន «នាយលេខាធិការរដ្ឋបាល» សម្រាប់ក្របខ័ណ្ឌលេខាធិការរដ្ឋបាលនិងក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ «គ្រូបង្រៀនកម្រិតបឋមដើមខ្សែពិសេស» សម្រាប់ក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម «មន្ត្រីបច្ចេកទេសបឋមដើមខ្សែពិសេស» សម្រាប់ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសបឋម «នាយអនុរក្ស» សម្រាប់ក្របខ័ណ្ឌអនុរក្សពន្ធនាគារក្រសួងមហាផ្ទៃនិង «មន្ត្រីសុខាភិបាលបឋមដើមខ្សែពិសេស» សម្រាប់ក្របខ័ណ្ឌមន្ត្រីសុខាភិបាលបឋមឋាននន្តរសក្តិក្របខ័ណ្ឌប្រភេទ"ឃ"[៥២]។

ក្របខ័ណ្ឌប្រភេទ "ឃ" ត្រូវបែងចែកជា ៣ឋាននន្តរស័ក្តិ ដែលរៀបតាមលំដាប់លំដោយពីតូចទៅធំដូចខាងក្រោម៖

---

[៤៨] មាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/១០៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល។

[៤៩] មាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/៦៥០០/០៩៧ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌអនុរក្សពន្ធនាគារក្រសួងមហាផ្ទៃ។

[៥០] លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗរបស់មន្ត្រីរាជការស៊ីវិល។

[៥១] មាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/១០៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល។

[៥២] លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗរបស់មន្ត្រីរាជការស៊ីវិល។

ឋានន្តរសក្តិទី៣នៃក្របខ័ណ្ឌប្រភេទ "**ឃ៣**" ជាឋានន្តរស័ក្តិទាបបំផុតនៃក្របខ័ណ្ឌប្រភេទ "**ឃ**" ហៅថា «ឋានន្តរសក្តិតាមការជ្រើសរើស» ហើយចំពោះមន្ត្រីដែលត្រូវបញ្ចូលក្នុងឋានន្តរសក្តិនេះធ្វើឡើងតាមរយៈការប្រឡងប្រជែងចំពោះបេក្ខជនដែលមានអាយុយ៉ាងច្រើន២៥ឆ្នាំ។ ក្នុងឋានន្តរសក្តិនេះមិនមានចែងពីឧបនិស្ស័យកាន់មុខតំណែងរបស់មន្ត្រីក្របខ័ណ្ឌ "**ឃ**" នេះឡើយព្រោះមន្ត្រីនេះជាអ្នកប្រតិបត្តិដែលគ្មានជំនាញ។ នៅពេលអនាគតមន្ត្រីប្រភេទនេះនឹងក្លាយជាមន្ត្រីជាប់កិច្ចសន្យា។ អង្គខ្លះមិនមានក្របខ័ណ្ឌប្រភេទ«**ឃ**»នេះទេ[៥៣]។

ឈ្មោះក្នុងឋានន្តរសក្តិទី៣នេះ ប្រែប្រួលទៅតាមប្រភេទក្របខ័ណ្ឌដែលមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗមាន «ភ្នាក់ងាររដ្ឋបាល» សម្រាប់ក្របខ័ណ្ឌមន្ត្រីភ្នាក់ងាររដ្ឋបាលនិងភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ និង «ភ្នាក់ងារបច្ចេកទេស» សម្រាប់ក្របខ័ណ្ឌមន្ត្រីភ្នាក់ងារបច្ចេកទេស[៥៤]។

ឋានន្តរសក្តិទី២នៃក្របខ័ណ្ឌប្រភេទ "**ឃ**"(**ឃ២**) ជា «ឋានន្តរសក្តិតាមការដំឡើង» ដែលសម្រាប់អនុវត្តចំពោះមន្ត្រីរាជការដែលមានស្នាដៃល្អ។ ការដំឡើងឋានន្តរស័ក្តិនេះត្រូវធ្វើចំពោះមន្ត្រីរាជការដែលបានឡើងដល់ថ្នាក់លេខ១១នៃឋានន្តរស័ក្តិទី៣(**ឃ**៣.១១) ឡើងទៅតាមរយៈការចុះឈ្មោះក្នុងតារាងដំឡើងឋានន្តរស័ក្តិនិងការប្រឡងប្រជែងផ្ទៃក្នុងដែលការដំឡើងឋានន្តរស័ក្តិនេះធ្វើឡើងដោយប្រកាស[៥៥]។

ឈ្មោះក្នុងឋានន្តរសក្តិទី២នៃក្របខ័ណ្ឌប្រភេទ "**ឃ**" នេះប្រែប្រួលតាមប្រភេទក្របខ័ណ្ឌដែលមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗមាន «ភ្នាក់ងាររដ្ឋបាលដើមខ្សែ» សម្រាប់ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលនិងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃនិង «ភ្នាក់ងារបច្ចេកទេសដើមខ្សែ» សម្រាប់ក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស។ ឋានន្តរសក្តិទី១ នៃក្របខ័ណ្ឌប្រភេទ "**ឃ**" (**ឃ១**) គឺជាឋានន្តរស័ក្តិខ្ពស់បំផុតនៃក្របខ័ណ្ឌប្រភេទ "**ឃ**" ហៅថា «ឋានន្តរសក្តិតាមការដំឡើង» ហើយការដំឡើងនេះត្រូវអនុវត្តចំពោះមន្ត្រីរាជការដែលបានឡើងដល់ថ្នាក់លេខ៧នៃឋាននរ្តសក្តិទី២(**ឃ**២.៧) តាមរយៈការចុះឈ្មោះក្នុងតារាងដំឡើងឋានន្តរសក្តិនិងការប្រឡងប្រជែងផ្ទៃក្នុង[៥៦]។

ឈ្មោះក្នុងឋានន្តរសក្តិនេះ ប្រែប្រួលទៅតាមប្រភេទក្របខ័ណ្ឌដែលមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗមាន «នាយភ្នាក់ងាររដ្ឋបាល» សម្រាប់ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល និងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃនិង «នាយភ្នាក់ងារបច្ចេកទេស» សម្រាប់ក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស។

---

[៥៣] មាត្រា ៥, ៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០០/១៣៥ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល។

[៥៤] លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗរបស់មន្ត្រីរាជការស៊ីវិល។

[៥៥] មាត្រា ១០, ១១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០០/១៣៥ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល។

[៥៦] មាត្រា ១០, ១១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០០/១៣៥ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល។

# ទស្សនៈនានាស្តីពីច្បាប់និងប្រព័ន្ធច្បាប់

**សមណបេក្ខបណ្ឌិត សុខ ម៉ុនធឿន**
**ផ្នែកនីតិសាស្ត្រ**



## សេចក្តីផ្តើម

កាលណាបើនិយាយពីច្បាប់ ក៏គប្បីនិយាយពីរដ្ឋផងដែរ។ ច្បាប់និងរដ្ឋមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជាទីបំផុត។ នៅក្នុងរដ្ឋមួយមានប្រជាជនជាក់លាក់ ដែនដីជាក់លាក់ រដ្ឋាភិបាលនិងសមត្ថភាពរបស់រដ្ឋាភិបាលក្នុងទំនាក់ទំនងអន្តរជាតិ។

ដើម្បីឱ្យរដ្ឋមួយប្រព្រឹត្តទៅប្រកបដោយភាពសុខសាន្ត រដ្ឋនោះត្រូវតែមានច្បាប់ឬប្រព័ន្ធច្បាប់សម្រាប់គ្រប់គ្រង។

រដ្ឋមានស្ថាប័នបង្កើតច្បាប់និងស្ថាប័នអនុវត្តច្បាប់ ចំណែកឯច្បាប់វិញបំពេញតួនាទីរបស់ខ្លួនក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គមនិងសុខដុមនីយកម្មនៅក្នុងរដ្ឋ។ តាមរយៈការបង្កើតច្បាប់ រដ្ឋត្រូវ៖

-មានកាតព្វកិច្ចធ្វើយ៉ាងណាឱ្យពលរដ្ឋអនុវត្តសិទ្ធិស្របតាមច្បាប់

-សម្របសម្រួលរវាងមនុស្សនៅក្នុងសង្គមឱ្យដើរតាមច្បាប់

-មានតួនាទីធ្វើជាអាបិ៊ត( referee )របស់ប្រជាពលរដ្ឋ។

ហេតុនេះ ច្បាប់មានតួនាទីយ៉ាងសំខាន់គឺធានានិរន្តរភាពនៃការប្រព្រឹត្តរបស់រដ្ឋឬស្ថាប័នរបស់រដ្ឋឱ្យប្រព្រឹត្តទៅប្រកបដោយភាពសុខសាន្តនិងផលប្រយោជន៍រួម។

## ១- ទ្រឹស្តីច្បាប់និងប្រព័ន្ធច្បាប់

ច្បាប់និងប្រព័ន្ធច្បាប់ត្រូវកំណត់នូវនិយមន័យដូចខាងក្រោមនេះ៖

តាមន័យចង្អៀត ច្បាប់គឺជាវិធាននៃអំពើណាមួយឬបទដ្ឋាននៃអំពើដែលអាចអនុវត្តបាននូវរាល់កម្មវត្ថុនៃការបង្កើតទាំងឡាយ[៥៧]។

តាមន័យទូលាយ ច្បាប់គឺជាបញ្ញត្តិនៃហេតុផលដែលបានប្រកាសដោយអាជ្ញាធរដែលបានតែងតាំងមានលក្ខណៈត្រឹមត្រូវសម្រាប់ផលប្រយោជន៍រួម។

តាមន័យជាក់លាក់ ច្បាប់គឺជាវិធាននៃការប្រព្រឹត្តប្រកបដោយភាពយុត្តិធម៌ ជាកាតព្វកិច្ច ហើយត្រូវប្រកាសផ្សព្វផ្សាយដោយអាជ្ញាធរស្របច្បាប់និងត្រូវគោរពនិងទទួលផលប្រយោជន៍រួម[៥៨]។

ច្បាប់ ជាអង្គច្បាប់ដែលចេញផ្សាយជាផ្លូវការដោយអាជ្ញាធរកាន់អំណាចនិងអនុវត្តដោយតុលាការ។ ច្បាប់មានតួនាទីសម្របសម្រួលទំនាក់ទំនងខាងក្រៅរវាងមនុស្សនឹងមនុស្ស[៥៩]។ ច្បាប់បានបង្កើតឡើងដោយអង្គការនីតិប្បញ្ញត្តិ។

---

[៥៧] Kong Phalack:*Introduction to Law*, Phnom Penh 2005,Page 1

[៥៨] Kong Phalack:*Introduction to Law*, ដ.ឯ.ម. ទំព័រ២។

[៥៩] ខ្លួត ធីតា *មូលដ្ឋានគ្រឹះនៃទស្សនវិជ្ជា* ភ្នំពេញ ព.ស.២៥៥២ គ.ស.២០០៨ ទំព័រ៧១។

ចំណែកឯ «ប្រព័ន្ធច្បាប់» ក្នុងន័យចង្អៀត គឺជាវិធាននីតិទាំងឡាយនិងស្ថាប័នទាំងឡាយរបស់ប្រទេសមួយសម្រាប់បង្កើតច្បាប់ បកស្រាយនិងអនុវត្តច្បាប់។ ក្នុងន័យទូលាយ ប្រព័ន្ធច្បាប់រួមបញ្ចូលផងដែរនូវប្រពៃណី ឬទស្សនវិជ្ជាច្បាប់មួយចំនួនព្រមទាំងនីតិវិធីទាំងឡាយ។

ច្បាប់និងប្រព័ន្ធច្បាប់បានកំណត់និយមន័យតាមវិស័យជាច្រើនក្នុងសង្គម។ វិស័យដែលផ្សារភ្ជាប់ក្នុងទ្រឹស្តីច្បាប់មានទ្រឹស្តីធម្មជាតិ ទ្រឹស្តីបទដ្ឋាន ទ្រឹស្តីចិត្តវិជ្ជា និងទ្រឹស្តីសង្គមសាស្ត្រ។

## ១.១- ទ្រឹស្តីធម្មជាតិ

ទ្រឹស្តីទាំងនេះជាប់ទាក់ទងនឹងទស្សនៈលោកដេម៉ូគ្រីដ(Democrites) សូក្រាត(Socrates) និងលោកប្លាតុង(Plato)។ អ្នកទាំងនេះបញ្ជាក់ថា មូលដ្ឋានសីលធម៌ យុត្តិធម៌មាននៅក្នុងច្បាប់ធម្មជាតិ។ ដើម្បីសម្រេចបំណងបាន លុះត្រាតែពលរដ្ឋខ្លួនឯង ប្រាថ្នាចង់រស់នៅប្រកបដោយយុត្តិធម៌។ ផ្អែកតាមទ្រឹស្តីច្បាប់ធម្មជាតិកើតឡើងពីៈ ១-គំនិតនៃសិទ្ធិពីកំណើត ២-សិទ្ធិពីកំណើតនិងសិទ្ធិវិជ្ជមានមានលក្ខណៈខុសគ្នា ៣-ការបង្រួមច្បាប់និងសីលធម៌ជាមួយគ្នាយ៉ាងស៊ីជម្រៅ។

ទ្រឹស្តីនេះបញ្ជាក់ពីការស្នើឡើងពីគំនិតចំពោះច្បាប់ អាចបង្កើតបានជាភាពយុត្តិធម៌ឬភាពអយុត្តិធម៌នៅក្នុងសកម្មភាពច្បាប់ពិតជាក់ស្តែង[៦០]។

## ១.២- ទ្រឹស្តីបទដ្ឋាន

ទ្រឹស្តីនេះបញ្ជាក់ថា ច្បាប់គឺជាបណ្តុំឬពហុភាពនៃបទដ្ឋានដែលស្តែងចេញមកខាងក្រៅនៅក្នុងច្បាប់និងលិខិតបទដ្ឋានផ្សេងៗទៀត។ ទ្រឹស្តីនេះបញ្ជាក់ថាៈ

ច្បាប់ជាប្រព័ន្ធបទដ្ឋានដែលមានចំណងទាក់ទងគ្នាទៅវិញទៅមកនឹងសកម្មភាព គំនិតក្នុងលិខិតបទដ្ឋាន។ បទដ្ឋាននៃច្បាប់បង្កើតឡើងដោយរដ្ឋ ហើយបទដ្ឋាននោះឆ្លុះបញ្ចាំងពីឆន្ទៈរបស់រដ្ឋដែលកំណត់ឡើងនៅក្នុងច្បាប់។ បទដ្ឋាននៃច្បាប់ធ្វើនិយតកម្មទំនាក់ទំនងសង្គមសំខាន់ៗ។

ច្បាប់ខ្លួនឯងនិងសមិទ្ធផលរបស់វា ផ្តត់ផ្គង់ឬធានារ៉ាប់រងដោយកម្លាំងបង្ខិតបង្ខំរបស់រដ្ឋក្នុងករណីចាំបាច់។ ច្បាប់និងមនសិការច្បាប់កើតឡើងអាស្រ័យបទដ្ឋាន[៦១]។

## ១.៣-ទ្រឹស្តីចិត្តវិជ្ជា

ច្បាប់ជាតថភាពនៃចិត្តសាស្ត្រ។ ទ្រឹស្តីចិត្តវិជ្ជាយកចិត្តទុកដាក់ទៅលើភាគីមួយក្នុងចំណោមភាគីសំខាន់ៗដទៃទៀតនៃប្រព័ន្ធច្បាប់។ ទ្រឹស្តីនេះមិនអាចរៀបចំនិងបង្កើតច្បាប់ផ្សេងៗ ដោយមិនបានសិក្សាអំពីកម្រិតនៃវប្បធម៌និងមនសិការច្បាប់នៅក្នុងសង្គមនោះបានទេ និងមិនអាចអនុម័តច្បាប់ផ្សេងៗ ដោយមិនសិក្សាអំពីលក្ខណៈនៃចិត្តសាស្ត្ររបស់បុគ្គលបានដែរ។ វាមានលក្ខណៈមិនគ្រប់គ្រាន់ មិនច្បាស់លាស់ ខ្វះតថភាពសត្យានុម័តនិងខ្វះលទ្ធភាពរៀបចំរចនាសម្ព័ន្ធរៀបចំច្បាប់ក្នុងក្របខ័ណ្ឌរបស់ខ្លួនធ្វើឱ្យច្បាប់មានលក្ខណៈខុសពីបាតុភូតនិយតភាពសង្គមផ្សេងទៀត[៦២]។

---

[៦០] អិម វិបុល, អ៊ុម សុផាន *ទ្រឹស្តីរដ្ឋនិងនីតិ* ភ្នំពេញ ២០០៨ ទំព័រ៣-៤។

[៦១] -ដ-។

[៦២] -ដ-។

### ១.៤- ទ្រឹស្តីសង្គមសាស្ត្រ

ទ្រឹស្តីនេះបញ្ជាក់ថា «ច្បាប់» មាននៅក្នុងជីវភាពឬជីវិតពិត មិនមែនស្ថិតនៅក្នុងបទដ្ឋាននិងស្មារតីទេ។ អ្វីៗត្រូវការពារដោយរដ្ឋ។ សញ្ញាណសម្គាល់របស់ច្បាប់ គឺជារបៀបរៀបរយនៅក្នុងទំនាក់ទំនងសង្គមក្នុងសកម្មភាពរបស់ពលរដ្ឋ។ ស្ថាប័នតុលាការឬស្ថាប័នរដ្ឋបាល តម្រូវឱ្យដោះស្រាយវិវាទស្ថានការណ៍ក្នុងសង្គមឬស្ថាប័នជាក់លាក់ដទៃទៀត ដែលបង្ហាញឱ្យឃើញច្បាស់អំពីខ្លឹមសារនៃសណ្តាប់ធ្នាប់ របៀបរៀបរយក្នុងសង្គមនោះ[៦៣]។ ទ្រឹស្តីសង្គមសាស្ត្របញ្ជាក់ថា៖

- ច្បាប់និងសង្គម ជាបាតុភូតរួមនិងមានទំនាក់ទំនងគ្នាទៅវិញទៅមក

-ការសិក្សាចាំបាច់មិនត្រឹមតែបទដ្ឋាននៃច្បាប់ដែលកំណត់ដោយរដ្ឋទេ ថែមទាំងសិក្សាទៅលើពហុភាពទាំងអស់នៃទំនាក់ទំនងច្បាប់ដែលមានក្នុងសង្គម។

## ២- ប្រភេទច្បាប់

ច្បាប់ដែលគ្រប់គ្រងសង្គមមនុស្សលើលោកនេះមានបីគឺ ១-ច្បាប់ធម្មជាតិ(Loi naturale) ២-ច្បាប់វិជ្ជមាន (Loi civile ou droit positif) ៣-ច្បាប់ប្រជាជាតិ(Loi gentium)។

### ២.១- ច្បាប់ធម្មជាតិ

ច្បាប់នេះមកពីពាក្យឡាតាំង «lex naturalis» គឺជាប្រព័ន្ធច្បាប់ត្រូវកំណត់ដោយធម្មជាតិ សំដៅដល់ការប្រើប្រាស់ហេតុផល ដើម្បីវិភាគនូវធម្មជាតិរបស់មនុស្សនិងស្រាវជ្រាវរកហេតុផលនៃចំណងវិធានឥរិយាបថសីលធម៌។ អ្នកច្បាប់មួយចំនួនប្រើប្រាស់ច្បាប់ធម្មជាតិស្មើនឹងយុត្តិធម៌ពីធម្មជាតិឬសិទ្ធិពីធម្មជាតិ។ ច្បាប់ធម្មជាតិនេះចែកចេញជាបីប្រភេទគឺ៖

**ក- នីតិរូបធាតុនិយម**(Physical Law) ក្នុងការអនុវត្តជាក់ស្តែងមានឯកភាពគ្នាទៅនឹងអំពើនិងនិយាមផលនៃអំពើ។ ការធ្វើឱ្យមានឯកភាពគ្នានិងនិយាមទាំងនេះ មានលក្ខណៈថេរដែលអាស្រ័យជាមួយនឹងទំនុកចិត្តនិងជំនឿ។ ទាំងនេះបានស្គាល់ថាជាច្បាប់រូបធាតុឬច្បាប់នៃវិទ្យាសាស្ត្ររូបធាតុ។ ចំពោះចំណាត់ថ្នាក់នេះបានគេហៅថាច្បាប់នៃទំនាញផែនដីនិងច្បាប់នៃល្បាយផែនដី។ វាប្រាកដណាស់និយាមមួយចំនួនក្នុងធម្មជាតិ ផលគឺអាស្រ័យលើហេតុរបស់វា។

**ខ- នីតិសីលធម៌**(Moral Law) គឺជាចំនួនសរុបនៃបទដ្ឋានសង្គមដែលគ្រប់គ្រងសកម្មភាពរបស់មនុស្សដែលកើតចេញពីមនសិការរួមឬមនសិការសាធារណៈចំពោះអ្វីដែលខុសនិងត្រូវរបស់មនុស្ស។

**គ- នីតិអាទិទេព**(Divine Law) គឺជាប្រព័ន្ធនៃវិធានដែលបានដាក់ចុះដោយអាទិទេព ដើម្បីគ្រប់គ្រងកិច្ចប្រតិបត្តិការរបស់លោកជាតុហៅថានីតិអាទិទេព។ វិធានទាំងនេះស្របទៅតាមសេចក្តីបញ្ញានិងឆន្ទៈរបស់ព្រះអាទិទេព។ វាជាច្បាប់នៃជំនឿសាសនាដែលពាក់ព័ន្ធនឹងទស្សនាទានស្តីពីបុណ្យ បាប ការសង្គ្រោះ សេចក្តីស្លាប់ ជីវិតនិងទស្សនាទានលោកិយនិងអនន្តភាព។

### ២.២- ច្បាប់វិជ្ជមាន

នីតិវិជ្ជមានត្រូវគេហៅថាជា មនុស្សនីតិ[៦៤](Human Law)។ នីតិនេះមានវិធាននៃការបង្គាប់បញ្ជាបានប្រកាសដោយអាជ្ញាធរមានសមត្ថកិច្ចដែលគ្រប់គ្រងទំនាក់ទំនងរបស់មនុស្ស។ ក្នុងន័យជាក់លាក់ ច្បាប់វិជ្ជមាន

---

[៦៣] អិម វិបុល, អ៊ុម សុផាន ***ទ្រឹស្តីរដ្ឋនិងនីតិ*** ដ.ឯ.ម.។

[៦៤] ច្បាប់ដែលបង្កើតដោយមនុស្ស។

គឺបញ្ញត្តិដែលបង្កើតឡើងដោយអង្គនីតិប្បញ្ញត្តិរបស់រដ្ឋ។ ច្បាប់នេះ មនុស្សត្រូវតែគោរពឧត្តមគតិយុត្តិធម៌ទើបទុកជាត្រឹមត្រូវ។ អង្គនីតិប្បញ្ញត្តិរបស់រដ្ឋជាអ្នកមានសិទ្ធិធ្វើនីតិកម្មលើច្បាប់ទាំងឡាយដូចជានីតិព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌ នីតិរដ្ឋប្បវេណី នីតិវិធីរដ្ឋប្បវេណី នីតិការងារនីតិសាធារណៈជាដើម។ នីតិវិជ្ជមាន បានបង្កើតជាពីរថ្នាក់សំខាន់ស្របទៅតាមទំហំនៃនីតិ គឺនីតិសាធារណៈឬនីតិទូទៅ និងនីតិឯកជន។

**ក- នីតិសាធារណៈ**(Public Law) ពាក់ព័ន្ធទៅនឹងតួនាទីរបស់រដ្ឋនិងដំណោះស្រាយការងាររបស់រដ្ឋ។ នីតិសាធារណៈ គ្រប់គ្រងការប្រព្រឹត្តទៅរបស់រដ្ឋនិងទំនាក់ទំនងរវាងរដ្ឋនឹងពលរដ្ឋមានដូចជា៖

**នីតិព្រហ្មទណ្ឌ** គឺជាផ្នែកមួយនៃនីតិសាធារណៈ។ ច្បាប់នេះគ្រប់គ្រងនិងធានានូវអំណាចបង្ខំរបស់ច្បាប់ដែលត្រូវតែគោរព។ វាបង្ការការគ្រោះថ្នាក់ដល់សង្គមដោយការប្រកាសនូវអ្វីដែលជាបទល្មើសព្រហ្មទណ្ឌ ដាក់ទណ្ឌកម្មសម្រាប់បទល្មើសនោះនិងកំណត់នូវនីតិវិធីដែលបទល្មើសនោះគួរស៊ើបអង្កេត កាត់ទោស វិនិច្ឆ័យទោស និងផ្តន្ទាទោស។

**នីតិរដ្ឋបាល** ក៏ជាផ្នែកមួយនៃនីតិសាធារណៈផងដែរ។ នីតិរដ្ឋបាលទាក់ទងទៅនឹងការអនុវត្តនូវអំណាច និងបុព្វសិទ្ធិរបស់នីតិប្រតិបត្តិ។

**ខ- នីតិឯកជន**(Private Law) គ្រប់គ្រងទំនាក់ទំនងនៃសមាជិករបស់សង្គមនិងទំនាក់ទំនងរវាងបុគ្គលនឹងបុគ្គល ដើម្បីធានាការប្រព្រឹត្តទៅរបស់សង្គមឱ្យមានភាពរលូនមានដូចជា**ច្បាប់ពាណិជ្ជកម្មច្បាប់ស្តីពីការងារ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ។**

ច្បាប់វិជ្ជមានអាចបានបែងចែកជាច្បាប់សារជាតុនិងច្បាប់នីតិវិធី។ ច្បាប់សារជាតុសំដៅដល់អង្គនៃវិធានទាំងឡាយដែលកំណត់នូវសិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលនិងសមូហភាព។ ច្បាប់នីតិវិធីគឺជាអង្គនៃវិធាននីតិទាំងឡាយដែលគ្រប់គ្រងនូវដំណើរសម្រាប់ការកំណត់នូវសិទ្ធិរបស់ភាគី។

ច្បាប់វិជ្ជមានអាចបានបែងចែកជាច្បាប់នៃបទបញ្ជាផង និងជាច្បាប់នៃសេចក្តីអនុញ្ញាតផង។ ច្បាប់នៃបទបញ្ជាគឺជាច្បាប់ត្រូវតែប្រតិបត្តិតាមពីព្រោះច្បាប់ទាំងនោះគឺជាបញ្ញត្តិនៃគោលនយោបាយសាធារណៈ ហើយការមិនគោរពត្រូវទទួលរងទណ្ឌកម្ម ផ្តន្ទាទោសឬក៏ពិន័យជាដើម។ ច្បាប់នៃសេចក្តីអនុញ្ញាតគឺជាច្បាប់ដែលអាចត្រូវវេ(ងាក)ចេញពីទណ្ឌកម្ម។

## ២.៣-ច្បាប់ប្រជាជាតិ

ច្បាប់ប្រជាជាតិបានសំដៅដល់ច្បាប់អន្តរជាតិ[៦៥]។ ច្បាប់នេះសំដៅដល់វិធាននិងបទដ្ឋានដែលគ្រប់គ្រងការប្រព្រឹត្តរបស់រដ្ឋនិងអង្គភាពដែលបានទទួលស្គាល់ជាបុគ្គលិកលក្ខណៈអន្តរជាតិក្នុងកិច្ចទំនាក់ទំនងគ្នាទៅវិញទៅមក[៦៦]។ ច្បាប់អន្តរជាតិចែកចេញជាពីរប្រភេទគឺ៖

- **ច្បាប់អន្តរជាតិសាធារណៈ** សម្រាមប់ទំនាក់ទំនងរដ្ឋនិងរដ្ឋផ្សេងៗដទៃទៀត
- **ច្បាប់អន្តរជាតិឯកជន** សម្រាប់គ្រប់គ្រងទំនាក់ទំនងឯកជន ដែលមានជនជាតិបរទេសនិងជនជាតិនៃប្រទេស។

---

[៦៥] សាយ បូរី ***នីតិរដ្ឋបាលទូទៅ*** បួស្ស៊ំ ឡូទឹស ២០០២ ទំព័រ៩។

[៦៦] Rebecca M.M. Wallace: ***International Law,*** Georgetown University Law Center, 2002 p.1

## ៣- ប្រព័ន្ធច្បាប់

ប្រព័ន្ធច្បាប់នីមួយៗផ្អែកលើបវេណីច្បាប់។ ប្រព័ន្ធច្បាប់ដែលមានឥទ្ធិពលលើប្រព័ន្ធច្បាប់មាន៤ប្រភេទសំខាន់គឺប្រព័ន្ធច្បាប់ស៊ីវិលឡ(Civil Law) ប្រព័ន្ធច្បាប់ខាំមិនឡ(Common Law) ប្រព័ន្ធច្បាប់សង្គមនិយម (Socialist Law) និងប្រព័ន្ធច្បាប់សាសនា(Religous Law)។

### ៣.១- ប្រព័ន្ធច្បាប់ស៊ីវិលឡ

ច្បាប់នេះគេបានស្គាល់ថាជាច្បាប់ឧបទ្វីបអឺរ៉ុប។ ប្រភពស្នូលនៃច្បាប់នេះត្រូវគេទទួលស្គាល់ថា អំណាចគឺការប្រមូលជាក្រមឬច្បាប់តែមួយ(codifications) ក្នុងរដ្ឋធម្មនុញ្ញឬបញ្ញត្តិដែលអនុម័តដោយអង្គការនីតិប្បញ្ញត្តិ។

### ៣.២- ប្រព័ន្ធច្បាប់ខាំមិនឡ

ប្រព័ន្ធច្បាប់ខាំមិនឡគឺជាច្បាប់ដែលបង្កើតឡើងដោយចៅក្រម តាមរយៈសេចក្តីសម្រេចរបស់តុលាការ។ ប្រភេទនៃប្រព័ន្ធច្បាប់នេះផ្អែកលើសេចក្តីសម្រេចរបស់ចៅក្រម។ ប្រព័ន្ធច្បាប់នេះអាចសរសេរតាមច្បាប់ជាក់លាក់មួយចំនួននិងទណ្ឌកម្មនៃបទល្មើសព្រហ្មទណ្ឌមួយចំនួនដែលមានពីមុនមក។

### ៣.៣- ប្រព័ន្ធច្បាប់សង្គមនិយម

ប្រព័ន្ធច្បាប់នេះកើតចេញពីទ្រឹស្តីសង្គមនិយមនិងបានប្រតិស្ឋាននៅប្រទេសធំៗពីរគឺសហភាពសូវៀតនិងប្រទេសចិន។ គំនិតវិធាននីតិក្នុងប្រទេសទាំងពីរនេះមានលក្ខណៈវិវឌ្ឍខុសគ្នាទាំងផ្លូវនីតិសាស្ត្រនិងមនុស្សសាស្ត្រ។

នៅសូវៀត ច្បាប់នៅសម័យរាជាធិរាជ មានប្រភពចេញមកពីច្បាប់រ៉ូម៉ាំង។ វាជាកេរដំណែលដែលកើតចេញពីទំនាក់ទំនងរវាងអធិរាជរុស្ស៊ីនិងចក្រភពរ៉ូម៉ាំងខាងលិច។

ចំពោះប្រទេសចិនវិញជាប្រទេសដែលមានប្រជាជនច្រើនជាងគេលើពិភពលោក។ ប្រទេសចិនបានខិតខំប្រឹងប្រែងធ្វើខ្លួនឱ្យដូចបស្ចិមប្រទេសនិងតម្រង់ច្បាប់របស់ខ្លួនឱ្យដូចច្បាប់អឺរ៉ុបយ៉ាងហោចណាស់ក្នុងសកម្មភាពសេដ្ឋកិច្ច។ ប្រទេសចិនមិនសូវទុកចិត្តលើអ្នកច្បាប់ទេ មនុស្សមិនត្រូវយកសិទ្ធិមកអះអាងទេ ជនគ្រប់រូបមានកាតព្វកិច្ចផ្សះផ្សាដើម្បីប្រយោជន៍រួម។ ច្បាប់អាចជាឧបសគ្គក្នុងការដោះស្រាយបញ្ហានានានិងអាចបំផ្លាញផលប្រយោជន៍រួម។ គ្រប់ដំណោះស្រាយត្រូវឱ្យស្របទៅនឹងសមធម៌និងមនោសញ្ចេតនារបស់មនុស្ស។

### ៣.៤- ប្រព័ន្ធច្បាប់សាសនា

ច្បាប់សាសនាសំដៅដល់ធម្មវិន័យ ក្រមសីលធម៌ ច្បាប់សីលធម៌ឬអភិសមាចារ្យដែលបញ្ញត្តិឡើងដោយមេដឹកនាំសាសនា។ សង្គមខ្មែរបានទទួលគោរពព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនាតាំងពីយូរណាស់មកហើយ។ សាសនាទាំងនេះបានរួមវិភាគទានយ៉ាងច្រើនក្នុងវិស័យច្បាប់និងវិធានសម្រាប់គ្រប់គ្រងសង្គម។ រដ្ឋធម្មនុញ្ញខ្មែរតាំងពីឆ្នាំ១៩៤៧មក ដល់បច្ចុប្បន្នមានមាត្រាជាច្រើនឆ្លុះបញ្ចាំងនូវតម្លៃសីលធម៌របស់ព្រះពុទ្ធសាសនា។

## សន្និដ្ឋាន

សរុបមក ច្បាប់មានតួនាទីយ៉ាងសំខាន់ក្នុងការធានាការគោរពសិទ្ធិមនុស្សនិងផលប្រយោជន៍របស់រដ្ឋ។ ច្បាប់និងរដ្ឋអាស្រ័យគ្នាទៅវិញទៅមកមិនអាចផ្តាច់ចេញពីគ្នាបាន។ រដ្ឋនីមួយៗត្រូវតែមានច្បាប់និងប្រព័ន្ធច្បាប់មួយឆ្លុះបញ្ចាំងនូវតម្លៃយុត្តិធម៌ សេដ្ឋកិច្ច សីលធម៌ សង្គមកិច្ចនិងវប្បធម៌សង្គមដើម្បីធានានូវនិរន្តរភាពនៃតួនាទីរបស់របស់រដ្ឋ។

ហេតុនេះដើម្បីឱ្យរដ្ឋមួយក្លាយទៅជានីតិរដ្ឋបាន រដ្ឋនោះត្រូវមានការបង្កើតច្បាប់(សភា) ការអនុវត្តច្បាប់ (រដ្ឋាភិបាល) ការត្រួតពិនិត្យការអនុវត្តច្បាប់(តុលាការ) និងការផ្សព្វផ្សាយច្បាប់។

# គន្ថនិទ្ទេស


១- ខ្លួត ធីតា *មូលដ្ឋានគ្រឹះទស្សនវិជ្ជា*បោះពុម្ពលើកទី៧ ឆ្នាំ២០០៨

២- សាយ បូរី *នីតិរដ្ឋបាលទូទៅ* ប្លុស្ស៊ំ ឡូទឹស ២០០២

៣- អិម វិបុល, អ៊ុម សុផាន *ទ្រឹស្តីរដ្ឋ និងនីតិ* ភ្នំពេញ ២០០៨

៤- Kong Phalack: *Introduction to Law*, Phnom Penh 2005

៥ -Rebecca M.M. Wallace: International Law, Georgetown University Law Center, 2002

# ទំនាក់ទំនងផ្នែកនយោបាយរវាងកម្ពុជា-ចិន


## បេក្ខជនបណ្ឌិត ម៉ុន ធឿន
## ផ្នែកវិទ្យាសាស្ត្រនយោបាយ


ការផ្លាស់ប្តូរសង្គមនិងរបៀបរស់នៅនាំឱ្យមនុស្សចាំបាច់ត្រូវតែប្រាស្រ័យទាក់ទងគ្នា។ ទំនាក់ទំនងគ្នានេះបានធ្វើឱ្យពិភពលោកកាន់តែរួញតូចនៅត្រឹមតែភូមិមួយ ដោយស្តែងចេញតាមការផ្លាស់ប្តូរខាងសេដ្ឋកិច្ចវប្បធម៌ បច្ចេកទេសជាពិសេសទំនាក់ទំនងអន្តរជាតិខាងនយោបាយនិងការទូត។ ប៉ុន្តែដោយមហាអំណាចប្រទាញប្រទេសទន់ខ្សោយឱ្យដើរតាមមនោគមវិជ្ជារបស់ខ្លួន បានធ្វើឱ្យពិភពលោកចែកទៅជាពីរចំណែកមានលោកសេរីនិងលោកកុម្មុយនិស្ត។ ការដណ្តើមឧត្តមភាពនេះបណ្តាលឱ្យប្រទេសមួយចំនួននៅលើពិភពលោកធ្លាក់ចូលទៅក្នុងសង្គ្រាម និងត្រូវបែងចែកជានិន្នាការប្រឆាំងគ្នាឯង។បញ្ហានេះធ្វើឱ្យប្រទេសមួយចំនួននៅទ្វីបអាស៊ី ទ្វីបអឺរ៉ុប និងអាម៉េរិកឡាទីនបាននាំគ្នាបង្កើតជាមនោគមថ្មីមួយតាមបែបអព្យាក្រឹត។

ស្របពេលជាមួយនោះប្រទេសចិនបានចេញមុខជាមេដឹកនាំអព្យាក្រឹតនៅក្នុងទ្វីបអាស៊ី។ ដោយមើលឃើញពីនយោបាយបែបនេះប្រទេសកម្ពុជាបានចងមេត្រីភាពជាថ្មីឡើងវិញជាមួយប្រទេសចិន។

តើកត្តាអ្វីដែលបានជំរុញឱ្យកម្ពុជាចាប់យកប្រទេសចិន ដែលជាប្រទេសកុម្មុយនីស្តទី១នៅអាស៊ី ធ្វើជាដៃគូទំនាក់ទំនងទៅវិញ? តើការធ្វើទំនាក់ទំនងនេះ ប្រទេសកម្ពុជាទទួលបានផលអ្វី?

## ១- ប្រវត្តិទំនាក់ទំនងប្រទេសកម្ពុជា-ចិន

ប្រវត្តិសាស្ត្របង្ហាញថាប្រទេសខ្មែរ-ចិនបានចងមេត្រីភាពនឹងគ្នាតាមរយៈជំនួញ បន្លាស់ប្តូរនៃជនជាតិនិងទំនាក់ទំនងការទូត។ ការធ្វើទំនាក់ទំនងជាមេត្រីនេះចាប់ផ្តើមតាំងពីគ.ស.២៤៣ម្ល៉េះ[៦៧]។ ការចងមេត្រីគ្នានេះបានប្រព្រឹត្តិទៅចំនួន១១លើករួចមកហើយមកទល់នឹងពេលនេះ[៦៨]។ ចំណងមេត្រីភាពនៃប្រទេសទាំងពីរបានពង្រីកគ្រប់ផ្នែកមានវប្បធម៌ នយោបាយ សេដ្ឋកិច្ចនិងការផ្តល់ជាជំនួយ។ បន្ទាប់ពីសន្និសីទទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ ប្រទេសកម្ពុជាបានក្លាយជារដ្ឋអព្យាក្រឹត។ សន្និសីទទីក្រុងហ្សឺណែវបានស្នើឱ្យវៀតណាមទាំងពីររួបរួមគ្នាតាមរយៈការបោះឆ្នោតដោយសេរី ប៉ុន្តែនៅពេលនោះវៀតណាមខាងជើងបានបដិសេធ។ បន្ទាប់មកលោក ហូ ជីមិញ បានដឹកនាំកងទ័ពវៀតមិញវាយលុកវៀតណាមខាងត្បូង។ បន្ទាប់ពីពេលនោះមក លោក ហូ ជីមិញ ចាប់ផ្តើមពង្រឹងបក្សកុម្មុយនីស្តតាមប្រទេសនីមួយៗមានកម្ពុជា ឡាវ ហើយបក្សកុម្មុយនីសខ្មែរក៏ចាប់ផ្តើមធ្វើចលនាដែលមានអាចារ្យមៀននិងលោក ទូ សាមុត ជាមេចលនា។ បញ្ញវន្តខ្មែរមួយចំនួនមានដូចជាលោក ហ៊ូ នឹម លោក ហ៊ូ យន់ បានងាកទៅរកនិន្នាការកុម្មុយនីស្តចិននិងមួយចំនួនទៀតងាកទៅវៀតណាម។ ការីករាលដាលនៃកុម្មុនីស្តនិងការរំលោភទឹកដីពីសម្ព័ន្ធមិត្តរបស់អាម៉េរិកបាននាំឱ្យកម្ពុជារកអ្នកការពារខ្លួន។ ស្របពេលជាមួយគ្នានេះប្រទេសចិនបានគាំទ្រកម្ពុជាបដិសេធសំណើរបស់លោក ផាំ វ៉ាន់ដុង ក្នុងការស្នើសុំបញ្ចូលខ្មែរវៀតមិញជាតំណាងស្របច្បាប់ក្នុងសន្និសីទទីក្រុងហ្សឺណែវ។ ម្យ៉ាងទៀតមានការទទួលស្គាល់អព្យាក្រឹតរបស់ប្រទេសកម្ពុជាពីសំណាក់ប្រទេសចិន។ នៅខែមេសាឆ្នាំ១៩៥៥ ក្នុងសន្និសីទនៅបាន់ឌុងកម្ពុជាបានបញ្ជាក់ជំហររបស់ខ្លួនថា

---

[៦៧] សម ញាណ៖ *"ព្រះរាជដំណើរព្រះបាទសម្តេចព្រះនរោត្តមសីហនុស្តេចយាងទៅកាន់ប្រទេសចិនសាធារណរដ្ឋប្រជាមានិត១៩៥៦"* ទំព័រ១៩-២០។

[៦៨] -ដ-ទំព័រទី២៤-៣២។

កម្ពុជានឹងមិនមានមូលដ្ឋានទ័ពអាម៉េរិកាំងនិងមិនសុំឱ្យសេអាតូការពារទេ។ ស្របពេលជាមួយគ្នានោះដែរកម្ពុជាក៏បានទទួលស្គាល់ឯករាជ្យរបស់ប្រទេសចិន។ នៅឆ្នាំ១៩៥៦ ក្នុងព្រះរាជទស្សនកិច្ចជាផ្លូវការលើកទីមួយនៅប្រទេសចិនសម្តេចព្រះ នរោត្តម សីហនុ បានប្រកាសទាត់ចោលកិច្ចការពារសេអាតូម្តងទៀត។ ចាប់តាំងពីពេលនោះមក ចំណងមិត្តភាពនៃប្រទេសទាំងពីរចេះតែចម្រើនឡើងជាលំដាប់រហូតបង្កើតជាស្ថានទូត រហូតមកដល់សព្វថ្ងៃនេះ។

## ២- ទំនាក់ទំនងផ្នែកនយោបាយរវាងកម្ពុជា-ចិនពីឆ្នាំ១៩៥៨-១៩៩១

តាមរយៈការគាំទ្ររបស់ប្រទេសចិនចំពោះកម្ពុជានៅឆ្នាំ១៩៥៤និងឆ្នាំ១៩៥៥បានជំរុញឱ្យប្រទេសកម្ពុជាប្រកាន់យកនយោបាយអព្យាក្រឹត ព្រមទាំងបានបង្ខិតប្រទេសចិននិងខ្មែរឱ្យជិតគ្នា។ តាមរយៈទំនាក់ទំនងនេះ ប្រទេសចិនបានការពារប្រទេសកម្ពុជា[៦៩]។ តាមរយៈការគាំទ្រគ្នាទៅវិញទៅមកប្រទេសទាំងពីរក៏បានចងសម្ព័ន្ធមិត្តតាមផ្លូវទូតនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៥៨។ ការគាំទ្រនិងការផ្តល់ជំនួយបានធ្វើឱ្យប្រទេសទាំងពីរមានទំនាក់ទំនងកាន់តែជិតស្និទ្ធ ភាពល្អកល្អើននេះក៏បានបង្កើតជាអរិភាពជាមួយអាម៉េរិកនិងប្រទេសថៃ។ ប្រទេសទាំងនេះបានគាំទ្រដល់ចលនាប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជា ដូចជាប្រទេសថៃបានជួយសម្រួលក្នុងការផ្សាយរបស់វិទ្យុខ្មែរសេរីដល់ក្រុមប្រឆាំងដែលដឹកនាំដោយលោក សឺង ង៉ុកថាញ់ ចេញពីប្រទេសថៃ។ ចំណែកឯសហរដ្ឋអាម៉េរិកនិងក្រុមភ្នាក់ងារសម្ងាត់(C.I.A)របស់ខ្លួនវិញបានគាំទ្រដល់លោក សម សារី និងក្រុមប្រឆាំងនៅក្នុងស្រុក។ នៅឆ្នាំ១៩៥៩រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា-ចិនបានធ្វើសេចក្តីថ្លែងការណ៍ស្តីពីសកម្មភាពរបស់ក្រុមប្រឆាំងនឹងកម្ពុជា។ នៅក្នុងដំណាក់កាលនោះ យើងឃើញថាប្រទេសចិននិងកម្ពុជាបានបង្ហាញពីគោលនយោបាយទៅវិញទៅមកក្នុងបំណងគាំទ្រគ្នា។ ឆ្លើយតបនឹងនយោបាយចិនដែលគាំទ្រដោយឥតលក្ខខណ្ឌនិងមិនជ្រៀតជ្រែកកម្ពុជា កម្ពុជាបានដើរតាមនយោបាយការបរទេសរបស់ចិន។ នៅខែតុលាឆ្នាំ១៩៦៣ ប្រទេសកម្ពុជាសម្រេចចិត្តនៅអ.ស.ប. ដេញតៃវ៉ាន់ចេញពីតំណាងអ.ស.ប. និងទទួលចិនប្រជាមានិតជំនួសវិញ។ នៅខែតុលាឆ្នាំ១៩៦៤ ពេលដែលប្រទេសចិនពិសោធគ្រាប់បែកបរមាណូទីមួយរបស់ខ្លួនសម្តេចព្រះ នរោត្តម សីហនុ បានផ្ញើសំបុត្រគាំទ្រចិន សម្តេចប្រើភាពជិតស្និទ្ធជាមួយចិននេះដើម្បីកម្ចាត់ពួកកុម្មុយនីស្តនៅក្នុងប្រទេសដែលកំពុងតែកើនឡើង។ ប៉ុន្តែការដែលប្រទេសចិនគិតពីទំនាក់ទំនងការទូត ដោយសារតែប្រទេសចិនចង់បានសន្តិភាពបរិបូណ៌។ដូច្នេះប្រទេសចិនត្រូវតែធ្វើទំនាក់ទំនងល្អជាមួយរដ្ឋទាំងអស់ ដែលមាននយោបាយផ្សេងៗ គ្នានិងស្មើទៅពួកគេដើម្បីចរចាជាមួយរដ្ឋទាំងនោះម្តងមួយៗ។ គោលនយោបាយនេះបានធ្វើឱ្យកម្ពុជាទទួលបានការគាំទ្រទាំងផ្នែកនយោបាយនិងផ្នែកសេដ្ឋកិច្ច។ សម្ព័ន្ធមេត្រីភាពរវាងប្រទេសកម្ពុជាចិនបានធ្វើឱ្យចិនផ្តល់ជំនួយមកកម្ពុជាយ៉ាងច្រើន[៧០]។

នៅខែធ្នូ ឆ្នាំ១៩៦៣ ប្រទេសកម្ពុជានិងចិនបានចុះកិច្ចព្រមព្រៀងលើកទីមួយខាងជំនួយយោធា។ស្របពេលជាមួយគ្នានេះ ប្រទេសកម្ពុជាបានកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយវៀតណាមខាងត្បូងនិងឈប់ទទួលជំនួយរបស់អាម៉េរិក។ នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៦៥ កម្ពុជាបានផ្តាច់ចំណងទូតជាមួយសហរដ្ឋអាម៉េរិក។ ក្នុងខណៈដែលកតិកាសញ្ញាយោធាកម្ពុជា-ចិន បានប្រកាសឡើងនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៦៥។ តាមរយៈ

[៦៩] ចាន់ ដារា- អ៊ិត ចុងងួន- ប៉ែន នារី កម្ពុជានិងសហព័ន្ធឥណ្ឌូចិន ឆ្នាំ១៩៨៣ទំព័រទី១២៩។

[៧០] *សុន្ទរកថាឯកឧត្តម ផូ ព្រឿង អនុប្រធានឧត្តមក្រុមប្រឹក្សាព្រះរាជបល្ល័ង្កជាតំណាងដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះប្រមុខរដ្ឋថ្លែងក្នុងឱកាសបុណ្យប្រគល់ការស្តាបនាជាលើកទីពីរនៃរាជស្ថានីយ៍វិទ្យុផ្សាយសំឡេងប្រទេសកម្ពុជា* ថ្ងៃទី២១ មិថុនា១៩៦២។

សន្ធិសញ្ញានេះចាប់ពីឆ្នាំ១៩៦៥រហូតដល់ឆ្នាំ១៩៧៥ កំពង់ផែក្រុងព្រះសីហនុនិងខេត្តភាគខាងកើតនិងខាងត្បូងនៃប្រទេសកម្ពុជាត្រូវបានអនុញ្ញាតឱ្យប្រើដើម្បីផ្គត់ផ្គង់គ្រឿងសព្វាវុធគ្រាប់រំសេវស្បៀងអាហារដែលមកពីប្រទេសចិននិងជាមូលដ្ឋានសឹកដល់កងទ័ពវៀតណាមខាងជើង និងវៀតកុងក្នុងការប្រយុទ្ធជាមួយអាម៉េរិក[៧១]។ ប្រទេសចិនជាប្រទេសដែលរដ្ឋាភិបាលកម្ពុជាមានជំនឿទុកចិត្តទាំងស្រុងដើម្បីការពារបូរណភាពដែនដីរបស់ខ្លួន។ ការណ៍ដែលប្រទេសចិនអាចធ្វើបានក៏ដោយសារយុទ្ធសាស្ត្ររបស់សម្តេចព្រះ នរោត្តម សីហនុ បដិសេធនឹងវត្តមានរបស់សហរដ្ឋអាម៉េរិកនៅអាស៊ីអាគ្នេយ៍ ឬក៏ ក្នុងក្រសែភ្នែកពួកចិន អព្យាក្រឹតភាពមានន័យថាការគ្មានវត្តមានពួកអាម៉េរិកាំងនៅប្រទេសកម្ពុជា។ ម្យ៉ាងទៀតបន្ទាប់ពីរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រទេសចិនបានខិតខំប្រឹងប្រែងដើម្បីរិះរកកិច្ចសហប្រតិបត្តិការជាមួយលោក លន់ នល់ មុននឹងរៀបចំឱ្យមានសម្ព័ន្ធភាពមួយរវាងសម្តេចព្រះ នរោត្តម សីហនុ និងខ្មែរក្រហម។ ប៉ុន្តែការទាមទារទាំងឡាយរបស់ចិនបានត្រូវក្រុងភ្នំពេញបដិសេធចោល ទើបចិនងាកមកគាំទ្រសម្តេចព្រះនរោត្តម សីហនុឱ្យបង្កើតរដ្ឋាភិបាលក្រៅប្រទេសនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧០។ មូលហេតុចម្បងដែលនាំឱ្យប្រទេសចិនខិតខំខ្នះខ្នែងយ៉ាងប្រញាប់ប្រញាល់ដូច្នេះ ក៏ព្រោះតែប្រទេសវៀតណាមបានសន្យានឹងគោរពបូរណភាពដែនដីគោគ និងពិសេសព្រំដែនទឹករបស់ចិនតាំងពីឆ្នាំ១៩៥៨។ រីឯសម្តេចព្រះ នរោត្តម សីហនុ វិញទ្រង់ដើរតាមប្រទេសចិនក៏ដោយសារទ្រង់សង្ឃឹមថាមិត្តភាពជាមួយប្រទេសចិនអាចនឹងផ្តល់ការការពារដល់ប្រទេសរបស់ព្រះអង្គ ប្រឆាំងនឹងមហិច្ឆតារបស់វៀតណាមខាងជើង និងសម្ព័ន្ធមិត្តអាម៉េរិកបានផងដែរ។

ក្នុងការគាំទ្ររបស់ចិនចំពោះសម្តេចព្រះ នរោត្តម សីហនុ លោក ជូ អេនឡាយ មិនឱ្យព្រះអង្គបោះបង់ចលនាតស៊ូ ព្រោះថាប្រជារាស្ត្ររបស់ព្រះអង្គកំពុងវាយប្រយុទ្ធដើម្បីសម្តេចបើសិនជាព្រះអង្គធ្វើឱ្យអ្នកទាំងនោះដឹងថាព្រះអង្គនឹងចាកចេញពីឆាកនយោបាយបន្ទាប់ពីជ័យជម្នះនោះពួកគេនឹងបោះបង់ការប្រយុទ្ធ ហើយបាត់អស់សេចក្តីក្លាហាន ពេលនោះក្រុមរបស់លោក លន់ នល់ និងសហរដ្ឋអាម៉េរិកនឹងឈ្នះសង្គ្រាមមិនខាន។ សម្តេចបានឆ្លើយតបទៅមិត្តចិនថាខ្ញុំនឹងប្រឹងប្រែងទប់បំណងចាកចេញពីមុខងាររបស់ខ្ញុំ រហូតទាល់តែការតស៊ូរបស់យើងបានទទួលជោគជ័យ[៧២]។ ដូច្នេះ យើងឃើញថា ដោយសារការជួយឧបត្ថម្ភពីសំណាក់សាធារណរដ្ឋ-ប្រជាមានិតចិនគ្រប់ផ្នែកទាំងអស់មានតាំងពីជំនួយស្មារតី នយោបាយ សេដ្ឋកិច្ច និងជំនួយយោធាបានធ្វើឱ្យចលនាតស៊ូទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ភាពជោគជ័យនេះបានបង្ហាញនូវឱកាសមួយចំពោះប្រទេសចិនក្នុងការដាក់តួនាទីដឹកនាំរបស់ខ្លួនជាមួយចលនាបដិវត្តន៍ឥណ្ឌូចិន។ ប៉ុន្តែ មហិច្ឆតារបស់ប្រទេសចិន ត្រូវជួបនឹងការប្រជែងជាមួយវៀតណាមដោយហេតុថា ក្រុងហាណូយបានបែកចេញពីប្រទេសចិននិងងាកទៅរកក្រុងម៉ូស្គូបន្ទាប់ពីជ័យជម្នះនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥។ ដោយសារបញ្ហានេះ ទើបចាប់តាំងពីឆ្នាំ១៩៧៥ ប្រទេសចិនបានចេញមុខជួយឧបត្ថម្ភជាសាធារណៈដល់កម្ពុជាប្រជាធិបតេយ្យដោយមិនអាចដកចេញនូវការគាំទ្រចំពោះកម្ពុជាឡើយ។ ដោយហេតុថា សត្រូវចំពោះឯករាជ្យកម្ពុជាគឺប្រទេសវៀតណាមកំពុងស្ថិតក្រោមឥទ្ធិពលរបស់សត្រូវសំខាន់របស់ចិននិងបង្កើតឥទ្ធិពលនៃសត្រូវសំខាន់របស់ប្រទេសចិនគឺ សហភាពសូវៀត។ ដូច្នេះ ការបំបាត់ចោលនូវឯករាជ្យរបស់កម្ពុជា អាចនាំឱ្យបាត់នូវឥទ្ធិលរបស់ប្រទេសចិននិងបង្កើតឥទ្ធិពលនៃសត្រូវរបស់ចិននៅឥណ្ឌូចិន។ កត្តាដែលនាំឱ្យចិនគាំទ្រកម្ពុជាក្នុងសង្គ្រាមឥណ្ឌូចិនទី៣ក៏ដោយសារតែប្រទេសចិនមានជម្លោះទឹកដីជាមួយវៀតណាម ដែលឈានទៅដល់ការបញ្ចប់ជំនួយរបស់ចិនទាំងអស់ក្នុង

[៧១] William Shawcross, *SIDESHOW, Kissinger, Nixon and the destruction of cambodia*, P. 64, 1979, U.S.A.

[៧២] នរោត្តម សីហនុ អ្នកទោសខ្មែរក្រហម បកប្រែដោយលោក ទីឃាយុ ទំព័រទី៥។

ខែមិថុនា ឆ្នាំ១៩៧៨។ ស្របពេលដែលការធ្វើទំនាក់ទំនងរវាងវៀតណាមនឹងសហភាពសូវៀតបានបង្កើតឡើង ដែលជាការរួមគំនិតប្រឆាំងនឹងប្រទេសចិន។ នៅចុងខែធ្នូ ឆ្នាំ១៩៧៧ និងដើមខែមករា ឆ្នាំ១៩៧៨ ពេលដែលខ្មែរក្រហមត្រូវវៀតណាមវាយប្រហារ ប្រទេសចិនបានបញ្ជូនភរិយានៃលោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ គឺលោកជំទាវ តេង យីងជាវ មកកាន់ទីក្រុងភ្នំពេញ។ តាមរយៈដំណើរទស្សនកិច្ចនេះ ប្រទេសចិនមានបំណងចង់ឱ្យពិភពលោក ជាពិសេសប្រទេសវៀណាមដឹងថាខ្លួននឹងគាំទ្រកម្ពុជាប្រជាធិបតេយ្យរហូតដល់ចុងបំផុតនិងយល់ព្រមផ្តល់ជំនួយចាំបាច់សព្វបែបយ៉ាងទាំងអស់ដល់កម្ពុជា។

ដូច្នេះ យើងអាចសន្និដ្ឋានបានថាវិវាទរវាងប្រទេសចិននិងវៀតណាម បានកើតឡើងដោយសារតែវៀតណាមបានចូលបក្សសម្ព័ន្ធជាមួយនឹងសហភាពសូវៀតដែលជាសត្រូវសំខាន់របស់ចិន។

សង្គ្រាមឥណ្ឌូចិនទី៣បានធ្វើឱ្យប្រទេសចិនទទួលជោគជ័យយ៉ាងធំធេង។ ដំបូងប្រទេសចិនបានខាតបង់លើការចំណាយកម្លាំងមនុស្ស និងកិត្យានុភាពក្នុងការបរាជ័យនៃការវាយលុកឆ្នាំ១៩៧៩ ដើម្បីដាក់សម្ពាធឱ្យវៀតណាមចេញពីកម្ពុជា។ បន្ទាប់មក ប្រទេសចិនមានប្រៀបខាងយោធានិងនយោបាយក្នុងតំបន់ ហើយការបាត់បង់មនុស្សនិងនយោបាយចំពោះការលូកដៃចូលកម្ពុជាបានប៉ះពាល់ដល់ការលូតលាស់សេដ្ឋកិច្ចនិងនយោបាយតិចតួចប៉ុណ្ណោះ។ នៅខែមករាឆ្នាំ១៩៧៩ រដ្ឋាភិបាលចិនបានរិះគន់ការវាយលុករបស់វៀតណាមថា ជាជំហានសំខាន់របស់វៀតណាម ក្នុងការដាក់អនុត្តរភាពក្នុងតំបន់និងការនាំមកនូវឥទ្ធិពលសូវៀតក្នុងអាស៊ីអាគ្នេយ៍ និងអាស៊ីប៉ូព៌ា។ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៧៩ ប្រទេសចិនបានវាយលុកវៀតណាម ដើម្បីជាការផ្តល់មេរៀនដល់វៀតណាម។ ចាប់ពីពេលនោះមក ប្រទេសចិនបានរក្សាជំនួយរបស់ខ្លួនសម្រាប់ផ្តល់ឱ្យខ្មែរក្រហមជារូបិយបណ្ណ ៥លានដុល្លារក្នុងមួយឆ្នាំ[៧៣]។ អស្ថិរភាពរបស់វៀតណាមដើម្បីលុបបំបាត់កម្លាំងប្រឆាំងកម្ពុជា រួមជាមួយនឹងការថយចុះជំនួយពីសហភាពសូវៀត បានធ្វើឱ្យវត្តមានយោធារបស់វៀតណាមនៅកម្ពុជាត្រូវបញ្ចប់។ ម្យ៉ាងទៀត សហគមន៍អន្តរជាតិ ក្នុងការប្រជុំប្រចាំឆ្នាំរបស់អង្គការសហប្រជាជាតិពុំបានទទួលស្គាល់រដ្ឋាភិបាលក្រុងភ្នំពេញ ដែលវៀតណាមគាំទ្រ។ ផ្ទុយទៅវិញគេបានទទួលស្គាល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហម។ បន្ទាប់ពីរដ្ឋាភិបាលចម្រុះបានបង្កើតនៅឆ្នាំ១៩៨២ រវាងខ្មែរក្រហមនិងក្រុមមិនមែនកុម្មុយនីស្តដែលដឹកនាំដោយសម្តេចព្រះ នរោត្តម សីហនុ និងលោក សឺន សាន ដែលមានឈ្មោះថា រដ្ឋាភិបាលចម្រុះនៃកម្ពុជាប្រជាធិ-បតេយ្យ(CGDK) ដោយទទួលបានសំឡេងគាំទ្រកាន់តែច្រើន នៅអង្គប្រជុំប្រចាំឆ្នាំរបស់អង្គការសហប្រជាជាតិនាជាបន្តបន្ទាប់[៧៤]។ ដូច្នេះ ផលវិបាកចម្បងនៃការសម្រេចចិត្តវាយលុកលើប្រទេសកម្ពុជា គឺជាភាពឯកោរបស់វៀតណាមទាំងការទូតនិងសេដ្ឋកិច្ច។ វត្តមាននៃកងទ័ពវៀតណាមនៅកម្ពុជាបានធ្វើឱ្យអន្តរជាតិមិនទទួលស្គាល់រដ្ឋាភិបាលថ្មីរបស់កម្ពុជាជាផ្លូវការនិងហ៊ុមព័ទ្ធសេដ្ឋកិច្ច។ ភាពអន់ថយខាងផ្នែកសេដ្ឋកិច្ចរបស់សហភាពសូវៀតបានបណ្តាលឱ្យមានការកាត់បន្ថយជំនួយយ៉ាងសម្បើមរបស់ខ្លួនមកឱ្យប្រទេសវៀតណាមនិងបានបញ្ចប់សម្ព័ន្ធភាពរវាងសូវៀត-វៀតណាមថែមទៀត។ ការផ្តាច់ជំនួយបានធ្វើឱ្យវៀតណាមជួបបញ្ហាក្នុងការជ្រោមជ្រែងដល់ប្រទេសកម្ពុជា។ ហេតុនេះការទប់ស្កាត់សេដ្ឋកិច្ចមកលើរដ្ឋាភិបាលថ្មីនិងវិបត្តិសេដ្ឋកិច្ចនៅសហភាពសូវៀតបានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាស្ទះដង្ហើម។ ភាពការណ៍នេះតម្រូវឱ្យកម្ពុជាត្រូវស្វែងរកដំណោះស្រាយសម្របសម្រួល

[៧៣] លិខិតឆ្លងឆ្លើយលោក អៀង សារី ឧបនាយករដ្ឋមន្ត្រីការទេសនៃកម្ពុជាប្រជាធិបតេយ្យនិងលោក មូហ្វា ឧបនាយករដ្ឋមន្ត្រីនៃប្រទេសចិន ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៧៩។

[៧៤] ស្តេហ្វិន ច.ម៉ូរីស ហេតុម្តេច វៀតណាម លុកលុយកម្ពុជា ឆ្នាំ២០០៨ទំព័រទី៤៦០។

ដើម្បីធ្វើសមាហរណកម្មក្នុងអន្តរជាតិនិងការងាកទៅរកផ្លូវចរចាដើម្បីសន្តិភាព[៧៥]។ កត្តាដែលនាំឱ្យមានកិច្ចព្រមព្រៀងសន្តិភាពនេះក៏មានការរួមចំណែកពីប្រទេសចិនផងដែរ ពីព្រោះតាំងពីដំបូងមកប្រទេសចិនបានយកបញ្ហាវាងវៀតណាមនិងកម្ពុជាដាក់លើគេក្នុងបញ្ជីដែលជាបញ្ហារបស់ចិនខ្លួនឯង។ ប្រទេសចិនបានប្រើឥទ្ធិពលរបស់ខ្លួន ជាពិសេសជាមួយសហរដ្ឋអាមេរិកនិងអាស៊ីអាគ្នេយ៍ដើម្បីគ្រប់គ្រងមតិអន្តរជាតិជុំវិញបញ្ហានោះ។ ការជជែកវែកញែកពីបញ្ហាកម្ពុជានៅឆ្នាំ១៩៧៩ នៅអង្គការសហប្រជាជាតិគឺជាការចារទុកជាលើកដំបូងដែលប្រទេសចិនដាក់ដំណោះស្រាយនៅចំពោះមុខគណៈកម្មាធិការសន្តិសុខនៃអង្គការសហប្រជាជាតិ។ ប្រទេសចិនបានស្នើសុំថ្កោលទោសវៀតណាម ហើយឱ្យកាត់ផ្តាច់ជំនួយពីវៀតណាមនិងបន្តទទួលស្គាល់ខ្មែរក្រហមជាតំណាងស្របច្បាប់នៃកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ។ នៅក្នុងការប្រកែកចុងក្រោយចំពោះប្រទេសចិនជាមួយសហភាពសូវៀតចំពោះរឿងនោះនៅអង្គការសហប្រជាជាតិសហរដ្ឋអាមេរិកជាអ្នកគាំទ្រធំជាងគេរបស់ចិន។ ប្រទេសចិនបានឈ្នះនូវអ្វីគ្រប់យ៉ាងដែលគេបានស្នើសុំនោះ។ រហូតមកដល់ឆ្នាំ១៩៨៥ ការព្យាយាមរបស់ប្រទេសចិនបានធ្វើឱ្យប្រទេសមហាអំណាចនៅតែមិនព្រមដើរចេញពីជម្លោះស្តីពីបញ្ហាកម្ពុជាដែលមិនអាចឈ្នះចាញ់ទេ។ ប្រទេសចិន សហរដ្ឋអាមេរិក និងប្រទេសអាស៊ានទាំងឡាយមិនព្រមទទួលស្គាល់ថាមានបញ្ហាអ្វីក្រៅពីការគ្រប់គ្រងរបស់វៀតណាមនៅកម្ពុជានោះឡើយ។ សកម្មជនបានបន្តវ៉ៃនៅវ៉ាស៊ីនតោន ទីក្រុងឡុងដ៍ និងទីក្រុងប៉ារីស៍ឱ្យមានដំណោះស្រាយកណ្តាលមួយដែលអាចឱ្យមានការដកទ័ពវៀតណាមចេញពីកម្ពុជា។ នៅទីបំផុត ក្នុងអំណាចលោកមីខាអ៊ីល ហ្គោ បាឆូវ គេបានអនុវត្តនយោបាយទាំងឡាយដែលសន្យានូវការកែប្រែនយោបាយរួមមានការបើកចំហ(Glasnot) ការកែប្រែរចនាសម្ព័ន្ធ(Perestroika) ប្រជាធិបតេយ្យកម្ម(Democratization)គំនិតថ្មី (New thinking) ដែលផ្តល់សេរីភាពពេញលេញ ដើម្បីធ្វើនយោបាយបរទេសរបស់សូវៀតបានរស់ឡើងវិញ។ ដំបូងគាត់ថាសហភាពសូវៀតនិងសហការជាមួយចិន ដើម្បីកំណត់ឡើងវិញនូវព្រំប្រទល់របស់ពួកគេនៅតាមផ្លូវកប៉ាល់នៃទន្លេអាមួ។ ចំពោះបញ្ហានៅកម្ពុជាគាត់បាននិយាយថានឹងពង្រឹងមិត្តភាពជាមួយប្រទេសទាំងអស់នៅអាស៊ីអាគ្នេយ៍ គឺមិនមែនត្រឹមតែជាមួយប្រទេសនៅឥណ្ឌូចិននិងប្រទេសចិនប៉ុណ្ណោះទេ។ គាត់បាននិយាយពីការបាត់បង់ដ៏ធំធេងរបស់កម្ពុជា ហើយបន្តថាបញ្ហារបស់កម្ពុជាមិនអាចដោះស្រាយបាននៅទីក្រុងឆ្ងាយៗឬនៅអង្គការសហប្រជាជាតិឡើយ។ នៅខែតុលាលោក ហ្គោ បាឆូវ បានទៅប៉េកាំងដើម្បីពិភាក្សាជាមួយប្រទេសចិន។ បន្ទាប់មកលោក ហ្គោ បាឆូវ បានបញ្ជាក់ពីភាពជាក់លាក់នៃជំហររបស់វៀតណាមថ្មីចំពោះរឿងរបស់កម្ពុជាដោយប្រកាសថា រឿងខ្មែរក្រហមអាចដាក់បញ្ចូលក្នុងការចរចាស្តីពីរឿងកម្ពុជា។ ឥរិយាបថនោះជាវិធីមួយដើម្បីយកចិត្តប្រទេសចិននិងបើកផ្លូវដើម្បីសម្របសម្រួលទំនាក់ទំនងរវាងសូវៀតជាមួយចិនដែលជាបំណងចម្បងរបស់លោក ហ្គោ បាឆូវ។

ដូច្នេះនៅអាស៊ី សង្គ្រាមត្រជាក់បានបង្រួមត្រឹមការសម្រុះសម្រួលរវាងសហភាពសូវៀតនិងចិនឱ្យស្រុះស្រួលគ្នា ដែលជាគន្លឹះអនុញ្ញាតឱ្យប្រទេសទាំងឡាយបើកទ្វារធ្វើទំនាក់ទំនងនិងនាំមកនូវទំនាក់ទំនងល្អរវាងប្រទេសនិងប្រទេស ហើយនាំទៅរកការឈានដល់ការបើកព្រំដែនលើកទី១អស់ពេលដ៏យូរ។ ដើម្បីសម្រុះសម្រួលប្រទេសចិននិងសូវៀត កងទ័ពវៀតណាមត្រូវតែដកចេញពីកម្ពុជានិងការបញ្ចុះបញ្ចូលឱ្យខ្មែរឈប់ច្បាំងគ្នាឯងដែលបានក្លាយជាកត្តាចម្បងនៃនយោបាយសង្គ្រាមត្រជាក់។ នៅនាទីចុងក្រោយលោក តេង ស៊ាវពីង និងលោក ហ្គោ បាឆូវ បានចុះហត្ថលេខាលើខ្លឹមសារសំខាន់ ១៨ចំណុច ដោយមានដាក់បញ្ចូលបញ្ហាកម្ពុជាជាចំណុចចម្បងនៅក្នុងបញ្ជីនោះផងដែរ។ មេដឹកនាំប្រទេសចិនត្រូវអញ្ជើញឱ្យទៅទស្សនកិច្ចនៅសូវៀតវិញផងដែរ។

---

[៧៥] នីកូឡារ៉េហ្គូ (Nicolas Regaud)៖ កម្ពុជាក្នុងព្យុះសង្ឃរា ប្រែសម្រួលដោយ ទីឃាយុ ទំព័រ៣៥៦។

ដូច្នេះយើងឃើញថា ដោយសារតែការស្រុះស្រួលរវាងមហាអំណាចចិននិងសូវៀតនេះ ហើយដែលធ្វើឱ្យកិច្ចព្រមព្រៀងដំបូងស្តីពីដំណោះស្រាយនៅកម្ពុជាបានចេញរួច និងរហូតធ្វើឱ្យក្រុមរបស់កម្ពុជាទាំងអស់ក៏ចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដើម្បីដោះស្រាយជម្លោះនៅកម្ពុជា។

# ព្រះសង្ឃ ទស្សនវិទូនិងអ្នកវិទ្យាសាស្ត្រ

**បេក្ខជនបណ្ឌិត សៅរ៍ ចន្ទថុល្ល**
**ផ្នែកទស្សនវិជ្ជា**



## ១- សេចក្តីផ្តើម

មនុស្សបានអភិវឌ្ឍ **សាសនា ទស្សនវិជ្ជា** និង**វិទ្យាសាស្ត្រ**ឡើង ក្នុងគោលបំណងដើម្បីដោះស្រាយបញ្ហារស់នៅរបស់ពួកគេ ប៉ុន្តែភាពសម្បូរបែបខាងផ្នែក **សាសនា ទស្សនវិជ្ជា** និង**វិទ្យាសាស្ត្រ**នេះបានបង្កឱ្យមានភាពចម្រូងចម្រាស់នៅក្នុងសង្គមនិងធម្មជាតិដែលមិនធ្លាប់មានពីមុនមក មានដូចជា ការអត់ឃ្លាន ការបះបោរ អំពើភេរវកម្ម ការគំរាមកំហែងដោយអាវុធនុយក្លេអ៊ែរ រញ្ជួយផែនដី ទឹកជំនន់ ខ្យល់ព្យុះ...។ល។ បញ្ហាដ៏គ្រោះថ្នាក់ទាំងនេះបានធ្វើឱ្យមានកង្វល់នៅក្នុងជីវភាពរស់នៅ។ ហេតុអ្វីបានជាបញ្ហាទាំងអស់នេះកើតឡើង ? តើមានវិធីដោះស្រាយទេ ?

ទាំងអស់នេះគឺជាបញ្ហា ដែលធ្វើឱ្យមានកង្វល់នៅក្នុងគំនិតនិងធ្វើឱ្យចិត្តមានមន្ទិលសង្ស័យ។ កង្វល់នៅក្នុងគំនិតនិងមន្ទិលសង្ស័យនៅក្នុងចិត្តនេះជាហេតុនាំឱ្យកើតទៅជាការលើកយកប្រធាន "**ព្រះសង្ឃ ទស្សនវិទូ** និង**អ្នកវិទ្យាសាស្ត្រ**" មកស្រាវជ្រាវស្វែងរកការពិត។

## ២- ព្រះសង្ឃ ទស្សនវិទូនិងអ្នកវិទ្យាសាស្ត្រ

### ២.១- ព្រះសង្ឃ

ព្រះពុទ្ធទ្រង់ហៅអ្នកបួសក្នុងព្រះពុទ្ធសាសនាថា ព្រះភិក្ខុសង្ឃដែលមានន័យថាក្រុមអ្នកដែលមើលឃើញភ័យក្នុងការកើត ចាស់ ឈឺ ស្លាប់[៧៦]។

នៅក្នុងព្រះពុទ្ធសាសនា ព្រះសង្ឃមានពីរប្រភេទ គឺ **ព្រះអរិយសង្ឃ** និង**ព្រះសម្មតិសង្ឃ**។

-**ព្រះអរិយសង្ឃ** ៖ ជាព្រះសង្ឃដែលបានសម្រេចនូវគុណធម៌ជាន់ខ្ពស់ក្នុងព្រះពុទ្ធសាសនា ដែលមាន៤ថ្នាក់ គឺថ្នាក់ សោតាបន្នបុគ្គល សកទាគាមីបុគ្គល អនាគាមីបុគ្គលនិងអរហត្តបុគ្គល។

-**ព្រះសម្មតិសង្ឃ** ៖ ជាសង្ឃដែលកំពុងសិក្សារៀនសូត្រនិងព្យាយាមបដិបត្តិសីល សមាធិនិងបញ្ញា ដើម្បីរំដោះខ្លួនឱ្យរួចផុតពីសេចក្តីទុក្ខដូចព្រះអរិយសង្ឃដែរ តែលោកនៅពុំទាន់បានសម្រេចនូវគុណធម៌ណាមួយក្នុងចំណោមថ្នាក់ទាំង៤នៅឡើយ។

អ្នកបួសនៅក្នុងព្រះពុទ្ធសាសនាមានពីរកម្រិត។ នៅក្នុងកម្រិតទី១ គេហៅថា **សាមណេរ**[៧៧] បើស្ត្រីជា**សាមណេរី**[៧៨] (តែសម័យឥឡូវមិនមាន) ឬលោកនេនដែលក្លាយមកពីសម្តីដីសៀមដែលអានអក្សរ "រ" តួប្រកប

---

[៧៦] ហមណីចិន្តា "*មគ្គុទេសក៍ជីវិត*", អន្លង់វិល, បោះពុម្ពលើកទី៣, ១៩៩៧,ទំព័រ១០៧។

[៧៧] តាជីគឺបុរសដែលកោរសក់ស្លៀកដណ្តប់សំពត់សឬសំពត់លឿងកាន់សីល១០ តែមិនមែនបួសជាសាមណេរទេ។ សូម្បីបុរសជាចាស់ព្រឹទ្ធាចារ្យឯទៀតក្រៅពីនោះពាក្យបុរាណក៏ហៅដោយគោរពថាតាជីបានដែរ។

[៧៨] ដូនជី/យាយជី/នាងជីគឺឧបាសិកាដែលកោរសក់ស្លៀកដណ្តប់សំពត់សឬសំពត់លឿងកាន់សីល១០ជានិច្ច(ច្រើនតែស្ត្រីចាស់ៗ តែទោះបីស្ត្រីនៅក្មេងក៏ដោយបើប្រព្រឹត្តកាន់វត្តប្រតិបត្តិដូច្នេះក៏ហៅដូនជីដែរ)។

ខាងចុងដូចជាតួ "ន" (សាមណេរអានថា សាមណេន) គឺណេរ>ណេន>នេន[៧៩]។ អ្នកបួសនៅក្នុងកម្រិតទី១ នេះមានអាយុក្រោម២០ឆ្នាំ កាន់**១០សិក្ខាបទ**។

ចំពោះកម្រិតទី២ គេហៅថា **ភិក្ខុ** មានអាយុលើសពី២០ឆ្នាំឡើងទៅកាន់ចំនួន**២២៧សិក្ខាបទ** (បើភិក្ខុមហាយានកាន់ចំនួន២៥៣សិក្ខាបទ) បើស្ត្រីជា**ភិក្ខុនី**ឬភិក្ខុស្រីគឺស្ត្រីដែលបួសជាភិក្ខុកាន់ចំនួន**៣១១សិក្ខាបទ** (មានតែក្នុងពុទ្ធកាលនិងពុទ្ធសាសនាកាលសម័យពីដើម សព្វថ្ងៃនេះមិនឃើញមានវត្តមាននៅស្រុកខ្មែរទេ មានតែនៅក្នុងនិកាយមហាយានដូចជា ជប៉ុន កូរ៉េ ចិន ចិនតៃវ៉ាន់កាន់ចំនួន៣៦៤សិក្ខាបទ)[៨០]។ នៅពេលសាមណេរក្លាយទៅជាភិក្ខុហើយ ភិក្ខុអង្គនោះត្រូវទទួលយកសិក្ខាបទចំនួន២២៧មាត្រា។ ប៉ុន្តែដោយសិក្ខាបទនេះមានចំនួនច្រើនពេក ម្យ៉ាងទៀតដោយភិក្ខុនោះទើបនឹងចូលមកថ្មី មានការលំបាកក្នុងការចងចាំទាំងអស់បាន ទើបគ្រូឧបជ្ឈាយ៍សង្ខេបយកតែសិក្ខាបទណាដែលសំខាន់និងចាំបាច់ត្រូវជៀសវាងជាងគេ មកឱ្យសិស្សបានដឹងជាដំបូងសិន ពីព្រោះសិក្ខាបទដែលសំខាន់និងចាំបាច់ត្រូវជៀសវាងជាងគេទាំងនោះមិនអាចអនុគ្រោះឱ្យបានទេ គឺមានទោសដែលហៅថា **អាបត្តិ**។ បើភិក្ខុណាប្រព្រឹត្តល្មើសនឹងសិក្ខាបទទាំងនោះហើយនឹងត្រូវខូចឋានៈជាភិក្ខុ ហើយត្រូវសឹកចេញ មិនអាចបួសតទៅទៀតបានទេ។ ទោសនេះមានទម្ងន់ស្មើគ្នានឹងទោសឧក្រិដ្ឋខាងផ្លូវរដ្ឋដែរ ដែលគេត្រូវតែប្រហារជីវិតចោល។ ទោសដ៏ធ្ងន់ទាំងនេះលោកហៅថា **បារាជិក** (អ្នកចាញ់) មាន៤សំខាន់ៗ ៖

១- ការសេពមេថុនធម្ម (សេពកាម)។ ភិក្ខុដែលសេពមេថុនធម្មប្រៀបដូចមនុស្សកំបុតក្បាលមិនអាចតឱ្យរស់វិញបាន។

២- កាន់យកទ្រព្យដែលគេមិនបានឱ្យដោយកាយ វាចា ចិត្ត (លួច)។ ភិក្ខុដែលលួចទ្រព្យគេប្រៀបដូចស្លឹកឈើទុំជ្រុះចាកទង មិនអាចតឱ្យជាប់វិញបាន។

៣- សម្លាប់ជីវិត សូម្បីតែញុំាងគភ៌ឱ្យរលូតកូនក៏ពុំបានដែរ។ ភិក្ខុដែលប្រព្រឹត្តអំពើនេះ ប្រៀបដូចដុំថ្មតាន់ដ៏ក្រាស់ដែលបែកចេញជាពីរផ្នែក មិនអាចតឱ្យជាប់វិញបានដូច្នេះដែរ។

៤- ពោលអួតអាងនូវឧត្តរិមនុស្សធម៌ ដោយហោចទៅ សូម្បីតែពោលថា ខ្ញុំត្រេកអរតែក្នុងទីសេនាសនៈដ៏ស្អាតដូច្នេះក៏ពុំបានដែរ។ ភិក្ខុដែលមានសេចក្ដីលោភ ពោលអួតនូវឧត្តរិមនុស្សធម៌។ ភិក្ខុដែលអួតប្រៀបដូចដើមត្នោតដែលកំបុតចុងដែលមិនអាចតឱ្យដុះលូតលាស់បានវិញ។

ទោសក្រៅពី៤យ៉ាងខាងលើនេះអាចអនុគ្រោះបាន ដោយការដាក់ទណ្ឌកម្មខ្លះ ដោយការសារភាពនៅចំពោះមុខសង្ឃខ្លះបាន។ តែចំពោះទោស **បារាជិក** នេះមិនអាចអត់ឱនឱ្យបានទេ[៨១]។

ក្រោយពេលបួសចប់ ព្រះឧបជ្ឈាយ៍បានប្រាប់ភិក្ខុជាសិស្សពីករណីយកិច្ច៤យ៉ាងដែលត្រូវបំពេញគឺ៖

១- ត្រូវព្យាយាមមន្តបិណ្ឌបាត្រពីអ្នកដែលមានសទ្ធា ដើម្បីចិញ្ចឹមជីវិត

២- ត្រូវព្យាយាមរកសំពត់បង្សុកូល (សំពត់ដែលគេចោលលើគំនរសំរាមឬសំពត់ប្រឡាក់សៅហ្មងដោយអាចម៍ដី ដោយធូលីដី ជាសំពត់ដែលគេសម្គាល់ថាជារបស់ឥតម្ចាស់ព្រោះគេបោះបង់ចោលលែងត្រូវការហើយ ទាញយកមកផ្សេផ្សំធ្វើជាចីវរប្រើប្រាស់តាមពុទ្ធានុញ្ញាត។ ចំពោះតែសំពត់មានព័ណ៌សឬលឿងដែលល្មមយកមកជ្រលក់សម្រួលពណ៌បាន រាប់ថាជាសំពត់ថ្លៃថ្លាវិសេសសម្រាប់បព្វជិតអ្នកមានសន្តោសស្ងប់រម្ងាប់)។ ប៉ុន្តែក៏អាចអនុញ្ញាតឱ្យទទួលយកសំពត់ដែលទាយកទាយិកាប្រគេនដែរ។

---

[៧៩] ជួន ណាត "*វចនានុក្រមខ្មែរ*" រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ២០០៨ ទំព័រសាមណេរ នេន។

[៨០] ទីបេត៍។

[៨១] ហមណីចិន្តា ដ.ឯ.ម. ទំព័រ១២១-១២២។

៣- ត្រូវព្យាយាមអាស្រ័យនៅក្រោមម្លប់ឈើជាសេនាសនៈ។

៤- ត្រូវព្យាយាមអាស្រ័យនូវទឹកមូត្រគោ( ទឹកនោម )ធ្វើជាថ្នាំរំងាប់រោគតែក៏អនុញ្ញាតនូវភេសជ្ជៈផ្សេងៗមាន ទឹកដោះថ្លា ទឹកដោះខាប់ ទឹកឃ្មុំ ទឹកអំពៅ ប្រេង សម្រាប់ប្រើប្រាស់ជាភេសជ្ជៈបាន[៨២]។

## ២.២- ទស្សនវិទូ

ពាក្យថា **ទស្សនវិទូ** ស្មើនឹងពាក្យអង់គ្លេសថា "philosopher" មកពីពាក្យក្រិចបុរាណថា"philosophos" ដែលមានន័យតាមខ្លឹមសារដើមថា "អ្នកស្នេហាគតិបណ្ឌិត ( lover of wisdom )"[៨៣]។

លោក **ប៊ីតថល**( Bittle ) ឱ្យនិយមន័យទស្សនវិទូថាជា ***«អ្នកវិទ្យាសាស្ត្រភាវៈដែលវិចារណញ្ញាណ មូលហេតុនិងគោលការណ៍ខ្ពស់របស់វាទទួលបានមកពីជំនួយនៃវិចារណញ្ញាណមនុស្សតែម្យ៉ាងប៉ុណ្ណោះ****( the scientists of being in their ultimate reasons, causes and principles acquired by the aid of human reason alone)»*[៨៤]។ ទស្សនវិទូគឺជា**អ្នកវិទ្យាសាស្ត្រ**ពីព្រោះពួកគេពឹងផ្អែកទៅលើ**ពុទ្ធិ** មិនត្រឹមតែទៅលើ**មតិយោបល់ ទ្រឹស្តីឬសម្មតិកម្ម**( hypothesis )[៨៥]នេះប៉ុណ្ណោះទេ។ ពួកគេគឺជា**អ្នកវិទ្យាសាស្ត្រភាវៈ** ពីព្រោះវាគ្របដណ្តប់ទៅលើ**វត្ថុទាំងអស់** ដែលគេអាចយល់ដឹងបានដោយសារ **គំនិតមនុស្ស** មានន័យថា អ្វីៗដែលមានអត្ថិភាពគឺនៅតែបន្តមានអត្ថិភាពអាចឱ្យគេគិតបានឬយល់បាន។ ទស្សនវិទូជា «អ្នកវិទ្យាសាស្ត្រភាវៈដែលមានវិចារណញ្ញាណ មានហេតុនិងមានគោលការណ៍ខ្ពស់»។ គឺឆ្លងតាម «**វិចារណញ្ញាណ**(reason)» នេះធ្វើឱ្យគេយល់និងស្គាល់វត្ថុមួយបាន **ហេតុគឺជាអ្វីមួយដែលធ្វើឱ្យវត្ថុផ្សេងៗទៀតកើតឡើង**។ នៅពេលដែលអ្នកវិទ្យាសាស្ត្រដទៃទៀតផ្តល់នូវហេតុជិតនិងផ្ទាល់ដល់វត្ថុនានានោះទស្សនវិទូស្វែងរក **ហេតុនិងគោលការណ៍ផ្តាច់ព្រ័ត្រ** នៃវត្ថុនោះ។ ទីបំផុត **គោលបំណង** របស់ទស្សនវិទូ បានមកដោយជំនួយពី **វិចារណញ្ញាណ** មនុស្សតែមួយគត់មានន័យថាទស្សនវិទូពឹងផ្អែកពុទ្ធិរបស់ខ្លួនតែទៅលើមូលដ្ឋាន**កម្លាំងស្មារតីពិចារណារបស់មនុស្ស** ( the reasoning power of the human mind )តែប៉ុណ្ណោះគឺមិនផ្អែកទៅលើកម្លាំងអ្វីក្រៅពីនេះឡើយ។ ជំនឿនិងអំណាចអាទិទេពមិនមានទីតាំងនៅក្នុងការស្រាវជ្រាវរបស់ទស្សនវិទូទេ។ ទោះជាយ៉ាងណាក៏ដោយ ក៏កត្តាទាំងនេះអ្នកជឿអាទិទេពតែងតែត្រូវការជានិច្ចដើម្បីដឹកនាំការពិចារណារបស់គេ ដើម្បីកុំឱ្យវាងាកចេញពីសច្ចភាពដែលជាគោលបំណងចុងក្រោយរបស់ទស្សនវិទូ។

ទស្សនៈខាងលើនេះបង្ហាញឱ្យឃើញថា ទស្សនវិទូជាអ្នកដែលមាន**មុខវិជ្ជា**សិក្សាមួយ**ទូលំទូលាយ**និង**គ្រប់សព្វ**។ ទស្សនវិទូចែកចេញជាពីរប្រភេទគឺ **ទស្សនវិទូទ្រឹស្តី** និង **ទស្សនវិទូអនុវត្តន៍**។

- **ទស្សនវិទូទ្រឹស្តី**មាន៖ អស្តិរូបវិទូ ប្រាណវិទូ លោកធាតុវិទូ ចិត្តវិទូ ពុទ្ធិវិទូ សាសនវិទូ។
- **ទស្សនវិទូអនុវត្តន៍**មាន៖ ភាសាវិទូ តក្កវិទូ សីលវិទូ សោភ័ណវិទូ តម្លៃវិទូ។

សព្វថ្ងៃ ទស្សនវិទូមានច្រើនប្រភេទដូចជាទស្សនវិទូរូបធាតុនិយម អ្នកមនោនិយម អ្នកអត្ថិភាព និយម អ្នកសុទិដ្ឋិនិយម អ្នកទុទិដ្ឋិនិយម ទស្សនវិទូស្គាល់ច្បាស់ពីខ្លួនឯង អ្នកអព្ភន្តរញាណនិយម ទស្សនវិទូផល

---

[៨២] ហមណីចិន្តា, ដ.ឯ.ម.ទំព័រ១២០-១២១។

[៨៣] Internet about philosopher in Philosopher - Wikipedia, the free encyclopedia

[៨៤] Venancio B. Ardales, *Introductory Text to Philosophy*, 2nd Ed., New York, 1987,p2

[៨៥] ជាគំនិតឬសំណើដែលពឹងផ្អែកលើការពិតនានាដែលគេបានស្គាល់ហើយដែលគេយកមកប្រើប្រាស់ធ្វើជាមូលដ្ឋានសម្រាប់ពិចារណា ឬពិនិត្យសង្កេតបន្ថែម។

ប្រយោជន៍និយម ទស្សនវិទូអត់ធ្មត់និយម ទស្សនវិទូអេភីខ្យួរៀននិយម ទស្សនវិទូប្រតិបត្តិនិយម ទស្សនវិទូតថភាពនិយម ទស្សនវិទូបុគ្គលនិយម អ្នកឥរិយាបថនិយម...។ល។

ក្នុងចំណោមទស្សនវិទូទាំងឡាយខាងលើ គេសង្កេតឃើញទស្សនវិទូពីរក្រុមដែលតែងតែមានទំនាស់យ៉ាងស្វិតស្វាញជាមួយគ្នាគឺក្រុម **ទស្សនវិទូរូបធាតុនិយម** និង **ទស្សនវិទូមនោនិយម**។

- **ក្រុមទស្សនវិទូរូបធាតុនិយម៖**ក្រុមនេះយល់ឃើញថារាល់វត្ថុទាំងអស់នៅក្នុងលោកនេះសុទ្ធតែតាក់តែងឡើងមកពី **រូបធាតុ** (matter)ហើយនិងយល់ថា **គុណភាពរូបធាតុ** (the propertiesof matter) កំណត់លើគ្រប់វត្ថុទាំងអស់ ដោយគិតរួមទាំង **បាតុភូតផ្លូវចិត្ត**(mental phenomena)នេះផង។ គ្រប់វត្ថុពន្យល់បានសុទ្ធតែត្រូវគេពន្យល់នៅលើមូលដ្ឋាន **ច្បាប់ធម្មជាតិ**(natural laws)ទាំងអស់។

- **ក្រុមទស្សនវិទូមនោនិយម៖**ជាក្រុមដែលមានជំហរថា **គំនិត** (ideas) គឺជា**កម្មវត្ថុពិតនៃពុទ្ធិ** គំនិតមានមុនវត្ថុគំនិតនាំមកនូវបឋមវិធាននៃភាវៈចំពោះវត្ថុ[៨៦]។ វត្ថុរូបធាតុមិនមានអត្ថិភាពដោយឯករាជ្យនោះទេ ប៉ុន្តែវាគ្រាន់តែជាការបង្កើតឡើងនៅក្នុងគំនិតតែប៉ុណ្ណោះ[៨៧]។ វត្ថុរូបធាតុ គឺជាស្រមោលឬការស្រមើស្រមៃ។

ទស្សនវិទូមានមុខងារ៣ខុសៗគ្នាគឺ**មុខងារទី១៖**ត្រួតពិនិត្យនិងរិះគន់ដោយប្រុងប្រយ័ត្នទៅលើ**មូលបដិញ្ញា** (premises)[៨៨]និង**ការសន្និដ្ឋាន**(conclusions)នៃគ្រប់អ្នកវិទ្យាសាស្ត្រ និងអ្នកសាសនាទាំងអស់ដូចជាជីវវិទូ រូបវិទូ សង្គមវិទូ គ្រិស្តសាសនិក អស្លាមសាសនិកជាដើម។ **មុខងារទី២៖សំយោគលទ្ធផល** (synthesize findings) នៃគ្រប់អ្នកវិទ្យាសាស្ត្រនិងអ្នកសាសនាទាំងអស់។ **មុខងារទី៣៖បង្រួបបង្រួមអ្នកវិទ្យាសាស្ត្រនិងអ្នកសាសនា**ឱ្យមានការឯកភាពគ្នា បំពេញបន្ថែមឱ្យគ្នានិងគាំទ្រគ្នាទៅវិញទៅមក។

## ២.៣- អ្នកវិទ្យាសាស្ត្រ

មានមធ្យោបាយកំណត់និយមន័យអ្នកវិទ្យាសាស្ត្រមួយគឺ ៖ **អ្នកវិទ្យាសាស្ត្រគឺជាអ្នកដែលប្រើវិធីជាប្រព័ន្ធមួយដែលសិក្សាពីពិភពដែលយើងកំពុងរស់នៅៗក្នុងនោះ។** វិធីជាប្រព័ន្ធនោះមាន៧ ឬ៨ជំហានគឺ ១- ការពិនិត្យសង្កេតវិទ្យាសាស្ត្រ(making scientific observations) ២-ការលើកឡើងពីចំណោទវិទ្យាសាស្ត្រ(proposing scientific questions) ៣-ធ្វើពិសោធន៍វិទ្យាសាស្ត្រ(designing scientific experiments) ៤-ប្រមូលទិន្នន័យវិទ្យាសាស្ត្រ (collecting scientific information), ៥-បកស្រាយវិទ្យាសាស្ត្រ (making scientific interpretations) ៦-វាយតម្លៃសន្មតិកម្មវិទ្យាសាស្ត្រ (evaluating scientific assum ptions) ៧- ពិភាក្សាពីលទ្ធផលវិទ្យាសាស្ត្រ (discussing scientific implications) និង៨-វាយតម្លៃចំពោះទស្សនៈខុសៗគ្នា (evaluating different points of view)។

អ្នកវិទ្យាសាស្ត្រមានពីរក្រុមគឺ **អ្នកវិទ្យាសាស្ត្រសង្គម** និង **អ្នកវិទ្យាសាស្ត្រធម្មជាតិ**។

- **អ្នកវិទ្យាសាស្ត្រសង្គម៖** គឺជាអ្នកសិក្សាផ្តោតទៅលើប្រភពនិងការអភិវឌ្ឍសង្គមមនុស្ស មានដូចជាស្ថាប័ននានា ទំនាក់ទំនងផ្សេងៗ ហើយនិងគំនិតដែលទាក់ទងទៅនឹង**ជីវិតសង្គម**។ មុខវិជ្ជាដែលគេតម្រូវទៅឱ្យ

---

[៨៦] Nicholas Bunnin and Jiyuan Yu, The Blackwell Dictionary of Western Philosophy,p. Idealism

[៨៧] Microsoft Encarta 2009.p. Idealism

[៨៨] អំណះអំណាងឬគំនិតដែលគេលើកយកមកធ្វើជាបង្អែកសម្រាប់ធ្វើវិចារ

ឧទាហរណ៍ - មនុស្សគ្រប់រូបសុទ្ធតែស្លាប់ (មូលបដិញ្ញាធំ)

- សូក្រាតគឺជាមនុស្សម្នាក់ (មូលបដិញ្ញាតូច)

- ហេតុនេះសូក្រាតត្រូវតែស្លាប់ (សន្និដ្ឋាន)

**អ្នកវិទ្យាសាស្ត្រសង្គម** នោះរួមមាន៖ នរវិទ្យា បុរាណវត្ថុវិទ្យា សង្គមវិទ្យា វិទ្យាសាស្ត្រនយោបាយ សេដ្ឋកិច្ច ប្រវត្តិវិទ្យា និង សំណេរប្រវត្តិសាស្ត្រវិទ្យា ច្បាប់ ភាសាវិទ្យា ទស្សនវិទ្យា ចិត្តវិទ្យា ឧក្រិដ្ឋវិទ្យា និង ចិត្តសាស្ត្រសង្គម[៨៩]។

- **មុខងារអ្នកវិទ្យាសាស្ត្រធម្មជាតិ៖** គឺជាក្រុមមួយទៀតរបស់អ្នកវិទ្យាសាស្ត្រដែលមានតួនាទីស្វែងរកការបំភ្លឺពីក្រិត្យក្រមនានា(the rules)ដែលគ្រប់គ្រងលើពិភពធម្មជាតិ តាមរយៈវិធីវិទ្យាសាស្ត្រ។ អ្នកវិទ្យាសាស្ត្រធម្មជាតិមាន៥ក្រុមគឺ តារាវិទូ ជីវវិទូ គីមីវិទូ អ្នកវិទ្យាសាស្ត្រផែនដី និង រូបវិទូ។

[៨៩] Microsoft Encarta Reference Library 2009 about social sciences

# ប្រេវ៉ាឡង់នៃជំងឺគ្រុនចាញ់នៅឆ្នាំ២០០៩


## បេក្ខបណ្ឌិត ម៉ាន់ សុខញ្ញា
## ផ្នែកវិទ្យាសាស្ត្រសុខាភិបាល


## ១-សេចក្តីផ្តើម

នៅលើពិភពលោកមានករណីជំងឺគ្រុនចាញ់ប្រមាណជា៣០០-៥០០ដែលក្នុងនោះមាន៩០%នៅអាហ្វ្រិកខាងត្បូង។ នៅកម្ពុជា យោងតាមរបាយការណ៍របស់មជ្ឈមណ្ឌលជាតិកម្ចាត់ជំងឺគ្រុនចាញ់បរាសិតនិងបាណកសត្វ(CNM) នៅឆ្នាំ២០០៧បង្ហាញថា មានអ្នកកើតជំងឺគ្រុនចាញ់ ៤២៥១៨ករណីដែលក្នុងនោះ ៨៧% បានបង្កដោយ Plasmodium faciparum។ កាលពីឆ្នាំ២០០៥ តាមរបាយការណ៍របស់មជ្ឈមណ្ឌល ជាតិ (CNM) ផងដែរបង្ហាញថា អត្រាអ្នកកើតជំងឺគ្រុនចាញ់មានដល់ទៅ ៧៤១៨៥ករណី ដែលក្នុងនោះ៨០% បង្កដោយ Plasmodium faciparum។ ដូច្នេះតាមរបាយការណ៍ទាំងពីរបង្ហាញថា មានការថយចុះនូវអត្រាជំងឺគ្រុនចាញ់ ២៧,១៤% ប៉ុន្តែមានការកើនឡើងនូវភាគរយអ្នកជំងឺដែលបង្កដោយ Plasmodium falciparum ដល់ទៅ ៧%។

គោលបំណងនៃគម្រោងគឺរកឱ្យឃើញប្រេវ៉ាឡង់នៃជំងឺគ្រុនចាញ់នៅកម្ពុជាក្នុងឆ្នាំ២០០៩។

## ២- វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សានេះគឺប្រើប្រាស់ទិន្នន័យដែលមានស្រាប់ ដែលបានផ្តល់ដោយមជ្ឈមណ្ឌលជាតិកម្ចាត់ជំងឺគ្រុនចាញ់បរាសិតនិងបាណកសាស្ត្រ(CNM)ដែលអង្កេតជំងឺគ្រុនចាញ់ឆ្នាំ២០០៩។ ការសិក្សានេះគឺជ្រើសរើសយកទិន្នន័យនៃជំងឺគ្រុនចាញ់ចំនួន១០ខេត្តមានពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ កំពង់ស្ពឺ សៀមរាប កោះកុង និងកំពត។ ទីកន្លែងសិក្សាទាំង១០ខេត្តនេះដែលខេត្តនីមួយៗត្រូវជ្រើសយក២ស្រុក ហើយស្រុកនីមួយៗត្រូវជ្រើសយក៣ឃុំ ដែលឃុំនីមួយៗត្រូវជ្រើសយក៩ភូមិ។

ចំនួនទំហំគំរូដែលត្រូវសិក្សាមាន ១,៩២០គ្រួសារក្នុង ៤៨កម្រង ដែលក្នុងមួយកម្រងមាន៤០គ្រួសារ។

ក្រុមសម្ភាសចុះទៅតាមកម្រងនីមួយៗមួយថ្ងៃនិងមួយយប់ ដើម្បីរង់ចាំអ្នកភូមិត្រឡប់ពីការងារស្រែចម្ការរបស់គាត់ដើម្បីចៀសវាងលម្អៀងបណ្តាលមកពីមិនជួបមនុស្សនៅពេលថ្ងៃ ហើយធានាថាសំណាកឈាមទាំងអស់ត្រូវបានយក។ ក្រុមនីមួយៗអាចធ្វើបាន៣-៤កម្រងក្នុងមួយសប្តាហ៍ (ចន្ទដល់ព្រហស្បត៍ធ្វើទាំងថ្ងៃទាំងយប់) ហើយថ្ងៃសុក្រគឺ ធ្វើគម្រោងរបាយការណ៍និងការផ្គត់ផ្គង់។

## ៣-លទ្ធផលនិងបំណកស្រាយ

តារាងខាងក្រោមអធិប្បាយពីបែបផែនមូលដ្ឋាននៃអ្នកចូលរួមឆ្លើយតបក្នុងការអង្កេត

តារាង៣.១- ប្រេវ៉ាឡង់គ្រុនចាញ់ដោយប្រភេទនិងដែន(តំបន់) និងគ្រុនក្តៅបានរាយការណ៍ដោយដែន

| | សរុប (N=៥០៧០) | | ដែន១ (N=២០២៦) | | ដែន២ (N=៣០៤៤) | | P-value* |
|---|---|---|---|---|---|---|---|
| | %(N) | ៩៥%CI | %(N) | ៩៥%CI | %(N) | ៩៥%CI | |
| Slides | | | | | | | |
| សរុបវិជ្ជមាន | ០.៩(៤៩) | ០.៥,១.៤ | ០.៦(១៧) | ០.២,២.១ | ០.៩(៣២) | ០.៦,១.៥ | ០.៥៣ |
| Pf | ០.១(៦) | ០.០,០.៤ | -(០) | - | ០.១(៦) | ០.០,០.៥ | |
| Pv | ០.៧(៤១) | ០.៤,១.១ | ០.៦(១៧) | ០.២,២.៣ | ០.៧(២៤) | ០.៤,១.២ | |
| Pf+Pv | ០.១(២) | ០.០,០.៦ | -(០) | - | ០.១(២) | ០.០,០.៧ | |
| ផ្សេងៗ | -(០) | - | -(០) | - | -(០) | - | |
| PCR | | | | | | | |
| សរុបវិជ្ជមាន | ២.៨(១៦១) | ២.០,៤.០ | ២.៧(៦៥) | ១.៥,៤.៧ | ២.៩(៩៦) | ១.៩,៤.២ | ០.៨៧ |
| Pf | ១.០(៥៣) | ០.៦,១.៦ | ១.០(២១) | ០.៥,១.៩ | ១.០(៣២) | ០.៥,១.៨ | |
| Pv | ១.៧(១០១) | ១.២,២.៥ | ១.៥(៤០) | ០.៧,៣.១ | ១.៨(៦១) | ១.១,២.៨ | |
| Pf+Pv | ០.១(៦) | ០.០,០.៣ | ០.២(៤) | ០.០,០.៩ | ០.១(២) | ០.០,០.៣ | |
| ផ្សេងៗ | ០.០(១) | ០.០,០.២ | -(០) | - | ០.០(១) | ០.០,០.២ | |
| សមាជិកគ្រួសារមានគ្រុនក្តៅកាលពី២សប្តាហ៍មុន | | | | | | | |
| បាទ/ចាស | ៥.៤(៤៩០) | ៤.៤,៦.៧ | ៤.៩(១៩៣) | ៣.៤,៧.០ | ៥.៦(២៩៧) | ៤.៤,៧.០ | ០.៥៦ |

**ការប្រៀបធៀបនៃដែន១និងដែន២*

តិចជាង១% នៃអ្នកផ្តល់គំរូឈាមគឺ វិជ្ជមានមេរោគគ្រុនចាញ់សម្រាប់មីក្រូទស្សន៍ ហើយភាគច្រើននៃអ្នកវិជ្ជមានទាំងនេះជាប្រភេទPv។ ទោះជាប្រេវ៉ាឡង់ទាំងអស់មានច្រើនបន្តិចនៅដែន២ តែពុំមានភាពខុសគ្នាសម្រាប់ប្រភេទរវាងដែន១និងដែន២។ ភាគរយខ្ពស់ (២.៨%) គឺវិជ្ជមានដោយPCR ហើយអនុបាតនៃPf ទៅនឹងPvគឺខ្ពស់ជាងមីក្រូទស្សន៍។ ប្រេវ៉ាឡង់PCR គឺក្នុងបន្ទាត់២% បានគណនាដើម្បីបញ្ជាក់ទំហំគំរូ។

តារាង៣.២- ប្រភេទគ្រុនចាញ់តាមខេត្ត

| ខេត្ត | ចំនួននៃគំរូឈាម | សរុប វិជ្ជមាន %(N) | Pf %(N) | Pv %(N) | Pf+Pv %(N) | ផ្សេងៗ %(N) |
|---|---|---|---|---|---|---|
| Slides | | | | | | |
| បន្ទាយមានជ័យ | ៣៧២ | ០.២(១) | -(០) | ០.២(១) | -(០) | -(០) |
| បាត់ដំបង | ១៣៥៥ | ០.៣(៤) | -(០) | ០.៣(៤) | -(០) | -(០) |
| កំពង់ស្ពឺ | ៣២៨ | ៣.១(១២) | ០.៦(៣) | ២.៣(៨) | ០.២(១) | ០.០(០) |
| កំពត* | ៦៥៦ | ០.១(១) | -(០) | ០.០(១) | -(០) | -(០) |
| កោះកុង | ៣២២ | -(០) | -(០) | -(០) | -(០) | -(០) |
| ឧត្តរមានជ័យ** | ៣៧២ | ២.១(៦) | -(០) | ២.១(៦) | -(០) | -(០) |
| ប៉ៃលិន | ៤៣៥ | ០.១(១) | -(០) | ០.១(១) | -(០) | -(០) |
| ព្រះវិហារ | ៤៣២ | ១.៩(៧) | ០.៦(៣) | ០.៧(៣) | ០.៦(១) | ០.០(០) |
| ពោធិ៍សាត់ | ៣៤៧ | ១.៧(១៥) | -(០) | ១.៧(១៥) | -(០) | -(០) |
| សៀមរាប | ៤៥១ | ០.៤(២) | -(០) | ០.៤(២) | -(០) | -(០) |
| PCR | | | | | | |
| បន្ទាយមានជ័យ | ៣៧២ | ១.១(៦) | ០.៥(២) | ១.២(៤) | -(០) | -(០) |
| បាត់ដំបង | ១៣៧៤ | ៣.៤(៤៣) | ១.៥(២០) | ១.៤(១៩) | ០.៣(៤) | ០.០(០) |
| កំពង់ស្ពឺ | ៣៣១ | ៨.២(៣០) | ១.៣(៨) | ៦.២(២២) | -(០) | -(០) |
| កំពត | ៧៧២ | ០.៧(៩) | ០.៣(១) | ០.៨(៨) | -(០) | -(០) |
| កោះកុង | ៣២២ | ០.៥(២) | ០.៦(២) | -(០) | -(០) | -(០) |
| ឧត្តរមានជ័យ | ៤៩៦ | ២.៥(១២) | ០.៤(២) | ២.០(១០) | -(០) | -(០) |
| ប៉ៃលិន | ៤៣៥ | ០.៩(៤) | ០.៣(១) | ០.៥(៣) | -(០) | -(០) |
| ព្រះវិហារ | ៤៣២ | ៥.៥(២៣) | ៣.១(១៣) | ១.៩(៨) | ០.៣(១) | ០.២(១) |
| ពោធិ៍សាត់ | ៣៤៨ | ៣.៦(២២) | -(០) | ៣.៩(២២) | -(០) | -(០) |
| សៀមរាប | ៤៥១ | ១.៩(១០) | ០.៩(៤) | ១.០(៥) | ០.២(១) | ០.០(០) |

** បាត់បង់ទិន្នន័យពី១/៧ចង្កោមដោយបញ្ហាបច្ចេកទេស*

*** បាត់បង់ទិន្នន័យពី១/៤ចង្កោមដោយបញ្ហាបច្ចេកទេស*

ខេត្តកំពង់ស្ពឺមានប្រេវ៉ាឡង់ជំងឺគ្រុនចាញ់ខ្ពស់ជាងគេ ដោយPCR (៨.២%) បន្ទាប់មក ខេត្តព្រះវិហារ (៥.៥%)។ ខេត្តទាំងពីរនេះជាប្រភពប្រភេទគ្រុនចាញ់ Pf (៦) និង Mixe (Pf+Pv) (២)ផងដែរ ដែលបានធ្វើរោគវិនិច្ឆ័យដោយមីក្រូទស្សន៍។ ប្រេវ៉ាឡង់នៃការឆ្លង Plasmodium ដោយ PCR មានកម្រិតទាប (≤១%) នៅខេត្តកោះកុងកំពតប៉ៃលិននិងបន្ទាយមានជ័យ។ ការអង្កេតនេះមិនមានឥទ្ធិពលដើម្បីប្រៀបធៀបស្ថិតិខេត្តខាងលើទេ វាគ្រាន់តែប្រើដើម្បីតាមដានទិន្នន័យប្រេវ៉ាឡង់តាមខេត្តប៉ុណ្ណោះ។

## ៤- ពិភាក្សា

- នៅឆ្នាំ២០០៥មានជំងឺគ្រុនចាញ់ ៧៤១៨៥ករណី ក្នុងនោះ៨០% ជាប្រភេទ Plasmodium falciparum។

- នៅឆ្នាំ២០០៧មានជំងឺគ្រុនចាញ់ ៤២៥១៨ករណី ក្នុងនោះ៨៧% ជាប្រភេទ Plasmodium falciparum។

- នៅឆ្នាំ២០០៩មានជំងឺគ្រុនចាញ់ ៥០៧០ករណី ក្នុងនោះ៥៩% ជាប្រភេទ Plasmodium falciparum។

## ៥-សន្និដ្ឋាន

ប្រេវ៉ាឡង់ជំងឺគ្រុនចាញ់នៅឆ្នាំ២០០៩ មានការថយចុះយ៉ាងខ្លាំង ៣៧៤៤៨ករណី ហើយប្រភេទ Plasmodium falciparum ២៨% បើធៀបទៅនឹងឆ្នាំ២០០៧។

# គ្រោះថ្នាក់ការងារចំពោះកម្មករ-និយោជិត នៅក្នុងសហគ្រាសកាត់ដេរ ភ្នំពេញ

បេក្ខបណ្ឌិត សុខ បូរី ជំនាន់ទី១
ជំនាញ នីតិសាស្ត្រ
សាស្ត្រាចារ្យណែនាំបណ្ឌិត សឿន សោភ័ណ្ឌ



## ១- សេចក្តីផ្តើម

តាមរយៈរបាយការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានឱ្យដឹងថានៅឆ្នាំ២០០៦[៩០]កម្ពុជាមានរោងចក្រវាយនភណ្ឌសម្លៀកបំពាក់និងដេរស្បែកជើងចំនួន៤៩២ និងមានកម្មករ-និយោជិតចំនួន ៤០៣ ៧៤៣នាក់។ រីឯកំណើនកម្មករ-និយោជិតពីមួយឆ្នាំទៅមួយឆ្នាំដែលកំពុងធ្វើការនៅក្នុងរោងចក្រ សហគ្រាសឯកជនកាន់តែមានចំនួនកើនឡើងឥតឈប់ឈរ ហើយទទួលរងនូវហានិភ័យការងារ ដូចជាគ្រោះថ្នាក់នៅនឹងកន្លែងធ្វើការបណ្តាលមកពីមូលហេតុជាច្រើនដូចជា ការដួលសន្លប់ដោយពុល និងជាតិគីមីនៅនឹងក្រណាត់ឬសម្លៀកបំពាក់កំពុងកាត់ដេរ កន្លែងហប់ពុំមានខ្យល់អុកស៊ីសែនគ្រប់គ្រាន់និងពន្លឺបំភ្លឺពុំគ្រប់គ្រាន់នៅពេលធ្វើការផងដែរ។

នៅពេលធ្វើដំណើរពីលំនៅឋានទៅកន្លែងធ្វើការ និងការវិលត្រឡប់ពីកន្លែងធ្វើការមកលំនៅឋានកម្មករ-និយោជិតតែងតែជួបប្រទះគ្រោះថ្នាក់ចរាចរណ៍មិនមានចំនួនតិចទេរហូតដល់ស្លាប់ រងរបួសធ្ងន់រហូតដល់បាត់បង់សមត្ថភាពការងារបណ្តោះអាសន្ននិងទាំងស្រុង ដែលនិយោជកឬម្ចាស់សហគ្រាសមួយចំនួនបានបដិសេធការទទួលខុសត្រូវរបស់ខ្លួនចំពោះហានិភ័យនេះ ទន្ទឹមនឹងការពុំគោរពតាមការណែនាំរបស់ក្រសួងមានសមត្ថកិច្ច[៩០]។

គោលបំណងនៃការស្រាវជ្រាវ៖

១- សិក្សាលើគ្រោះថ្នាក់ការងារដែលកំពុងអនុវត្តក្នុងរោងចក្រ-សហគ្រាស។

២- ស្វែងយល់ពីកត្តាលំបាករបស់និយោជក ក្នុងការអនុវត្តច្បាប់ការងារនៅតាមរោងចក្រ-សហគ្រាស។

## ២- វិធីសាស្ត្រស្រាវជ្រាវ

### ២.១- ការជ្រើសរើសសំណាក

សំណាកបានជ្រើសរើសដោយចៃដន្យ តាមគោលបំណងនៃការស្រាវជ្រាវដោយជ្រើសរើសយកតែកម្មករ-និយោជិតណាដែលធ្វើការងារនៅក្នុងសហគ្រាសកាត់ដេរតែប៉ុណ្ណោះ។

ទំហំសំណាកវិញបានជ្រើសរើសយក១០០% នៃចំនួនកម្មករ-និយោជិតក្នុងរោងចក្រទាំងអស់។

n = 113នាក់

n = ចំនួនកម្មករ-និយោជិតដែលត្រូវសម្ភាស

---

[៩០] ឆ្នាំ២០០៦ ឆ្នាំ២០០៧និងឆ្នាំ២០០៨ របាយការណ៍ប្រចាំឆ្នាំ២០០៧ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**២.២- ការប្រមូលទិន្នន័យបឋម** ( Primary Data )

ជាបឋមត្រូវរៀបចំកម្រងបញ្ជីសំណួរដែលបានធ្វើឡើងដោយមានការកែតម្រូវនិងឯកភាពពីសាស្ត្រាចារ្យដឹកនាំ។

បន្ទាប់មកត្រូវចុះទៅសម្ភាសផ្ទាល់ យកព័ត៌មាននៅនឹងទីកន្លែងជាក់ស្តែង តាមរយៈកម្រងបញ្ជីសំណួរ ( Questionnaires )ដើម្បីប្រមូលព័ត៌មានដែលទាក់ទងទៅនឹងប្រធានបទខាងលើ។

**២.៣- ការប្រមូលទិន្នន័យទី២** ( Secondary Data )

គឺទិន្នន័យដែលមានស្រាប់ ដូចជាឯកសារស្នាដៃអ្នកនិពន្ធកម្រិតជាតិ ស្នាដៃអ្នកនិពន្ធបរទេសច្បាប់ជាតិ ច្បាប់អន្តរជាតិនិងលិខិតបទដ្ឋានក្រោមច្បាប់នានា។ បន្ថែមក្រៅពីនេះទៀតមានឯកសារតាមប្រព័ន្ធអ៊ីនធឺ-ណែត ព្រឹត្តិបត្រព័ត៌មាននិងឯកសារមកពីប្រភពផ្សេងៗទៀត។ វិធីសាស្ត្រប្រមូលទិន្នន័យសម្រាប់ការស្រាវជ្រាវនេះមានពីរបែបគឺ៖

**១. វិធីសាស្ត្របែបគុណភាព និង បែបបរិមាណ**

វិធីសាស្ត្រនេះ តម្រូវឱ្យមានព័ត៌មានចាំបាច់ដូចជា

ទិន្នន័យទី ១ ៖ សាកសួរផ្ទាល់តាមរយៈកម្រងសំណួរ

ទិន្នន័យទី ២ ៖ ប្រមូលឯកសារដែលមានស្រាប់ដូចជាព្រះរាជក្រឹត្យអនុក្រឹត្យ ឯកសារនានាដែលពាក់ព័ន្ធ Internet ច្បាប់ សារាចរ របាយការណ៍។ល។

**២. វិធីសាស្ត្រវិភាគ**

ទិន្នន័យដែលប្រមូលបានត្រូវធ្វើវិភាគតាមបែបគុណភាពតាម Chi square Test នៃកម្មវិធី SPSS ( Statistic Pakage of Social Science )។

## ៣- លទ្ធផលនៃការស្រាវជ្រាវនិងការពិភាក្សា

### ៣.១- គ្រោះថ្នាក់ការងារដែលកំពុងអនុវត្តក្នុងរោងចក្រ-សហគ្រាស

តារាងទី៤-៣ កម្រិតវប្បធម៌ទូទៅរបស់ប្រជាជន

| បឋម | មធ្យមបឋមភូមិ | មធ្យមទុតិយភូមិ | ឧត្តមសិក្សា | Chi-square | Probability |
|---|---|---|---|---|---|
| ៤១ | ៥៣ | ១៩ | ១ | ៥៦.២៤ | <0.00១ |

បកស្រាយ៖ លទ្ធផលតារាងទី៤-៣ខាងលើបានបញ្ជាក់ពីឱ្យដឹងថាកម្រិតវប្បធម៌ទូទៅរបស់កម្មករភាគច្រើនមានកម្រិតទាបត្រឹមតែបឋមនិងមធ្យមសិក្សាប៉ុណ្ណោះ $p<0.001$ រីឯកម្រិតមធ្យមទុតិយភូមិក៏មានចំនួនតិចដែរ។

តារាងទី៤-៦ ប្រាក់បំណាច់ប្រចាំខែរបស់កម្មករ-និយោជិត

| Mean | Std. Deviation | អប្បបរមា( រៀល ) | អតិបរមា( រៀល ) |
|---|---|---|---|
| ៥១៦ ៤០៨.៥ | ២៩៨.៩០៦.៩៩ | ១២៣ ៦០០ | ១ ៩៣៧ ៩៤០ |

បកស្រាយ៖ លទ្ធផលតារាងទី៤-៦ខាងលើនេះបានបញ្ជាក់ឱ្យដឹងថា មធ្យមភាគប្រាក់បំណាច់ប្រចាំខែរបស់កម្មករ-និយោជិត ៥១៦ ៤០៨.៥០រៀល។

តារាងទី៤-៧ កម្មករធ្លាប់ទទួលរងគ្រោះថ្នាក់នៅកន្លែងធ្វើការ

| មាន | គ្មាន | Chi-square | Probability |
|---|---|---|---|
| ៧៣ | ១ | ៦៨.០៥ | <0.00១ |

បកស្រាយ៖ លទ្ធផលតារាងទី៤-៧ខាងលើនេះបានបញ្ជាក់ឱ្យដឹងថា ជាទូទៅកម្មករធ្លាប់ទទួលរងគ្រោះថ្នាក់នៅកន្លែងធ្វើការស្ទើរតែទ្វេដងជាងអ្នកពុំដែលមានគ្រោះថ្នាក់ដោយ p<0.001។

តារាងទី៤-៩ ប្រភេទគ្រោះថ្នាក់ដែលកើតឡើង

| សន្លប់ | ផ្សេងៗ | Chi-square | Probability |
|---|---|---|---|
| ៧១ | ១ | ៦៨.០៥ | <0.00១ |

បកស្រាយ៖ លទ្ធផលតារាងទី៤-៩ខាងលើនេះបានបញ្ជាក់ឱ្យដឹងថា ប្រភេទគ្រោះថ្នាក់ដែលកើតឡើងញឹកញាប់ជាងគេគឺសន្លប់នៅនឹងកន្លែងដោយ p<0.001 ។

តារាងទី៤-១២ កម្មករ ធ្លាប់ទទួលរងគ្រោះថ្នាក់នៅក្រៅម៉ោងធ្វើការ

| មាន | គ្មាន | Chi-square | Probability |
|---|---|---|---|
| ១១ | ១០១ | ៧២.៣២ | <0.00១ |

បកស្រាយ៖ លទ្ធផលតារាងទី៤-១២ខាងលើនេះបានបញ្ជាក់ឱ្យដឹងថា កម្មករដែលធ្លាប់ទទួលរងគ្រោះថ្នាក់នៅក្រៅម៉ោងធ្វើការមានចំនួនតិចជាងក្នុងម៉ោងធ្វើការ p<0.001។

តារាងទី៤-១៣ ចំនួនដងដែលកម្មករធ្លាប់គ្រោះថ្នាក់ក្រៅម៉ោង

| ១លើក | ២លើក | Chi-square | Probability |
|---|---|---|---|
| ១៣ | ១ | ១០.២៨ | <0.00១ |

បកស្រាយ៖ លទ្ធផលតារាងទី៤-១៣ខាងលើនេះបានបញ្ជាក់ឱ្យដឹងថា កម្មករដែលធ្លាប់គ្រោះថ្នាក់ក្រៅម៉ោងធ្វើការចំនួន១ដងមាន១៣នាក់ p<0.001។

តារាងទី ៤-១៦ ករណីឈប់សម្រាកឆ្លងទន្លេ

| ១ដង | ២ដង | Chi-square | Probability |
|---|---|---|---|
| ១៧ | ២៤ | ១៩.៧២ | <0.00១ |

បកស្រាយ៖ លទ្ធផលតារាងទី៤-១៦ខាងលើនេះបានបញ្ជាក់ឱ្យដឹងថាជាទូទៅកម្មករស្ត្រី ការឆ្លងទន្លេម្តងទៅ២ដងក្នុងពេលបំពេញការងាររបស់ខ្លួនក្នុងខណៈនេះកម្មករ-និយោជិត បានអនុញ្ញាតឱ្យឈប់សម្រាកចំនួន៣ខែ p<0.001។

តារាងទី៤-១៧ តើនិយោជកមានដែលកាត់ប្រាក់បំណាច់ប្រចាំខែសម្រាកឆ្លងទន្លេ ឬទេ?

| មាន | Chi-square | Probability |
|---|---|---|
| ១៦ | | <0.00១ |

បកស្រាយ៖ លទ្ធផលតារាងទី៤-១៧ខាងលើនេះបានបញ្ជាក់ឱ្យដឹងថាមានស្ត្រីមួយចំនួនត្រូវបាននិយោជកកាត់ប្រាក់បៀវត្សដោយការសម្រាកឆ្លងទន្លេp<0.001។

តារាងទី៤-១៩ តើនិយោជកមានបណ្តេញកម្មករចេញពីការងារពេលឈប់សំរាក ឬទេ?

| មាន | គ្មាន | Chi-square | Probability |
|---|---|---|---|
| ១១០ | ២ | ១០៤.១៤ | <0.00១ |

បកស្រាយ៖ លទ្ធផលតារាងទី៤-១៩ខាងលើនេះបានបញ្ជាក់ឱ្យដឹងថា ភាគច្រើននិយោជកបានបណ្តេញកម្មករចេញពេលមានការឈប់សម្រាកច្រើនដងp<0.001។

តារាងទី៤-២០ ការមិនផ្តល់សំណងដល់និយោជិត-កម្មករពីនិយោជក

| មាន | គ្មាន | Chi-square | Probability |
|---|---|---|---|
| ៥ | ១០៤ | ៨៩.៩១ | <0.00១ |

បកស្រាយ៖លទ្ធផលតារាងទី៤-២០ខាងលើនេះបានបញ្ជាក់ឱ្យដឹងថាជាទូទៅពេលមានហានិភ័យម្តងៗនិយោជកពុំដែលផ្តល់សំណងដល់កម្មករទេ p<0.001។

ទន្ទឹមនឹងគ្រោះថ្នាក់នៅនឹងកន្លែងធ្វើការ គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកមានច្រើនសន្ទឹកសន្ធាប់គួរឱ្យកត់សម្គាល់។ គ្រាន់តែក្នុងរយៈពេល៨ឆ្នាំ គឺពីឆ្នាំ២០០០រហូតដល់ឆ្នាំ២០០៧ មានជនរងគ្រោះ ដោយគ្រោះថ្នាក់ចរាចរណ៍ចំនួន៨៣ ៦៥៧នាក់ ដែលក្នុងនោះមានមនុស្សស្លាប់ ៧ ០០២នាក់ របួសធ្ងន់ ២៨ ៨៦០នាក់ របួសស្រាល ៤៧ ៧៩៥នាក់[៩១] ដែលត្រូវចំណាយថវិការាប់រយលានដុល្លារក្នុងមួយឆ្នាំៗ ហើយអ្នករងគ្រោះមួយចំនួនពិការនិងបាត់បង់សមត្ថភាពពលកម្មអស់មួយជីវិត។

តាមការវាយតម្លៃរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន[៩២]មូលហេតុដែលនាំឱ្យមានគ្រោះថ្នាក់ចរាចរណ៍បណ្តាលមកពី ៖

ទី១ កត្តាមនុស្ស ៩៤% ទី២ កត្តាផ្លូវថ្នល់ ១% ទី៣ កត្តាយានជំនិះ ៣% និងទី៤ កត្តាផ្សេងៗ ២%។

តាមលទ្ធផលស្រាវជ្រាវខាងលើបានបង្ហាញឱ្យឃើញថា ពីឆ្នាំ១៩៩៧ដល់ឆ្នាំ២០០៧ ការចុះអង្កេតគ្រោះថ្នាក់ការងារតាមរោងចក្រ សហគ្រាសមានសកម្មភាពតិចតួច ដែលធ្វើឱ្យមានការចកល្វែងគួរឱ្យកត់សម្គាល់។ នៅក្នុងឆ្នាំ២០០៤ដល់ឆ្នាំ២០០៦ មានរោងចក្រ សហគ្រាសសរុបពី ១ ១៨៣ ទៅ ១ ១៦៧ ហើយមានកម្មករនិយោជិតពី ២៦៦ ២៦៣នាក់ទៅ៣០៣ ១៥៧នាក់ គ្រាន់តែ ២៧សហគ្រាសមានកម្មករ-និយោជិតរងគ្រោះរហូតដល់ទៅ ១ ១០៧នាក់ ក្នុងនោះមាន ស្លាប់សន្លប់និងរបួស។ តើរោងចក្រ សហគ្រាសចំនួន ១១៨៣ (ឆ្នាំ២០០៤) ១២២៩ (ឆ្នាំ២០០៥) ១១៦៧(ឆ្នាំ២០០៦) អាចនឹងមានកម្មករ-និយោជិតប៉ុន្មាននាក់ទៀតដែលទទួលរងហានិភ័យការងារ កាលបើគេបានចុះអង្កេតឱ្យបានម៉ត់ចត់និងត្រឹមត្រូវនោះ?

ឆ្នាំ២០០៧ ក្រសួងទទួលបន្ទុកវិស័យការងារបានចុះអង្កេតគ្រោះថ្នាក់ការងារតែ២ក្រុមហ៊ុនតែប៉ុណ្ណោះគឺក្រុមហ៊ុន Global Footwear Co., Ltd និងរោងចក្រកាត់ដេរ MSមានកម្មករ-និយោជិតរងគ្រោះចំនួនសរុប៥៦នាក់ ក្នុងនោះមានស្លាប់ របួសធ្ងន់និងរបួសស្រាល ក្នុងខណៈចំនួនសហគ្រាស គ្រឹះស្ថាន ១៣០៣ ដែលមានកម្មករ-និយោជិតសរុប ៣០៧ ៣៩២នាក់។ ដូច្នេះ យើងអាចសន្និដ្ឋានបានថា ជាមធ្យមចំនួនកម្មករ-និយោជិតដែលទទួលរងហានិភ័យការងារក្នុងឆ្នាំ២០០៧ អាចនឹងកើនឡើងរហូតជាង៣៦ពាន់នាក់។

[៩១] ក្រសួងមានសមត្ថកិច្ចទីនេះ គឺក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

[៩២] ក្រសួងមានសមត្ថកិច្ចទីនេះ គឺក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ឆ្នាំ២០០៨ បន្ទាប់ពីមានការគ្រប់គ្រងដោយបេឡាជាតិរបបសន្តិសុខសង្គមដោយផ្ទាល់ បានបង្ហាញឱ្យឃើញមានកម្មករ-និយោជិតទទួលរងគ្រោះរហូតដល់ ៣ ៧៩២នាក់ក្នុងចំណោមកម្មករ-និយោជិតសរុប៣៥១ ៩៨០នាក់ ក្នុងចំណោមសហគ្រាស គ្រឹះស្ថាន ៩៨៣ ដែលមកចុះបញ្ជីការនៅបេឡាជាតិ។ ស្ថិតិទាំងនេះនៅមិនទាន់គ្រប់គ្រាន់នៅឡើយ បើប្រៀបទៅនឹងរោងចក្រ សហគ្រាសសរុប ១២៧៣ ដែលក្រសួងទទួលបន្ទុកវិស័យការងារបានគ្រប់គ្រង។

រោងចក្រសហគ្រាស គ្រឹះស្ថានដែលក្រសួងទទួលបន្ទុកវិស័យការងារបានគ្រប់គ្រងមកទល់ឆ្នាំ២០០៨ មានចំនួន ១២៧៣ ចំនួនច្រើនជាងគេគឺសហគ្រាសកាត់ដេរសម្លៀកបំពាក់ ដេរស្បែកជើង (៤៣២សហគ្រាស) ក្រុមហ៊ុនពាណិជ្ជកម្ម សិប្បកម្ម សេវាកម្ម។ល។ គេនៅពុំទាន់ឃើញមានក្រុមហ៊ុន សហគ្រាសសំណង់ អាជីវកម្មរ៉ែនិងការដ្ឋានដាំដុះធំៗ ដែលប្រើប្រាស់កម្មកររាប់ម៉ឺននាក់កន្លងទៅ បានគ្រប់គ្រងដោយម៉ត់ចត់និងត្រឹមត្រូវនោះឡើយ ក្នុងរយៈពេល១០ឆ្នាំកន្លងទៅនេះ។

### ៣.២- កង្វះខាតរបស់និយោជកក្នុងការអនុវត្តច្បាប់ការងារតាមរោងចក្រ-សហគ្រាស

ខ្លឹមសារលិខិតប្រកាសលេខ២៤៣សកបយ. ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីការជូនដំណឹងគ្រោះថ្នាក់ការងារ របៀបផ្តល់តាវកាលិកនិងអត្រាបាត់បង់សមត្ថភាពការងារគ្រង់ប្រការ៧ ពុំទាន់ឃើញមាននិយោជក ឬម្ចាស់សហគ្រាសណាមួយអនុវត្តបាននៅឡើយ ចំពោះកម្មករ-និយោជិតរបស់ខ្លួនដែលរបួសរហូតដល់បាត់បង់សមត្ថភាព ជាកាលិកឬជាអចិន្ត្រៃយ៍ដោយផ្នែកឬទាំងស្រុង ក្រោយពីបានព្យាបាលជាសះស្បើយ និយោជកត្រូវឧបត្ថម្ភសម្រាប់ការងារសម្របសម្រួលមុខងារឡើងវិញឬការជួយបង្រៀនវិជ្ជាជីវៈបានសមស្របតាមកាយសម្បទារបស់ជនរងគ្រោះថ្នាក់។

## ៤- សន្និដ្ឋាននិងអនុសាសន៍

### ៤.១- សន្និដ្ឋាន

តាមការសិក្សាស្រាវជ្រាវ គ្រោះថ្នាក់ដែលកើតឡើងនៅនឹងកន្លែងភាគច្រើននៅនឹងសហគ្រាសដេរស្បែកជើងបណ្តាលមកពី៖

១- រោងចក្រសហគ្រាសនោះតូចចង្អៀត ពុំសមស្របទៅនឹងចំនួនកម្មករដែលបម្រើការងារនៅទីនោះ

២- ទីកន្លែងធ្វើការហប់ ពុំមានខ្យល់អុកស៊ីសែនគ្រប់គ្រាន់។

៣- ក្រណាត់និងស្បែកដែលមានបរិមាណច្រើនមានជាតិគីមី។

៤- អាហារហូបចុកប្រចាំថ្ងៃរបស់កម្មករពុំបានសមរម្យ ដោយប្រាក់ឈ្នួលបានត្រឹមតែ៥០ដុល្លាអាម៉េរិកក្នុង ១ខែប៉ុណ្ណោះ គឺចំនួននេះមានចំនួនតិចបំផុតសម្រាប់ការរស់នៅរបស់កម្មករ-និយោជិត។

ក្នុងរយៈពេល៨ឆ្នាំ គឺពីឆ្នាំ២០០០រហូតដល់ឆ្នាំ២០០៧ មានជនរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍ចំនួន ៨៣ ៦៥៧នាក់ ដែលក្នុងនោះមានមនុស្សស្លាប់ ៧ ០០២នាក់ របួសធ្ងន់ ២៨ ៨៦០នាក់ របួសស្រាល ៤៧ ៧៩៥នាក់[៩៣]ក្នុងនោះក៏មានកម្មករ-និយោជិតនៃសហគ្រាសដេររស្បែកជើងមួយចំនួនដែរ។

[៩៣] របាយការណ៍ឆ្នាំ២០០៤ ដល់ឆ្នាំ២០០៧ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

### ៤.២- អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវលើប្រធានបទ"របបហានិភ័យការងារនៅកម្ពុជា"ពីឆ្នាំ១៩៩៧ដល់ឆ្នាំ២០០៨ ទន្ទឹមនឹងលទ្ធផលនៃការសិក្សាស្រាវជ្រាវ ខ្ញុំបាទមានអនុសាសន៍មួយចំនួនដើម្បីរួមចំណែកក្នុងការអនុវត្តគោលនយោបាយវិស័យឯកជន ជាពិសេសរបបហានិភ័យការងារនៅកម្ពុជា ដែលបេឡាជាតិរបបសន្តិសុខសង្គមកំពុងអនុវត្តផ្ទាល់ចាប់ពីឆ្នាំ២០០៨ នេះដូចតទៅ ៖

១- កម្មករ-និយោជិតដែលបាននឹងកំពុងធ្វើការនៅក្នុងសហគ្រាសគ្រឹះស្ថានដែលមានចំនួនក្រោម៨នាក់ចុះគួរត្រូវបានគ្រប់គ្រងរបបហានិភ័យការងារ ដោយបេឡាជាតិរបបសន្តិសុខសង្គមឱ្យបានឆាប់តាមដែលអាចធ្វើទៅបានពុំត្រូវទុកពួកគេឱ្យបន្តអនុវត្តរបបហានិភ័យការងារតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារនេះតទៅទៀតឡើយ។ ខ្ញុំបាទនៅតែមានសុទុដ្ឋិនិយម ព្រួយបារម្ភក្នុងការអនុវត្តគោលនយោបាយរបបហានិភ័យការងារនិងរបបសន្តិសុខសង្គមដទៃទៀត ដោយនិយោជកផ្ទាល់ដែលមានទម្លាប់ដូចពីបណ្តាឆ្នាំកន្លងទៅ ក្នុងខណៈដែលក្រសួងទទួលបន្ទុកវិស័យការងារគ្រប់គ្រងសហគ្រាសទាំងនោះពុំបានជិតដល់ ហើយកម្មករ-និយោជិតជាជនរងគ្រោះថ្នាក់ការងារពុំបានយល់ដឹងពីគោលនយោបាយគ្រោះថ្នាក់ការងារដែលនឹងទទួលខុសត្រូវពីនិយោជកដោយផ្ទាល់។

២- គួរសហប្រតិបត្តិការជាមួយអគ្គនាយកដ្ឋានពន្ធដារ ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការគ្រប់គ្រងស្ថិតិកម្មករ-និយោជិតនិងសហគ្រាស គ្រឹះស្ថានដែលត្រូវបង់ពន្ធតាមរបបពិតនិងម៉ៅការ ព្រោះថាមកទល់ពេលនេះគ្មានសហគ្រាស គ្រឹះស្ថានណាមួយរួចចាកផុតពីការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារដើម្បីបង់ពន្ធដារជូនរដ្ឋឡើយ។

៣- ផ្នែកសោធននិវត្តគួរបន្តអនុវត្តបន្ទាប់ពីរបបហានិភ័យការងារព្រោះថាកម្មករ-និយោជិតមួយចំនួនបានចូលធ្វើការតាំងពីឆ្នាំ១៩៩៧ រហូតដល់បច្ចុប្បន្ន ធ្វើឱ្យពួកគេកាន់តែបាត់បង់នូវអតីតភាពការងារ ទម្រាំដល់ឆ្នាំអាយុចូលនិវត្ត។

៤- ទីតាំងនិងបច្ចេកទេសនៃការសាងសង់គ្រឹះស្ថាន សហគ្រាសគួរតែត្រូវបានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនិងបច្ចេកទេសឱ្យបានត្រឹមត្រូវជាមុន ជៀសវាងបញ្ហាដែលនឹងអាចកើតឡើងជាយថាហេតុ ដូចជាទីតាំងតូចចង្អៀត ហាប់ និង ខ្វះពន្លឺ មានជាតិគីមី ដែលនាំឱ្យប៉ះពាល់ដល់សុខភាពកម្មករ-និយោជិតដែលកំពុងបំពេញការងារដែលតែងតែកើតឡើងជារឿយៗ ពិសេសនៅក្នុងរោងចក្រសហគ្រាសកាត់ដេរសម្លៀកបំពាក់ និងដេរស្បែកជើង។

៥- ការរៀបចំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ គួរសិក្សាស្រាវជ្រាវឱ្យបានសមស្រប ដើម្បីជៀសវាងគ្រោះថ្នាក់ចរាចរណ៍ដែលមានទំហំតូចចង្អៀត។ ដូច្នេះការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់គួរសិក្សាពីការរៀបចំសុវត្ថិភាពពីបណ្តាប្រទេសជឿនលឿនដែលមានអត្រាគ្រោះថ្នាក់ចរាចរណ៍ទាបបំផុត បើប្រៀបមកប្រទេសជាតិរបស់យើង។

៦- ការចាត់ចែងនិងគ្រប់គ្រងការវិនិយោគមូលនិធិសន្តិសុខសង្គមដែលមានចែងក្នុងចំណុច៧ នៃមាត្រា៣ នៃអនុក្រឹត្យលេខ១៦អនក្រ.បក. ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់សភាពការណ៍បច្ចុប្បន្នគួរផ្តោតអារម្មណ៍វិនិយោគទុនទៅលើវិស័យមីក្រូឥណទាននាពេលអនាគត ពីព្រោះមានហានិភ័យទាបជាងគេបើប្រៀបទៅនឹងការវិនិយោគដទៃទៀត។ ធ្វើយ៉ាងដូច្នេះបានទាល់តែត្រៀមធនធានមនុស្ស និងបណ្តុះបណ្តាលចាប់ពីពេលនេះទៅ។

៧- គួរពង្រឹងការងារធ្វើអធិការកិច្ចឱ្យបានម៉ឺងម៉ាត់និងជាប់ជាប្រចាំដល់រោងចក្រ សហគ្រាស គ្រឹះស្ថានទាំងការផ្សព្វផ្សាយច្បាប់និងការអនុវត្តច្បាប់ស្តីពីការងារនិងច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ

ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឱ្យបានទូលំទូលាយ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ការងារនៅនឹងកន្លែងធ្វើការឱ្យមានប្រសិទ្ធភាព។ ការយកចិត្តទុកដាក់នឹងការបណ្តុះបណ្តាលធនធានមនុស្សគឺមន្ត្រីរាជការដែលកំពុងបម្រើការងារផ្នែកនេះឱ្យបានសមស្របទៅនឹងសមត្ថភាពបច្ចេកទេសបច្ចុប្បន្ននិងសីលធម៌សង្គម។

# គន្ថនិទ្ទេស


១- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរបាយការណ៍ប្រចាំឆ្នាំ២០០៧
២- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ របាយការណ៍ឆ្នាំ២០០៤ដល់ឆ្នាំ២០០៨
៣- ក្រសួងសាធារណការនិងដឹកជញ្ជូន របាយការណ៍ឆ្នាំ២០០៤ដល់ឆ្នាំ២០០៧

# ដំណើរអាជីវកម្មនាំចូលនិងនាំចេញតាមមាត់ច្រកអន្តរជាតិ ភ្នំដិន

បេក្ខជនបណ្ឌិត **ចិន្តា បណ្ឌិត**
ផ្នែកគ្រប់គ្រង



## ១- សេចក្តីផ្តើម

ការលើកយកប្រធានបទស្តីពីដំណើរការអាជីវកម្មនាំចូលនិងនាំចេញតាមមាត់ច្រកអន្តរជាតិភ្នំដិនមកសិក្សាស្រាវជ្រាវ ដោយហេតុថា កន្លងមកបានសង្កេតឃើញថាការផ្តល់សេវាកម្មគយដល់ធុរជនដែលដំណើរការអាជីវកម្មនាំចូលនិង/ឬនាំចេញតាមមាត់ច្រកអន្តរជាតិនេះនៅមានកម្រិតនៅឡើយ ព្រោះនៅមានឧបសគ្គរាំងមិនមែនពន្ធហើយបញ្ហាប្រឈមនានាក៏មិនទាន់បានដោះស្រាយនៅឡើយ។

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះក្នុងគោលបំណង ដើម្បីស្វែងរកឱ្យឃើញនូវកត្តាប្រឈមនានា ចំណុចខ្លាំង ចំណុចខ្សោយ ឱកាសនិងចំណុចខ្វះខាតលើការផ្តល់សេវាកម្មគយដល់ធុរជន(SWOT analysis)។

## ២- វិធីសាស្ត្រស្រាវជ្រាវ

### ២-១- ការជ្រើសរើសសំណាក

ទីកន្លែងសម្រាប់ការសិក្សាស្រាវជ្រាវគឺមាត់ច្រកអន្តរជាតិភ្នំដិនដែលស្ថិតនៅក្នុងភូមិ ផ្សារ ឃុំ ភ្នំដិន ស្រុកគីរីវង់ ខេត្តតាកែវ ភាគខាងត្បូងនៃព្រះរាជាណាចក្រកម្ពុជាជាប់ព្រំដែននៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលមានចម្ងាយប្រហែល១២៧គីឡូម៉ែត្រពីរាជធានីភ្នំពេញនិងមានចម្ងាយប្រហែល៤៧គីឡូម៉ែត្រ ពីទីរួមខេត្តតាកែវតាមបណ្តោយផ្លូវជាតិលេខ២។

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងចំពោះតែធុរជនដែលដំណើរអាជីវកម្មនាំចូលនិង/ឬនាំចេញតាមមាត់ច្រកអន្តរជាតិភ្នំដិន ដែលមានចំនួនសរុបទាំងអស់១៣០នាក់។ ការជ្រើសរើសទំហំសំណាកពីសកលស្ថិតិ មិនបានអនុវត្តតាមរបៀបជ្រើសរើសដោយចៃដន្យ(Random Sampling)ទេ តែបានអនុវត្តដោយការជ្រើសរើសយកទាំងអស់គឺ ១០០%(មួយរយភាគរយ)។ ដូច្នេះទំហំសំណាកដែលបានជ្រើសរើសយកចេញពីសកលស្ថិតិមានចំនួនសរុបទាំងអស់ ១៣០នាក់ (n = ១៣០នាក់)។

### ២-២- ការប្រមូលទិន្នន័យបឋម

ទិន្នន័យបឋម ជាទិន្នន័យសំខាន់បំផុតដែលប្រមូលបានពីសំណាកតាមរយៈការប្រើប្រាស់នូវឧបករណ៍ប្រមូលទិន្នន័យសំខាន់ៗមាន កម្រងសំណួរ ការសម្ភាសន៍និងការសង្កេត។

### ២-៣- ការប្រមូលទិន្នន័យមានស្រាប់

ទិន្នន័យមានស្រាប់ជាទិន្នន័យគួបផ្សំបន្ថែម ដែលប្រមូលបានពីប្រភពផ្សេងៗជាច្រើនរួមមាន អ៊ីនធឺណិត (Internet) និងឯកសារនានាដែលពាក់ព័ន្ធ។

## ២-៤- វិធីសាស្ត្រវិភាគ (Method of Analysis Used)

ទិន្នន័យដែលប្រមូលបានត្រូវធ្វើវិភាគរកតម្លៃភាគរយ(%) មធ្យមភាគនិងឈីខ្វែរ(Chi-square Test) តាមកម្មវិធី SPSS (Social Package of Social Science)។

# ៣- លទ្ធផលនៃការស្រាវជ្រាវ

១- លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញឱ្យឃើញថាការអប់រំរបស់ធុរជនភាគច្រើនមានកម្រិតត្រឹមមធ្យមសិក្សាបឋមភូមិ p<0.00១។

២- ធុរជនប្រកបអាជីវកម្មនាំចេញនាំចូលតាមមាត់ច្រកអន្តរជាតិភ្នំដិនភាគច្រើនមានទំហំតូច។

តារាងទី១- ទំហំអាជីវកម្មនាំចេញ និង/ឬនាំចូលរបស់ធុរជន

| ល.រ. | ទំហំអាជីវកម្ម | ចំនួនអ្នកឆ្លើយតប(F) | Chi-Square | Probability |
|---|---|---|---|---|
| ១ | កម្រិតធំ | ០នាក់ | ៨៦.៨០ | <0.00១ |
| ២ | កម្រិតមធ្យម | ២៦នាក់ | | |
| ៣ | កម្រិតតូច | ១០៤នាក់ | | |
| ៤ | ផ្សេងៗ | ០នាក់ | | |
| | សរុប | ១៣០នាក់ | | |

៣- មន្ត្រីគយនៃទីស្នាក់ការគយនិងរដ្ឋាករភ្នំដិនបានប្រកាន់ខ្ជាប់នូវឥរិយាបទសមរម្យនិងថ្លៃថ្នូរចំពោះធុរជនដែលបានប្រកបអាជីវកម្មនាំចេញនិងនាំចូលតាមមាត់ច្រកអន្តរជាតិភ្នំដិន។

៤- មន្ត្រីគយនិងរដ្ឋាករបានបំពេញបែបបទនិងទម្រង់ការគយផ្សេងៗជូនធុរជនបានរហ័សដោយបានប្រើប្រាស់នូវរយៈពេលចាប់ពី ៣០នាទីរហូតដល់៦០នាទី។

៥- ការបំពេញបែបបទគយនិងទម្រង់ការគយផ្សេងៗ នៅមាត់ច្រកអន្តរជាតិភ្នំដិនបានទទួលការពេញចិត្តកម្រិតល្មមពីធុរជន។

តារាងទី២- កម្រិតនៃការពេញចិត្តរបស់ធុរជន ចំពោះការបំពេញបែបបទបញ្ចេញទំនិញពីគយ

| ល.រ. | កម្រិតនៃការពេញចិត្ត | ចំនួនអ្នកឆ្លើយតប(F) | Chi-Square | Probability |
|---|---|---|---|---|
| ១ | ពេញចិត្តខ្លាំង | ០នាក់ | ៨០.៦០ | <0.00១ |
| ២ | ពេញចិត្តបង្គួរ | ០នាក់ | | |
| ៣ | ពេញចិត្ត | ២៦នាក់ | | |
| ៤ | ពេញចិត្តល្មម | ៩១នាក់ | | |
| ៥ | មិនសូវពេញចិត្ត | ១៣ នាក់ | | |
| | សរុប | ១៣០នាក់ | | |

៦-របាំងមិនមែនពន្ធដែលបាននឹងកំពុងកើតមានឡើងនៅមាត់ច្រកអន្តរជាតិភ្នំដិនគឺមានប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់ ការិយាធិបតេយ្យនិងការបង្ខាំងទុកឯកសារយូរដើម្បីផលប្រយោជន៍អ្វីមួយ។ ប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់មានចាប់ពី ៣កន្លែងទៅ៨កន្លែង ដែលឈរជើងចាប់ពីមាត់ច្រកចូលរហូតដល់ក្នុងភូមិសាស្ត្រខេត្ត តាកែវ។

តារាងទី៣- ចំនួនប៉ុស្តិ៍ក្រៅច្បាប់ ចាប់ពីមាត់ច្រកអន្តរជាតិភ្នំដិនរហូតដល់ភូមិសាស្ត្រខេត្តតាកែវ

| ល.រ. | ចំនួនប៉ុស្តិ៍ក្រៅច្បាប់ | ចំនួនអ្នកឆ្លើយតប(F) | Chi-Square | Probability |
|---|---|---|---|---|
| ១ | ៨កន្លែង | ២៥នាក់ | ១៧.១៤ | <0.00១ |
| ២ | ៧កន្លែង | ២៥នាក់ | | |
| ៣ | ៦កន្លែង | ៧នាក់ | | |
| ៤ | ៥ កន្លែង | ៣៣នាក់ | | |
| ៥ | ៤ កន្លែង | ២០នាក់ | | |
| ៦ | ៣ កន្លែង | ២០នាក់ | | |
| | សរុប | ១៣០នាក់ | | |

៧-ទីតាំងផលិតទំនិញមានចម្ងាយឆ្ងាយជាងមាត់ច្រកដទៃ ដែលជាប់ព្រំដែនប្រទេសវៀតណាមដូចគ្នា។ ធុរជនត្រូវចំណាយសោហ៊ុយលើការដឹកជញ្ជូនខ្ពស់ជាងច្រកដទៃដូចជា មាត់ច្រកអន្តរជាតិបាវិតខេត្តស្វាយរៀង និងមាត់ច្រកត្រពាំងផ្លុងនៃខេត្តកំពង់ចាម។

តារាងទី៤- ការប្រៀបធៀបអំពីចំណាយលើការដឹកជញ្ជូនពីមាត់ច្រកភ្នំដិនទៅរាជធានីភ្នំពេញជាមួយមាត់ច្រកដទៃដែលជាប់ព្រំដែនប្រទេសវៀតណាមដូចគ្នាក្នុង១លើកៗ។

| ល.រ | កម្រិតនៃការចំណាយលើការដឹកជញ្ជូន | ចំនួនអ្នកឆ្លើយតប(F) | Chi-Square | Probability |
|---|---|---|---|---|
| ១ | ខ្ពស់ជាងមាត់ច្រកដទៃ | ៨៥នាក់ | ៦៤.២៦ | <0.00១ |
| ២ | ប្រហាក់ប្រហែលគ្នា | ៣២នាក់ | | |
| ៣ | ទាបជាង | ១៣នាក់ | | |
| | សរុប | ១៣០នាក់ | | |

៨-ការបំពេញបែបបទផ្តល់សេវាកម្មជូនធុរជនគឺស្ថិតក្នុងរយៈពេលចាប់ពីក្រោម៣០នាទីទៅ៣០នាទី។

៩- ធុរជនដែលប្រតិបត្តិការនាំចូលនិង/ឬនាំចេញតាមមាត់ច្រកអន្តរជាតិភ្នំដិន បានសំណូមពរដល់ស្ថាប័នគយសម្រួលបែបបទគយ និង ផ្តល់សេវាឱ្យបានឆាប់និងពេញចិត្តជួយអន្តរាគមន៍លើប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់ដែលធ្វើឱ្យស្ទះដល់លំហូទំនិញ បង្កើនប្រាក់ចំណាយដែលមានផលប៉ះពាល់អវិជ្ជមានដល់អាជីវកម្មពួកគាត់។

តារាងទី៥- សំណូមពរសំខាន់ៗរបស់ធុរជន ចំពោះការផ្តល់សេវាកម្មគយនៅច្រកអន្តរជាតិភ្នំដិន

| ល.រ. | សំណូមពរសំខាន់ៗរបស់ធុរជន | ចំនួនអ្នកឆ្លើយតប | Chi-Square | Probability |
|---|---|---|---|---|
| ១ | ជួយសម្រួលនិតិវិធីនឹងផ្តល់សេវាកម្មគយឱ្យបានឆាប់ | ៦៤នាក់ | ៨៣.៣0 | <0.00១ |
| ២ | លុបបំបាត់ប៉ុស្តិ៍ក្រៅច្បាប់និងបន្ថយការបង់ប្រាក់ពន្ធ | ២៦នាក់ | | |
| ៣ | ពន្លឿនការត្រួតពិនិត្យឯកសារនិងទំនិញឱ្យឆាប់ | ២៦នាក់ | | |
| ៤ | សូមស្ថាប័នគយជួយអន្តរាគមន៍លើប៉ុស្តិ៍ក្រៅច្បាប់ | ៧នាក់ | | |
| ៥ | ពុំមានសំណូមពរ | ៧នាក់ | | |
| | សរុប | ១៣០នាក់ | | |

## ៤- ការពិភាក្សាលើលទ្ធផលនៃការស្រាវជ្រាវ

យើងលើកយកតែចំណុចខ្លាំងនិងចំណុចខ្សោយចាំបាច់មួយចំនួនមកពិភាក្សាដូចខាងក្រោម៖

### ៤-១- ចំណុចខ្លាំង

១- អាកប្បកិរិយានិងសម្តីរបស់មន្ត្រីរាជការគយនិងរដ្ឋាករប្រព្រឹត្តចំពោះធុរជនលទ្ធផលបានបង្ហាញថា មន្ត្រីគយនៃទីស្នាក់ការគយនិងរដ្ឋាករភ្នំដិនបានប្រកាន់ខ្ជាប់នូវឥរិយាបថសមរម្យនិងថ្លៃថ្នូរ ចំពោះធុរជនដែលបានប្រកបអាជីវកម្មនាំចេញនិងនាំចូលតាមមាត់ច្រកអន្តរជាតិនេះ ដោយពួកគាត់បានយល់ដឹងច្បាស់អំពីគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងវិស័យឯកជន ព្រោះថា វិស័យនេះត្រូវរាជរដ្ឋាភិបាលចាត់ទុកជាក្បាលម៉ាស៊ីនសេដ្ឋកិច្ចជាតិ។

២- រយៈពេលនៃការបំពេញបែបបទបានរហ័សដោយបានប្រើប្រាស់នូវរយៈពេលចាប់ពីក្រោម ៣០នាទី រហូតដល់ត្រឹម៣០នាទី និង ត្រឹម៣០នាទី រហូតដល់ ៦០នាទី $p<0.05$។

៣- វិធានការផ្តល់សេវាកម្មគយបានរហ័ស ពេញចិត្តនិងគួរឱ្យទុកចិត្តដល់ធុរជន

៤- កម្រិតនៃការពេញចិត្តរបស់ធុរជនចំពោះការបំពេញបែបបទ ដើម្បីបញ្ចេញទំនិញពីគយទិន្នន័យបានបង្ហាញថា ការបំពេញបែបបទគយនិងទម្រង់ការគយផ្សេងៗនៅមាត់ច្រកអន្តរជាតិភ្នំដិនបានទទួលការពេញចិត្តកម្រិតល្អមពីធុរជន $p<0.001$។

### ៤-២- ចំណុចខ្សោយ

១- ការអប់រំរបស់ធុរជនភាគច្រើនមានកម្រិតត្រឹមមធ្យមសិក្សាបឋមភូមិ $p<0.001$ នេះ បញ្ជាក់ថា ពួកគាត់ពិតជាមានការលំបាកច្រើនក្នុងការប្រកបអាជីវកម្មនិងមុខរបរផ្សេងៗទៀតនិងមិនយល់ដឹង បានស៊ីជម្រៅអំពីនិតិវិធីគយ ការបំពេញបែបបទគយនិងទម្រង់ការផ្សេងៗ ជាពិសេស កាតព្វកិច្ចពន្ធ។

២- របាំងមិនមែនពន្ធ លទ្ធផលស្រាវជ្រាវបានបង្ហាញឃើញថារបាំងមិនមែនពន្ធដែលបាននឹងកំពុងកើតមានឡើងនៅមាត់ច្រកអន្តរជាតិភ្នំដិនគឺមានប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់ ការិយាធិបតេយ្យនិងការបង្ខាំងទុកឯកសារយូរ ដើម្បីផលប្រយោជន៍អ្វីមួយ $p>0.05$។ របាំងមិនមែនពន្ធនេះហើយដែលបណ្តាលឱ្យមានការចំណាយក្រៅផ្លូវការធ្វើឱ្យថ្លៃដើមទំនិញនាំចូលកើនឡើង លំហូទំនិញនាំចូលឬនាំចេញពុំមានភាពល្អប្រសើរនិងអាចធ្វើឱ្យធុរជនមានភាពខ្លាចរអាមិនហ៊ាននាំចូលឬកាត់បន្ថយនូវការនាំចូលឬនាំចេញរបស់ពួកគេ។

៣- ប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់ លទ្ធផលបានបង្ហាញឱ្យឃើញថា នៅមានប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់ចាប់ពី៣កន្លែងទៅ៨កន្លែងដែលបោះទីតាំងនៅតាមដងផ្លូវជាតិ ចាប់ពីច្រកចូលរហូតដល់ក្នុងភូមិសាស្ត្រខេត្តតាកែវ។

### ៤-៣- ឱកាស

១- ភាពរហ័សនៃការបំពេញបែបបទគយជូនធុរជន

ការធ្វើសាមញ្ញកម្មនៃនិតិវិធីគយនិងការសម្រួលបែបបទគយឱ្យបានឆាប់គឺជាប្រការមួយដែលចាំបាច់បំផុតសម្រាប់លំហូរទំនិញនាំចូលនិងនាំចេញ ដើម្បីឱ្យធុរជនដែលប្រតិបត្តិការនាំទំនិញចូលនិងនាំទំនិញចេញតាមមាត់ច្រកអន្តរជាតិភ្នំដិនមានឱកាសបានយកទំនិញទៅធ្វើអាជីវកម្មលក់ដូរទាន់ពេលតាមតម្រូវការរបស់អតិថិជននៅលើទីផ្សារ។ ទិន្នន័យបានឱ្យដឹងថា មន្ត្រីគយបានបំពេញបែបបទជូនធុរជនបានរហ័ស ដោយពួកគាត់បានយល់ដឹងនិងបានអនុវត្តការធ្វើសាមញ្ញកម្មនៃនិតិវិធីគយនិងការសម្រួលបែបបទគយឱ្យបានឆាប់រហ័សដល់ធុរជនសមស្របតាមច្បាប់ស្តីពីគយនិងបទបញ្ញត្តិនានាជាធរមាន។

### **៤-៤- ឧបសគ្គ**

- របាំងមិនមែនពន្ធ

- នៅមានប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់ចាប់ពី៣កន្លែងទៅ៨កន្លែង ដែលបោះទីតាំងនៅតាមដងផ្លូវជាតិចាប់ពីមាត់ច្រកចូលរហូតដល់ក្នុងភូមិសាស្ត្រខេត្តតាកែវ។

## **៥- សន្និដ្ឋាន**

លទ្ធផលនៃការសិក្សាស្រាវជ្រាវ លើប្រធានបទអំពី **ដំណើរការអាជីវកម្មនាំចូលនិងនាំចេញ តាមមាត់ច្រកអន្តរជាតិភ្នំដិន** ដែលមានវិសាលភាពចាប់ពីឆ្នាំ២០០២ រហូតដល់ឆ្នាំ២០១១ បានបញ្ជាក់ឱ្យដឹងថា ការផ្តល់សេវាកម្មគយជូនដល់ធុរជនដែលប្រកបអាជីវកម្មនាំចូលនិង/ឬចេញតាមមាត់ច្រកអន្តរជាតិភ្នំដិនមានទាំងគុណ-សម្បត្តិនិងគុណវិបត្តិដូចខាងក្រោមនេះ

**គុណសម្បត្តិ** : វិធានការសមស្របមួយចំនួនត្រូវបានប្រតិបត្តិ ដូចជាលុបបំបាត់នូវភាពអសកម្មក្នុងការបំពេញបែបបទគយត្រូវមានក្រមសីលធម៌ក្នុងការងារនិងមានទំនាក់ទំនងល្អជាមួយនិងធុរជន។

មន្ត្រីគយនិងរដ្ឋាករបានបំពេញបែបបទនិងទម្រង់ការគយផ្សេងៗជូនធុរជនបានរហ័សដោយបានប្រើប្រាស់នូវរយៈពេលចាប់ពីក្រោម ៣០នាទីរហូតដល់ត្រឹម៣០នាទី និង ត្រឹម៣០នាទី រហូតដល់ ៦០នាទី $p<0.05$។ ការបំពេញបែបបទនិងទម្រង់ការគយផ្សេងៗក៏ទទួលបាននូវការពេញចិត្តពីធុរជនផងដែរ $p>0.05$។

**គុណវិបត្តិ** : របាំងមិនមែនពន្ធបានកើតមានឡើងនៅក្នុងទីស្នាក់ការគយនិងរដ្ឋាករភ្នំដិនដែលនៅក្នុងនោះមានជាអាទិ៍ ការិយាធិបតេយ្យ ការបង្ខាំងទុកឯកសារយូរដើម្បីប្រយោជន៍អ្វីមួយ ប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់ដែលឈរជើងពីមាត់ច្រកចូលរហូតដល់ក្នុងភូមិសាស្ត្រខេត្តតាកែវ $p>0.05$។ ចំពោះ ឯកសារសម្រាប់ទំនិញនាំចូលនិង/ឬនាំចេញត្រូវតម្រូវឱ្យឆ្លងកាត់ការត្រួតពិនិត្យអង្គភាពដទៃដែលមិនមែនជាស្ថាប័នគយមានអង្គភាពនគរបាលបសុពេទ្យនិងកាំកុងត្រូល $p>0.05$។

ចំពោះការអប់រំរបស់ធុរជន ភាគច្រើនមានកម្រិតត្រឹមមធ្យមសិក្សាបឋមភូមិ $p<0.001$ នេះ បញ្ជាក់ថាពួកគាត់ពិតជាមានការលំបាកច្រើនក្នុងការប្រកបអាជីវកម្មនិងមុខរបរផ្សេងៗទៀតនិងមិនសូវ យល់ដឹងបានស៊ីជម្រៅអំពីនីតិវិធីគយ ការបំពេញបែបបទគយ ទម្រង់ការផ្សេងៗ ជាពិសេស កាតព្វកិច្ចពន្ធ ហើយពួកគាត់ភាគច្រើនបានប្រកបអាជីវកម្មនាំចេញនិង/ឬនាំចូលមានកម្រិតតូច ដោយប្រើប្រាស់ដើមទុនគិតជាមធ្យមភាគគឺ ចាប់ពី ១,១៨៧,៩០៤ (មួយលានមួយរយប៉ែតសិបប្រាំពីរពាន់និង ប្រាំបួនរយបួន)ទៅ ១៥,៧៦៣,៦៣៣ (ដប់ប្រាំលានប្រាំពីររយហុកសិបបីពាន់និងប្រាំមួយរយសាមសិបបី)រៀល ដោយមិនគិតពីទំហំអាជីវកម្ម $p<0.001$។

ចំពោះប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់វិញ គិតជាមធ្យម មានចំនួនចាប់ពី ៣កន្លែងទៅ៨កន្លែង ដែលឈរជើងពីមាត់ច្រកចូលរហូតដល់ក្នុងភូមិសាស្ត្រខេត្តតាកែវ ហើយការចំណាយសរុបសម្រាប់ ប៉ុស្តិ៍ទាំងនេះគិតជាមធ្យមភាគគឺ២៧៣,៥៥៩(ពីររយចិតសិបបីពាន់និងប្រាំរយហាសិបប្រាំបួន)រៀល ក្នុងមួយលើកៗ។

ដោយសារកត្តាភូមិសាស្ត្រមានចម្ងាយផ្លូវឆ្ងាយជាងមាត់ច្រកដទៃ ដែលជាប់ព្រំដែនប្រទេសវៀតណាមដូចគ្នាបានធ្វើឱ្យការចំណាយសោហ៊ុយលើការដឹកជញ្ជូនតាមផ្លូវគោកគិតជាមធ្យមភាគ គឺ ៧០២,៨៦៧រៀល។

សរុបសេចក្តីមក មានការពេញចិត្តពីធុរជនលើការផ្តល់សេវាកម្មគយ។ ចំពោះចំណុចខ្សោយ វិញមានដូចជាប៉ុស្តិ៍ត្រួតពិនិត្យក្រៅច្បាប់ច្រើននាំឱ្យមានការចំណាយច្រើន ទំហំពាណិជ្ជកម្មមានទ្រង់ទ្រាយតូច សេវាកម្មមិនទាន់សូវល្អនិងទីតាំងមិនអំណោយផល។

# គន្ថនិទ្ទេស

១-ជួន ណាត ***វចនានុក្រមខ្មែរ*** ភាគ ១-២ ការផ្សាយរបស់ពុទ្ធសាសនាបណ្ឌិត្យ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧។
២-The United Nations Conference on Trade and Development (UNCTAD), Technical Note N$^{o}$ 21, ***Automated System for Customs Data (ASYCUDA)***.

# ការគ្រប់គ្រងនិងការអភិវឌ្ឍកំពង់ផែស្វយ័តភ្នំពេញ

បេក្ខបណ្ឌិត **ជា ម៉ុនធឿន**
ផ្នែកគ្រប់គ្រង

## ១- សេចក្ដីផ្ដើម

ក្រោយពេលដែលប្រទេសកម្ពុជាបានរួចផុតពីសង្គ្រាមដែលអូសបន្លាយពេលជាងពីរទសវត្សរ៍មកហើយនេះ រាជរដ្ឋាភិបាលបានខិតខំស្តារនិងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធស្ទើរតែគ្រប់វិស័យនៃខឿន សេដ្ឋកិច្ចជាតិ។ តួយ៉ាង វិស័យគមនាគមន៍គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងសេដ្ឋកិច្ច ដែលបម្រើសេវាកម្ម ផ្នែកដឹកជញ្ជូននិងចរាចរទៅមក របស់ប្រជាពលរដ្ឋផងដែរ។ មុនឆ្នាំ១៩៥២ យើងមានតែផ្លូវគោកនិងផ្លូវដែកប៉ុណ្ណោះដែលជាមធ្យោបាយធ្វើដំណើរ និងដឹកជញ្ជូនផ្សេងៗទៀត តែដោយសារតែមានការរីកចម្រើនផ្នែកបច្ចេកវិជ្ជាបានអភិវឌ្ឍវិស័យគមនាគមន៍ឱ្យមាន ការរីកលូតលាស់ឡើងដល់កម្រិតមួយគួរឱ្យ កត់សម្គាល់។ ជាក់ស្តែងដូចជាផ្លូវអាកាសនិងផ្លូវទឹកជាដើម ក៏បានផ្តល់ជាមធ្យោបាយមួយបែបផ្សេងទៀតផងដែរ ក្នុងការធ្វើដំណើរនិងដឹកជញ្ជូនដែលតម្រូវទៅតាមកាលៈទេសៈនិងទីតាំងភូមិសាស្ត្ររបស់គោលដៅដែលយើងចង់ទៅ ហើយជាពិសេស មធ្យោបាយទាំងនោះអាចជំនួសឱ្យគ្នាបានថែមទៀតផង។ ផ្នែកមួយដែលផ្តល់សេវាកម្មលើវិស័យគមនាគមន៍នេះគឺ កំពង់ផែ។

**កំពង់ផែ** ជាកន្លែងមួយដ៏សំខាន់ដែលជាដង្ហើមនៃសេដ្ឋកិច្ចជាតិ ព្រោះថា វាជាច្រកទ្វារចេញចូលរាល់ទំនិញផ្សេងៗមិនថា ជាទំនិញក្នុងស្រុកសម្រាប់នាំចេញឬទំនិញពីបរទេស ដែលនាំចូលនោះទេ។ កំពង់ផែ គឺជាផ្នែកមួយនៃវិស័យគមនាគមន៍ដែលបម្រើឱ្យពាណិជ្ជកម្មជាតិនិងអន្តរជាតិ ព្រមទាំងជាកន្លែងប្រមូលផ្តុំគ្រប់មធ្យោបាយដឹកជញ្ជូន រថយន្ត រថភ្លើង យន្តហោះ នាវាសមុទ្រ និងទំនិញបែងចែកតាមខេត្តនានានិងប្រមូលផ្តុំចរាចរណ៍ទំនិញគ្រប់ប្រទេស ផលិតផលកសិកម្មនិងឧស្សាហកម្ម។

## ២ - វិធីសាស្ត្រស្រាវជ្រាវ

### ២-១- ការជ្រើសរើសសំណាក

ការសិក្សានេះ ប្រើវិធីសាស្ត្រស្រាវជ្រាវបែបអង្កេតស្រាវជ្រាវ(Survey Research)ដោយបានធ្វើសម្ភាសអ្នកត្រួតការ-អ្នកគ្រប់គ្រងចំនួន ៨នាក់និងបុគ្គលិក-កម្មករចំនួន១៦៨នាក់ក្នុងការិយាល័យចំនួន៤ អំពីការគ្រប់គ្រងអាជីវកម្ម។ ការគណនាទំហំសំណាក ដូចរូបមន្តខាងក្រោម៖

$$n = \frac{N}{1+Ne^2}$$

- n = ទំហំសំណាកគំរូ ដែលត្រូវសម្ភាសន៍
- N = ចំនួន អ្នកត្រួតការ - អ្នកគ្រប់គ្រង និងបុគ្គលិក - កម្មករ សរុបទាំងអស់
- e = កម្រិតលម្អៀង ១…………..១២%

n = ៤៤២/១ + ៤៤២ (0,0៥៨) ២ = ១៧៦ នាក់

ការជ្រើសរើសយកទំហំសំណាក អាស្រ័យដោយចំនួនអ្នកត្រួតការ-អ្នកគ្រប់គ្រងនិងបុគ្គលិក-កម្មករជាអ្នកធ្វើការជូនកំពង់ផែស្វយ័តភ្នំពេញមានចំនួន ៤៤២នាក់និងមានកម្រិតលម្អៀង ០,០៥៨%។ ជាលទ្ធផលយើងទទួលបានទំហំសំណាកគំរូត្រឹមតែ ១៧៦នាក់ ប្រហែល ៤០ភាគរយ សម្រាប់ធ្វើសម្ភាសន៍អ្នកត្រួតការ-អ្នកគ្រប់គ្រងនិងបុគ្គលិក-កម្មករជាអ្នកធ្វើការជូនកំពង់ផែស្វយ័តភ្នំពេញ។

### ២-២- ការប្រមូលទិន្នន័យទី២ ( Secondary Data )

ទិន្នន័យទី២៖ ជាទិន្នន័យដែលបានដកស្រង់ពីឯកសារដែលមានស្រាប់ផ្សេងៗ ជាពិសេស និក្ខេបបទ អត្ថបទវិទ្យាសាស្ត្រ សៀវភៅពុម្ព ស្ថិតិតាមអង្គភាពនានា។ល។

### ២-៣- វិធីសាស្ត្រវិភាគ

ទិន្នន័យដែលប្រមូលបានធ្វើវិភាគតាមបែបគុណភាពនិងគុណភាពតាម Chi-square test, ANOVA នៃកម្មវិធី SPSS ( Statistic Package of Social Science )

## ៣- លទ្ធផលនៃការស្រាវជ្រាវនិងការពិភាក្សា

### ៣-១- ការគ្រប់គ្រង

ការគ្រប់គ្រងជាការធ្វើផែនការ ចាត់តាំង ដឹកនាំនិងត្រួតពិនិត្យលើការប្រើប្រាស់ធនធានមនុស្សនិងធនធានដទៃទៀតដើម្បីសម្រេចគោលដៅអង្គការចាត់តាំងដោយមានប្រសិទ្ធភាពខ្ពស់បំផុត[៥៤]។ មានន័យថា ការគ្រប់គ្រងគឺជាដំណើរទាក់ទងទៅលើបណ្តាញការងារស្មុគស្មាញរវាងមនុស្សនិងមនុស្ស រវាងមនុស្សជាមួយនឹងធនធានផ្សេងទៀតដែលធនធានទាំងនោះមានរូបិយវត្ថុ សម្ភារៈ អាគារ ដីធ្លីឬវត្ថុធាតុដើម។ ការគ្រប់គ្រងសម្រេចគោលដៅនៃអង្គការចាត់តាំង មានន័យថា គ្រប់គ្រងជាការនាំយកសកម្មភាពទាំងឡាយឱ្យទៅដល់គោលដៅកំណត់ គឺជាចំណុចចាប់ផ្តើមរហូតដល់ទីបញ្ចប់ដែលបង្ហាញនូវមុខងារបួនសំខាន់គឺផែនការចាត់តាំង ដឹកនាំនិងត្រួតពិនិត្យ។ ការគ្រប់គ្រងសម្រេចបានប្រសិទ្ធភាព មានន័យថា គ្រប់គ្រងទាក់ទងទៅនឹងលក្ខណៈវិនិច្ឆ័យពីរគឺ ប្រសិទ្ធភាពនិងសមត្ថភាព។ ប្រសិទ្ធភាពគឺជារង្វាស់មួយនៃការចំណាយធនធានដែលមាននៅក្នុងការសម្រេចគោលដៅមានន័យថាជារង្វាស់មួយ នៃមុខចេញនិងមុខចូល ( Output/Input )។

#### ៣-១-១- ការគ្រប់គ្រងអាជីវកម្មកំពង់ផែ

ដើម្បីឱ្យការងារគ្រប់គ្រងនិងអភិវឌ្ឍន៍កំពង់ផែមានប្រសិទ្ធភាព ឆ្លើយតបទៅនឹងតម្រូវការនាពេលអនាគត ការងារគ្រប់គ្រងអភិវឌ្ឍន៍អាជីវកម្មនិងធនធានមនុស្ស កំពង់ផែស្វយ័តភ្នំពេញប្រព្រឹត្តទៅមិនទាន់បានល្អនោះ

---

[៥៤] Management by Gomer-Mejia, L., & Balkin, D. (2002), P. 5-6

ទេ។ ឆ្លងតាមការសិក្សាលើលក្ខណៈទូទៅរបស់កំពង់ផែស្វយ័តភ្នំពេញ យើងឃើញថា អង្គភាពមានការចាត់តាំងរចនាសម្ព័ន្ធត្រឹមត្រូវ ដោយមានការគ្រប់គ្រងពីថ្នាក់ក្រុមផ្នែកនិងការិយាល័យឬសេវាដ្ឋាន។ អង្គភាពមានយុទ្ធសាស្ត្រល្អក្នុងការគ្រប់គ្រងនិយោជិត-កម្មកររបស់ខ្លួនដោយមិនឱ្យមានសញ្ញាដែលធ្វើឱ្យអាក់ខានដល់ដំណើរអាជីវកម្មរបស់អង្គភាព។ ចំណែកការងារគ្រប់គ្រងសហប្រតិ-បត្តិការអាជីវកម្មរបស់កំពង់ផែស្វយ័តភ្នំពេញបានទាក់ទាញអតិថិជនជាម្ចាស់ទំនិញ ព្រោះថា សព្វថ្ងៃ នេះអង្គភាពកំពុងតែរៀបចំបែបបទសម្រាប់នាវានាំចេញ-នាំចូលផែ ដោយចំណាយពេលវេលាឱ្យខ្លី។ ម្យ៉ាងវិញទៀត ដើម្បីបម្រើការងារអាជីវកម្មរបស់ខ្លួនឱ្យមានសភាពល្អ អង្គភាពផែបានធ្វើទំនាក់ទំនងយ៉ាងល្អជាមួយស្ថាប័នដទៃទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការអតិថិជនសព្វថ្ងៃ។

### ៣-១-២- សហប្រតិបត្តិការអាជីវកម្មនិងប្រតិបត្តិការអាជីវកម្ម

នៅរាល់ចុងឆ្នាំម្តងៗ កំពង់ផែស្វយ័តភ្នំពេញនិងសហគ្រាសដទៃទៀតដែរ តែងតែបូកសរុបលទ្ធផលនិងបិទបញ្ជីរបស់ខ្លួន។ នៅពេលដែលបិទបញ្ជីម្តងៗកំពង់ផែត្រូវមានតំណាងចូលរួមរបស់ក្រសួងសាធារណការនិងដឹកជញ្ជូននិងក្រសួងហិរញ្ញវត្ថុចូលរួមផងដែរ។ ដើម្បីធ្វើបែបបទនាំចេញនាំចូលផលិតផលដែលដឹកជញ្ជូនតាមនាវាត្រូវមានតំណាងសមត្ថកិច្ចចូលរួមដូចជា៖ តំណាងកំពង់ផែ(Port Representative) ១រូប/ភ្នាក់ងារគយ(Custom Officer)១រូប/ភ្នាក់ងារប៉ូលិសច្រកទ្វារព្រំដែន(Immigration Officer)១រូប/ភូតគាមនាម័យ(Phyto Sanitary Officer)១រូប/ចត្តាឡីស័ក(Quarantin Officer) ១រូបនិងភ្នាក់ងារនាវាចរណ៍(Ship agent) ១រូប។

ក្នុងគោលនយោបាយលើកទឹកចិត្តនិងសម្រួលដល់នាវាចរណ៍ ពិសេស នាទីនាវា(Barge)និងនាវាអ្នកដំណើរ សមាសភាពខាងលើត្រូវកាត់បំព្រួញឬបន្ថយការត្រួតពិនិត្យឱ្យនៅត្រឹមតែជំនាញចាំបាច់តែប៉ុណ្ណោះនិងរយៈពេលសម្រាប់ធ្វើបែបបទត្រូវប្រព្រឹត្តទៅតាមធម្មតា ចំនួនមិនលើសពី៣០នាទី ដោយគិតចាប់ពីពេលដែលបានបង្ហាញដល់សមត្ថកិច្ចគ្រប់ជំនាញនូវសំណុំឯកសារនៃនាវានិងទំនិញ លិខិតឆ្លងដែនរហូតដល់មានការអនុញ្ញាតរួចរាល់។

ដើម្បីធានាបាននូវសុវត្ថិភាពរវាងប្រទេសដែលនាំទំនិញតាមនាវាឆ្លងកាត់និងចូលចតតាមផែបាន នាវាទាំងនោះតម្រូវឱ្យមានឯកសារសំខាន់ៗ មួយចំនួនដូចជា ឯកសារនាវិកមាន អត្តសញ្ញាណ បណ្ណនាវិកឬលិខិតឆ្លងដែន (Seamen Book or Seamen Passport) វិញ្ញាបនបត្រសមត្ថភាព របស់នាវិក (Certificate of Competency)។ សំណុំឯកសារពាណិជ្ជកម្មមានអញ្ញាណបណ្ណ(Bill of Lading) កិច្ចសន្យាជួលនាវា (Charter Parties) និវេទនបណ្ណ(Manifeste)។ ឯកសាររបស់នាវាមាន វិញ្ញាបនបត្រអនុញ្ញាតសម្រាប់នាវាចរណ៍ (Navigation Certificate) វិញ្ញាបនបត្រសញ្ជាតិ(Certificate of Nationality) វិញ្ញាបនបត្រអន្តរជាតិចំណុះមាឌនាវា (International Tonnage Certificate) វិញ្ញាបនបត្រចុះបញ្ជី(Certificate of Registry) វិញ្ញាបនបត្រចំណាត់ថ្នាក់នាវា (Classification Certificate) វិញ្ញាបនបត្របន្ទាត់ផ្ទុក (Certificate of Load Line) វិញ្ញាបនបត្រសុវត្ថិភាពនាវាអ្នកដំណើរឬនាវាដឹកទំនិញទាក់ទងនឹងការសាងសង់ ឧបករណ៍ និងវិទ្យុ (Passenger Ship Safety Certificate or Cargo Safety Certificate Relating to Construction Equipment and Radio) វិញ្ញាបនបត្រអប្បបរមានាវិកធានាសុវត្ថិភាព (Minimum Safe Manning Certificate) វិញ្ញាបនបត្រអន្តរជាតិការពារការបំពុលបរិស្ថានដោយប្រេ (Oil Pollution Prevention

Certificate) វិញ្ញាបនបត្រជានារូចផុតពីការបំផ្លាញនៃសត្វកណ្ដុរ (De-ral or Derating Exemption Certificate) ឯកសារផ្សេងៗទៀតប្រសិនបើចាំបាច់ លិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនទំនិញឬអ្នកដំណើរ ដោយមានកំណត់ផែគោលលដៅច្បាប់អនុញ្ញាតឱ្យចេញចូលផលយាននិងអ្នកដំណើរដែលចេញដោយក្រសួង។

## ៣-២- ការពង្រឹងនិងអភិវឌ្ឍន៍ធនធានមនុស្សកំពង់ផែ

ការបណ្ដុះបណ្ដាលអភិវឌ្ឍន៍សមត្ថភាព គឺជាការតព្វកិច្ចចាំបាច់ដែលអង្គភាពអាជីវកម្មត្រូវតែអនុវត្តន៍ ដើម្បីរៀបចំនិយោជិតថ្មី និង ចាស់មុនពេលដែលគេចូលបំពេញការងារឬក៏ចំពោះនិយោជិត-កម្មករចាស់ដែល ត្រូវតែបំពាក់បំប៉នបន្ថែមឱ្យសមស្រប និង ការវិវត្តរបស់ស្ថានភាពអាជីវកម្មនិងការរីកចម្រើនរបស់វិទ្យាសាស្ត្រ។ ចំពោះកំពង់ផែស្វយ័តភ្នំពេញមានការយកចិត្តទុកដាក់ក្នុងការបណ្ដុះបណ្ដាលដល់និយោជិករបស់ខ្លួនផងដែរទាំង ការបណ្ដុះបណ្ដាលខាងក្នុង និង ខាងក្រៅកន្លែងធ្វើការមានការបញ្ជូនឱ្យទៅរៀនតាមការអញ្ជើញរបស់ក្រសួង អាណាព្យាបាលឬស្ថាប័ននានា ការបណ្ដុះបណ្ដាលនៅបរទេសនិងសិក្ខាសាលានៅក្នុងនិងក្រៅប្រទេសជាដើម។

តាមការសិក្សាយើងឃើញថា មានការយកចិត្តទុកដាក់ក្នុងការបណ្ដុះបណ្ដាលដល់និយោជិត-កម្មករ ដូចមាននៅក្នុងរបាយការណ៍ស្ដីពីសកម្មភាពការងាររបស់កំពង់ផែស្វយ័តភ្នំពេញប្រចាំឆ្នាំ២០០៦ ការបំពាក់បំប៉ន សមត្ថភាពរបស់និយោជិត-កម្មករជាប្រចាំដោយបានបណ្ដុះបណ្ដាលលើជំនាញកុំព្យូទ័រ ៤៦នាក់ភាសាអង់គ្លេស ៧៤នាក់ សិក្ខាសាលា៣០នាក់ ការពារបរិស្ថានផ្លូវទន្លេ៣នាក់ បណ្ដុះបណ្ដាលនាវាចរណ៍ (គ្រូបណ្ដុះបណ្ដាល) ៤ នាក់ នៅប្រទេសវៀតណាម និង ១៤នាក់ នៅក្នុងស្រុក ជំនាញផែ ១នាក់នៅប្រទេសបារាំង ទស្សនកិច្ចដក ពិសោធន៍ការងារកំពង់ផែនៅក្រៅប្រទេសចំនួន៥នាក់និងគ្រប់គ្រងកំពង់ផែ ៨នាក់ក្នុងប្រទេស។




ក្រាហ្វិចទី ៣-១៖ ការងារបណ្ដុះបណ្ដាលនិយោជិត-កម្មករ ឆ្នាំ២០០៦

## ៣-៣- សិក្សាលើ SWOT

**ចំណុចខ្លាំង** ជាផែតែមួយគត់ដែលមានទីតាំងស្ថិតក្នុងតំបន់មជ្ឈមណ្ឌលសេដ្ឋកិច្ចធំនៃប្រទេសកម្ពុជា។ កំពង់ផែមានទីតាំងជាប់ទន្លេមេគង្គ មានទីលានសម្រាប់ស្តុកទំនិញ មានទីលានសម្រាប់កុងតឺន័រនិងបានទទួល សិទ្ធិពីរាជរដ្ឋាភិបាលឱ្យធ្វើអាជីវកម្មផែដែលមានរបបស្វ័យភិបាលសេដ្ឋកិច្ច។ មានទំនាក់ទំនងល្អរវាងថ្នាក់ដឹកនាំ នឹងនិយោជិត-កម្មករដោយមិនប្រកាន់ឋានៈតួនាទី។ កំពង់ផែស្វយ័តភ្នំពេញបានសាងសង់ឡើងតាមខ្នាតអន្តរ ជាតិនិងស្ថិតនៅតាមដងទន្លេមេគង្គ។ រដ្ឋាភិបាលជប៉ុននិងធនាគារពិភពលោកបានផ្ដល់ជំនួយជាច្រើន ដើម្បី អនុវត្តការងារជួសជុលនិងសាងសង់កំពង់ផែស្វយ័តភ្នំពេញឡើងវិញ។

**ចំណុចខ្សោយ** ជាកំពង់ផែស្វយ័តភ្នំពេញពុំទាន់មានធនធានមនុស្សមានសមត្ថភាពគ្រប់គ្រាន់ក្នុងការងារបច្ចុប្បន្ន។ កំពង់ផែនៅឆ្ងាយពីសមុទ្រមុននឹងចូលមកដល់ប្រទេសកម្ពុជាត្រូវឆ្លងកាត់ប្រទេសវៀតណាម។ ប្រព័ន្ធរដ្ឋបាលត្រួតពិនិត្យនៃកំពង់ផែស្វយ័តភ្នំពេញមានលក្ខណៈស៊ាំញ៉ាំ ធ្វើឱ្យម្ចាស់ទំនិញត្រូវចំណាយពេលដឹកជញ្ជូនយូរដោយសារប្រព័ន្ធត្រួតពិនិត្យនិងឆែកឆេរនៅពុំទាន់មានលក្ខណៈល្អ។ បរិមាណទំនិញនាំចូលពុំសូវទៀងទាត់ ពេលខ្លះតិចពេលខ្លះច្រើន។ បញ្ហាបរិស្ថានមានការលំបាកជាខ្លាំងដូចជា សំរាម ប្រេងជាដើម។ គ្រឿងបរិក្ខារមិនទាន់គ្រប់គ្រាន់ ឧទាហរណ៍៖ គ្មានប្រដាប់ស្ទូចសម្រាប់លើកទំនិញ៧០តោន។ គ្មានឧបករណ៍សម្រាប់បូមទំនិញចាក់ជា ដូចជា ពោត សណ្តែក ធ្យូង។ល។ ទីតាំងជម្រៅទឹកពុំគ្រប់គ្រាន់សម្រាប់កំពង់ផែត្រូវបូមដីជារៀងរាល់ឆ្នាំ។ មិនទាន់មានឧបករណ៍ទំនើបៗសម្រាប់ត្រួតពិនិត្យទំនិញ។

**ឱកាស** ប្រទេសកម្ពុជាទើបចូលសេដ្ឋកិច្ចទីផ្សារសេរី ហើយជាសមាជិកពេញសិទ្ធិរបស់អាស៊ានធ្វើឱ្យកំពង់ផែស្វយ័តភ្នំពេញមានឱកាសច្រើនក្នុងការអភិវឌ្ឍកំពង់ផែនិងការអភិវឌ្ឍប្រទេស ពោលចាប់យកអតិថិជនថ្មី។ ការបង្កើតផែក្នុងតំបន់ព្រំប្រទល់អាជីវកម្មនៃកំពង់ផែស្វយ័តភ្នំពេញដូចជាបង្កើតផែក្នុងស្រុក ដើម្បីពង្រីកសមត្ថភាពរបស់ខ្លួនទប់ទល់នឹងគូប្រកួតប្រជែងថ្មីនិងប្តូរបទពិសោធន៍គ្នា។ ការដឹកជញ្ជូនផ្លូវសមុទ្រ ការស្តុកទុកនិងការកែទម្រង់វត្ថុធាតុត្រូវអនុវត្តន៍តាមកំពង់ផែ។

**ការគំរាមកំហែង** កំពង់ផែស្វយ័តភ្នំពេញ សព្វថ្ងៃមានការលំបាកក្នុងការប្រកួតប្រជែងជាមួយកំពង់ផែក្រុងព្រះសីហនុនិងផែស្ងួតចុងទី ព្រោះបើម្ចាស់នាវាដឹកនាំនាវាឆ្លងកាត់ប្រទេសវៀតណាមម្ចាស់នាវាត្រូវចំណាយថវិកាច្រើន មួយភាគត្រូវបង់ជូនកំពង់ផែស្វយ័តភ្នំពេញនិងមួយភាគទៀតត្រូវបង់ឱ្យវៀតណាម។ ដោយសារកំពង់ផែនៅឆ្ងាយពីសមុទ្រ មុននឹងចូលមកដល់ព្រំដែនប្រទេសកម្ពុជាត្រូវឆ្លងកាត់ប្រទេសវៀតណាមតាមផ្លូវទន្លេមេគង្គដែលធ្វើឱ្យមានការលំបាកយ៉ាងច្រើនដល់ការធ្វើបែបបទឆ្លងកាត់ នេះជាបញ្ហាធ្វើឱ្យមានការយឺតយ៉ាវក្នុងការបញ្ជូនទំនិញទៅដល់ដៃគូពាណិជ្ជកម្មនិងដល់អ្នកប្រើប្រាស់ ហើយសោហ៊ុយក្នុងការដឹកជញ្ជូនទំនិញ ការស៊ីចតក៏ត្រូវចំណាយច្រើនធ្វើឱ្យមានការរាំងស្ទះដល់កិច្ចសន្យាធ្វើពាណិជ្ជកម្ម។ សំណង់ឃ្លាំងរបស់កំពង់ផែ តូចទាប ហើយមានសភាពចាស់ៗទៀតផងធ្វើឱ្យមានការលំបាកក្នុងការដកស្តុកនិងបញ្ចូលស្តុក។ បញ្ហាបរិស្ថានមានការលំបាកជាខ្លាំង ដូចជា សំរាម ប្រេង ជាដើម ធ្លាក់ចូលក្នុងទឹកទន្លេ។

## ៤ - សន្និដ្ឋាន

លទ្ធផលនៃការសិក្សាបានបញ្ជាក់ឱ្យដឹងថា កំពង់ផែស្វយ័តភ្នំពេញពុំទាន់មានធនធានមនុស្សមានសមត្ថភាពគ្រប់គ្រាន់ក្នុងការងារនៅឡើយទេ។ ម្យ៉ាងវិញទៀត កំពង់ផែនេះនៅឆ្ងាយពីសមុទ្រមុននឹងចូលមកដល់ប្រទេសកម្ពុជាត្រូវឆ្លងកាត់ប្រទេសវៀតណាម ហើយប្រព័ន្ធរដ្ឋបាលត្រួតពិនិត្យនៃកំពង់ផែស្វយ័តភ្នំពេញមានលក្ខណៈស៊ាំញ៉ាំធ្វើឱ្យម្ចាស់ទំនិញត្រូវចំណាយពេលដឹកជញ្ជូនយូរ ដោយមានប្រព័ន្ធត្រួតពិនិត្យនិងឆែកឆេរនៅពុំទាន់មានលក្ខណៈល្អ។ បរិមាណទំនិញនាំចូលនូវពុំសូវទៀងទាត់ ពេលខ្លះតិច ពេលខ្លះច្រើន។ កំពង់ផែមិនទាន់មានឧបករណ៍ទំនើបៗសម្រាប់ត្រួតពិនិត្យទំនិញនិងគ្រឿងបរិក្ខារមិនទាន់គ្រប់គ្រាន់ ឧទាហរណ៍៖ គ្មានប្រដាប់ស្ទូចសម្រាប់លើកទំនិញ ៧០តោន។ រីឯការអភិវឌ្ឍនៅមានការខ្វះខាតខ្លាំងនៅឡើយដែលទាមទារឱ្យរាជរដ្ឋាភិបាលត្រូវតែពង្រឹងសកម្មភាពការងារអាជីវកម្ម កសិកម្ម សិប្បកម្មឬឧស្សាហកម្មក្នុងស្រុកឱ្យកាន់តែប្រសើរឡើងទើបរដ្ឋបាលកំពង់ផែអាចមានលទ្ធភាពរកប្រាក់ចំណូលបានច្រើន៕

# ឯកសារយោង

- របាយការណ៍ ស្តីពីសកម្មភាពការងាររបស់កំពង់ផែស្វយ័តភ្នំពេញ ប្រចាំឆ្នាំ២០០៦។

- Yamaner Taro. 1967 WWW.Google.com

- Management by Gomer-Mejia, L., & Balkin, D. (2002), P. 5-6

© ២០១៤ រាជបណ្ឌិត្យសភាកម្ពុជា

ចំនួន ១,០០០ ច្បាប់

រក្សាសិទ្ធិគ្រប់យ៉ាង គ្មានផ្នែកណាមួយនៃទស្សនាវដ្ដីនេះនឹងត្រូវបានបោះពុម្ពឡើងវិញ
ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីរាជបណ្ឌិត្យសភាកម្ពុជាឡើយ

---

© 2014 Royal Academy of Cambodia

No. 1,000 copies

All rights reserved. No part of this book may be reproduced,
in any form, by any means, without permission in writing from
Royal Academy of Cambodia.



ប្រាសាទ អង្គរវត្ត

**Royal Academy of Cambodia Review**
Russian Federation Blvd
P.O Box: 531, Phnom Penh
Kingdom of Cambodia
Tel: (855) 23 640 66 22
Fax: (855) 23 890 180
E-mail: magazinerac@yahoo.com
Website: www.rac-academy.edu.kh

**រាជបណ្ឌិត្យសភាកម្ពុជា**
មហាវិថីសហព័ន្ធរុស្ស៊ី
ប្រអប់សំបុត្រលេខ: ៥៣១ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៦៤០ ៦៦ ២២
ទូរសារលេខ: (៨៥៥) ២៣ ៨៩០ ១៨០
អ៊ីមែល / សារអេឡិចត្រូនិក: magazinerac@yahoo.com
គេហទំព័រ: www.rac-academy.edu.kh